# សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
# និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

## របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សា

# ប្រតិបត្តិការទូទាត់ និងសេវាផ្ទេរប្រាក់

កម្មសិក្សាពីថ្ងៃទី ១៨ ខែមីនា ឆ្នាំ២០១៩ ដល់ថ្ងៃទី ១៦ ខែឧសភា ឆ្នាំ២០១៩

ឈ្មោះស្ថាប័ន : **ធនាគារឯកទេសវីង (ខេមបូឌា) លីមីតធីត**

| | |
|---|---|
| តាក់តែងដោយ | សាស្ត្រាចារ្យណែនាំ |
| និស្សិតឈ្មោះ កញ្ញា **គឹម សុពុំរ័ត្ន** | លោក **សួន ចំរើន** |
| កញ្ញា **រ៉ា រីណា** | |
| ថ្នាក់បរិញ្ញាបត្រ ហិរញ្ញវត្ថុ និងធនាគារ | ឆ្នាំចូលសិក្សា ២០១៥ |
| ជំនាន់ទី ១២ | ឆ្នាំសរសេររបាយការណ៍ ២០១៩ |

# សេចក្ដីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **គីម សុពុំរ័ត្ន** និង **រ៉ា រីណា** ជានិស្សិតបរិញ្ញាបត្រ ជំនាញធនាគារ និងហិរញ្ញវត្ថុ ឆ្នាំទី៤ ជំនាន់ទី១២ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា ២០១៨-២០១៩។

## សូមថ្លែងអំណរគុណ និងការដឹងគុណយ៉ាងជ្រាលជ្រៅចំពោះ

១- លោកឪពុក និងអ្នកម្ដាយ ដែលបានផ្ដល់កំណើតដល់កូន និងខិតខំជំនះរាល់ឧបសគ្គទាំងឡាយ ដើម្បីថែរក្សាដល់កូនព្រមទាំងផ្គត់ផ្គង់ជាសម្ភារៈ និងថវិកាដល់ការសិក្សារបស់កូនជាដរាបរៀងមកដើម្បីអនាគតរបស់យើងខ្ញុំជាកូន។

២- ឯកឧត្តម បណ្ឌិត **លុយ ចន្ធា** សាកលវិទ្យាធិការ លោកសាកលវិទ្យាធិការរង និងលោក-លោកស្រីសាស្ត្រាចារ្យគ្រប់មុខវិជ្ជា នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចទាំងអស់ ដែលបានខិតខំប្រឹងប្រែងទាំងកម្លាំងកាយ និងចិត្តក្នុងការអប់រំ ផ្ដល់ចំណេះដឹងគ្រប់បែបយ៉ាងអស់រយៈពេល ៤ឆ្នាំកន្លងមកនេះ។

៣- ជាពិសេស លោកសាស្ត្រាចារ្យ **សួន ចំរើន** ដែលជាសាស្ត្រាចារ្យណែនាំ បានចំណាយពេលវេលាដ៏មានតម្លៃក្នុងការបង្ហាត់បង្រៀន ណែនាំ តម្រង់ទិស ផ្ដល់យោបល់ និងគំនិតល្អៗក្នុងការដឹកនាំកម្មសិក្សារបស់យើងខ្ញុំរហូតបានសម្រេចជោគជ័យ។

៤- លោកអគ្គនាយក ធនាគារឯកទេសរីង (ខេមបូឌា) លីមីតធីត ព្រមទាំងប្រធានផ្នែកធនធានមនុស្សនៃធនាគារ ដែលបានអនុញ្ញាតឱ្យយើងខ្ញុំបានចុះកម្មសិក្សាដោយបានផ្ដល់ឯកសារ និងធ្វើបទសម្ភាសន៍ដើម្បីប្រមូលទិន្នន័យចងក្រងកិច្ចការស្រាវជ្រាវនេះរហូតទទួលបានជោគជ័យ។

ជាទីបញ្ចប់ យើងខ្ញុំសូមធ្វើការថ្លែងអំណរគុណជាអនេកប្បការ និងសូមធ្វើការអធ្យាស្រ័យរាល់កំហុសទាំងឡាយដែលកើតមានតាំងពីពេលចុះកម្មសិក្សារហូតដល់ពេលបញ្ចប់។ យើងខ្ញុំសូមជូនពរឲ្យលោកអ្នកមានគុណទាំងអស់ បានជួបតែនឹងពុទ្ធពរទាំង ៤ប្រការគឺ អាយុ វណ្ណៈ សុខៈ និង ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

យើងខ្ញុំជានិស្សិតជំនាន់ទី១២ ជំនាញធនាគារ និងហិរញ្ញវត្ថុ នៃសាកលវិទ្យាល័យ ភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ឆ្នាំសិក្សា ២០១៨-២០១៩ បានធ្វើការស្រាវជ្រាវ និងចងក្រងកិច្ចការស្រាវជ្រាវនេះឡើងក្នុងគោលបំណងដើម្បីពង្រីកនូវចំណេះដឹង និងស្វែងយល់បន្ថែមឲ្យកាន់តែច្បាស់ទៅលើគ្រឹះស្ថានធនាគារប្រភេទឯកទេសដែលកំពុងតែមានសន្ទុះគាំទ្រនៅក្នុងវិស័យធនាគារបច្ចុប្បន្ន ទាំងទ្រឹស្តី និងការអនុវត្តជាក់ស្តែង ដែលបានឆ្លងកាត់តាមរយៈការសិក្សានៅសាកលវិទ្យាល័យអស់រយៈពេលបួនឆ្នាំកន្លងមកនេះ និងការអង្កេតនូវប្រតិបត្តិការផ្ទាល់អស់រយៈពេល ១ខែនៅធនាគារ។

ដើម្បីសម្រេចបានជោគជ័យនៅក្នុងការរៀបចំជាសៀវភៅនេះឡើង យើងខ្ញុំបានខិតខំស្រាវជ្រាវតាមរយៈការចុះកម្មសិក្សានៅធនាគារឯកទេសវីង (ខេមបូឌា) លីមីតធីត ព្រមទាំងមានការជួយជ្រោមជ្រែងពន្យល់ណែនាំ និងការផ្តល់យោបល់ល្អៗ ពីសំណាក់សាស្រ្តាចារ្យដឹកនាំ ព្រមទាំងរៀមច្បងដែលជាបុគ្គលិកនៅធនាគារផ្ទាល់ជាដើម។

ប្រធានបទ "**ប្រតិបត្តិការទូទាត់ និងសេវាផ្ទេរប្រាក់របស់ធនាគារឯកទេសវីង (ខេមបូឌា) លីមីតធីត**" នេះ គឺជាគំនិតស្តួចស្តើងមួយដែលលេចឡើង ជារូបរាងដោយសារការខិតខំប្រឹងប្រែងរបស់ក្រុមយើងខ្ញុំ។ ម្យ៉ាងទៀត នេះក៏ជាស្នាដៃទី១ នៃប្រធានបទកម្មសិក្សាដែលលើកយកប្រភេទធនាគារឯកទេសមកបកស្រាយ ដែលនឹងអាចជាទុនមួយ សម្រាប់និស្សិតជំនាន់ក្រោយ ទុកជាគំរូឯកសារក្នុងការស្រាវជ្រាវបន្តទៀត។

យើងខ្ញុំជឿជាក់ថាកិច្ចការស្រាវជ្រាវនេះនៅពុំទាន់មានលក្ខណៈគ្រប់ជ្រុងជ្រោយនៅឡើយទេ បើទោះបីជាយើងខ្ញុំខិតខំប្រឹងប្រែងក្នុងការសរសេរ និងកែតម្រូវជាច្រើនលើកច្រើនសារហើយក៏ដោយ។ ហេតុដូចនេះហើយ យើងខ្ញុំសង្ឃឹមថានិស្សិត និងមិត្តអ្នកអានទាំងអស់ពិតជាមានការអធ្យាស្រ័យនូវរាល់កំហុសឆ្គងទាំងឡាយដែលកើតមានឡើងដោយអចេតនា។

# មាតិកា

ទំព័រ


បញ្ជីអក្សរកាត់ ........ vi
បញ្ជីតារាង ........ vii
បញ្ជីដ្យាក្រាម ........ viii
បញ្ជីឧបសម្ព័ន្ធ ........ ix


## សេចក្តីផ្តើម


១. លំនាំបញ្ហា ........ ១
២. ចំណោទបញ្ហា ........ ២
៣. គោលបំណងនៃការស្រាវជ្រាវ ........ ២
៤. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ........ ៣
៥. សារៈសំខាន់នៃការស្រាវជ្រាវ ........ ៣
៦. វិធីសាស្ត្រនៃការស្រាវជ្រាវ ........ ៣
៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៤


## ជំពូកទី ១
## រំលឹកទ្រឹស្តី


១.១ លក្ខណៈទូទៅរបស់ធនាគារឯកទេស ........ ៦
១.១.១ សញ្ញាណនៃធនាគារឯកទេស ........ ៦
១.១.១.១ និយមន័យ ........ ៦
១.១.១.២ របៀបនៃការបង្កើតធនាគារឯកទេស ........ ៦
១.១.២ ប្រភេទធនាគារឯកទេស ........ ៨
១.១.៣ តួនាទីរបស់ធនាគារឯកទេសក្នុងការអភិវឌ្ឍសេដ្ឋកិច្ច ........ ៩
១.២ ប្រតិបត្តិការទូទាត់ ........ ១០
១.២.១ និយមន័យ ........ ១០
១.២.១.១ ការទូទាត់ជាសាច់ប្រាក់ ........ ១១
១.២.១.២ ការទូទាត់តាមធនាគារ ........ ១១
១.២.១.៣ ការប្រើប្រាស់ប័ណ្ណទូទាត់ ........ ១១
១.២.២ ប្រភេទនៃមធ្យោបាយទូទាត់ ........ ១២

១.២.២.១ មូលប្បទានបត្រ ........ ១២

១.២.២.២ លិខិតឥណទាន ........ ១៣

១.២.២.៣ ប័ណ្ណឥណទាន ........ ១៣

១.២.៣ អត្ថប្រយោជន៍នៃប្រតិបត្តិការទូទាត់ ........ ១៤

១.២.៤ ហានិភ័យនៃប្រតិបត្តិការទូទាត់ ........ ១៥

១.៣ ការផ្ទេរប្រាក់ ........ ១៦

១.៣.១ និយមន័យ ........ ១៦

១.៣.២ ប្រភេទនៃការផ្ទេរប្រាក់ ........ ១៦

១.៣.២.១ ការផ្ទេរប្រាក់ក្នុងស្រុក ........ ១៦

១.៣.២.២ ការផ្ទេរប្រាក់ក្រៅប្រទេស ឬអន្តរជាតិ ........ ១៧

១.៣.៣ ប្រព័ន្ធផ្ទេរប្រាក់អន្តរជាតិ ........ ១៧

១.៣.៣.១ ប្រព័ន្ធផ្ទេរប្រាក់អន្តរជាតិ Western Union ........ ១៧

១.៣.៣.២ ប្រព័ន្ធផ្ទេរប្រាក់អន្តរជាតិ SWIFT ........ ១៨

១.៣.៣.៣ ប្រព័ន្ធផ្ទេរប្រាក់អន្តរជាតិ MoneyGram ........ ១៩

១.៣.៤ អត្ថប្រយោជន៍នៃសេវាផ្ទេរប្រាក់ ........ ២០

១.៣.៥ ហានិភ័យនៃសេវាកម្មផ្ទេរប្រាក់ ........ ២៣

## ជំពូកទី ២

## ស្ថានភាពទូទៅរបស់ធនាគារឯកទេសរីង (ខេមបូឌា) លីមីតធីត

២.១ ប្រវត្តិនៃធនាគារឯកទេសរីង ........ ២៥

២.២ គោលបំណងនៃធនាគារឯកទេសរីង ........ ២៦

២.៣ ទីតាំង និងសាខាធនាគារឯកទេសរីង ........ ២៦

២.៤ ចក្ខុវិស័យ បេសកកម្ម និងគុណតម្លៃ ........ ២៨

២.៤.១ ចក្ខុវិស័យ ........ ២៨

២.៤.២ បេសកកម្ម ........ ២៨

២.៤.៣ គុណតម្លៃ ........ ២៨

២.៥ ស្លាកសញ្ញា និងអត្ថន័យ ........ ២៩

២.៦ រចនាសម្ព័ន្ធរបស់ធនាគារ ........ ២៩

២.៦.១ ក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការក្រុមប្រឹក្សាភិបាល ........ ២៩

២.៦.២ គណៈគ្រប់គ្រង ..........៣០
២.៧ ផលិតផល និងសេវាកម្មនានារបស់ធនាគារ ..........៣១
២.៧.១ ផលិតផល..........៣១
២.៧.១.១ គណនីវីង..........៣១
២.៧.១.២ កាតវីង..........៣២
២.៧.១.៣ ផលិតផលផ្សេងៗទៀត..........៣៤
២.៧.២ សេវាកម្មរបស់ធនាគារឯកទេសវីង ..........៣៥
២.៧.២.១ សេវាផ្ទេរប្រាក់(Money Transfer) ..........៣៥
២.៧.២.២ សេវាបង់វិក្កយបត្រ(Bill Payment)..........៣៦
២.៧.២.៣ សេវាទូទាត់តាមអ៊ីនធឺណេត(Online Payment) ..........៣៦
២.៧.២.៤ សេវាទូទាត់តាមវីងគិតលុយ(WingPay)..........៣៦
២.៧.២.៥ សេវាបញ្ចូលទឹកប្រាក់ទូរស័ព្ទ(Phone Top Up)..........៣៦
២.៧.២.៦ សេវាអាំងប៉ាវវីង (Wing Ang Pao)..........៣៩

## ជំពូកទី ៣

## ប្រតិបត្តិការទូទាត់ និងសេវាផ្ទេរប្រាក់របស់ធនាគារឯកទេសវីង

៣.១ ប្រតិបត្តិការទូទាត់ .......... ៤០
៣.១.១ សេវាទូទាត់បង់វិក្កយបត្រ (Bill Payment).......... ៤០
៣.១.១.១ នីតិវិធីនៃការទូទាត់បង់វិក្កយបត្រ (Bill Payment).......... ៤១
ក. នីតិវិធីនៃការទូទាត់បង់វិក្កយបត្រតាមរយៈ USSD .......... ៤១
ខ. នីតិវិធីនៃការទូទាត់បង់វិក្កយបត្រតាមរយៈកម្មវិធីស្មាតហ្វូនវីង.......... ៤២
គ. នីតិវិធីនៃការទូទាត់បង់វិក្កយបត្រតាមរយៈភ្នាក់ងារវីង .......... ៤២
៣.១.១.២ តម្លៃសេវានៃការទូទាត់បង់វិក្កយបត្រ ..........៤៣
៣.១.២ សេវាទូទាត់តាមអ៊ីនធឺណេត (Online Payment) .......... ៤៥
៣.១.២.១ នីតិវិធីនៃការទូទាត់តាមអ៊ីនធឺណេត (Online Payment).......... ៤៥
៣.១.២.២ តម្លៃសេវានៃការទូទាត់តាមអ៊ីនធឺណេត .......... ៤៦
៣.១.៣ សេវាទូទាត់តាមវីងគិតលុយ (WingPay).......... ៤៦
៣.១.៣.១ នីតិវិធីនៃការទូទាត់តាមវីងគិតលុយ (WingPay) ..........៤៧
ក. សេវាទូទាត់WingPayតាមរយៈកាត..........៤៧

ខ. សេវាទូទាត់WingPayតាមរយៈUSSD ........ ៤៧
គ. សេវាទូទាត់WingPayតាមរយៈQR Code ........ ៤៨
ឃ. សេវាទូទាត់WingPayតាមរយៈMaster Pass QR ........ ៤៨
៣.១.៣.២ តម្លៃសេវានៃការទូទាត់តាមវីងគិតលុយ ........ ៤៩
៣.១.៤ អត្ថប្រយោជន៍នៃប្រតិបត្តិការទូទាត់ ........ ៤៩
៣.២ សេវាផ្ទេរប្រាក់........ ៥០
៣.២.១ សេវាផ្ទេរប្រាក់ក្នុងប្រទេស........ ៥១
៣.២.១.១ សេវាផ្ទេរប្រាក់វីងទៅវីង(Wing To Wing)........ ៥១
ក. នីតិវិធីនៃការប្រើប្រាស់សេវាផ្ទេរប្រាក់វីងទៅវីងតាម USSD........ ៥១
ខ. នីតិវិធីនៃការប្រើប្រាស់សេវាផ្ទេរប្រាក់វីងទៅវីងតាមកម្មវិធីស្មាតហ្វូនវីង ........ ៥២
គ. ការយកថ្លៃសេវាផ្ទេរប្រាក់វីងទៅវីង ........ ៥២
៣.២.១.២ សេវាផ្ទេរប្រាក់វីងវេរលុយ (Wing Wei Luy)........ ៥២
ក. នីតិវិធីនៃការប្រើប្រាស់សេវាផ្ទេរប្រាក់វីងវេរលុយតាម USSD........ ៥៣
ខ. នីតិវិធីនៃការប្រើប្រាស់សេវាផ្ទេរប្រាក់វីងវេរលុយតាមកម្មវិធីស្មាតហ្វូនវីង........ ៥៣
គ. ការយកថ្លៃសេវាផ្ទេរប្រាក់វីងវេរលុយ........ ៥៣
៣.២.១.៣ សេវាផ្ទេរប្រាក់វេរលុយអ៊ិចប្រេស(WeiLuy Xpress) ........ ៥៥
ក. នីតិវិធីនៃការផ្ទេរប្រាក់តាមភ្នាក់ងារវីង ........ ៥៥
ខ. នីតិវិធីនៃការទទួលប្រាក់តាមភ្នាក់ងារវីង ........ ៥៥
គ. ការយកថ្លៃសេវាផ្ទេរប្រាក់វេរលុយអ៊ិចប្រេស........ ៥៦
៣.២.១.៤ សេវាផ្ទេរប្រាក់រវាងគណនីវីង និងធនាគារ(Wing to Bank and Bank to Wing)៥៧
៣.២.១.៥ អត្ថប្រយោជន៍នៃសេវាផ្ទេរប្រាក់ក្នុងស្រុក ........ ៥៧
៣.២.២. សេវាផ្ទេរប្រាក់ក្រៅប្រទេស (Wing2World)........ ៥៩
៣.២.២.១ នីតិវិធីនៃការផ្ទេរប្រាក់ទៅក្រៅប្រទេស ........ ៥៩
ក. ការផ្ទេរប្រាក់ចេញតាមប្រព័ន្ធ Western Union........ ៥៩
ខ. ការផ្ទេរប្រាក់ចេញតាមប្រព័ន្ធផ្សេងៗទៀត ........ ៦៣
៣.២.២.២ នីតិវិធីនៃការទទួលប្រាក់ពីក្រៅប្រទេស........ ៦៤
ក. ការផ្ទេរប្រាក់ចូលតាមប្រព័ន្ធ Western Union ........ ៦៥
ខ. ការផ្ទេរប្រាក់ចូលតាមប្រព័ន្ធ MoneyGram ........ ៦៦

គ. ការផ្ទេរប្រាក់ចូលតាមប្រព័ន្ធ WorldRemit ............ ៦៧
ឃ. ការផ្ទេរប្រាក់ចូលតាមប្រព័ន្ធផ្សេងៗ ............ ៦៧
៣.២.២.៣ អត្ថប្រយោជន៍នៃសេវាផ្ទេរប្រាក់អន្តរជាតិ ............ ៧១
៣.៣ ការសិក្សាពីបម្រែបម្រួលចំណូលនៃប្រតិបត្តិការទូទាត់ និងសេវាផ្ទេរប្រាក់ ............ ៧១
៣.៤ ហានិភ័យ និងវិធីសាស្រ្តគ្រប់គ្រងហានិភ័យនៃប្រតិបត្តិការទូទាត់ ............ ៧៣
៣.៤.១ ហានិភ័យនៃប្រតិបត្តិការទូទាត់ ............ ៧៣
៣.៤.២ វិធីសាស្រ្តគ្រប់គ្រងហានិភ័យនៃប្រតិបត្តិការទូទាត់ ............ ៧៤
៣.៥ ហានិភ័យ និងវិធីសាស្រ្តគ្រប់គ្រងហានិភ័យនៃសេវាកម្មផ្ទេរប្រាក់ ............ ៧៥
៣.៥.១ ហានិភ័យនៃសេវាកម្មផ្ទេរប្រាក់ ............ ៧៥
៣.៥.២ វិធីសាស្រ្តគ្រប់គ្រងហានិភ័យនៃសេវាកម្មផ្ទេរប្រាក់ ............ ៧៧
៣.៦ ការវិភាគ SWOT ............ ៧៩
៣.៦.១ ភាពខ្លាំង ............ ៧៩
៣.៦.១ ភាពខ្សោយ ............ ៨០
៣.៦.៣ ឱកាស ............ ៨១
៣.៦.៤ ការគំរាមគំហែង ............ ៨២

## សេចក្ដីសន្និដ្ឋាន និងការផ្ដល់អនុសាសន៍

១. សេចក្ដីសន្និដ្ឋាន ............ ៨៤
២. ការផ្ដល់អនុសាសន៍ ............ ៨៥
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# បញ្ជីអក្សរកាត់

| | |
|---|---|
| ATM | : Automated Teller Machine |
| EDC | : Electicite Du Cambodge |
| EXIM Bank | : Export and Import Bank |
| FinTech | : Financial Technology |
| KYC | : Know Your Customer |
| NABARD | : National Bank for Agriculture and Rural Development |
| OTC | : Over The Counter |
| PIN | : Personal Identification Number |
| POS | : The Point of Sale |
| QR Code | : Quick Response Code |
| SIDBI | : Small Industries Development Bank |
| SWIFT | : The Society for Worldwide Interbank Financial Telecommunication |
| USSD | : Unstructured Supplementary Service Data |
| WCX | : Wing Cash Express |
| WTO | : World Trade Organization |

# បញ្ជីតារាង


តារាងទី១ ចំនួនភ្នាក់ងារតាមបណ្តាខេត្តក្រុងនានានៃព្រះរាជាណាចក្រកម្ពុជា

តារាងទី២ តម្លៃសេវាកម្មនៃការផ្ទេរចេញតាមប្រព័ន្ធ Western Union

តារាងទី៣ តម្លៃសេវាកម្មនៃការផ្ទេរចេញទៅប្រទេសវៀតណាម

តារាងទី៤ តម្លៃសេវាកម្មនៃការផ្ទេរចេញទៅប្រទេសហ្វីលីពីន

តារាងទី៥ តម្លៃសេវាកម្មនៃការផ្ទេរចេញទៅប្រទេសចិន

តារាងទី៦ តម្លៃសេវាកម្មនៃការផ្ទេរចេញទៅប្រទេសមីយ៉ាន់ម៉ា

តារាងទី៧ តម្លៃសេវាកម្មផ្ទេរប្រាក់ទៅប្រទេសវៀតណាមតាមធនាគារសាខមប៊ែង

តារាងទី៨ តម្លៃសេវាកម្មផ្ទេរប្រាក់ទៅប្រទេសថៃតាមប្រព័ន្ធ Deemoney

តារាងទី៩ បញ្ជីឈ្មោះប្រទេសដែលអាចផ្ទេរមកប្រទេសកម្ពុជាបានតាមប្រព័ន្ធ WorldRemit

តារាងទី១០ តម្លៃសេវាកម្មនៃការផ្ទេរពីប្រទេសកូរ៉េខាងត្បូងតាមធនាគារ Kookmin

តារាងទី១១ តម្លៃសេវាកម្មនៃការផ្ទេរពីប្រទេសកូរ៉េខាងត្បូងតាមធនាគារ PPCBank

តារាងទី១២ តម្លៃសេវាកម្មនៃការផ្ទេរពីប្រទេសថៃតាម Deemoney

តារាងទី១៣ ចំណូលនៃប្រតិបត្តិការទូទាត់ និងសេវាផ្ទេរប្រាក់របស់ធនាគារឯកទេសវីងចន្លោះឆ្នាំ ២០១៣ ដល់ ២០១៦

# បញ្ជីដ្យាក្រាម

ដ្យាក្រាមទី១  ដ្យាក្រាមសង្ខេបនៃប្រតិបត្តិការផ្ទេរប្រាក់វេរលុយអ៊ិចប្រេសរបស់ធនាគារឯកទេសវីង
ដ្យាក្រាមទី២  ដ្យាក្រាមសង្ខេបនៃប្រតិបត្តិការផ្ទេរប្រាក់ទៅក្រៅប្រទេសតាម Western Union
ដ្យាក្រាមទី៣  ដ្យាក្រាមសង្ខេបនៃប្រតិបត្តិការទទួលប្រាក់ពីក្រៅប្រទេសតាម Western Union

# បញ្ជីឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១ របាយការណ៍ប្រតិបត្តិការអ្នកដំណើរការតតិយភាគី ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៨

ឧបសម្ព័ន្ធទី២ តារាងដៃគូសហការប្រតិបត្តិការទូទាត់វិក្កយបត្ររបស់ធនាគារឯកទេសវីង

ឧបសម្ព័ន្ធទី៣ តារាងដៃគូសហការប្រតិបត្តិការទូទាត់តាមអ៊ីនធឺណេតរបស់ធនាគារឯកទេសវីង

ឧបសម្ព័ន្ធទី៤ ធនាគារទំនាក់ទំនងក្រៅប្រទេសរបស់ធនាគារឯកទេសវីង

ឧបសម្ព័ន្ធទី៥ តម្លៃសេវាផ្ទេរប្រាក់ក្នុងស្រុករបស់ធនាគារឯកទេសវីង

ឧបសម្ព័ន្ធទី៦ តម្លៃសេវាផ្ទេរប្រាក់ទៅក្រៅប្រទេសតាមរយៈវីង

ឧបសម្ព័ន្ធទី៧ តារាងថ្លៃសេវាកម្មផ្ទេរប្រាក់ទៅក្រៅប្រទេសតាម Western Union

ឧបសម្ព័ន្ធទី៨ លក្ខន្តិកៈនៃការប្រើប្រាស់សេវាផ្ទេរប្រាក់តាម Western Union

# សេចក្តីផ្តើម

## ១. លំនាំបញ្ហា

ស្ថានភាពសេដ្ឋកិច្ច និងសង្គមរបស់ប្រទេសកម្ពុជានាពេលបច្ចុប្បន្ននេះមានការរីកចម្រើនជាលំដាប់ ដែលផ្លែផ្កាបែបនេះបានមកដោយសារតែការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលក្នុងការអនុវត្តគោលនយោបាយប្រកបដោយប្រសិទ្ធភាព និងការអនុវត្តប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសេរីតាមរយៈការធ្វើឯកជនភាវូបនីយកម្ម ការបង្កើតទំនាក់ទំនងពាណិជ្ជកម្មអន្តរជាតិ ក្នុងកម្រិតតំបន់ដូចជាការដែលបានចូលជាសមាជិករបស់សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ដែលហៅកាត់ថា អាស៊ាន នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៩ និងបានបង្កើតទំនាក់ទំនងសេដ្ឋកិច្ចអន្តរជាតិក្នុងកម្រិតពិភពលោកដោយប្រទេសកម្ពុជា បានក្លាយជាសមាជិកពេញសិទ្ធិរបស់អង្គការពាណិជ្ជកម្មពិភពលោក (WTO) នៅឆ្នាំ២០០៤។ នេះជា មាគ៌ាដ៏ប្រពៃមួយដែលនាំអោយប្រទេសកម្ពុជា អាចឈានទៅរកការពង្រីកទីផ្សារឲ្យកាន់តែមានវិសាលភាពធំឡើងថែមទៀត។ កត្តាទាំងនេះ បានផ្តល់ឱកាសល្អសម្រាប់ការវិនិយោគ ដែលអាចឲ្យប្រទេសកម្ពុជា មានលទ្ធភាពទាក់ទាញអ្នកវិនិយោគទុនបរទេសក៏ដូចជាអ្នកវិនិយោគក្នុងស្រុកមកវិនិយោគកាន់តែច្រើនកុះករនាពេលសព្វថ្ងៃ។

តាមរយៈការសង្កេត និងតាមដានទីផ្សារសេដ្ឋកិច្ចនៅកម្ពុជា យើងសង្កេតឃើញថា បច្ចុប្បន្នវិស័យធនាគារ គឺជាវិស័យមួយដែលកំពុងតែទទួលបានការចាប់អារម្មណ៍ច្រើនពីវិនិយោគិនមិនថាពីមជ្ឈដ្ឋានក្នុង ឬក្រៅស្រុក។ ធនាគារជាច្រើន បានឈរជើងប្រកួតប្រជែងគ្នា មិនថាជាប្រភេទធនាគារពាណិជ្ជដែលផ្តួចផ្តើមឡើង ដោយសហគ្រិនខ្មែរផ្ទាល់ ឬធនាគារពាណិជ្ជ ដែលជាសាខារបស់ធនាគារបរទេស នៅក្នុងបណ្តាប្រទេសអាស៊ាន គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងជាពិសេសគឺធនាគារឯកទេសប្រភេទផ្សេងៗគ្នា បាននឹងកំពុងតែបង្ហាញវត្តមាន នៅក្នុងវិស័យធនាគារហិរញ្ញវត្ថុកម្ពុជា។ នាមួយរយៈចុងក្រោយនេះ សន្ទុះនៃធនាគារឯកទេសបានកើនឡើងដើម្បីធ្វើការប្រកួតប្រជែងនៅក្នុងទីផ្សារហិរញ្ញវត្ថុ ដោយបានបំបែកអតិថិជនគោលដៅរបស់ធនាគារពាណិជ្ជអោយងាកមកចាប់អារម្មណ៍លើការប្រើប្រាស់សេវាទូទាត់ ផ្ទេរប្រាក់ ឥណទាន បង់រំលស់ របស់ខ្លួន។ ធនាគារឯកទេស បានដណ្តើមនូវទីផ្សារមួយភាគធំពីស្ថាប័នហិរញ្ញវត្ថុនានាតាមរយៈការផ្តល់សេវាច្បាស់លាស់មួយជូនដល់អតិថិជន ជាមួយនឹងភាពងាយស្រួល លឿនរហ័ស និងប្រកបទៅដោយបច្ចេកវិទ្យាទំនើប។

ជាក់ស្តែង ធនាគារឯកទេសវីង គឺជាធនាគារឯកទេសដែលនាំមុខគេក្នុងចំណោមប្រភេទធនាគារឯកទេសផ្សេងៗដទៃទៀត ដោយបានក្តោបក្តាប់នូវទីផ្សារប្រតិបត្តិការទូទាត់ និងសេវាផ្ទេរ

ប្រាក់មិនថាក្នុង ឬក្រៅប្រទេស តាមរយៈការចាប់ដៃគូសហការណ៍ជាមួយសមាជិកអាស៊ាន ផ្តល់ភាពស្រួល លឿនរហ័សជូនទៅកាន់អតិថិជនត្រឡប់វិញ។ ធនាគារមិនត្រឹមតែរួមចំណែកលើកស្ទួយវិស័យធនាគារហិរញ្ញវត្ថុជាតិ តែក៏បាននាំវិស័យនេះ និងអតិថិជនឆ្ពោះទៅកាន់យុគសម័យនៃបច្ចេកវិទ្យាទំនើបមុនគេបង្អស់ដែលសម្រួលដល់ការចំណាយទូទាត់ មានសុវត្ថិភាព ព្រមទាំងជួយសន្សំសំចៃទាំងថវិកា និងពេលវេលាដល់អ្នកប្រើប្រាស់។

## ២. ចំណោទបញ្ហា

វត្តមាននៃធនាគារឯកទេស គឺជាសញ្ញាណវិជ្ជមាននៃការរីកចម្រើននូវសេដ្ឋកិច្ចហិរញ្ញវត្ថុនៅក្នុងសង្គមកម្ពុជា ហើយប្រតិបត្តិការទូទាត់ និងសេវាផ្ទេរប្រាក់ក៏ជាកាតាលីករនៅក្នុងការជម្រុញអោយមានលំហូរសាច់ប្រាក់ នៅក្នុងប្រទេសនាំទៅកាន់ការអភិវឌ្ឍ និងរីកលូតលាស់ទៅមុខ។ បច្ចុប្បន្នធនាគារឯកទេសរីង កំពុងតែប្រតិបត្តិការលើសេវាកម្មទាំងពីរនេះយ៉ាងមមាញឹក ហើយការសិក្សាស្រាវជ្រាវមួយនេះនឹងផ្តោតទៅលើបញ្ហាមួយចំនួនដូចខាងក្រោម ៖

- តើធនាគារឯកទេសរីងធ្វើប្រតិបត្តិការទូទាត់ និងសេវាផ្ទេរប្រាក់យ៉ាងដូចម្តេចខ្លះ?
- តើធនាគារមាននីតិវិធីយ៉ាងណាខ្លះ ចំពោះប្រតិបត្តិការទូទាត់ និងសេវាផ្ទេរប្រាក់ក្នុង និងក្រៅប្រទេសរបស់ខ្លួន? ហើយការយកកម្រៃសេវាយ៉ាងដូចម្តេច?
- តើអ្វីទៅជាហានិភ័យនៃប្រតិបត្តិការទូទាត់ និងសេវាផ្ទេរប្រាក់របស់ធនាគារឯកទេសរីង?

## ៣. គោលបំណងនៃការស្រាវជ្រាវ

គោលបំណងសំខាន់ក្នុងការស្រាវជ្រាវរបស់យើងខ្ញុំ គឺផ្តោតសំខាន់ទៅលើកត្តាសំខាន់ៗដូចតទៅ៖

- ស្វែងយល់ពីស្ថានភាពទូទៅរបស់ធនាគារឯកទេសរីង (ខេមបូឌា) លីមីតធីត
- ផ្សារភ្ជាប់ទ្រឹស្តីដែលបានសិក្សាកន្លងមកជាមួយនឹងការអនុវត្តជាក់ស្តែង
- ស្វែងយល់ពីនីតិវិធី និងដំណើរការគ្រប់គ្រងប្រតិបត្តិការទូទាត់ និងសេវាកម្មផ្ទេរប្រាក់ក្នុងស្រុក និងអន្តរជាតិ
- សិក្សាពីហានិភ័យនៃប្រតិបត្តិការទូទាត់ និងសេវាកម្មផ្ទេរប្រាក់ក្នុងស្រុក និងអន្តរជាតិ
- ធ្វើការវិភាគទិន្នន័យពីប្រតិបត្តិការ និងថ្លៃសេវារបស់សេវាកម្មទូទាត់ និងផ្ទេរប្រាក់
- ព្រមទាំងចូលរួមផ្តល់យោបល់ដើម្បីស្ថាបនា

## ៤. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះ ផ្តោតសំខាន់ទៅលើប្រតិបត្តិការសេវាកម្មធំៗពីររបស់ធនាគារឯកទេសរីង គឺប្រតិបត្តិការទូទាត់ និងសេវាផ្ទេរប្រាក់របស់ធនាគារឯកទេសរីង ទីស្នាក់ការកណ្តាល ដែលយើងខ្ញុំបានចុះកម្មសិក្សាផ្ទាល់តែប៉ុណ្ណោះ។ ម្យ៉ាងទៀត ការលើកឡើង នៅក្នុងប្រធានបទនេះ សុទ្ធតែពាក់ព័ន្ធនឹងប្រភេទនៃប្រតិបត្តិការទូទាត់ និងសេវាផ្ទេរប្រាក់របស់ធនាគារឯកទេសរីង ការពិភាក្សា និងការវិភាគទិន្នន័យទាក់ទិនទៅនឹងប្រតិបត្តិការទាំងនោះ។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

យើងខ្ញុំបានខិតខំស្រាវជ្រាវ និងចងក្រងជារបាយការណ៍កម្មសិក្សានេះឡើងដោយសង្ឃឹមថារបាយការណ៍នេះនឹងផ្តល់នូវអត្ថប្រយោជន៍មួយចំនួនដូចខាងក្រោម៖

- អាចឲ្យយើងយល់ដឹងបន្ថែមអំពីទ្រឹស្តី និងចំណេះដឹងដែលពាក់ព័ន្ធនឹងប្រធានបទ
- បង្កើនសមត្ថភាពក្នុងការវិភាគ និងបកស្រាយទិន្នន័យដែលប្រមូលបាន
- ទុកជាឯកសារ សម្រាប់ការស្រាវជ្រាវរបស់និស្សិតជំនាន់ក្រោយ ជាពិសេស និស្សិតផ្នែកហិរញ្ញវត្ថុ និងធនាគារ
- អាចផ្តល់ជាមតិយោបល់ដល់គ្រឹះស្ថានហិរញ្ញវត្ថុទាំងឡាយ ដែលផ្តល់សេវាកម្មទូទាត់ និងផ្ទេរប្រាក់ អាចធ្វើការអភិវឌ្ឍ និងកែលម្អនូវចំណុចខ្វះខាតនៃសេវាកម្មរបស់ខ្លួនឲ្យកាន់តែមានភាពប្រសើរឡើង។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

ក្នុងការចងក្រង និងសរសេររបាយការណ៍កម្មសិក្សានេះយើងខ្ញុំបានប្រើវិធីសាស្ត្រប្រមូលទិន្នន័យទីពីរ (Secondary Data) ដែលទាក់ទិននឹងប្រធានបទនេះ។ យើងខ្ញុំធ្វើការប្រមូលទិន្នន័យនេះតាមរយៈការប្រមូលទិន្នន័យ ឬឯកសារដែលមានស្រាប់ដូចជា៖

- ទិន្នន័យដែលទទួលបានការពីសាកសួរ និងសម្ភាសន៍ជាមួយបុគ្គលិកធនាគារ
- ឯកសារនៅបណ្ណាល័យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
- ឯកសារស្រាវជ្រាវលើរបាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សារបស់និស្សិតជំនាន់មុនៗ
- ឯកសារសៀវភៅដែលផ្តល់ដោយសាស្ត្រាចារ្យដែលយើងខ្ញុំធ្លាប់បានសិក្សាកន្លងមក
- ឯកសារពាក់ព័ន្ធផ្សេងៗដែលផ្តល់ដោយប្រធានផ្នែកធនធានមនុស្ស និងបុគ្គលជំនាញខាងសេវាកម្មទូទាត់ និងផ្ទេរប្រាក់របស់ធនាគារឯកទេសរីង
- ឯកសារដែលទទួលបានតាមរយៈអ៊ីនធឺណេត

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះមានរចនាសម្ព័ន្ធដូចខាងក្រោម៖




យើងបានធ្វើការរៀបចំជាគម្រោងសម្រាប់ការស្រាវជ្រាវដូចខាងក្រោម៖

**-សេចក្តីផ្តើម**

ផ្នែកនេះ បង្ហាញអំពី ៧ ចំណុចនៃការស្រាវជ្រាវដែលរួមមានដូចជា លំនាំបញ្ហា ចំណោទបញ្ហា គោលបំណងនៃការស្រាវជ្រាវ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ វិធីសាស្ត្រនៃការស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ។

**-ជំពូកទី ១ : រំលឹកទ្រឹស្តី**

នៅក្នុងជំពូកនេះយើងធ្វើការលើកឡើង នូវទ្រឹស្តីផ្សេងៗទាក់ទិនទៅនឹងប្រធានបទដែលយើងលើកយកមកសិក្សា។ ទ្រឹស្តីដែលលើកយកមកផ្សារភ្ជាប់ទាំងនោះរួមមានដូចជា ការបង្ហាញអំពីលក្ខណៈទូទៅរបស់ធនាគារឯកទេស ទ្រឹស្តីអំពីប្រតិបត្តិការទូទាត់ និងការផ្ទេរប្រាក់ជាដើម។

**-ជំពូកទី ២: ស្ថានភាពទូទៅរបស់ធនាគារឯកទេសវីង**

ក្នុងជំពូកនេះ យើងនឹងបង្ហាញយ៉ាងលម្អិត អំពីស្ថានភាពទូទៅរបស់ ធនាគារឯកទេសវីង មួយចំនួនរួមមានដូចជា ប្រវត្តិនៃការកកើត គោលបំណងនៃធនាគារឯកទេសវីង ទីតាំងធនាគារ និងភ្នាក់ងារវីងជាដើម។ ម្យ៉ាងទៀត ជំពូកនេះ ក៏លើកបង្ហាញអំពីចក្ខុវិស័យ បេសកកម្ម គុណតម្លៃ អត្ថន័យនៃស្លាកសញ្ញា ព្រមទាំងរចនាសម្ព័ន្ធគ្រប់គ្រងរបស់ធនាគារផងដែរ ដើម្បីឲ្យបានស្គាល់កាន់តែច្បាស់ពីទិដ្ឋភាពខាងក្នុងរបស់ធនាគារនេះ។ ផ្នែកចុងក្រោយនៃជំពូកនេះ ក៏បានលើកបង្ហាញអំពីផលិតផល និងសេវាកម្មទាំងអស់ដែលធនាគារឯកទេសវីងផ្តល់ជូនអតិថិជន នាពេលបច្ចុប្បន្ន។

**-ជំពូកទី ៣ : ប្រតិបត្តិការទូទាត់ និងសេវាផ្ទេរប្រាក់របស់ធនាគារឯកទេសវីង**

នៅក្នុងជំពូកនេះ យើងធ្វើការសិក្សាស៊ីជម្រៅទៅលើ ប្រភេទសេវាកម្មធំ ២ របស់វីង គឺ ប្រតិបត្តិការទូទាត់ និងសេវាផ្ទេរប្រាក់ ដោយសង្កត់ធ្ងន់ទៅលើ ប្រភេទនៃសេវាកម្មទាំងនោះ ដំណើរការ និងការយកកម្រៃសេវាកម្មនីមួយៗ។ បន្ថែមពីនេះ យើងក៏ធ្វើការសិក្សាពីបម្រែបម្រួលចំណូលពីសេវានាំមុខរបស់ធនាគារឯកទេសវីង ការសិក្សាពីហានិភ័យនៃប្រតិបត្តិការទូទាត់ និងសេវាផ្ទេរប្រាក់ វិធីសាស្ត្រក្នុងការគ្រប់គ្រងហានិភ័យ រួមជាមួយនឹងការវិភាគ SWOT ផងដែរ។

**-សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍**

ផ្នែកនេះ យើងធ្វើការបូកសរុបសំយោគឡើងវិញ នូវចំណុចសំខាន់ៗទាំងអស់ ដែលជាលទ្ធផលនៃការសិក្សាស្រាវជ្រាវ និងការផ្តល់ជាអនុសាសន៍ដល់ធនាគារ សម្រាប់ធ្វើការពិចារណា និងកែលម្អនូវចំនុចខ្វះខាតនៃសេវាកម្មរបស់ខ្លួន។

**-ឧបសម្ព័ន្ធ**

**-ឯកសារយោង**

# ជំពូកទី ១

# រំលឹកទ្រឹស្តី

## ១.១. លក្ខណៈទូទៅរបស់ធនាគារឯកទេស

### ១.១.១ សញ្ញាណនៃធនាគារឯកទេស

#### ១.១.១.១ និយមន័យ

យោងតាមឯកសារច្បាប់នៃធនាគារជាតិ[1] ធនាគារឯកទេសគឺជា អង្គភាពណាដែលអនុវត្តតែសកម្មភាពមួយក្នុងចំណោមសកម្មភាពជាមូលដ្ឋានទាំងបីរបស់ធនាគារ ឬអនុវត្តតែផ្នែកមួយ នៃសកម្មភាពនីមួយៗនៃសកម្មភាពទាំងបីខាងក្រោម៖

១. ផ្តល់ឥណទានគ្រប់ប្រភេទចំពោះសាធារណៈជនដោយមានកម្រៃរាប់បញ្ចូលទាំងឥណទានភតិសន្យា និងការសន្យាតាមហត្ថលេខា

២. ការទទួលប្រាក់បញ្ញើមិនមានមុខសញ្ញាប្រើពីសាធារណជន

៣. ប្រព្រឹត្តិកម្ម និងការដាក់ឲ្យអតិថិជនប្រើប្រាស់នូវមធ្យោបាយទូទាត់ជារូបិយវត្ថុ ឬជារូបិយប័ណ្ណ

យោងតាមឯកសារបរទេស[2]ធនាគារឯកទេស គឺត្រូវបានឲ្យនិយមន័យថា ជាធនាគារដែលមានប្រតិបត្តិការទាក់ទងទៅនឹងសកម្មភាពណាមួយនៅក្នុងសេដ្ឋកិច្ច អាចជាធនាគារឯកទេសទៅលើខាងផ្នែកអចលនទ្រព្យ កសិកម្ម ឬឧស្សាហកម្មជាដើម ហើយធនាគារឯកទេសនេះផងដែរ សកម្មភាពចម្បង គឺមិនមែនជាការទទួលប្រាក់បញ្ញើនោះទេ។

#### ១.១.១.២ របៀបនៃការបង្កើតធនាគារឯកទេស[3]

ធនាគារឯកទេស គឺត្រូវបានបង្កើតឡើងតាមដំណាក់កាលដូចជា ការបង្កើតធនាគារពាណិជ្ជដែរ ក៏ប៉ុន្តែមានការបំពេញបែបបទខ្លះមានល័ក្ខខ័ណ្ឌផ្សេងដែលខុសពីការបង្កើតធនាគារពាណិជ្ជដូចជា៖

- ការកំណត់ដើមទុនបង្កើត

[1] ធនាគារជាតិនៃកម្ពុជា,១៩៩៩, "ក្រមច្បាប់អនុវត្តចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ", ទំព័រ២០

[2] Vai, M. (2018, May 06). Specialized banks. Retrieved from http://cststudy.blogspot.com/2018/05/specialized-banks.html

[3] បេក្ខជនបណ្ឌិត ហ៊ី សុខនី,២០១៣,"នីតិធនាគារ",ទំព័រ៣៥

ធនាគារឯកទេស ដែលបង្កើតឡើងក្រោមរូបភាព ជាក្រុមហ៊ុនក្នុងស្រុក ត្រូវមានដើមទុនអប្បរមាស្មើនឹង ៦០,០០០,០០០,០០០ រៀល (ហុកសិបពាន់លានរៀល) (ប្រហែល ១៥ លានដុល្លារអាមេរិក។[4]

- ការបង់សោហ៊ុយអាជ្ញាប័ណ្ណ

គ្រឹះស្ថានត្រូវបង់សោហ៊ុយសិក្សាសំណុំលិខិតចំនួន ៥,០០០ រៀល (ហាសិបពាន់រៀល) នៅពេលដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណ។ គ្រឹះស្ថានតម្រូវឲ្យបង់សោហ៊ុយអាជ្ញាប័ណ្ណប្រចាំឆ្នាំ ចំនួន ១,០០០,០០០រៀល (មួយលានរៀល) នៅមុនថ្ងៃទី ១៥ ខែ មករា រៀងរាល់ឆ្នាំ ។

- ការតំកល់មូលធនបម្រុង

តម្រូវអោយរក្សាប្រាក់តំកល់ធានាលើដើមទុន ស្មើនឹងប្រាំភាគរយ ដោយគ្មានការប្រាក់នៃដើមទុនដែលបានចុះបញ្ជីនៅក្នុងគណនី ដែលបានបើកនៅធនាគារជាតិនៃកម្ពុជា គ្រឹះស្ថានអាចដកយកមូលនិធិដែលនៅសល់ពីនោះបាន។ ធនាគារជាតិនៃកម្ពុជា នឹងទូទាត់សងប្រាក់តំកល់ធានាលើដើមទុននេះ ទៅអោយគ្រឹះស្ថានវិញ តែនៅពេលគ្រឹះស្ថាននោះត្រូវបានជំរះបញ្ជីដោយស្ម័គ្រចិត្ត និងគ្មានប្រាក់បញ្ញើនៅខាងទ្រព្យអកម្ម ។

- ការតំកល់ទុនបម្រុងកាតព្វកិច្ចលើប្រាក់បញ្ញើ[5]

គ្រឹះស្ថានដែលបានទទួលអាជ្ញាប័ណ្ណហើយ ត្រូវតម្កល់ទុនបម្រុងកាតព្វកិច្ចចំនួនប្រាំភាគរយនៃប្រាក់បញ្ញើ ដែលបានទទួលពីអតិថិជននៅក្នុងគណនីដែលបានបើកនៅធនាគារជាតិនៃកម្ពុជា ។ ទុនបំរុងកាតព្វកិច្ចនេះត្រូវបានរក្សាទុក តាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងបទបញ្ជាដោយឡែកស្តីពីទុនបម្រុងកាតព្វកិច្ច ។

គ្រឹះស្ថានត្រូវរក្សាទុកអនុបាតគ្រប់គ្រាន់នៃដើមទុនយ៉ាងតិចបំផុត ស្មើម្ភៃភាគរយរវាងដើមទុនដែលអាចទទួលបាន និង ហានិភ័យថ្លឹងថ្លែង ។

កម្រិតឥណទានចំពោះអ្នកខ្ចីឯកត្តជនម្នាក់ឬអ្នកខ្ចីមួយក្រុម ដែលរួមបង្កើតជាអ្នកទទួលផលតែមួយ ដោយសារមានទំនាក់ទំនងជាមួយគ្នាទៅវិញទៅមក ត្រូវកំណត់មិនអោយលើសពីដប់ភាគរយ នៃមូលនិធិផ្ទាល់របស់គ្រឹះស្ថានឡើយ ។

- អភិបាលកិច្ច

[4] Dr.Hem, D.(2015, November). Licensing of Banking and Financial Institutions in Cambodia, Page 02

[5] Khemsarith. (2016, October 12). ការសុំអាជ្ញាប័ណ្ណធនាគារឯកទេស. Retrieved from https://khemsarith.wordpress.com/2016/10/12/ការសុំអាជ្ញាប័ណ្ណធនាគារ-2/

ធនាគារឯកទេសតម្រូវអោយមាន ក្រុមប្រឹក្សាភិបាលរបស់ធនាគារ ដែលរួមបញ្ចូលសមាជិកយ៉ាងតិច ៣ រូបដែលក្នុងនោះមួយរូបត្រូវតែ ជាសមាជិកឯករាជ្យ។ ដោយសមាជិកនេះ គឺមិនមានការបំពេញកាតព្វកិច្ច នៅកន្លែងធ្វើការជាប្រចាំរៀងរាល់ថ្ងៃនោះទេ សមាជិកឯករាជ្យគឺបង្ហាញវត្តមានតែនៅពេលមានអង្គប្រជុំសំខាន់ៗនៅក្នុងការសម្រេចចិត្តលើកិច្ចព្រមព្រៀង ឬគោលការណ៍អនុវត្តនៅក្នុងធនាគារតែប៉ុណ្ណោះ។ នៅក្នុងករណីដែល ធនាគារឯកទេសនោះ មានសមាជិកលើសពី ៣ រូបគ្រឹះស្ថានត្រូវធានាថា យ៉ាងតិចមួយភាគបីនៃសមាជិក ត្រូវតែជាសមាជិកឯករាជ្យ។

**១.១.២ ប្រភេទនៃធនាគារឯកទេស**

នៅក្នុងបរិបទប្រទេសកម្ពុជាធនាគារឯកទេស គឺត្រូវបានកំណត់ប្រតិបត្តិការសកម្មភាពណាមួយនៅក្នុងចំណោមសកម្មភាពទាំងបី ដូចដែលបានរៀបរាប់នៅខាងលើ។ តាមការសង្កេតឃើញជាទូទៅ ធនាគារឯកទេសនៅក្នុងប្រទេសកម្ពុជា[6] មានពីរប្រភេទ ដែលកំពុងដំណើរការ និងមានការឈានទៅមុខយ៉ាងល្អប្រសើរ ក្នុងនោះរួមមាន៖

ធនាគារឯកទេសខាងផ្នែកកម្ចី ៖ គឺជាធនាគារដែលផ្តោតសំខាន់ទៅលើសកម្មភាពផ្តល់កម្ចីទៅលើកសិកម្ម អចលនទ្រព្យ និងមានការបង់រំលោះនានាជាដើម។ ធនាគារប្រភេទនេះ ទទួលបានចំណូលដោយពឹងផ្អែកទៅលើអត្រាការប្រាក់នៃប្រាក់កម្ចីដែលបានផ្តល់ចេញទៅ។ ជាក់ស្តែង មានធនាគារឯកទេសអ៊ីអន ធនាគារឯកទេសកាំកូ ធនាគារឯកទេសអានកូជាដើម។

ធនាគារឯកទេសខាងផ្នែកទូទាត់ និងសេវាផ្ទេរប្រាក់ ៖ ធនាគារឯកទេសប្រភេទនេះ គឺចាប់យកអតិថិជនជាលក្ខណៈបុគ្គល នៅក្នុងការប្រើប្រាស់សេវាទូទាត់ ក៏ដូចជាការផ្ទេរប្រាក់របស់ធនាគារផ្ទាល់។ ធនាគារប្រភេទនេះ គឺទទួលចំណេញតាមរយៈការចំណាយលើថ្លៃសេវារបស់អតិថិជន។ បច្ចុប្បន្ននេះ នៅក្នុងប្រទេសកម្ពុជាមានធនាគារឯកទេសវីង ដែលជាធនាគារដែលស្ថិតនៅក្នុងប្រភេទដែលបម្រើសេវាទូទាត់ និងផ្ទេរប្រាក់តែមួយគត់ជូនទៅកាន់អតិថិជន។

ចំណែកឯនៅជុំវិញពិភពលោក ធនាគារឯកទេសមានប្រភេទផ្សេងៗគ្នា ជាច្រើនទៅតាមការកំណត់រៀងៗខ្លួនទៅតាមប្រទេសហើយធនាគារឯកទេស ដែលត្រូវបានគេស្គាល់ច្រើននោះរួមមាន[7]ដូចជា៖

[6] បេក្ខជនបណ្ឌិត ហ៊ឺ សុខនី,២០១៣,″នីតិធនាគារ″,ទំព័រ៣៣

[7] Mylearnings. (2017, April 29). Various Types of Banks. Retrieved from https://www.my-learningz.biz/2017/04/various-types-of-banks.html?m=1

ធនាគារអភិវឌ្ឍន៍ ៖ គឺជាប្រភេទធនាគារឯកទេសដែលផ្តល់កម្ចី សម្រាប់ការអភិវឌ្ឍទៅលើសង្គម ឬក៏ជាការអភិវឌ្ឍទៅលើជំនួញអាជីវកម្មតូចនានា។

ធនាគារវិនិយោគ ៖ គឺជាប្រភេទធនាគារឯកទេស ដែលទទួលទិញ នូវភាគហ៊ុនដែលបោះហើយថ្មីជាមួយនឹងកាលវសាន្តយូរ ហើយលក់វាចេញវិញទៅកាន់វិនិយោគិន និងទទួលបានកម្រៃមកវិញនៅក្នុងរូបភាពជាអ្នកប្រឹក្សាលើការទិញភាគហ៊ុន។

EXIM Bank ៖ គឺជាធនាគារឯកទេសដែលផ្តល់នូវជំនួយខាងផ្នែកហិរញ្ញវត្ថុទៅកាន់វិស័យនាំចេញនិងនាំចូល ហើយដែនកំណត់របស់ធនាគារនេះគឺផ្តល់ជំនួយនិងការគាំទ្រ ខាងផ្នែកហិរញ្ញវត្ថុ ទៅកាន់វិនិយោគិននាំចេញនិងនាំចូលទំនិញតែប៉ុណ្ណោះ។

SIDBI ៖ គឺជាធនាគារឯកទេស ដែលផ្តល់ជំនួយខាងផ្នែកហិរញ្ញវត្ថុទៅកាន់អាជីវកម្មតូចៗ ដោយធនាគារផ្តល់នូវកម្ចីជាមួយល័ក្ខខ័ណ្ឌសមស្រប និងងាយស្រួលទៅកាន់អាជីវកម្មតូចនោះ ដើម្បីឲ្យពួកគេបានបន្តនូវអាជីវកម្មរបស់ខ្លួនទៅមុខទៀត។

NARBARD ៖ គឺជាធនាគារឯកទេសដែលផ្តល់ជំនួយផ្នែកហិរញ្ញវត្ថុទៅកាន់វិស័យកសិកម្មនៅតំបន់ដាច់ស្រយាល ឬតំបន់ស្រែចំការ ដែលកំពុងតែជួបប្រទះនូវបញ្ហាលំបាកនានា មិនថាជាបញ្ហាគ្រោះធម្មជាតិ ឬបញ្ហាខ្វះដើមទុនបង្វិល។

### ១.១.៣ តួនាទីរបស់ធនាគារឯកទេសក្នុងការអភិវឌ្ឍសេដ្ឋកិច្ច

ធនាគារ ត្រូវបានបង្កើតឡើងជាច្រើនប្រភេទតាមប្រទេសនីមួយៗ ជាមួយនឹងមុខងារផ្សេងៗគ្នា។ ទោះបីជា ធនាគារឯកទេស ជាធនាគារមួយប្រភេទដែលមានលក្ខណៈខុសប្លែកពីធនាគារពាណិជ្ជក៏ពិតមែន ប៉ុន្តែប្រតិបត្តិការនានារបស់ធនាគារឯកទេស បានដើរតួនាទីសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចដូចធនាគារពាណិជ្ជដែរ។

បើទោះបីជា ធនាគារមិនបានបង្កើតទ្រព្យសម្បត្តិក៏ដោយ កម្ចីដែលផ្តល់ដោយធនាគារឯកទេសមួយចំនួនបានជួយឲ្យមានភាពងាយស្រួលដល់សង្គមជាតិក្នុងការដោះស្រាយបញ្ហាហិរញ្ញវត្ថុ និងដោះស្រាយជីវភាពរស់នៅប្រចាំថ្ងៃរបស់បុគ្គល ព្រមទាំងបង្កើតមុខរបរដល់ពួកគេ ដែលធ្វើឲ្យពួកគេមានជីវភាពប្រសើរជាងមុន។ ជាក់ស្តែង ការផ្តល់កម្ចីដោយធនាគារឯកទេស បានជួយជម្រុញផ្នែកផលិតកម្មរបស់សហគ្រាស ការពង្រីកអាជីវកម្ម ការផ្តល់ភាពងាយស្រួល នៅក្នុងការវិនិយោគបន្ថែម និងការបង្វិលដើមទុន ដែលជាហេតុធ្វើឲ្យការផលិតក្នុងស្រុកមានការកើនឡើង

និងជាលទ្ធផល សហគ្រាស ឬក្រុមហ៊ុនកាន់តែអាចបង្កើនប្រាក់ចំណូលរបស់ខ្លួនបានច្រើន។[8] ហេតុដូចនេះហើយ ការផ្ដល់កម្ចីរបស់ធនាគារឯកទេស បានដើរតួនាទីជាអ្នកសម្របសម្រួលស្ថានភាពហិរញ្ញវត្ថុរបស់បុគ្គល ព្រមទាំងក្រុមហ៊ុន និងដោយប្រយោលបានចូលរួមជំរុញដល់សេដ្ឋកិច្ចជាតិឲ្យកាន់តែរីកចំរើនឡើង។

ធនាគារឯកទេស[9] ក៏ជាផ្នែកមួយនៃទីផ្សារ និងស្ថាប័ននៅក្នុងប្រព័ន្ធហិរញ្ញវត្ថុ ដែលមានតួនាទីសំខាន់ក្នុងសេដ្ឋកិច្ច។ តួនាទីចំបងរបស់ធនាគារឯកទេសក្នុងប្រព័ន្ធហិរញ្ញវត្ថុ គឺការលើកទឹកចិត្តបុគ្គលម្នាក់ៗ និងស្ថាប័ននានា ឲ្យសន្សំប្រាក់ នៅធនាគារតាមរយៈសេវាកម្មប្រាក់បញ្ញើ។ ក្នុងប្រតិបត្តិការនេះ គឺធនាគារឯកទេសដើរតួនាទីជាអ្នកផ្ទេរប្រាក់សន្សំពីបុគ្គលដែលមានប្រាក់លើសតម្រូវការ ឲ្យទៅជាកម្ចីឲ្យបុគ្គល ឬស្ថាប័នផ្សេងទៀត ដែលមានតម្រូវការសាច់ប្រាក់ ដើម្បីប្រើប្រាស់ក្នុងការវិនិយោគរបស់ខ្លួន។

ជាងនេះទៅទៀត ធនាគារឯកទេសបានរួមចំណែកដោះស្រាយភាពលំបាកនៅក្នុងការទូទាត់ និងការផ្ទេរប្រាក់ក្នុង និងក្រៅប្រទេស។ តាមរយៈសេវាកម្មផ្ទេរប្រាក់ និងឧបករណ៍ទូទាត់ដូចជា ប័ណ្ណឥណទាន និងប័ណ្ណឥណពន្ធ បានធ្វើឲ្យប្រតិបត្តិការទូទាត់មានការកើនឡើង និងធ្វើឲ្យជំនួញពាណិជ្ជកម្ម និងទីផ្សារមានដំណើរការបានកាន់តែរលូន។ ចំណែកឯ សេវាកម្មផ្ទេរប្រាក់បានដើរតួនាទីជាអន្តរការី និងមធ្យោបាយដោះស្រាយបញ្ហាហិរញ្ញវត្ថុរបស់បុគ្គល និងស្ថាប័នក៏ដូចជាជួយឲ្យមានលំហូរសាច់ប្រាក់ក្នុងប្រទេស ដែលធ្វើអោយសេដ្ឋកិច្ចមានដំណើរការជានិច្ច។

ជារួម រាល់សេវាកម្មទាំងអស់របស់ធនាគារឯកទេសសុទ្ធតែដើរតួនាទីសំខាន់ក្នុងការចូលរួមអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិឲ្យមានភាពរីកចម្រើនទៅមុខជានិច្ច។

## ១.២. ប្រតិបត្តិការទូទាត់

### ១.២.១ និយមន័យ

ប្រតិបត្តិការទូទាត់[10] គឺជាតម្លៃតបស្នងទៅវិញទៅមក រវាងភាគី២ឬច្រើនដែលបានចុះកិច្ចព្រមព្រៀងជាមួយគ្នា។ ប្រតិបត្តិការទូទាត់ ត្រូវបានធ្វើឡើងតាមរយៈធនាគារ ដែលដើរតួជាអ្នកសម្របសម្រួលនូវរាល់ការទូទាត់នានាដូចជា មូលប្បទានបត្រ ប័ណ្ណឥណទាន ប័ណ្ណឥណពន្ធជា

[8] What Is The Importance Of The Banks? (n.d.). Retrieved from https://business-finance.blurtit.com/107203/what-is-the-importance-of-the-banks

[9] Rose, P.s., & Hudgins, S.C. ,2008, ‟Bank management & Financial Service˝ , p.08

[10] Banking Circle. 2015. Payments Terminology and Acronyms. Retrieved from https://www.bankingcircle.com/payments-terminology-acronyms-glossary

ដើម ដែលជាមធ្យោបាយងាយស្រួល និងមានសុវត្ថិភាព ហើយត្រូវបានគេទទួលយកប្រើប្រាស់ដោយមានសេចក្តីជឿជាក់ និងទុកចិត្ត។ ចរិតលក្ខណៈនៃការទូទាត់មាន ៣ ប្រភេទ[11] គឺការទូទាត់ជាសាច់ប្រាក់ ការទូទាត់តាមធនាគារ និងការប្រើប្រាស់ប័ណ្ណទូទាត់។

**១.២.១.១ ការទូទាត់ជាសាច់ប្រាក់**

ការទូទាត់ជាសាច់ប្រាក់ គឺជាការប្រើប្រាស់វិធីសាស្ត្រដ៏សាមញ្ញមួយ និងមានប្រសិទ្ធភាពខ្ពស់ ក្នុងចំណោមការទូទាត់ទាំងឡាយវាត្រូវបានផ្ទេរដោយងាយស្រួលពីបុគ្គលម្នាក់ទៅបុគ្គលម្នាក់ទៀត ក្រោមទម្រង់ជា សន្លឹកក្រដាសប្រាក់ ដែលអាចយកទៅតាមខ្លួនបាន និងមានបរិមាណដ៏ច្រើន ហើយក៏ងាយស្រួលសម្រាប់ការយកដាក់ក្នុងសំពាយ ឬកាបូបដៃផងដែរ។

**១.២.១.២ ការទូទាត់តាមធនាគារ**

ការទូទាត់តាមធនាគារ គឺជាការទូទាត់ដ៏ឆ្លាតវៃមួយដែលធ្វើឲ្យអ្នកប្រើប្រាស់បញ្ឈប់ការទូទាត់ ដោយយកសាច់ប្រាក់ធ្វើជាឧបករណ៍ និងប្រែក្លាយឲ្យទៅជាការទូទាត់សម្របនឹងប្រព័ន្ធអេឡិចត្រូនិករបស់ធនាគារជំនួសវិញ។ ភាគីទាំងពីរ អាចរក្សាទុកប្រាក់របស់ពួកគេ នៅក្នុងគណនីធនាគារហើយធ្វើការទូទាត់ឲ្យភាគីម្ខាងទៀតបានភ្លាមៗ ដោយប្រើប្រាស់មធ្យោបាយណាមួយរបស់ធនាគារដូចជាមូលប្បទានបត្រដែលបញ្ជាក់ចំនួនទឹកប្រាក់ច្បាស់លាស់ និងមានហត្ថលេខាត្រឹមត្រូវនៅលើនោះ ឲ្យទៅអ្នកទទួលជាការស្រេច ឯអ្នកទទួលអាចប្រមូលប្រាក់នោះ ត្រឡប់វិញដោយតាមរយៈការយកមូលប្បទានបត្រនោះទៅកាន់ធនាគារ ដែលបានចេញមូលប្បទានបត្រឲ្យ និងបើកប្រាក់តាមរយៈមធ្យោបាយនោះ ឬផ្ទេរទឹកប្រាក់ចូលទៅក្នុងគណនីរបស់ខ្លួន។

**១.២.១.៣ ការប្រើប្រាស់ប័ណ្ណទូទាត់**

ការប្រើប្រាស់ប័ណ្ណទូទាត់មានវត្តមានដំបូងនៅក្នុងសហរដ្ឋអាមេរិកនាទសវត្សរ៍ឆ្នាំ ១៩១៥។ ការអនុវត្តនោះ ដំបូងឡើយមានតែក្នុងផ្នែកសណ្ឋាគារ និងហាងលក់ទំនិញប៉ុណ្ណោះ រហូតដល់ឆ្នាំ ១៩៤៧ ទើបមានធនាគារបោះពុម្ពនូវប័ណ្ណទូទាត់នេះ ឲ្យអតិថិជនក្នុងស្រុកប្រើប្រាស់ដែលទទួលស្គាល់ដោយអាជ្ញាធរសមាគមប័ណ្ណទូទាត់ ហើយការទូទាត់អាចធ្វើបានតែអ្នកកាន់ប័ណ្ណទៅឈ្មួញដែលបានចុះឈ្មោះជាមុនសិនថា យល់ព្រមទទួលការយកតាមរយៈការប្រើប័ណ្ណនោះតែប៉ុណ្ណោះ។ ធនាគារនោះត្រូវបានគេហៅថាជាធនាគារបោះផ្សាយប័ណ្ណ មានន័យថាធនាគារឈ្មោះអ្នកកាន់កាប់ប័ណ្ណ និងចេញប័ណ្ណដែលមានភ្ជាប់និមិត្តសញ្ញារបស់ សមាគមធនាគារ

[11] Business Gov Au. (2018, December 04). Choosing payment methods. Retrieved from https://www.business.gov.au/finance/payments-and-invoicing/choosing-payment-methods

ព្រមទាំងដាក់ឲ្យដំណើរការគណនីរបស់ប័ណ្ណដែលការទូទាត់ គឺជាបន្ទុករបស់ធនាគារ។

### ១.២.២. ប្រភេទនៃមធ្យោបាយទូទាត់[12]

ប្រភេទនៃមធ្យោបាយទូទាត់មានច្រើនប្រភេទដូចជា៖

#### ១.២.២.១ មូលប្បទានបត្រ

មូលប្បទានបត្រ គឺជាប័ណ្ណដែលត្រូវបានប្រើប្រាស់ជាឧបករណ៍ទូទាត់ និងជាឧបករណ៍សម្រាប់ដកសាច់ប្រាក់ពីធនាគារហើយទាក់ទងទៅនឹងបុគ្គល ៣ គឺម្ចាស់មូលប្បទានបត្រ ធនាគារ និងអ្នកទទួលផល។ មូលប្បទានបត្រដែលចេញផ្សាយអោយប្រើប្រាស់ជាទូទៅត្រូវមានលក្ខណៈដូចខាងក្រោម៖

***ផ្នែកច្បាប់មានចំនួន ៦ ចំណុចគឺ***

- ពាក្យថាមូលប្បទានបត្រត្រូវចែងក្នុងមូលប្បទានបត្រ
- ចាំបាច់ត្រូវមានការបង្គាប់ជាចាំបាច់របស់អ្នកផ្ញើមូលប្បទានបត្រទៅធនាគារឲ្យប្រគល់សាច់ប្រាក់ ក្នុងបរិមាណមួយទៅអ្នកទទួលហើយទឹកប្រាក់ត្រូវសរសេរជាអក្សរ
- ឈ្មោះធនាគារដែលទៅប្រគល់សាច់ប្រាក់
- បញ្ជាក់ពីទីកន្លែងដែលត្រូវប្រគល់សាច់ប្រាក់
- កាលបរិច្ឆេទ និងទីកន្លែងដែលម្ចាស់មូលប្បទានបត្រចុះហត្ថលេខា
- ហត្ថលេខារបស់ម្ចាស់មូលប្បទានបត្រ

***ផ្នែកពាណិជ្ជកម្មមាន ៩ ចំណុចគឺ***

- លេខមូលប្បទានបត្រ
- លេខកូដរបស់ធនាគារ
- លេខគណនី
- សរសេរបរិមាណទឹកប្រាក់សារឡើងវិញម្តងទៀតជាលេខ
- Credit Balance
- Bearer Clause
- បញ្ជាក់ពីអ្នកទទួលមូលប្បទានបត្រ
- ទិសដៅនៃការបង់

[12] Trade Facilitation Implementation Guide. (2012). Payments. Retrieved from http://tfig.unece.org/contents/payments-types.htm

- បញ្ជាក់ពីCode Line របស់មូលប្បទានបត្រ

***នីតិវិធីនៃការអោយប្រើប្រាស់មូលប្បទានបត្រ***

ធនាគារអាចផ្តល់មូលប្បទានបត្រឲ្យអតិថិជនថ្មីប្រើប្រាស់បានលុះត្រាតែ ៖

- បានពិនិត្យលើបញ្ជីឈ្មោះហាមឃាត់ ក្នុងការប្រើប្រាស់មូលប្បទានបត្រដែលបានប្រកាសផ្សាយដោយធនាគារកណ្តាល
- អតិថិជនត្រូវបើកគណនីចរន្តមួយនៅធនាគារ
- ធនាគាររក្សាសិទ្ធិ មិនអនុញ្ញាតឲ្យទៅអតិថិជនណាម្នាក់ ប្រើប្រាស់មូលប្បទានបត្រ បានតាមការយល់ឃើញដោយពុំចាំបាច់បញ្ជាក់មូលហេតុដល់អតិថិជននោះឡើយ។
- ទន្ទឹមនឹងនោះធនាគារក៏អាចបដិសេធការទូទាត់ចំពោះមូលប្បទានបត្រក្នុងករណីដែល ៖
- មូលប្បទានបត្របាត់ ឬចោរលួចដើរម្ចាស់មូលប្បទានបត្របានប្តឹងឲ្យបិទ
- ការក្លែងបន្លំហត្ថលេខាមានស្នាមលុបឬកែចំនួនទឹកប្រាក់ឬភាពមិនប្រក្រតីណាមួយដែលធនាគារសង្ស័យ។

**១.២.២.២ លិខិតឥណទាន**

លិខិតឥណទាន គឺជាឯកសារមួយប្រភេទដែលបោះពុម្ព ដោយស្ថាប័នហិរញ្ញវត្ថុប្រើប្រាស់នៅក្នុងហិរញ្ញប្បទានពាណិជ្ជកម្ម ដែលផ្តល់អោយនូវការសន្យាទូទាត់ដែលពុំអាចបដិសេធបាន។ លិខិតនេះត្រូវបានប្រើប្រាស់ជាទូទៅ នៅក្នុងប្រតិបត្តិការពាណិជ្ជកម្មអន្តរជាតិ និងអតិថិជនក្នុងប្រទេសមួយផ្សេងទៀត។ ភាគីពាក់ព័ន្ធទៅនឹងលិខិតឥណទាន រួមមានអ្នកទទួលផល (Beneficiary) ដែលនឹងត្រូវបានទូទាត់ឲ្យធនាគារអ្នកទទួលផល (Advising bank ) និងធនាគារចេញលិខិតឥណទាន (Issuing bank) ដែលត្រូវបាន អ្នកទិញទំនិញបានពឹងពាក់ក្នុងការធានាចំពោះភាគីអ្នកផ្គត់ផ្គង់។

**១.២.២.៣ ប័ណ្ណឥណទាន**

ប័ណ្ណឥណទានត្រូវបានបង្កើតឡើងសម្រាប់ជាមធ្យោបាយទូទាត់មួយប្រភេទទៀត ហើយត្រូវបានចេញផ្សាយដោយគ្រឹះស្ថានឥណទានឯកទេស និងធនាគារផងដែរ។ ប័ណ្ណនេះ គឺជាប្រភេទប័ណ្ណប្លាស្ទិកមួយដែលមាន Magnetic Strip សម្រាប់ផ្ទុកនូវទិន្នន័យ ដែលស្រដៀងទៅនឹងប័ណ្ណឥណពន្ធដែរ និងជាឧបករណ៍ហិរញ្ញវត្ថុមួយ ដែលអនុញ្ញាតអោយម្ចាស់ប័ណ្ណធ្វើការទូទាត់ថ្លៃទំនិញ ឬសេវាកម្មជាឥណទាន និងជំនួសឲ្យសាច់ប្រាក់។ អតិថិជនអាចធ្វើការទិញទំនិញបង់ថ្លៃសេវាកម្ម និងទូទាត់ភ្លាមៗហើយធ្វើការទូទាត់ទៅកាន់ធនាគារវិញនៅពេលក្រោយ។ ម្ចាស់ប័ណ្ណ

ឥណទានអាចធ្វើការទិញទំនិញ ជាមួយនឹងកម្រិតឥណទានមួយ ដែលបានកំណត់ជាមុន ហើយត្រូវបង់ត្រឡប់តាមកាលបរិច្ឆេទព្រមព្រៀងថាឲ្យស្ថាប័នចេញបានវិញ។ ក្នុងករណីខកខានបំពេញកាតព្វកិច្ចទាន់ពេល ការប្រាក់ នឹងត្រូវបានគិតបន្ថែមទៅលើចំនួនទឹកប្រាក់នោះ។ ប័ណ្ណឥណទាននីមួយៗ គឺសុទ្ធសឹងតែមានលេខកូដសម្ងាត់បញ្ជាក់ (PIN)។

**នីតិវិធីនៃការទូទាត់**

ប័ណ្ណនេះបង្កើតដំបូង ម្ចាស់ប័ណ្ណឥណទានគ្រាន់តែចុះហត្ថលេខាលើវិក្កយបត្រ ហើយអ្នកលក់ទំនិញនឹងយកវិក្កយបត្រដូចគ្នានេះ ទៅឲ្យស្ថាប័នហិរញ្ញវត្ថុទូទាត់បន្ត។ ដោយឡែកចំពោះបច្ចុប្បន្នបច្ចេកវិទ្យាទំនើប នៅពេលទូទាត់ពាណិជ្ជករឬអ្នកលក់នឹងបញ្ចូលប័ណ្ណឥណទានរបស់អតិថិជនទៅក្នុងម៉ាស៊ីន ហើយចុះចំនួនទឹកប្រាក់ដែលត្រូវទូទាត់ បន្ទាប់មកម្ចាស់ប័ណ្ណចុចលេខកូដសម្ងាត់របស់ខ្លួនហើយចុច Valid បន្ទាប់មក ម៉ាស៊ីននឹងចេញវិក្កយបត្រពីរសន្លឹក ដែលមួយសម្រាប់ម្ចាស់ប័ណ្ណ និងមួយទៀតសំរាប់ពាណិជ្ជករ ដើម្បីធ្វើជាអំណះអំណាងសម្រាប់យកទៅទូទាត់ជាមួយនឹងធនាគារឬគ្រឹះស្ថានដែលជាអ្នកចេញផ្សាយ។ ចំណែកឯម្ចាស់ប័ណ្ណត្រូវទូទាត់សងទៅឲ្យស្ថាប័ន ដែលបានចេញផ្សាយ នូវរាល់ដំណាច់ខែនីមួយៗ នូវចំនួនទឹកប្រាក់ដែលខ្លួនបានប្រើប្រាស់។

### ១.២.៣ អត្ថប្រយោជន៍នៃប្រតិបត្តិការទូទាត់[13]

ប្រតិបត្តិការទូទាត់ គឺជាមធ្យោបាយដ៏ប្រសើរមួយដែលមានធនាគារជាអន្តរការីជួយសម្របសម្រួលទៅលើការទូទាត់អោយមានភាពកាន់តែងាយស្រួល ចំពោះភាគីពីរដែលអាចជាអ្នកលក់ឬអ្នកទិញ ដៃគូរកស៊ី ជាដើម។ ប្រតិបត្តិការទូទាត់មានអត្ថប្រយោជន៍ដូចជា៖

- អតិថិជនចំណេញពេលវេលានៅក្នុងការកាន់សាច់ប្រាក់ទៅទូទាត់អោយបុគ្គលម្នាក់ទៀតដែលនៅតំបន់ផ្សេងឬឆ្ងាយពីខ្លួន។
- អតិថិជនទទួលបាននូវសុវត្ថិភាព និងទំនុកចិត្ត នៅក្នុងការទូទាត់សាច់ប្រាក់ទៅអោយភាគីម្ខាងទៀត ដោយមានធនាគារ ជាអ្នកត្រួតពិនិត្យ និងផ្ទៀងផ្ទាត់នូវភាពត្រឹមត្រូវ ច្បាស់លាស់ទាំងនោះ។
- ធនាគារទទួលបានកម្រៃតាមរយៈការទូទាត់នានារបស់អតិថិជន។

[13] K. (2016, February 27). Advantages of Payments in Bank. Retrieved from http://www.keralabanking.com/advantages-of-payments-bank/

- ធនាគារអាចផ្សារភ្ជាប់ដៃគូរពាណិជ្ជកម្មរបស់ខ្លួន ជាមួយនឹងធនាគារដទៃ ឬពាណិជ្ជករដែលនាំមកនូវឱកាសពង្រីក និងអភិវឌ្ឍខ្លួន តាមរយៈការបង្កើនបណ្តាញទូទាត់អោយកាន់តែធំទូលាយ។

### ១.២.៤ ហានិភ័យនៃប្រតិបត្តិការទូទាត់[14]

ហានិភ័យនៃប្រតិបត្តិការទូទាត់ អាចកើតមានឡើងក្រោមរូបភាព ៣ខាងក្រោម៖

- ការទូទាត់សាច់ប្រាក់លើស ឬខ្វះ ៖ ហានិភ័យនេះ អាចជាការបាត់បង់របស់ភាគីអតិថិជន ឬក៏ជាធនាគារដែលជាអន្តរការីក្នុងការទូទាត់ផ្ទាល់។ កំហុសនេះអាចកើតឡើងបានដោយសារតែការខ្វះភាពប្រុងប្រយ័ត្ន និងផ្ទៀងផ្ទាត់របស់អតិថិជនក្នុងការរាប់លុយមុនពេលយកទៅកាន់ធនាគារ ឬជាភាពធ្វេសប្រហែសរបស់បុគ្គលិកធនាគារ ក្នុងការផ្ទៀងផ្ទាត់សាច់ប្រាក់ ដែលទទួលពីអតិថិជន ជាមួយនឹងការរាប់ដោយផ្ទាល់ដៃ និងប្រើប្រាស់ម៉ាស៊ីនរាប់សាច់ប្រាក់ផ្ទាល់។ ក្នុងល័ក្ខខ័ណ្ឌមួយទៀត តាមរយៈការទូទាត់ដោយប្រើប្រាស់កាតធនាគារ គឺពាណិជ្ជករដែលប្រើប្រាស់ម៉ាស៊ីនឆូតកាត វាយតម្លៃលេខច្រឡំ ដោយមិនបានពិនិត្យ ច្បាស់លាស់ ដែលជាហេតុបណ្តាលអោយមានការខាតបង់ ទាំងពេលវេលា និងប្រាក់កាសក្នុងពេលតែមួយ។
- ការទទួលបានក្រដាសប្រាក់ក្លែងក្លាយតាមរយៈការទូទាត់ ៖ ចរាចរសាច់ប្រាក់ក្លែងក្លាយ គឺជាហានិភ័យមួយដែលធនាគារប្រឈមខ្លាំង តាមរយៈការទទួលសាច់ប្រាក់សុទ្ធពីអតិថិជន ដោយមិនបានប្រើប្រាស់ឧបករណ៍ជំនួយ ក្នុងការចាប់នូវសាច់ប្រាក់ក្លែងក្លាយនោះ ក្នុងករណីដែលហានិភ័យនេះកើតឡើងធនាគារមានភាគរយខ្ពស់ក្នុងការខូចខាតលើកិត្តិយស និងស្លាកយីហោរបស់ខ្លួន។
- ការឆបោកតាមអនឡាញ ៖ ការទូទាត់តាមអ៊ីនធឺណេត គឺជាមធ្យោបាយដ៏ពេញនិយម និងងាយស្រួលសម្រាប់អតិថិជន នាពេលបច្ចុប្បន្ន។ ប៉ុន្តែទន្ទឹមនឹងនេះ វាក៏មានហានិភ័យខ្ពស់ នៅក្នុងល័ក្ខខ័ណ្ឌ ដែលអតិថិជនមិនបានប្រើប្រាស់វា ដោយគោរពតាមគោលការណ៍របស់ធនាគារ ដែលជាចន្លោះប្រហោងអោយជនឆ្លៀតឱកាសនៅលើអនឡាញលួចលេខកាត ព័ត៌មានផ្ទាល់ខ្លួន និងលេខសំងាត់ ដើម្បីធ្វើប្រតិបត្តិការលួចលុយតាមអនឡាញ ឬការបង្កើតជាកាតក្លែងក្លាយសម្រាប់ធ្វើប្រតិបត្តិការទូទាត់ ដែលប្រាក់ទាំងនោះ សុទ្ធសឹងតែកាត់ចេញ ពីគណនីអតិជននៅក្នុងរូបភាពក្លែងបន្លំឆបោក។

[14] Neville, L. (2012, October 9). Cash management: Payment risk. Retrieved from https://www.euromoney.com/article/b12kjgf8txkb94/cash-management-payment-risk

## ១.៣. ការផ្ទេរប្រាក់

### ១.៣.១ និយមន័យ[15]

ការផ្ទេរប្រាក់ គឺជាប្រតិបត្តិការដែលធនាគារិកនៅលើបទបញ្ជាអតិថិជន កាត់យកប្រាក់មួយចំនួនមុនពីគណនីមួយ ហើយផ្ទេរទៅឲ្យគណនីមួយទៀត ដែលអាចខ្លួនឯងជាម្ចាស់ ឬអាចជាបុគ្គលម្នាក់ទៀត។

បទបញ្ជាផ្ទេរ អាចសរសេរជាលាយលក្ខណ៍អក្សរនៅលើក្រដាសធម្មតា តែធនាគារច្រើនបង្កើតបទបញ្ជាផ្ទេរបោះពុម្ពរួចជាស្រេចទុកឲ្យអតិថិជនរបស់ខ្លួនបំពេញ។ បទបញ្ជាផ្ទេរ តម្រូវឲ្យអតិថិជនទទួលស្គាល់ឈ្មោះអ្នកទទួល ឈ្មោះធនាគារ អ្នកកាន់បញ្ជីគណនី និងលេខគណនី។

### ១.៣.២ ប្រភេទនៃការផ្ទេរប្រាក់

ការផ្ទេរប្រាក់ចែកចេញជាពីរប្រភេទគឺ ការផ្ទេរប្រាក់ក្នុងស្រុក និងការផ្ទេរប្រាក់ក្រៅប្រទេស ឬការផ្ទេរប្រាក់អន្តរជាតិ។

#### ១.៣.២.១ ការផ្ទេរប្រាក់ក្នុងស្រុក

ការផ្ទេរប្រាក់ក្នុងស្រុក គឺជាការផ្ទេររូបិយវត្ថុ ពីធនាគារមួយទៅធនាគារមួយទៀត ដែលជាសាខារបស់ធនាគារសាមី ឬជាលក្ខណៈមិនមែនជាសាខារបស់ធនាគារ។

ចំពោះការផ្ទេរប្រាក់ក្នុងស្រុកនេះអាចមាន ២ របៀបគឺ៖

- ការផ្ទេរនៅធនាគារតែមួយ ៖ គឺជាការផ្ទេរពីស្នាក់ការកណ្ដាលទៅសាខា ឬពីសាខាមកស្នាក់ការកណ្ដាល ឬពីសាខាទៅសាខារវាងធនាគារតែមួយ។ ការផ្ទេរនេះអាចធ្វើឡើងតាមរវាង ៤ប្រភេទដូចជា៖

- ការផ្ទេរពីគណនីមួយទៅគណនីមួយទៀតស្ថិតក្នុងសាខាតែមួយ
- ការផ្ទេរពីគណនីមួយទៅគណនីមួយទៀតស្ថិតក្នុងសាខាផ្សេងគ្នា
- ការផ្ទេរពីអ្នកមានគណនីទៅអ្នកគ្មានគណនី (ឧទា៖ សេវាផ្ទេរប្រាក់របស់ធនាគារ ABA ដែលអាចផ្ទេរពីអ្នកមានគណនីទៅបុគ្គលម្នាក់ទៀតតាមរយៈមុខងារ E-Cash របស់ ABA Mobile Banking)
- ការផ្ទេរពីអ្នកគ្មានគណនីទៅអ្នកគ្មានគណនីដូចគ្នា (ឧទា៖ សេវាផ្ទេរប្រាក់របស់វីង ដែលអាចផ្ទេរប្រាក់តាមរយៈលេខទូរស័ព្ទ)

[15] ហ៊ីង ចូវ៉ាក់ស៊ី និងហ៊ាន សាហ៊ីប, ១៩៩៨, "វចនានុក្រមសេដ្ឋកិច្ច" ទំព័រ ២៨

- ការផ្ទេរនៅធនាគារពីរផ្សេងគ្នា ៖ គឺជាការផ្ទេរពីគណនីរបស់ធនាគារមួយទៅគណនីរបស់ធនាគារមួយផ្សេងទៀតដែលជាដៃគូសហការនឹងគ្នា។ ឧទាហរណ៍៖ សេវាផ្ទេរប្រាក់របស់ធនាគារ ABA អាចផ្ទេរពីគណនី ABA ទៅគណនីនៃធនាគារផ្សេងទៀតតាមរយៈប្រព័ន្ធផ្ទេរប្រាក់រហ័ស (Fast Payment) ដែលដាក់ចេញឲ្យប្រើដោយធនាគារជាតិ ។

### ១.៣.២.២ ការផ្ទេរប្រាក់ក្រៅប្រទេស ឬអន្តរជាតិ

ការផ្ទេរប្រាក់ក្រៅប្រទេស ឬអន្តរជាតិ គឺជាការផ្ទេររូបិយវត្ថុពីប្រទេសមួយទៅកាន់បរទេស ឬប្រទេសមួយទៀត តាមរយៈធនាគារដែលជាដៃគូទំនាក់ទំនងធនាគារឬ តាមរយៈធនាគារកណ្តាល។ ចំពោះការផ្ទេរប្រាក់ក្រៅប្រទេសត្រូវបានគេបែងចែកជា ២ បែបគឺ ការផ្ទេរប្រាក់ចូលពីបរទេស និងការផ្ទេរប្រាក់ចេញទៅបរទេស។ ជាទូទៅ ការផ្ទេរប្រាក់ក្រៅប្រទេសត្រូវបានធ្វើឡើងតាមរយៈប្រព័ន្ធផ្ទេរប្រាក់អន្តរជាតិជាច្រើន រួមមានដូចជា៖

- ប្រព័ន្ធផ្ទេរប្រាក់អន្តរជាតិ Western Union
- ប្រព័ន្ធផ្ទេរប្រាក់អន្តរជាតិ SWIFT
- ប្រព័ន្ធផ្ទេរប្រាក់អន្តរជាតិ MoneyGram

## ១.៣.៣ ប្រព័ន្ធផ្ទេរប្រាក់អន្តរជាតិ

### ១.៣.៣.១ ប្រព័ន្ធផ្ទេរប្រាក់អន្តរជាតិ Western Union[16]

ប្រព័ន្ធផ្ទេរប្រាក់ Western Union ត្រូវបានបង្កើតឡើងនៅទីក្រុងញូយ៉ក សហរដ្ឋអាមេរិកក្នុងឆ្នាំ ១៨៥១ ហើយមានឈ្មោះ Western Union ជាផ្លូវការនៅឆ្នាំ ១៨៥៦។ វាគឺជាបណ្តាញផ្ទេរប្រាក់ដ៏ធំបំផុតនៅលើពិភពលោកដែលបានផ្តល់សេវាផ្ទេរប្រាក់ជូនអតិថិជនរបស់ខ្លួនអស់រយៈពេលជាង ១៥០ ឆ្នាំមកហើយ។ ភ្នាក់ងារជាច្រើន នៅគ្រប់ទីកន្លែង គឺមានច្រើនជាង ៥៥០,០០០ កន្លែងទូទាំងពិភពលោក សម្រាប់បម្រើសេវាផ្ទេរប្រាក់ ដោយពុំបាច់មានគណនីនៅធនាគារ។ ភាគច្រើននៅការិយាល័យរបស់ភ្នាក់ងារ Western Union មានផ្តល់សេវារាល់ម៉ោងពេញមួយសប្តាហ៍ និងបានប្រើប្រាស់បច្ចេកវិទ្យាអេឡិចត្រូនិចដ៏ទំនើបបំផុត និងមានតែមួយគត់ពាសពេញពិភពលោកក្នុងការទូទាត់ភ្លាមៗរហូតដល់ជាង ២០០ប្រទេស និងប្រភេទរូបិយប័ណ្ណរហូតដល់ទៅ ១៣០ រូបិយប័ណ្ណ។

[16] Heaton, L. (2018, September 20). The History of Western Union. Retrieved from https://embily.com/the-history-of-western-union/

**នីតិវិធីនៃការផ្ញើប្រាក់តាមប្រព័ន្ធ Western Union**[17]

អតិថិជនដែលមានតម្រូវការផ្ញើប្រាក់ ត្រូវស្វែងរកការិយាល័យធនាគារ ឬគ្រឹះស្ថានទាំងឡាយណាដែលមានបម្រើសេវាផ្ទេរប្រាក់ Western Union ដោយភ្ជាប់នឹងអត្តសញ្ញាណប័ណ្ណរបស់ខ្លួនទៅជាមួយផងដែរ។ បន្ទាប់មកទៀត ត្រូវផ្តល់ព័ត៌មានមួយចំនួនទៅកាន់ភ្នាក់ងារ Western Union ដូចជា ឈ្មោះរបស់អតិថិជនអ្នកផ្ញើ និងអាសយដ្ឋាន ឈ្មោះអ្នកទទួល (ដូចលើអត្តសញ្ញាណប័ណ្ណ) និងឈ្មោះប្រទេសដែលផ្ញើ។ អតិថិជនត្រូវប្រគល់ឲ្យភ្នាក់ងារ Western Union ជាមួយនឹងទឹកប្រាក់ដែលត្រូវការផ្ញើ និងកម្រៃសេវានៃប្រតិបត្តិការផ្ញើ។ ក្រោយពីទទួលបានព័ត៌មានពីអតិថិជនគ្រប់គ្រាន់ហើយ ភ្នាក់ងាររបស់ Western Union នឹងផ្តល់ឲ្យអ្នកផ្ញើនូវវិក្កយបត្រផ្ញើប្រាក់ និងលេខសម្ងាត់ចំនួន ១០ខ្ទង់ (MTCN: Money Transfer Control Number) ។ បន្ទាប់មក អតិថិជនដែលជាអ្នកផ្ញើចាំបាច់ត្រូវប្រាប់លេខសម្ងាត់១០ខ្ទង់នោះទៅកាន់អ្នកទទួលដើម្បីអាចបើកប្រាក់។

**នីតិវិធីនៃការទទួលប្រាក់តាមប្រព័ន្ធ Western Union**

អតិថិជនដែលជាអ្នកទទួលប្រាក់ត្រូវមកកាន់ការិយាល័យរបស់ Western Union នៅទីតាំងសន្មតដែលត្រូវធ្វើការទូទាត់ រួចធ្វើការបង្ហាញលេខសម្ងាត់១០ខ្ទង់ (MTCN: Money Transfer Control Number) ព្រមទាំងឯកសារសម្គាល់ខ្លួន (ដូចជាអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន ឬប័ណ្ណបើកបរដែលមិនទាន់ផុតសុពលភាព) ទៅកាន់ភ្នាក់ងារ Western Union។ ប្រសិនបើព័ត៌មានត្រឹមត្រូវ និងគ្រប់គ្រាន់ហើយ អតិថិជននឹងទទួលបានប្រាក់ភ្លាមៗពីភ្នាក់ងារ Western Union ហើយចុះហត្ថលេខានៅលើវិក្កយបត្រ។ ចំពោះការប្រគល់ប្រាក់ គឺប្រគល់ជាសាច់ប្រាក់សុទ្ធហើយជាប្រភេទរូបិយប័ណ្ណក្នុងស្រុក។

### ១.៣.៣.២ ប្រព័ន្ធផ្ទេរប្រាក់អន្តរជាតិ SWIFT[18]

ប្រព័ន្ធផ្ទេរប្រាក់ SWIFT (The Society for Worldwide Interbank Financial Telecommunication) គឺជាប្រព័ន្ធផ្ទេរប្រាក់មួយដែលផ្តល់នូវសុវត្ថិភាពក្នុងការធ្វើប្រតិបត្តិការផ្លាស់ប្តូរព័ត៌មានរវាងធនាគារ និងស្ថាប័នហិរញ្ញវត្ថុផ្សេងទៀតទូទាំងពិភពលោក។ ប្រព័ន្ធផ្ទេរប្រាក់នេះ ត្រូវបានបង្កើតឡើងនៅឆ្នាំ ១៩៧៣ នៅទីក្រុងប្រ៊ូសសែល (Brussels) នៃប្រទេសប៊ែលសិក (Belgium)។ SWIFT

[17] Lewis, M. R. (2019, March 29). How to Transfer Money with Western Union. Retrieved from https://www.wikihow.com/Transfer-Money-with-Western-Union

[18] Society for Worldwide Interbank Financial Telecommunication. (2019, July 04). Retrieved from https://en.wikipedia.org/wiki/Society_for_Worldwide_Interbank_Financial_Telecommunication

គឺ ជាបណ្តាញផ្ទេរប្រាក់ដ៏មានសុវត្ថិភាព និង គួរជាទីទុកចិត្ត ដែលតាមរយៈប្រព័ន្ធ SWIFT (សមាគមទូរគមនាគមន៍ សម្រាប់កិច្ចការហិរញ្ញវត្ថុរវាងធនាគារទូទាំងពិភពលោក) មានធនាគារដែលជាសមាជិក ជាង ៧,៩០០ ក្នុងប្រទេសចំនួន ១៩៩ប្រទេស។

**នីតិវិធីនៃការផ្ញើប្រាក់តាមប្រព័ន្ធ SWIFT**

ការផ្ទេរប្រាក់តាមប្រព័ន្ធផ្ទេរប្រាក់អន្តរជាតិមួយនេះ គឺមានភាពងាយស្រួលដោយអតិថិជនជាអ្នកផ្ញើត្រូវបំពេញទម្រង់ផ្ទេរប្រាក់ឲ្យបានត្រឹមត្រូវនៅការិយាល័យ ឬធនាគារជាភ្នាក់ងារ SWIFT មួយណាដែលនៅជិតខ្លួន។ អតិថិជន ត្រូវបំពេញព័ត៌មានដូចជាលេខគណនីអ្នកទទួលជាមួយធនាគារ អត្តសញ្ញាណអ្នកទទួល (ឈ្មោះ និងព័ត៌មានចាំបាច់មួយចំនួន) អាសយដ្ឋានអ្នកទទួល និងចំនួនទឹកប្រាក់ដែលត្រូវផ្ញើ។

**នីតិវិធីនៃការទទួលប្រាក់តាមប្រព័ន្ធ SWIFT**

អ្នកទទួលប្រាក់ត្រូវទៅការិយាល័យ ឬធនាគារជាភ្នាក់ងារ SWIFT រួចធ្វើការបំពេញទម្រង់ទទួលប្រាក់ ដែលសរសេរចំនួនទឹកប្រាក់ជាលេខ ឬអក្សរ។ បន្ទាប់មក អតិថិជនត្រូវបំពេញឈ្មោះអ្នកផ្ទេរប្រាក់ និងអាសយដ្ឋានឲ្យបានត្រឹមត្រូវដូចដែលអ្នកផ្ញើបានបំពេញ រួចបំពេញឈ្មោះធនាគារអន្តរការី និងអាសយដ្ឋាន ជាមួយនឹង SWIFT Code ឲ្យបានត្រឹមត្រូវ។ នៅពេលព័ត៌មានត្រឹមត្រូវ និងគ្រប់គ្រាន់នោះ អតិថិជននឹងទទួលបានប្រាក់ភ្លាមពី SWIFT។

**១.៣.៣.៣ ប្រព័ន្ធផ្ទេរប្រាក់អន្តរជាតិ** MoneyGram

MoneyGram International Inc. គឺជាក្រុមហ៊ុនដែលផ្តល់សេវាកម្មហិរញ្ញវត្ថុមួយដ៏ធំ លំដាប់ទី ២ លើពិភពលោក ដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៩៨ និងមានការិយាល័យកណ្តាលស្ថិតនៅទីក្រុងមីនាប៉ូលីស (Minneapolis) នៃរដ្ឋ Minnesota នៅអាមេរិកខាងជើង។ MoneyGram ផ្តល់សេវាកម្មមួយចំនួនដូចជា Money Transfer, Money Order និង Bill Payment។ ជាងនេះទៅទៀត ប្រព័ន្ធ Money Gram គឺជាការផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិច រៀបចំដោយក្រុមហ៊ុនអន្តរជាតិរបស់សហរដ្ឋអាមេរិច ដែលអតិថិជនអាចផ្ញើប្រាក់ជុំវិញពិភពលោកដោយប្រើពេលត្រឹមតែ ១០ នាទីប៉ុណ្ណោះ និងមិនចាំបាច់មានគណនីធនាគារ ឬប័ណ្ណឥណទានឡើយ។ ប្រទេសដែលជាដៃគូប្រព័ន្ធ Money Gram មានប្រមាណ ២០០ប្រទេស និងច្រើនជាង ៣៥០,០០០តំបន់នៅលើពិភពលោក។[19]

[19] MoneyGram History. (n.d.). Retrieved from http://corporate.moneygram.com/about-moneygram/history

**នីតិវិធីនៃការផ្ញើប្រាក់តាមប្រព័ន្ធ MoneyGram[20]**

អតិថិជនដែលមានបំណងផ្ញើប្រាក់តាមប្រព័ន្ធ MoneyGram ត្រូវមកកាន់ភ្នាក់ងារដោយមកជាមួយនឹងអត្តសញ្ញាណប័ណ្ណសម្គាល់ខ្លួន លិខិតឆ្លងដែន ឬប័ណ្ណបើកបរ។ អតិថិជនអាចនឹងត្រូវបានស្នើឲ្យបង្ហាញអាសយដ្ឋាន ឬវិក្កយបត្រ។ ល័ក្ខខ័ណ្ឌតម្រូវគឺខុសគ្នាទៅតាមប្រទេសនីមួយៗ។ ក្រៅពីឯកសារទាំងនោះ អតិថិជនចាំបាច់ត្រូវបំពេញទម្រង់បែបបទផ្ញើប្រាក់ (ត្រូវបំពេញឈ្មោះអ្នកទទួលឲ្យត្រឹមត្រូវតាមអត្តសញ្ញាណរបស់គេ ព្រមទាំងអាសយដ្ឋាន) រួចហើយប្រគល់ទៅឲ្យបេឡា ឬភ្នាក់ងារ MoneyGram ជាមួយទឹកប្រាក់ដែលត្រូវផ្ញើ និងថ្លៃសេវាផ្ញើប្រាក់ដែលបានកំណត់។ លើសពីនេះទៅទៀត អតិថិជនអាចធ្វើការផ្ញើសារ ១០ពាក្យ នៅលើបែបបទផ្ញើប្រាក់ដោយឥតគិតថ្លៃ។ បន្ទាប់មកអតិថិជននឹងទទួលបានលេខកូដផ្ញើ (Reference Number) ដើម្បីប្រគល់ឲ្យទៅអ្នកដែលត្រូវទទួលប្រាក់ ហើយត្រឹមតែ ១០នាទីប៉ុណ្ណោះ អ្នកទទួលនឹងអាចដកប្រាក់ចេញបានពីគ្រប់សាខា MoneyGram។

**នីតិវិធីនៃការទទួលប្រាក់តាមប្រព័ន្ធ MoneyGram[21]**

ដើម្បីអាចបើកប្រាក់ដែលផ្ញើតាមប្រព័ន្ធ MoneyGram បាន ដំបូងអតិថិជនត្រូវទាក់ទងទៅកាន់អ្នកផ្ញើប្រាក់ដើម្បីអោយផ្តល់លេខសម្ងាត់ឲ្យ។ អ្នកទទួលត្រូវទៅកាន់ ទីតាំងភ្នាក់ងាររបស់ MoneyGram ដោយភ្ជាប់មកជាមួយនូវអត្តសញ្ញាណប័ណ្ណ និងលេខកូដសម្ងាត់មកជាមួយ។ បន្ទាប់មក អតិថិជនត្រូវបំពេញទម្រង់បែបបទទទួលប្រាក់ រួចបង្ហាញអត្តសញ្ញាណប័ណ្ណរបស់ខ្លួនទៅកាន់ភ្នាក់ងារ MoneyGram។ ប្រសិនបើព័ត៌មានត្រឹមត្រូវ និងគ្រប់គ្រាន់ហើយ អតិថិជននឹងទទួលបានប្រាក់ភ្លាមៗ ដែលជាទូទៅសាច់ប្រាក់នោះជារូបិយប័ណ្ណនៃប្រទេសអ្នកទទួល។

### ១.៣.៤ អត្ថប្រយោជន៍នៃសេវាកម្មផ្ទេរប្រាក់[22]

ជាការពិតណាស់ ការផ្ទេរប្រាក់ គឺជាប្រតិបត្តិការដ៏សំខាន់មួយសម្រាប់ការរស់នៅប្រចាំថ្ងៃ ព្រោះមនុស្សជាច្រើនតែងមានតម្រូវការផ្ទេរប្រាក់ ក្នុងគោលបំណងដោះស្រាយរាល់បញ្ហាហិរញ្ញវត្ថុផ្សេងៗរបស់ពួកគេ។ កាលពីដើមឡើយ ការផ្ទេរប្រាក់ត្រូវបានធ្វើឡើងក្រៅប្រព័ន្ធធ្វើឲ្យមានភាពលំបាក ប៉ុន្តែបច្ចុប្បន្ន សេវាផ្ទេរប្រាក់ត្រូវបានប្រព្រឹត្តឡើងក្នុងប្រព័ន្ធធនាគារ។ ជាក់ស្តែង ក្នុង

[20] http://moneygram.com.ng/how-to-send-money

[21] http://moneygram.com.ng/how-to-receive-money

[22] Conrad, B. (2019, March 11). Advantages of Money Transfers. Retrieved May, 2019, from https://pocketsense.com/advantages-money-transfers-6627547.html

ចំណោមសេវាកម្មរបស់ធនាគារ សេវាផ្ទេរប្រាក់ត្រូវបានគេចាត់ទុកថា ជាសេវាកម្មដែលមានតួនាទីសំខាន់ ក្នុងការបំពេញតម្រូវការចាំបាច់របស់មនុស្សនៅក្នុងសង្គម ក៏ដូចជាប្រទេសជាតិទាំងមូលផងដែរ។ ប្រតិបត្តិការផ្ទេរប្រាក់នេះបានផ្តល់អត្ថប្រយោជន៍ជាច្រើនដល់បុគ្គល គ្រឹះស្ថានហិរញ្ញវត្ថុ ឬធនាគារ ព្រមទាំងប្រទេសជាតិដូចជា ៖

***ចំពោះអតិថិជន***

- ភាពងាយស្រួល

សេវាកម្មផ្ទេរប្រាក់របស់ធនាគារបានផ្តល់ភាពងាយស្រួលដល់អ្នកប្រើប្រាស់ ទាំងអតិថិជនដែលជាអ្នកផ្ញើប្រាក់ និងអ្នកទទួលប្រាក់។ មូលហេតុដែលជំរុញឲ្យសេវាកម្មនេះមានភាពងាយស្រួលនោះ គឺមកពីដំណើរការនៃការផ្ញើតាមធនាគារ ឬគ្រឹះស្ថានហិរញ្ញវត្ថុ មិនមានភាពស្មុគស្មាញសាំញ៉ាំ រីឯការផ្តល់ព័ត៌មាន និងឯកសារផ្សេងៗ គឺងាយស្រួលយល់។ ម្យ៉ាងវិញទៀត នាពេលបច្ចុប្បន្ននេះ សេវាផ្ទេរប្រាក់មានច្រើនសាខានៅគ្រប់ទីកន្លែង ដែលធ្វើអោយការផ្ទេរប្រាក់កាន់តែអាចប្រព្រឹត្តទៅបានយ៉ាងងាយស្រួលសម្រាប់អ្នកដែលមានតម្រូវការទៅផ្ញើប្រាក់ និងអ្នកទទួលដែលត្រូវទៅបើកប្រាក់។ ជាងនេះទៅទៀត បើអតិថិជនជ្រើសរើសការផ្ទេរប្រាក់តាមរយៈការប្រើប្រាស់ E-Banking នោះការផ្ទេរប្រាក់កាន់តែមានភាពងាយស្រួល និងឆាប់រហ័សថែមទៀត។

- សុវត្ថិភាព

អត្ថប្រយោជន៍ចម្បងនៃសេវាកម្មផ្ទេរប្រាក់តាមធនាគារនោះ គឺផ្តល់នូវសុវត្ថិភាពខ្ពស់ដែលអតិថិជនអាចជឿទុកចិត្តបាន។ ផ្ទុយទៅវិញ ការធ្វើផ្ទេរប្រាក់ក្រៅប្រព័ន្ធធនាគារ ដែលធ្វើឡើងតាមមធ្យោបាយផ្សេងៗតែងជួបហានិភ័យដូចជា ការកេងបន្លំ ឬឆបោកផ្សេងៗពីសំណាក់ឈ្មួញ ហើយការផ្ទេរប្រាក់ទាំងនោះតែងធ្វើឡើងដោយភាពប្រថុយប្រថានបំផុត។ ការប្រើប្រាស់សេវាផ្ទេរប្រាក់របស់ធនាគារអាចជួយកាត់បន្ថយហានិភ័យ ដែលកើតមានពីការផ្ញើប្រាក់តាមអ្នកស្គាល់គ្នា ឬការយកប្រាក់ទៅតាមខ្លួន ពីព្រោះការផ្ទេរប្រាក់របស់ធនាគារគឺប្រព្រឹត្តទៅក្នុងប្រព័ន្ធ ហើយជានិច្ចកាលធនាគារតែងតែប្រើប្រាស់ ដំណើរការ Two-Step Verification Procedure ដែលមិនធ្វើឲ្យអតិថិជនបារម្ភពីការបាត់បង់សាច់ប្រាក់របស់ខ្លួនឡើយ។

- ចំណាយតិច

ផ្ទេរប្រាក់ដោយផ្ញើតាមគ្នា គឺមានការចំណាយថវិកាច្រើនដើម្បីឲ្យប្រាក់ទៅដល់អ្នកទទួល។ ប៉ុន្តែបច្ចុប្បន្ន ការផ្ទេរប្រាក់តាមរយៈធនាគារ គឺមិនត្រឹមតែលឿនរហ័សនោះទេ ថែមទាំងចំណាយថ្លៃប្រតិបត្តិការតិចថែមទៀត។ កម្រៃសេវាផ្ទេរប្រាក់ត្រូវបានកំណត់តាមចំនួនសាច់ប្រាក់ដែលបាន

ផ្ទេរ ឬគិតជាភាគរយនៃចំនួនសាច់ប្រាក់ដែលត្រូវផ្ទេរ។ ម្យ៉ាងវិញទៀត កំណើននៃការប្រើប្រាស់សេវាកម្មផ្ទេរប្រាក់កាន់តែកើនឡើង ធ្វើឲ្យមានការប្រកួតប្រជែងទីផ្សារ ជាហេតុជំរុញឲ្យធនាគារនីមួយៗធ្វើការបន្ថយនូវថ្លៃសេវារបស់ខ្លួនឲ្យទាបជាងដៃគូប្រកួតប្រជែង។

- ចំណេញពេលវេលា

ដោយសារបណ្ដាញធនាគារ ឬភ្នាក់ងារដែលផ្ទេរប្រាក់មាននៅគ្រប់ទីកន្លែង អតិថិជនចំណាយពេលតិច ក្នុងការធ្វើប្រតិបត្តិការផ្ទេរប្រាក់ និងទទួលប្រាក់របស់ខ្លួន។ នីតិវិធីនៃការផ្ទេរប្រាក់ប្រព្រឹត្តទៅតាមរយៈប្រព័ន្ធបច្ចេកវិទ្យាដែលធ្វើឲ្យការផ្ទេរប្រាក់មានភាពរហ័ស បើករណីផ្ទេរប្រាក់ក្នុងស្រុក គឺអាចទទួលបានប្រាក់ភ្លាមៗតែម្ដង។ រីឯការផ្ទេរប្រាក់ក្រៅប្រទេសអាចមានរយៈពេលខុសគ្នាតាមប្រទេស និងប្រព័ន្ធផ្ទេរប្រាក់អន្តរជាតិដែលធនាគារប្រើប្រាស់។ ទោះជាយ៉ាងណាក៏ដោយ បើធៀបនឹងការផ្ទេរប្រាក់តាមវិធីផ្សេងទៀត ការផ្ទេរប្រាក់ក្រៅប្រព័ន្ធ គឺប្រើប្រាស់ពេលវេលាយូរជាងការផ្ទេរប្រាក់ក្នុងប្រព័ន្ធធនាគារ។

***ចំពោះធនាគារ***

នៅពេលដែលសេវាផ្ទេរប្រាក់ត្រូវបានដាក់ឲ្យដំណើរការ ធនាគារសាមី គឺអាចបង្កើនប្រាក់ចំណូលរបស់ខ្លួនកាន់តែច្រើនតាមរយៈសេវាកម្មមួយនេះ ព្រោះវាជាសេវាកម្មធំមួយក្នុងចំណោមសេវាកម្មទាំងបីរបស់ធនាគារ។ កម្រៃដែលទទួលបានមកពីតម្លៃប្រតិបត្តិការផ្ទេរប្រាក់នីមួយៗ ធ្វើឲ្យធនាគារមានឱកាសទទួលបានប្រាក់ចំណូលរបស់ខ្លួនកាន់តែច្រើនទ្វេដង។ ស្របពេលជាមួយគ្នានេះដែរ ធនាគារក៏អាចបង្កើនភាពសម្បូរបែបនៃសេវាកម្មរបស់ខ្លួន បន្ថែមលើសេវាប្រាក់បញ្ញើ និងការផ្ដល់កម្ចីដល់អតិថិជន។

***ចំពោះប្រទេសជាតិ***

ប្រតិបត្តិការផ្ទេរប្រាក់ដើរតួនាទីយ៉ាងសំខាន់ក្នុងការធ្វើឲ្យសេដ្ឋកិច្ចមានការរីកចម្រើនឿនលឿន ដោយសារវាបានធ្វើអោយមានចលនាសាច់ប្រាក់ក្នុងប្រទេសឥតឈប់ឈរ។ ជាងនេះទៅទៀត សេវាផ្ទេរប្រាក់ក្រៅប្រទេសក៏បានរួមចំណែកធ្វើឲ្យមានទំនាក់ទំនងអន្តរជាតិកាន់តែជិតស្និទ្ធថែមទៀត។ បម្រើបម្រាស់សេវាកម្មផ្ទេរប្រាក់ក្នុងប្រព័ន្ធរបស់ធនាគារ ក៏បានផ្ដល់ភាពងាយស្រួលដល់រដ្ឋាភិបាលក្នុងការត្រួតពិនិត្យ និងគ្រប់គ្រងលំហូរសាច់ប្រាក់ក្នុង និងក្រៅប្រទេសបានយ៉ាងប្រសើរ និងបានជួយឲ្យរាជរដ្ឋាភិបាល អាចដាក់ចេញនូវគោលនយោបាយរូបិយវត្ថុយ៉ាងមានប្រសិទ្ធភាពសម្រាប់ប្រទេសជាតិទាំងមូលផងដែរ។

## ១.៣.៥ ហានិភ័យនៃសេវាកម្មផ្ទេរប្រាក់[23]

ហានិភ័យដែលជួបប្រទះក្នុងការផ្ទេរប្រាក់ គឺអាចកើតមានឡើងដោយសារកំហុសមួយចំនួនដូចជា កំហុសអចេតនារបស់អតិថិជន ឬធនាគារ កំហុសបន្លំ និងកំហុសខុសច្បាប់ជាដើម។

**ការផ្ទេរប្រាក់ខុស** ៖ ហានិភ័យនៃការផ្ទេរប្រាក់ខុស គឺកើតឡើងដោយសារកំហុសអចេតនារបស់អតិថិជន ឬបុគ្គលិកធនាគារ។ ចំពោះកំហុសរបស់អតិថិជនអាចកើតឡើងក្នុងករណីមានការធ្វើខុសលើព័ត៌មានរបស់អ្នកទទួល ដែលជាទូទៅ គឺនៅពេលដែលអតិថិជនបំពេញឈ្មោះអ្នកទទួល ឬលេខគណនីរបស់អ្នកទទួលមិនត្រឹមត្រូវដោយច្រឡំទៅជាឈ្មោះ ឬលេខគណនីរបស់បុគ្គលផ្សេងទៅវិញ។ ជួនកាល ឈ្មោះដែលអតិថិជនបំពេញនៅលើបែបបទផ្ទេរប្រាក់ គឺត្រឹមត្រូវ ប៉ុន្តែខុសលេខគណនីរបស់អ្នកទទួល។ ដូច្នេះហើយ នៅពេលដែលទិន្នន័យផ្ទេរប្រាក់បានបញ្ចូលទៅដល់ធនាគារទទួលផល ឬធនាគារទំនាក់ទំនង ហើយធនាគារមិនបានពិនិត្យមើលឈ្មោះអ្នកទទួលទៀតនោះប្រតិបត្តិការផ្ទេរប្រាក់នឹងចូលទៅក្នុងគណនីដែលខុសនោះ។ ម្យ៉ាងវិញទៀត កំហុសផ្ទេរប្រាក់នេះក៏អាចកើតមានឡើងនៅពេលបុគ្គលិកផ្នែកផ្ទេរប្រាក់មានការធ្វេសប្រហែសមិនបានធ្វើការផ្ទៀងផ្ទាត់ព័ត៌មានលម្អិត មុនធ្វើការផ្ទេរប្រាក់ ឬអាចមកពីការបញ្ចូលព័ត៌មានខុស។ ប៉ុន្តែ បញ្ហានេះកម្រនឹងកើតមានឡើងណាស់ ពីព្រោះប្រព័ន្ធផ្ទេរប្រាក់របស់ធនាគារ គឺដំណើរការដោយស្វ័យប្រវត្តិ ហើយបុគ្គលិកធនាគារតែងតែពិនិត្យ និងផ្ទៀងផ្ទាត់ព័ត៌មានរបស់អតិថិជនយ៉ាងហ្មត់ចត់មុននឹងពួកគេធ្វើប្រតិបត្តិការផ្ទេរប្រាក់ជូនអតិថិជន។

**ការកេងបន្លំ ឬលួចយកព័ត៌មាន** ៖ ក្នុងសេវាផ្ទេរប្រាក់ ការកេងបន្លំតែងកើតឡើងជារឿយៗដូចជាករណីដែលអតិថិជនទទួលបានសារពីក្រុមហ៊ុនមិនស្គាល់ឈ្មោះណាមួយ ដែលអះអាងថាអតិថិជនបានឈ្នះរង្វាន់ រួចពួកគេតម្រូវឲ្យអតិថិជនធ្វើការផ្ទេរប្រាក់សម្រាប់ថ្លៃសេវាមួយចំនួន ដើម្បីអាចទទួលបានរង្វាន់នោះ។ ក្នុងករណីផ្ទេរប្រាក់បែបនេះ អតិថិជន អាចនឹងប្រឈមមុខនឹងការបាត់បង់ប្រាក់របស់ខ្លួនដោយអសារបង់ ហើយធនាគារនឹងមិន ទទួលខុសត្រូវចំពោះករណីផ្ទេរប្រាក់បែបនេះឡើយ។ រីឯហានិភ័យមួយទៀតនោះ គឺកើតឡើងដោយការលួចយកព័ត៌មានរបស់អ្នកទទួលប្រាក់ ដោយអតិថិជនដែលជាអ្នកផ្ញើមានការធ្វេសប្រហែសធ្វើឲ្យជនទីបីណាមួយ ដឹងពីព័ត៌មានរបស់អ្នកទទួល ព្រមទាំងលេខសម្ងាត់ដើម្បីបើកប្រាក់ដែលផ្ញើអោយជនទីបីនោះ អាចប្រើប្រាស់ព័ត៌មានទាំងនោះដើម្បីទៅបើកប្រាក់មុនអ្នកដែលត្រូវទទួលប្រាក់ពិតប្រាកដ។ ដូចនេះ រាល់ការផ្ញើ

[23] Identification and analysis of risks. (1998). *Risk Management For Electronic Banking And Electronic Money Activities*, 4-9. Retrieved March, 1998, from https://www.bis.org/publ/bcbsc215.pdf.

ប្រាក់ទៅកាន់នរណាម្នាក់ អតិថិជនចាំបាច់ប្រុងប្រយ័ត្នរក្សាព័ត៌មានសំងាត់ទាំងឡាយរបស់ខ្លួន និងត្រូវទំនាក់ទំនងទៅកាន់អ្នកទទួលប្រាក់ឲ្យបានច្បាស់លាស់មុននឹងធ្វើការផ្ញើប្រាក់។

**ការផ្ទេរប្រាក់ដើម្បីសម្អាតប្រាក់ ឬហិរញ្ញប្បទានភេរវកម្ម**[24] **៖** ការសម្អាតប្រាក់មានន័យថា ការបំប្លែង ឬការផ្ទេរទ្រព្យសម្បត្តិដែលជាផលនៃបទល្មើស ក្នុងគោលបំណងបិទបាំង ឬក្លែងប្រភពដើមមិនស្របច្បាប់នៃទ្រព្យសម្បត្តិទាំងនោះ ឬជួយបុគ្គលពាក់ព័ន្ធបទល្មើសនោះឲ្យគេចផុតពីផលវិបាកតាមផ្លូវច្បាប់នូវសកម្មភាពរបស់គេ។ រីឯ ហិរញ្ញប្បទានភេរវកម្ម គឺជាការផ្តល់ដោយចេតនានូវសេវាកម្មហិរញ្ញវត្ថុ ឬមូលនិធិក្នុងគោលបំណងប្រើប្រាស់មូលនិធិនោះសម្រាប់គាំទ្រភេរវកម្ម សកម្មភាពរបស់ភេរវករ ឬអង្គការចាត់តាំងរបស់ភេរវកម្ម។ ហានិភ័យបែបនេះ គឺជាហានិភ័យមួយដែលកើតមានសម្រាប់សេវាកម្មផ្ទេរប្រាក់អន្តរជាតិ ហើយធនាគារ ក៏ដូចជាគ្រឹះស្ថានហិរញ្ញវត្ថុទាំងឡាយមានការព្រួយបារម្ភខ្លាំងជាងគេ។ ប្រសិនបើ ធនាគារត្រូវបានគេរកឃើញថាបានធ្វេសប្រហែសធ្វើឲ្យមានការផ្ទេរប្រាក់ដើម្បីលាងលុយកខ្វក់ ឬការផ្ទេរប្រាក់ដើម្បីធ្វើភេរវកម្មបានសម្រេចនោះ ធនាគារនឹងត្រូវទទួលពិន័យយ៉ាងធ្ងន់ធ្ងរ ដែលអាចពិន័យជាសាច់ប្រាក់ចំនួនច្រើន ឬ ការផ្តាច់ទំនាក់ទំនងអន្តរជាតិជាមួយធនាគារដទៃជាដើម។ ហេតុដូច្នេះហើយទើប ធនាគារតែងមានការប្រុងប្រយ័ត្នខ្ពស់ និងធ្វើតាមការណែនាំរបស់ធនាគារកណ្តាលស្តីពីការប្រឆាំងនឹងការសម្អាតប្រាក់ ឬ ហិរញ្ញប្បទានភេរវកម្មដើម្បីបង្ការ និងទប់ស្កាត់នូវហានិភ័យមួយនេះ។

[24] ឧបសម្ព័ន្ធទី១ នៃប្រកាសលេខ ធ៧-០៨-០៨៩ ប្រ.ក ស្តីពីការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម

# ជំពូកទី ២

# ស្ថានភាពទូទៅរបស់ធនាគារឯកទេសវីង

## ២.១ ប្រវត្តិនៃធនាគារឯកទេសវីង

ធនាគារឯកទេសវីង (ខេមបូឌា) លីមីតធីត បានបង្កើតឡើង នៅក្នុងព្រះរាជាណាចក្រកម្ពុជានៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៨ ក្រោមការចុះបញ្ជីពាណិជ្ជកម្មលេខ 5223E/2008។ ធនាគារ គឺជាបុត្រសម្ព័ន្ធទាំងស្រុងរបស់ WING Holding President Limited ជាក្រុមហ៊ុនដែលបង្កើតឡើងនៅប្រទេសសិង្ហបុរីដែលកាន់កាប់ដោយផ្ទាល់ពីសំណាក់ភាគទុនិកមួយរូបដែលជាសញ្ជាតិខ្មែរ ហើយបច្ចុប្បន្នក៏មានតួនាទីជាអភិបាលនៅក្នុងធនាគារនេះផងដែរ។ សកម្មភាពចម្បងរបស់ធនាគារ រួមមានការធ្វើពាណិជ្ជកម្មតាមរយៈប្រព័ន្ធអេឡិចត្រូនិច ការទូទាត់តាមរយៈទូរស័ព្ទចល័ត និងសេវាកម្មដែលពាក់ព័ន្ធផ្សេងៗទៀតនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ នៅក្នុងកំឡុងឆ្នាំ២០០៩ គឺជាឆ្នាំមួយដែលសេវាផ្ទេរប្រាក់នៅក្នុងស្រុកខ្មែរគឺ នៅមានកម្រិតដែលត្រូវចំណាយរយៈពេលយូរ និងមិនមានសុវត្ថិភាពក្នុងការផ្ញើ (អាចមានការខូះខាត ឬបាត់បង់ទឹកប្រាក់មួយចំនួន) ជាមួយនឹងកម្រៃថ្លៃឈ្នួលក្នុងការផ្ញើដ៏ខ្ពស់។ ដោយសារឃើញភាពខ្វះចន្លោះនេះហើយ វីងក៏បានក្ដោបក្ដាប់ចាប់យកទីផ្សារផ្ទេរប្រាក់លឿនរហ័សទៅកាន់គ្រប់ខេត្តក្រុងជាមួយតម្លៃសេវាសមរម្យដែលជាទីពេញនិយមដល់អ្នកដែលធ្វើការឆ្ងាយពីស្រុកកំណើត ជាពិសេសកម្មករ កម្មការនី។ មិនត្រឹមតែមានសេវាផ្ទេរប្រាក់លឿនរហ័ស ធនាគារឯកទេសវីង ក៏ជាអ្នកផ្ដួចផ្ដើមនូវ ការប្រើធនាគារតាមទូរស័ព្ទដៃដំបូងបង្អស់ នៅប្រទេសកម្ពុជាផងដែរ ដែលគំនិតផ្ដួចផ្ដើមនេះ ជួយជំរុញឲ្យធនាគារដទៃផ្សេងទៀតឈានជើងចូលទៅក្នុងទីផ្សារបច្ចេកវិទ្យាធនាគារ ដោយបង្កើតឲ្យមានធនាគារតាមទូរស័ព្ទដៃ នៅតាមធនាគាររៀងៗខ្លួន។ ដោយសារសន្ទុះនៃគំនិតច្នៃប្រឌិតថ្មីរបស់ធនាគារវីង នៅក្នុងឆ្នាំ២០១៥ ធនាគារមានភ្នាក់ងារសរុបចំនួន ៣,៦០០ ទីតាំងខុសៗគ្នាដែលជួយបន្ថយនូវអត្រាអត់ការងារធ្វើ បង្កើតនូវការងារថ្មីៗបន្ថែមប្រាក់ចំណូលជូនប្រជាពលរដ្ឋដែលចូលរួមជាដៃគូសហការក្នុងនាមជាភ្នាក់ងារទទួល និងផ្ទេរប្រាក់នៅតាមទីតាំងដែលខ្លួនរស់នៅរៀងៗខ្លួន។ លើសពីនោះនៅក្នុងឆ្នាំ ២០១៦ ភ្នាក់ងារវីងក៏មានការកើនឡើងដល់ទៅ ៥,០០០ភ្នាក់ងារ ដែលបង្ហាញពីសក្ដានុពលក៏ដូចជាការគាំទ្រពីប្រជាជនទូទៅទូទាំងផ្ទៃប្រទេស ដោយមានដៃគូសហការរបស់ខ្លួនជាមួយក្រុមហ៊ុនជាង ២០០ មានទាំង

វិស័យឯកជន និងសាធារណៈ។ ចំពោះវិស័យឯកជន បច្ចុប្បន្ននេះធនាគារវីង បានធ្វើជាដៃគូសហការជាមួយនឹងធនាគារ FTB ក្រុមហ៊ុនសេវាដឹកជញ្ជូន Passapp ជាដើម។ វីង វិស័យសាធារណៈ:

វិញ ធនាគារមានជាការសហការជាមួយនឹងក្រសួងសាធារណការ និងដឹកជញ្ជូន ជាឧទាហរណ៍ ដូចជាការបង្កើតឲ្យមានការទូទាត់ថ្លៃរថយន្តក្រុងជាមួយនឹងកាតស្កេន ដែលជាការជួយដល់ការគ្រប់គ្រងសាច់ប្រាក់មិនឲ្យមានការបាត់បង់ (ចំណូលចូលខ្វង់ថវិការដ្ឋច្បាស់លាស់) ក៏ដូចជាផ្តល់ភាពងាយស្រួលដល់អ្នកដំណើរ នៅក្នុងការជិះរថយន្តក្នុងជាមួយនឹងការដេញតាមភាពជឿនលឿននៃការប្រើប្រាស់បច្ចេកវិទ្យា ដូចប្រទេសអភិវឌ្ឍន៍នានាដទៃផងដែរ។

## ២.២ គោលបំណងនៃធនាគារឯកទេសវីង

វីងបានធ្វើការផ្សារភ្ជាប់គម្លាតរវាងអ្នកជនបទ និងអ្នកទីក្រុងដោយផ្តល់ជូន នូវសេវាកម្មហិរញ្ញវត្ថុដូចគ្នាដែលប្រកបដោយសុវត្ថិភាព ងាយស្រួល និងរហ័សដល់ប្រជាជនទាំងអ្នកនៅទីក្រុង និងជនបទ។ ចំណែកឯការលើកឡើងបានបញ្ជាក់ថា វីង បានទទួលជោគជ័យក្នុងការឈានដល់ការចាប់យកអតិថិជនដែលមានចំណូលទាប ហើយមិនធ្លាប់ប្រើប្រាស់សេវាហិរញ្ញវត្ថុរបស់ធនាគារពីមុនមកឲ្យងាកមកប្រើប្រាស់សេវាហិរញ្ញវត្ថុដូចអ្នកមានចំណូលខ្ពស់ និងមធ្យមដែរ។ ជាងនេះទៅទៀត សេវាហិរញ្ញវត្ថុដែលធនាគារផ្តល់ជូនអ្នកប្រើប្រាស់ គឺមានលក្ខណៈសាមញ្ញងាយស្រួលប្រើប្រាស់ និងសមស្របទៅនឹងកម្រិតជីវភាពប្រជាជនដែលជាអតិថិជនគោលដៅ។

គោលបំណងរបស់វីង គឺដើម្បីជួយប្រជាជនកម្ពុជាដែលចង់ប្រើប្រាស់សេវាហិរញ្ញវត្ថុឲ្យមានជីវភាពប្រសើរឡើង និងកាត់បន្ថយភាពក្រីក្ររបស់ពួកគេ តាមរយៈការបង្កើនដំណើរការប្រតិបត្តិការសេវាហិរញ្ញវត្ថុក្នុងទម្រង់មិនមែនធនាគារ។ វីងបានជួយសម្រួលជីវភាពប្រចាំថ្ងៃដល់អ្នកប្រើប្រាស់ គឺតាមរយៈការផ្តល់នូវសេវាផ្ទេរប្រាក់ដោយមានភាពងាយស្រួល រហ័ស និងមានសុវត្ថិភាពខ្ពស់ ចំណាយតិច ព្រមទាំងមិនចាំបាច់មានគណនីធនាគារផ្ទាល់។

ឆន្ទៈរបស់វីង គឺធ្វើឲ្យមានភាពប្រសើរជាងសេវាធនាគារ មានន័យថា សេវាហិរញ្ញវត្ថុមួយចំនួនរបស់ធនាគារឯកទេសវីង គឺពុំមានគិតកម្រៃសេវាកម្មប្រចាំខែឡើយ គណនីអតិថិជនមិនទាមទារឲ្យមានការដាក់ប្រាក់តម្កល់ទាបបំផុត នៅពេលបើកគណនីប្រើប្រាស់នោះទេ។ ម្យ៉ាងវិញទៀត វីងមានបណ្តាញភ្នាក់ងារច្រើនគ្របដណ្តប់ទូទាំងប្រទេសកម្ពុជាដែលរង់ចាំបម្រើសេវាកម្មដាក់ប្រាក់ ដកប្រាក់ និងផ្ទេរប្រាក់ជាមួយនឹង តម្លៃសេវាកម្មទាបជាង តម្លៃសេវាកម្មរបស់ធនាគារធម្មតា និងមធ្យោបាយដទៃទៀត។

## ២.៣. ទីតាំង និងសាខាធនាគារឯកទេសវីង

បច្ចុប្បន្ននេះ ទីស្នាក់ការកណ្តាលរបស់ធនាគារឯកទេសវីង (ខេមបូឌា) លីមីតធីតស្ថិតនៅអគារលេខ ៧២១ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងកេងកងទី៣ ខណ្ឌចំការមន រាជធានីភ្នំពេញ។

ដោយសារសកម្មភាពអាជីវកម្មរបស់ ធនាគារវីងមានសន្ទុះរីកចម្រើន ស្របពេលដែលកេរ្តិ៍ឈ្មោះកំពុងល្បីសុះសាយទាំងក្នុង និងក្រៅប្រទេស និងមានការជឿទុកចិត្តពីសំណាក់អតិថិជនរបស់ខ្លួននោះ ធនាគារវីងបានពង្រីកសាខានៅទូទាំង ២៥ ខេត្តក្រុងនៃព្រះរាជាណាចក្រកម្ពុជា។ យោងតាមរបាយការណ៍របស់ធនាគារវីង ចុះថ្ងៃទី ៣១ ធ្នូ ២០១៨ ធនាគារនេះមានភ្នាក់ងារវីងខាសអ៊ិចប្រេស (Wing Cash Express) សរុបចំនួន ៦០០២ ភ្នាក់ងារ។

តារាងទី១ ៖ ចំនួនភ្នាក់ងារតាមបណ្ដាខេត្តក្រុងនានានៃព្រះរាជាណាចក្រកម្ពុជា

| ល.រ | សាខា | ចំនួនភ្នាក់ងារ |
|---|---|---|
| ១ | កណ្ដាល | ៩៤០ |
| ២ | កែប | ១៧ |
| ៣ | កោះកុង | ៦០ |
| ៤ | ក្រចេះ | ១២២ |
| ៥ | កំពង់ចាម | ៣៩១ |
| ៦ | កំពង់ឆ្នាំង | ១៥៣ |
| ៧ | កំពង់ធំ | ២២៣ |
| ៨ | កំពង់ស្ពឺ | ២៤៣ |
| ៩ | កំពត | ១៨៧ |
| ១០ | តាកែវ | ២៨៧ |
| ១១ | ត្បូងឃ្មុំ | ២៥២ |
| ១២ | បន្ទាយមានជ័យ | ២៥៨ |
| ១៣ | ប៉ៃលិន | ២៩ |
| ១៤ | បាត់ដំបង | ៣៦៩ |
| ១៥ | ពោធិ៍សាត់ | ១៤៣ |
| ១៦ | ព្រៃវែង | ២៥៤ |
| ១៧ | ព្រះវិហារ | ៨៤ |
| ១៨ | ព្រះសីហនុ | ១២៨ |
| ១៩ | ភ្នំពេញ | ១៦០៩ |
| ២០ | មណ្ឌលគិរី | ៥០ |
| ២១ | រតនគិរី | ៨៥ |

| | | |
|---|---|---|
| ២២ | សៀមរាប | ៣៥៩ |
| ២៣ | ស្ទឹងត្រែង | ៥៥ |
| ២៤ | ស្វាយរៀង | ១៧៤ |
| ២៥ | ឧត្តរមានជ័យ | ៨០ |
| សរុប Total | | ៦០០២ |

ប្រភព ៖ របាយការណ៍ប្រតិបត្តិការអ្នកដំណើរការតតិយភាគីរបស់ធនាគារឯកទេសវីង ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៨

## ២.៤. ចក្ខុវិស័យ បេសកកម្ម និងគុណតម្លៃ

### ២.៤.១ ចក្ខុវិស័យ

ធនាគារឯកទេសវីងមានចក្ខុវិស័យផ្តល់នូវភាពងាយស្រួល និងសុវត្ថិភាពក្នុងការប្រើប្រាស់សេវាកម្មហិរញ្ញវត្ថុតាមរយៈទូរស័ព្ទដៃ និងសេវាកម្មដែលពាក់ព័ន្ធផ្សេងៗទៀតដល់ប្រជាជនកម្ពុជា ដើម្បីជួយដល់បង្កើនជីវភាពប្រចាំថ្ងៃរបស់ពួកគេ។

### ២.៤.២ បេសកកម្ម

ធនាគារឯកទេសវីងមានបេសកកម្មដូចតទៅ៖

**អតិថិជនជាអាទិភាព ៖** ស្វែងយល់ពីតំរូវការទីផ្សារដោយការផ្តល់ជូននូវផលិតផល និងសេវាកម្មដែលល្អបំផុតដើម្បីបំពេញតំរូវការអតិថិជនទាន់ពេលវេលា។

**ផ្តោតលើការអភិវឌ្ឍសហគមន៍ ៖** ផ្តល់ជូននូវសេវាហិរញ្ញវត្ថុចល័តដែលងាយស្រួល និងអាចទទួលយកបានសំរាប់ជួយសហគមន៍អោយមានជីវភាពប្រសើរឡើង និងកាត់បន្ថយវិសមភាពសង្គម។

**បុគ្គលិកជាសសរស្តម្ភ ៖** បង្កើតអោយមានបរិយាកាសការងារល្អដែលមានការទទួលស្គាល់នូវស្នាដៃនិងសមិទ្ធផលការងារល្អជាមួយនិងការអនុវត្តគុណតំលៃរបស់ធនាគារ។

**សមិទ្ធផលខ្ពស់សំរាប់ភាគទុនិក ៖** បង្កើតនូវស្តង់ដាអភិបាលកិច្ចល្អមួយ ដែលរក្សាអោយបាននូវអត្ថប្រយោជន៍ខ្ពស់ សំរាប់ភាគទុនិកក្នុងគោលដៅអាជីវកម្មរយៈពេលខ្លី និងរយៈពេលវែង ជាមួយ និងការឈានមុខគេជាធនាគារដែលផ្តល់នូវសេវាកម្មហិរញ្ញវត្ថុចល័ត ដែលងាយស្រួលបំផុតសំរាប់អតិថិជនគ្រប់រូប។

### ២.៤.៣ គុណតម្លៃ

គុណតម្លៃរបស់ធនាគារឯកទេសវីងរួមមាន៖

**ការគោរព ៖** យើងគោរព និងផ្តល់តម្លៃដល់អ្នកដែលយើងធ្វើការជាមួយ និងការរួមចំណែករបស់

ពួកគេ។

**សុចរិតភាព** ៖ យើងធ្វើការប្រកដដោយភាពយុត្តិធម៌ ក្រមសីលធម៌ និង ការបើកទូលាយ។

**សេវាកម្ម** ៖ យើងចាត់ទុកអតិថិជនគឺជាចំនុចសំខាន់នៃការបម្រើសេវាកម្ម។

**ភាពឥតខ្ចោះ** ៖ យើងប្រើប្រាស់នូវថាមពល ជំនាញ និងធនធានរបស់យើងដើម្បីបង្កើតនូវលទ្ធផលល្អបំផុតនិងមាននិរន្តរភាព។

## ២.៥ ស្លាកសញ្ញា និងអត្ថន័យ

**អត្ថន័យពាក្យវីង (Wing)**

- W - Winning : ការឈ្នះ
- I - Innovation : ការច្នៃប្រឌិតថ្មីៗ
- N - Nurturing : ការអប់រំ
- G - Growth : ការរីកចម្រើនទៅមុខ

**អត្ថន័យរូបសត្វត្រចៀកកាំ**

រូបសត្វត្រចៀកកាំដែលស្ថិតនៅចំពីលើអក្សរ "I" និងមានពណ៌ខៀវ គឺជាតំណាងឲ្យការហោះហើរបានលឿន ខ្ពស់ និងឆ្ងាយទៅដល់គ្រប់ទីកន្លែងឆ្លងប្រទេស ដែលប្រៀបបាននឹងសេវាកម្មផ្ទេរប្រាក់របស់ធនាគារឯកទេសវីងដែលអាចផ្ទេរប្រាក់បានលឿន រហ័ស និងគ្រប់ទីកន្លែង មិនថាក្នុង និងក្រៅប្រទេស។

## ២.៦. រចនាសម្ព័ន្ធធនាគារឯកទេស

យោងតាមរបាយការណ៍ប្រចាំ ២០១៦ ធនាគារឯកទេសវីង មានរចនាសម្ព័ន្ធក្រុមហ៊ុនដូចតទៅនេះ៖

### ២.៦.១ ក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល គឺជាគណៈកម្មាធិការដែលធ្វើការសម្រេចចិត្តខ្ពស់បំផុតរបស់ធនាគារដែលមានតួនាទីអនុម័តយុទ្ធសាស្ត្រ គោលនយោបាយ និងនីតិវិធីផ្សេងៗរបស់ធនាគារ។

សមាសភាពនៃក្រុមប្រឹក្សាភិបាលរួមមានសមាជិក ៣ រូបដូចខាងក្រោម៖

១. អ្នកឧញ៉ា គិត មេង ជាប្រធានក្រុមប្រឹក្សាភិបាល

២. លោក MARK HANNA ជាអភិបាល

៣. លោក IAN GORDON WATSON ជាអភិបាល

គណៈកម្មាធិការក្រុមប្រឹក្សាភិបាល គឺជាគណៈកម្មាធិការផ្នែកបន្ថែមក្នុងក្រុមប្រឹក្សាភិបាលរបស់រីងដែលបានបង្កើតឡើងដើម្បីពិភាក្សាពីបញ្ហានៅក្នុងសេចក្តីលម្អិត និងមានការបើកអង្គប្រជុំនានា។ សមាសភាពនៃគណៈកម្មាធិការក្រុមប្រឹក្សាភិបាលមាន ២ គឺ៖

១. គណៈកម្មាធិការក្រុមប្រឹក្សាភិបាលគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម

២. គណៈកម្មាធិការសវនកម្ម

## ២.៦.២ គណៈគ្រប់គ្រង

ធនាគារឯកទេសរីង (ខេមបូឌា) លីមីតធីត មានគណៈគ្រប់គ្រងដូចតទៅនេះ៖

១. លោក Elmer "JOJO" Manzanero Malolos ជាអគ្គនាយកនៃធនាគារឯកទេសរីង

២. លោកជំទាវ ម៉ៅ ចំណាន ជាអគ្គនាយកប្រតិបត្តិការ

ក្រៅពីនេះធនាគារនេះមាននាយកផ្នែកនានាចំនួន ១១ រូបដែលទទួលបន្ទុកដឹកនាំ និងមើលការខុសត្រូវតាមផ្នែកនីមួយៗ រួមមាន៖

១. លោក ឌឿក តាភរុធ ជានាយកផ្នែកគ្រប់គ្រងហានិភ័យនិងប្រតិបត្តិតាម

២. លោក ហោ ប៊ុនថៃ ជានាយកផ្នែកហិរញ្ញវត្ថុ

៣. លោក ឡៅ សៀងហៃ ជានាយកផ្នែកធនធានមនុស្ស

៤. លោក ឈុន វឌ្ឍនភក្តី ជានាយកផ្នែកអាជីវកម្មសហគ្រាស

៥. លោក ហាម ភារុណ ជានាយកផ្នែកប្រតិបត្តិការ

៦. លោក FRANCHETTE CARDONA ជានាយកផ្នែកផលិតផល និងទីផ្សារ

៧. លោក CHRISTOPHE EYQUEM ជានាយកផ្នែកព័ត៌មានវិទ្យា

៨. លោក សុធី សុវិត្យា ជានាយកផ្នែក អាជីវកម្មខ្នាតតូច និងមធ្យម

៩. លោក កែវ សាម៉ុន ជានាយកផ្នែកលក់ និងចែកចាយ

១០. លោក វ៉ាន សុធារី ជានាយកផ្នែក Merchant

១១. លោក KHIZAR ILYAS ជានាយកផ្នែកគ្រប់គ្រងគម្រោង

ខាងក្រោមជាគំនូសតាងរចនាសម្ព័ន្ធរបស់ធនាគារឯកទេសរីង ៖




# ២.៧ ផលិតផល និងសេវាកម្មនានារបស់ធនាគារ

## ២.៧.១ ផលិតផល

### ២.៧.១.១ គណនីរីង

គណនីរីង គឺជាផលិតផលរបស់ធនាគារមួយដែលផ្តល់ភាពងាយស្រួលដល់អតិថិជននៅក្នុងការប្រើប្រាស់គណនីផ្ទាល់ខ្លួនសម្រាប់ការដក-ដាក់ប្រាក់ ធ្វើការទូទាត់សេវាកម្មនានា និងសេវាផ្ទេរប្រាក់ចេញចូលផងដែរ។ ចំពោះការបើកគណនីរីងថ្មី អតិថិជនអាចទៅកាន់ភ្នាក់ងាររីងណាមួយក៏បាន ដែលមានច្រើនជាង៦០០០កន្លែងទូទាំងប្រទេសហើយប្រាប់ពីប្រភេទគណនីដែលចង់បានជារៀលឬជាដុល្លារ។ ចំពោះតម្លៃសេវាកម្មក្នុងការប្រើប្រាស់គណនីរីងមានការកំណត់ខុសៗគ្នាតាមការប្រភេទនៃសេវាកម្មនីមួយៗ។

ដើម្បីបើកគណនី អតិថិជនតម្រូវអោយមានឯកសារដែលមានសុពលភាពមួយចំនួនដូចជា៖

- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬ

- លិខិតឆ្លងដែន (ទិដ្ឋាការដែលមានសុពលភាពសម្រាប់ជនបរទេស) ឬ
- ប័ណ្ណបើកបរ ឬ
- អត្តសញ្ញាណប័ណ្ណមន្ត្រីរាជការ ឬ កាតបុគ្គលិករាជការស៊ីវិល ឬ
- ព្រះឆ័យាល័ក្ខព្រះសង្ឃ ភ្ជាប់ជាមួយនិងសំបុត្រកំណើត ឬ
- ប័ណ្ណសម្គាល់របស់បុគ្គលិកភ្ជាប់ជាមួយនឹងសំបុត្រកំណើត ឬសៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ) ឬ សំបុត្របញ្ជាក់អត្តសញ្ញាណពីអាជ្ញាធរស្រុកដែលមានព័ត៌មានដូចជា នាមត្រកូល ភេទ ថ្ងៃខែឆ្នាំកំណើត ទីកន្លែងកំណើត និងអាសយដ្ឋានដោយមានរូបថតបញ្ជាក់។ រូបថតត្រូវបិទភ្ជាប់ និងមានបោះត្រាបញ្ជាក់។

### ២.៧.១.២ ភាគទីខ

### វីងអនឡាញម៉ាស្ទ័រកាត

វីងអនឡាញម៉ាស្ទ័រកាត គឺជាប្រភេទកាតដែលអាចទិញទំនិញអនឡាញដោយមិនពិបាក មិនចាំបាច់សាច់ប្រាក់សុទ្ធឬកាតវីងនោះទេ។ អតិថិជនអាចប្រើវីងគ្រប់ទីកន្លែងលើពិភពលោក ដើម្បីទិញទំនិញ និងបង់ប្រាក់អនឡាញតាមរយៈម៉ាស្ទ័រកាត។

ដើម្បីទទួលយកវីងអនឡាញម៉ាស្ទ័រកាត អតិថិជនតម្រូវអោយធ្វើតាមជំហានងាយៗខាងក្រោម ៖

ជំហានទី១៖ បើកគណនីវីង ពីភ្នាក់ងារវីងដែលមានច្រើនជាង ៥,០០០ កន្លែងទូទាំងប្រទេស ឬចុះឈ្មោះអនឡាញដោយប្រើកម្មវិធីស្មាតហ្វូនវីង ប្រសិនបើអតិថិជនមានគណនីវីងរួចហើយ គឺអាចទាញយកកម្មវិធីស្មាតហ្វូនវីងលើទូរស័ព្ទបន្តបាន។

ជំហានទី២៖ ក្នុងកម្មវិធីស្មាតហ្វូនវីង ចុចលើ Online Card (កាតអនឡាញ) និងធ្វើការចុះឈ្មោះ ហើយកាតនឹងចេញនៅលើអេក្រង់ទូរស័ព្ទដោយមានលេខកាតចំនួន ១៦ខ្ទង់។

ជំហានទី៣៖ អតិថិជនអាចដាក់ប្រាក់ និងចាប់ផ្តើមទិញអីវ៉ាន់បាន។

- តម្លៃ និងសេវាកម្ម

- ទទួលយកវីងអនឡាញម៉ាស្ទ័រកាតដោយឥតគិតថ្លៃ។
- មិនចាំបាច់ក្រដាសស្នាមនិងគ្មានសេវាប្រចាំខែក្នុងរយៈពេល ៦ ខែដំបូងនៃការចុះឈ្មោះ។
- បង្កើតកាត មិនគិតតម្លៃសេវា
- រូបិយប័ណ្ណ ដុល្លារ
- ការកំណត់ការបញ្ជាទិញប្រចាំថ្ងៃ ១០០ដុល្លារ ១,០០០ដុល្លារ

- សុពលភាពកាត ២៤ ខែ

- តម្លៃសេវាលើប្រតិបត្តិការ

- ហាងក្នុងស្រុក ៖ មិនគិតតម្លៃសេវាសម្រាប់ប្រតិបត្តិការច្រើនជាង ឬស្មើ ៥០ដុល្លារ (០.១៥ដុល្លារ សម្រាប់ប្រតិបត្តិការតិចជាង ៥០ដុល្លារ)
- ហាងក្រៅស្រុក ៖ ២% នៃទំហំការបញ្ជាទិញ (តម្លៃសេវាអតិបរិមា ០.១៥ដុល្លារ)

**វីងម៉ាស្ទ័រកាត**

វីងម៉ាស្ទ័រកាត គឺជាប្រភេទកាតវីងដែលខុសគ្នាទៅនឹងវីងអនឡាញម៉ាស្ទ័រកាត ដែលជាប្រភេទកាតសិប្បនិម្មិត។ វីងម៉ាស្ទ័រកាតអាចប្រើប្រាស់ដើម្បីឆូតលើម៉ាស៊ីន POS នៅតាមហាងនានាបាន ដើម្បីញ៉ាំអាហារ ភេសជ្ជៈ និងទិញទំនិញគ្រប់ទីកន្លែងដែលទទួលម៉ាស្ទ័រកាត ។

របៀបបើកវីងម៉ាស្ទ័រកាតមានដូចខាងក្រោម៖

- បើកគណនីវីង និងស្នើសុំម៉ាស្ទ័រកាតពីភ្នាក់ងារវីងខាសអ៊ិចប្រេស និងហាងដែលបានកំណត់។
- ទាញយកកម្មវិធីស្មាតហ្វូនវីង។
- ដាក់ប្រាក់ចូលយ៉ាងតិចចំនួន $១០
- ស្កេននិងវាយបញ្ចូលលេខសម្គាល់ដែលមាននៅក្នុងកញ្ចប់វីងម៉ាស្ទ័រកាត។
- ជ្រើសរើសគណនីវីងដែលភ្ជាប់ទៅកាន់កាត បន្ទាប់មកជ្រើសយក យល់ព្រម។
- កំណត់លេខកូដសម្ងាត់ PIN ម៉ាស្ទ័រកាត បន្ទាប់មកបញ្ចូលលលេខកូដសម្ងាត់ PIN របស់វីង។
- ឆូតកាត និងទូទាត់ដោយងាយស្រួល

- តម្លៃសេវាកម្ម

- សេវាប្រចាំឆ្នាំ $៦ ជាមួយរយៈពេលផុតកំណត់ ៥ ឆ្នាំ
- ការដកប្រាក់តាម ATM ធនាគារផ្សេងក្នុងមួយប្រតិបត្តិការ ២%នៃចំនួនដែលបានដកតិចបំផុត$៥
- ទិញតាមអនឡាញ-ក្នុងមួយប្រតិបត្តិការ ឥតគិតថ្លៃ
- ការទិញ ឬដកប្រាក់ មិនមែនជាប្រាក់ដុល្លារ ក្នុងមួយប្រតិបត្តិការ ២.៥% សម្រាប់ការបំប្លែងរូបិយប័ណ្ណ
- ធ្វើប្រតិបត្តិការបរាជ័យតាម ATM ធនាគារឯកទេសវីង-ក្នុងមួយប្រតិបត្តិការ ឥតគិតថ្លៃសេវា
- ធ្វើប្រតិបត្តិការបរាជ័យតាម ATM/POS ធនាគារផ្សេង $០.៤០
- ពិនិត្យទឹកប្រាក់នៅតាម ATM/POS ធនាគារផ្សេង $០.៥០
- ប្តូរលេខកូដសម្ងាត់ PIN វីងម៉ាស្ទ័រកាត / លេខកូដសុវត្ថិភាព 3D $០.១០

- ការដកប្រាក់/ការទិញច្រើនបំផុត-ក្នុងមួយថ្ងៃ/ក្នុងមួយប្រតិបត្តិការ $១,០០០
- ប្រតិបត្តិការដកប្រាក់ច្រើនបំផុត-ក្នុងមួយថ្ងៃ ៥ ដង
- ប្រតិបត្តិការទិញច្រើនបំផុត-ក្នុងមួយថ្ងៃ ៥ ដង

### ២.៧.១.៣. ផលិតផលផ្សេងៗទៀត

**កាតរថយន្តក្រុង**

ការទូទាត់សេវារថយន្តក្រុងតាមរីង គឺជាការទូទាត់ ដោយពុំចាំបាច់ប្រើប្រាស់សាច់ប្រាក់។ អតិថិជនគ្រាន់តែប្រើប្រាស់កាតក្នុងការទូទាត់ប្រាក់ជាមួយរថយន្តក្រុងប៉ុណ្ណោះ។ វាបានផ្លាស់ប្តូរពីការទូទាត់តាមសាច់ប្រាក់សុទ្ធទៅជាការទូទាត់ជាមួយម៉ាស៊ីនអេឡិចត្រូនិចទំនើបទាន់សម័យ រហ័ស ងាយស្រួល និង សុវត្ថិភាព។ កាតរថយន្តក្រុងសាធារណៈ សេវាកម្មនេះត្រូវបានគេបង្កើតឡើងនៅថ្ងៃទី៩ ខែកក្កដា ២០១៨។ កាតរថយន្តក្រុងសាធារណៈមាន ២ ជម្រើសគឺ ៖

កាតពណ៌ខៀវ ៖ ជាកាតពិសេសមួយសម្រាប់ អតិថិជនជាព្រះសង្ឃ សិស្ស និស្សិត កុមារដែលមានកម្ពស់ទាបជាង១ម៉ែត្រ ជនពិការ និងចាស់ជរាដែលមានអាយុច្រើនជាង ៧០ឆ្នាំ។តម្លៃកាតគឺ ៤,០០០ រៀលដែលអតិថិជនអាចជិះបាន ១៨០ដង ។ រាល់ការស្នើសុំកញ្ចប់ថ្មី គឺមិនមានការគិតថ្លៃនោះទេ ដែលមានចំនួន ១៨០ដង និងសុពលភាព ៦ខែ។ អតិថិជនអាចបើកកាត និងស្នើសុំកញ្ចប់រថយន្តក្រុងថ្មីនៅតាមបញ្ជរភ្នាក់ងាររថយន្តក្រុងតែប៉ុណ្ណោះ រីឯ ការចុះឈ្មោះបើកកាត អតិថិជនត្រូវមានឯកសារសម្គាល់ខ្លួន (ដើម្បីសម្គាល់ថាជា ព្រះសង្ឃ សិស្ស និស្សិត ឬ ចាស់ជរា) និងលេខទូរស័ព្ទដើម្បីចុះឈ្មោះ។

កាតរថយន្តក្រុង ពណ៌បៃតង ៖ ជាប្រភេទកាតសម្រាប់អតិថិជនទូទៅ ដែលមិនរាប់បញ្ចូលប្រភេទអតិថិជនពិសេស (កាតរថយន្តក្រុង ពណ៌ខៀវ)។ តម្លៃកាត គឺ ១០,០០០រៀល ដោយត្រូវមានសមតុល្យ ៦,០០០រៀល ក្នុងគណនីរួចជាស្រេច។ ការបញ្ចូលទឹកប្រាក់ គឺមិនមានការគិតថ្លៃសេវានោះទេ។ រីឯ ការបញ្ចូលប្រាក់ គឺមាននៅតាមភ្នាក់ងាររីង ឬការិយាល័យកណ្តាល របស់ធនាគារឯកទេសរីង។ តម្លៃជិះមួយដង គឺ ១,៥០០រៀល (ត្រូវមានសមតុល្យក្នុងកាតដើម្បីជិះរថយន្តក្រុង)។ តម្រូវការសម្រាប់ការចុះឈ្មោះគឺ អតិថិជនត្រូវមានលេខទូរស័ព្ទ និងត្រូវបើកកាត នៅតាមបញ្ជរភ្នាក់ងាររថយន្តក្រុង។

ចំពោះលក្ខណៈពិសេសផ្សេងទៀតនៃកាតរថយន្តក្រុងសាធារណៈរីង វាមិនត្រឹមតែជាកាតរថយន្តក្រុងសាធារណៈនោះទេ។ កាតរថយន្តក្រុងសាធារណៈសហការ ដោយរីងក៏មានលក្ខណៈពិសេសផ្សេងទៀតដែលផ្តល់ភាពងាយស្រួល និងប្រសើរជាងមុន ដូចជាការបញ្ចូលទឹកប្រាក់ទូរស័ព្ទ ការទូទាត់វិក្កយបត្រ ការទូទាត់តាមអ៊ីនធឺណេត និងរីងគិតលុយ។

**កិច្ចសហការរវាងក្រសួងសាធារណការនិងដឹកជញ្ជូន និងធនាគារឯកទេសរីង**

វីង បានចាប់ដៃគូសហការជាមួយក្រសួងសាធារណការ និងដឹកជញ្ជូនក្នុងការផ្តល់ជូននូវមធ្យោបាយថ្មីក្នុងការទូទាត់តាមប្រព័ន្ធឌីជីថល ដែលអាចឲ្យប្រជាពលរដ្ឋកម្ពុជាធ្វើការទូទាត់លើសេវាកម្មផ្សេងៗ ដូចជា សេវាកម្មចុះបញ្ជីរថយន្ត និងទិញផ្លាកលេខរថយន្ត សេវាកម្មត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានជំនិះ សេវាកម្មផ្តល់បណ្ណបើកបរយានយន្ត និងសេវាកម្មស្នើសុំលិខិតអនុញ្ញាតធ្វើអាជីវកម្មដឹកជញ្ជូន តាមរយៈប្រព័ន្ធកុំព្យូទ័រ ឬទូរស័ព្ទស្មាតហ្វូន និងធ្វើការទូទាត់វិក្កយបត្រសេវាកម្មទាំងនោះតាមរយៈគណនីវីង ឬភ្នាក់ងារវីងដែលនៅជិត អតិថិជនអាចធ្វើការត្រួតពិនិត្យតម្លៃផ្លាកលេខរថយន្ត និងធ្វើការកក់ទុកភ្លាមៗដោយងាយស្រួល។

របៀបប្រើប្រាស់

ជំហានទី១៖ ចូលទៅកាន់តំណភ្ជាប់របស់ក្រសួងសាធារណការ និងដឹកជញ្ជូន រួចជ្រើសរើសប្រភេទសេវាកម្មដែលត្រូវការ៖

- https://vehicle.mpwt.gov.kh/ សម្រាប់សេវាកម្មចុះបញ្ជីរថយន្ត និងទិញផ្លាកលេខរថយន្ត
- https://technispection.mpwt.gov.kh/ សម្រាប់សេវាកម្មត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានជំនិះ
- http://driverlicense.mpwt.gov.kh/ សម្រាប់សេវាកម្មផ្តល់ប័ណ្ណបើកបររថយន្ត
- http://transportlicense.mpwt.gov.kh/ សម្រាប់សេវាកម្មស្នើសុំលិខិតអនុញ្ញាត ធ្វើអាជីវកម្មដឹកជញ្ជូន

ជំហានទី២៖ សូមធ្វើការបំពេញនូវព័ត៌មាន និងឯកសារដែលចាំបាច់ផ្សេងៗ

ជំហានទី៣៖ បន្ទាប់ពីបំពេញរួចរាល់ហើយ សូមធ្វើការបង់ប្រាក់

- សម្រាប់អ្នកមានគណនីវីង៖ សូមជ្រើសរើសយក Wing បន្ទាប់មកធ្វើការបំពេញនូវលេខគណនី និងលេខកូដសម្ងាត់ដែលបានស្នើសុំ
- សម្រាប់អ្នកគ្មានគណនីវីង៖ អតិថិជន ក៏អាចធ្វើប្រតិបត្តិការបាន ដោយគ្រាន់តែជ្រើសរើសយក No Wing Account បន្ទាប់មកធ្វើការព្រីននូវវិក្កយបត្រ ហើយយកទៅទូទាត់នៅភ្នាក់ងារវីងណាមួយដែលនៅជិត។

### ២.៧.២ សេវាកម្មរបស់ធនាគារឯកទេសវីង

#### ២.៧.២.១ សេវាផ្ទេរប្រាក់ (Money Transfer)

សេវាផ្ទេរប្រាក់របស់វីង អាចឲ្យអតិថិជនធ្វើការផ្ទេរប្រាក់បានយ៉ាងងាយស្រួល រហ័សទាន់ចិត្ត ចំណាយតិច និងមានសុវត្ថិភាពបំផុត។ ដើម្បីបំពេញតម្រូវការរបស់អតិថិជន ធនាគារបាន

ពង្រីកសេវាកម្មផ្ទេរប្រាក់របស់ខ្លួនឲ្យកាន់តែច្រើនសម្បូរបែបថែមទៀត ដែលរួមមានដូចជា វីងទៅវីង (Wing To Wing) វីងវេវលុយ (Wing Wei Luy) វេវលុយអុិចប្រេស (Wei Luy Xpress) និងវីងផ្ទេរប្រាក់អន្តរជាតិ (Wing2World)។

**២.៧.២.២ សេវាទូទាត់បង់វិក្កយបត្រ** ( Bill Payment )

សេវាបង់វិក្កយបត្រ គឺជាសេវាកម្មមួយដែលអាចឲ្យអតិថិជនវីងអាចធ្វើការបង់វិក្កយបត្រទឹកភ្លើង កម្ចីខ្នាតតូច ទូទាត់ទៅកាន់អ្នកផ្គត់ផ្គង់ និងក្រុមហ៊ុនជាច្រើនទៀត ជាមួយនឹងដៃគូបង់វិក្កយបត្រច្រើនជាង ២00 ក្រុមហ៊ុន។ អតិថិជនអាចជ្រើសរើសសេវាទូទាត់វិក្កយបត្រនេះតាមវិធីសាស្ត្រ ២គឺ ការបង់វិក្កយបត្រតាមរយៈភ្នាក់ងារវីង និងការបង់វិក្កយបត្រតាមគណនីវីង (អាចប្រើប្រាស់លើកម្មវិធីស្មាតហ្វូនវីង ឬតាម USSD)។

**២.៧.២.៣ សេវាទូទាត់តាមអ៊ីនធឺណេត** ( Online Payment )

សេវាទូទាត់តាមអ៊ីនធឺណេត គឺជាសេវាកម្មថ្មីមួយរបស់ធនាគារឯកទេសវីងផ្តល់អោយអតិថិជនដែលមានគណនីវីងអាចទូទាត់ប្រាក់សម្រាប់ទំនិញ និងសេវាកម្មផ្សេងៗតាមអនឡាញថែមទាំងអាចទិញសំបុត្រកុន សំបុត្រឡានក្រុង សំលៀកបំពាក់ និងសៀវភៅតាមអនឡាញបានទៀត។

**២.៧.២.៤ សេវាទូទាត់តាមវីងគិតលុយ** ( WingPay )

សេវាទូទាត់តាមវីងគិតលុយ គឺជាសេវាកម្មមួយដែលអ្នកដែលមានទឹកប្រាក់ក្នុងគណនីវីងអាចទូទាត់ថ្លៃចំណាយរបស់ខ្លួន ជាមួយនឹងហាងជាដៃគូជាច្រើនទូទាំងប្រទេសដែលមាន ដូចជាភោជនីយដ្ឋាន រោងភាពយន្ត ហាងលក់សំលៀកបំពាក់ ផ្សារទំនើប -ល- តាមរយៈទូរស័ព្ទដៃ ឬប្រើកាតវីងដើម្បីឆូតលើម៉ាស៊ីនឆូតកាតវីងបានយ៉ាងឆាប់រហ័ស។

**២.៧.២.៥ សេវាបញ្ចូលទឹកប្រាក់ទូរស័ព្ទ** ( Phone Top Up )

សេវាបញ្ចូលទឹកប្រាក់ទូរស័ព្ទ គឺជាសេវាកម្មដែលអាចឲ្យអតិថិជនដែលមានគណនីវីងអាចបញ្ចូលទឹកប្រាក់ទូរស័ព្ទគ្រប់ប្រព័ន្ធ ឬអតិថិជនអាចទិញកាតទូរស័ព្ទពីភ្នាក់ងារវីងបានយ៉ាងងាយស្រួលនៅទូទាំងប្រទេស។ ប្រព័ន្ធទូរស័ព្ទ (ក្រុមហ៊ុនផ្តល់សេវាទូរស័ព្ទក្នុងស្រុក) ដែលអាចបញ្ចូលទឹកប្រាក់តាមវីងបានមានដូចជា ប្រព័ន្ធទូរស័ព្ទ Cellcard ប្រព័ន្ធទូរស័ព្ទ Smart ប្រព័ន្ធទូរស័ព្ទ Metfone ប្រព័ន្ធទូរស័ព្ទ Cootel ប្រព័ន្ធទូរស័ព្ទ QB និងប្រព័ន្ធទូរស័ព្ទ Seatel។

បច្ចុប្បន្ននេះ សេវាបញ្ចូលទឹកប្រាក់ទូរស័ព្ទរបស់ធនាគារឯកទេសវីង បានបង្កើនភាពងាយស្រួលដល់អតិថិជន តាមរយៈការផ្តល់នូវមធ្យោបាយច្រើនបែប សម្រាប់អតិថិជនដែលប្រើប្រាស់

សេវានេះ។ ក្នុងនោះរួមមានដូចជា៖

**ការទិញកាតទូរស័ព្ទជាមួយភ្នាក់ងារវីង**

ការទិញកាតទូរស័ព្ទពីភ្នាក់ងារវីង ជាសេវាកម្មមួយដែលពេញនិយមសម្រាប់អតិថិជនដែលគ្មានគណនីវីងប្រើប្រាស់។ វាផ្តល់ភាពងាយស្រួល ព្រោះអតិថិជនមិនពិបាកស្វែងរកកន្លែងទិញកាតបញ្ចូលទឹកប្រាក់ទូរស័ព្ទពីភ្នាក់ងារវីងខាសអ៊ិចប្រេសដែលមានជាង ៦,០០០ ភ្នាក់ងារ និងភ្នាក់ងារបញ្ចូលលុយទូរស័ព្ទ (Wing Point / Wing Mini) ប្រមាណជាង ២,០០០ភ្នាក់ងារនៅទូទាំងរាជធានីខេត្ត ដែលមានដូចជា ហាងទូរស័ព្ទដៃ ហាងលក់ទំនិញ កន្លែងលក់គ្រឿងទេសទូទៅ (ហាងចាប់ហួយ) និង សណ្ឋាគារ ដែលមានម៉ាស៊ីនវីង។ វីងការទិញនេះ គឺមានភាពរហ័សទាន់ចិត្ត និងអាចទិញបានគ្រប់ប្រព័ន្ធទូរស័ព្ទទាំងអស់ ហើយអាចជ្រើសរើសការបញ្ចូលទឹកប្រាក់ទូរស័ព្ទតាមរយៈក្រដាសបញ្ចូលទឹកប្រាក់ទូរស័ព្ទ ឬ បាញ់ទឹកប្រាក់ទៅកាន់ទូរស័ព្ទអ្នកដោយផ្ទាល់ក៏បាន ដោយគ្រាន់តែអនុវត្តនូវជំហាន ដូចខាងក្រោម៖

ជំហានទី ១ ៖ ប្រាប់ពីប្រព័ន្ធទូរស័ព្ទដែលត្រូវបញ្ចូល (Cellcard, Smart, Metfone, qb, Seatel និង CooTel)

ជំហានទី ២ ៖ ប្រាប់ពីចំនួនទឹកប្រាក់ដែលត្រូវបញ្ចូល

ជំហានទី ៣ ៖ បន្ទាប់មកភ្នាក់ងារវីង នឹងហុចក្រដាសដែលមានលេខកូដសម្រាប់បញ្ចូលទឹកប្រាក់

**ការបញ្ចូលទឹកប្រាក់ជាមួយ USSD**

ការបញ្ចូលទឹកប្រាក់ជាមួយ USSD គឺជា សេវាកម្មមួយ ដែលផ្តល់ភាពងាយស្រួលដល់អតិថិជនដែលមិនមានកម្មវិធីស្មាតហ្វូនវីង ឬអ៊ីនធឺណេតប្រើប្រាស់តែអាចបញ្ចូលទឹកប្រាក់ទូរស័ព្ទបានគ្រប់ពេលវេលាគ្រប់ទីកន្លែងជាមួយ USSD នៅលើទូរស័ព្ទរបស់ខ្លួន។ ដើម្បីប្រើប្រាស់សេវានេះបាន អតិថិជនត្រូវមានគណនីវីងដែលមានសមតុល្យទឹកប្រាក់ ហើយអនុវត្តនូវជំហានងាយៗ ដូចខាងក្រោម៖

ជំហានទី ១ ៖ វាយលេខ *989# រួចចុចបញ្ជូន

ជំហានទី ២ ៖ ក្នុងករណីដែលអតិថិជនមានគណនីលើសពីមួយភ្ជាប់ជាមួយលេខទូរស័ព្ទតែមួយ ត្រូវបញ្ចូលលេខគណនីរបស់ខ្លួនឲ្យបានត្រឹមត្រូវ

ជំហានទី ៣ ៖ បញ្ចូលលេខ ៣ ដើម្បីប្រើប្រាស់សេវាបញ្ចូលកាតទូរស័ព្ទ

ជំហានទី ៤ ៖ បញ្ចូលលេខ ១ សម្រាប់ការបញ្ចូលទឹកប្រាក់ទូរស័ព្ទដោយផ្ទាល់ ឬលេខ ២ សម្រាប់ការទិញលេខកោសកាត

ជំហានទី ៥ ៖ បញ្ចូលលេខទូរស័ព្ទដែលត្រូវបញ្ចូលទឹកប្រាក់

ជំហានទី ៦ ៖ ជ្រើសរើសលេខសម្រាប់ចំនួនទឹកប្រាក់ដែលត្រូវបញ្ចូលកាតទូរស័ព្ទ

**ការបញ្ចូលទឹកប្រាក់ទូរស័ព្ទជាមួយកម្មវិធីស្មាតហ្វូនវីង**

ការបញ្ចូលទឹកប្រាក់ទូរស័ព្ទជាមួយកម្មវិធីស្មាតហ្វូនវីង (លើ App Wing Money) គឺជាសេវាកម្មមួយដែលមានភាពងាយស្រួលបំផុត សម្រាប់បញ្ចូលកាតទូរស័ព្ទខ្លួនឯងផ្ទាល់ ឬទិញកាតបញ្ចូលទឹកប្រាក់។ អតិថិជនអាចជ្រើសរើសប្រភេទនៃការបញ្ចូលទឹកប្រាក់ទូរស័ព្ទបាន ៣វិធីរួមមាន៖

- ការបញ្ចូលទឹកប្រាក់ទូរស័ព្ទដោយផ្ទាល់ (Direct Top Up for My phone number)
- ការបញ្ចូលទឹកប្រាក់ទូរស័ព្ទសម្រាប់លេខទូរស័ព្ទដទៃ (Direct Top Up for other number)
- ការបញ្ចូលទឹកប្រាក់ទូរស័ព្ទដោយទិញកាតបញ្ចូលទឹកប្រាក់ (Buy a Voucher)

ជំហានទី ១ ៖ ចូលទៅកាន់កម្មវិធីស្មាតហ្វូនវីង

ជំហានទី ២ ៖ ចុចលើប៊ូតុង "បញ្ចូលលុយទូរស័ព្ទ" ឬ "Phone Top Up"

ជំហានទី ៣ ៖ ជ្រើសរើសគណនី (បើមានគណនីចាប់ពី ២ ឡើងទៅ)

ជំហានទី ៤ ៖ ជ្រើសរើសប្រភេទនៃការបញ្ចូលទឹកប្រាក់ទូរស័ព្ទ និងប្រព័ន្ធទូរស័ព្ទ

ជំហានទី ៥ ៖ ជ្រើសរើសចំនួនទឹកប្រាក់ រួចចុចបញ្ជាក់ ហើយវាយលេខសំងាត់ ៤ខ្ទង់

**បញ្ចូលទឹកប្រាក់ផ្សេងៗ**

ក្រៅពីការបញ្ចូលទឹកប្រាក់ទូរស័ព្ទ អ្នកក៏អាចបញ្ចូលទឹកប្រាក់សេវាកម្មផ្សេងៗ ជាមួយភ្នាក់ងារវីងបានផងដែរ។

វីងអនុញ្ញាតឲ្យអតិថិជនបញ្ចូលទឹកប្រាក់សម្រាប់សេវាកម្មផ្សេងៗដូចជា ទូរទស្សន៍ខ្សែកាប ទិន្នន័យអ៊ីនធឺណេត ហ្គេមអនឡាញ ឬហាងទំនិញអនឡាញ។ វីងផ្តល់ភាពងាយស្រួលក្នុងការបញ្ចូលទឹកប្រាក់ផ្សេងៗជាច្រើនក្នុងជីវភាពប្រចាំថ្ងៃដែលរួមមានដូចជា ៖

- One TV (បញ្ចូលទឹកប្រាក់ទូរទស្សន៍ខ្សែកាប)
- Y5Net (សេវាអ៊ីនធឺណេត)
- Osja game (បញ្ចូលទឹកប្រាក់សម្រាប់លេងហ្គេម)
- សំណាង (ឥណទានសម្រាប់ទិញទំនិញអនឡាញ)
- MKS (សេវាអ៊ីនធឺណេត)
- I top (សេវាអ៊ីនធឺណេត)

**២.៧.១.៦ សេវាអាំងប៉ាវវីង** ( Wing Ang Pao )

សេវាអាំងប៉ាវវីង គឺជាសេវាកម្មដែលផ្តល់មធ្យោបាយ យ៉ាងទំនើបដល់អតិថិជនវីង ដើម្បីផ្តល់អំណោយ ឬអាំងប៉ាវជាសាច់ប្រាក់ទៅមនុស្សជាទីស្រលាញ់គ្រប់ពេលវេលា តាមរយៈគណនីវីង។ សេវាកម្មថ្មីមួយនេះជាសេវាកម្មថ្មីចុងក្រោយគេបង្អស់ ដែលទើបតែបើកដំណើរការអោយអតិថិជនប្រើប្រាស់នៅដើមខែកុម្ភៈ ឆ្នាំ ២០១៩ នេះតែប៉ុណ្ណោះ។ គោលបំណងនៃការបង្កើតសេវាមួយនេះឡើង គឺដើម្បីបំពេញតម្រូវការរបស់អតិថិជន នាឱកាសចូលឆ្នាំចិនក្នុងការចែករំលែកក្តីស្រលាញ់ និងកាដូអាំងប៉ាវដល់បងប្អូនញាតិមិត្តរបស់ខ្លួន។ ជាងនេះទៅទៀត លក្ខណៈពិសេសរបស់អាំងប៉ាវវីងនោះគឺ វាជាមធ្យោបាយយ៉ាងទំនើប ដើម្បីផ្តល់អំណោយជាសាច់ប្រាក់ ទៅមនុស្សជាទីស្រលាញ់បានគ្រប់ពេលវេលា និងអាចផ្ញើអាំងប៉ាវវីងតាមអ៊ីនធឺណេតជាលក្ខណៈបុគ្គល ឬជាក្រុមក៏បាន។ រីឯលក្ខខណ្ឌដើម្បីប្រើប្រាស់អាំងប៉ាវវីងបាននោះ គឺអតិថិជនចាំបាច់ត្រូវមាន គណនីវីងដែលមាន KYC ពេញលេញ និងកម្មវិធីស្មាតហ្វូនវីង។

# ជំពូកទី ៣

# ប្រតិបត្តិការទូទាត់ និងសេវាផ្ទេរប្រាក់របស់ធនាគារឯកទេសវីង

ធនាគារឯកទេសវីង (ខេមបូឌា) លីមីតធីត ផ្តល់នូវសេវាកម្មធំៗ ២ គឺប្រតិបត្តិការទូទាត់ និងសេវាផ្ទេរប្រាក់ទាំងក្នុង និងក្រៅប្រទេស។ នៅពេលដែលអតិថិជនមានតម្រូវការទូទាត់ថ្លៃទំនិញ ឬសេវាកម្មផ្សេងដែលបានប្រើប្រាស់ ឬត្រូវការផ្ញើប្រាក់ទៅនណារម្នាក់ជាបន្ទាន់ ធនាគារឯកទេសវីងនឹងជួយបំពេញតម្រូវការទាំងនេះជូនអតិថិជន។

## ៣.១ ប្រតិបត្តិការទូទាត់

ប្រតិបត្តិការទូទាត់របស់ធនាគារឯកទេសវីង គឺត្រូវបានបង្កើត ដើម្បីជួយសម្រួលដល់ការទូទាត់ចំណាយរបស់អតិថិជនទៅកាន់ភ្នាក់ងារលក់នានា ក៏ដូចជាការបង់ថ្លៃសេវាទៅកាន់អង្គភាពរដ្ឋឬឯកជនអោយកាន់តែមានភាពលឿនរហ័ស និងចំណាយនូវតម្លៃសេវាមួយដ៏ទាប។

ជាមួយបច្ចេកវិទ្យាហិរញ្ញវត្ថុដ៏ទំនើបនាំមុខគេ ធនាគារឯកទេសវីងមានប្រតិបត្តិការទូទាត់ធំៗចំនួនបី រួមមានៈ សេវាបង់វិក្កយបត្រ (Bill Payment), សេវាទូទាត់តាមអ៊ីនធឺណេត (Online Payment) និងសេវាទូទាត់តាមវីងគិតលុយ (WingPay)។

### ៣.១.១ សេវាទូទាត់បង់វិក្កយបត្រ ( Bill Payment )

សេវាបង់វិក្កយបត្រ គឺជាសេវាកម្មទូទាត់មួយដែលបង្កើតឡើងដើម្បីបង្កើនភាពងាយស្រួលដល់អតិថិជនក្នុងការបង់វិក្កយបត្រនូវពីរជម្រើសនៃការទូទាត់ដែលអាចប្រព្រឹត្តទៅបានតាមរយ: ការបង់ផ្ទាល់ទៅកាន់ភ្នាក់ងារវីង និង ការបង់តាមរយ:កម្មវិធីទូរស័ព្ទដៃ ឬតាម USSD[25] ទៅលើ ការប្រើប្រាស់ទឹកភ្លើង (EDC) កម្ចីខ្នាតតូច ការទូទាត់ទៅកាន់អ្នកផ្គត់ផ្គង់ និងក្រុមហ៊ុនជាច្រើនទៀតជាង ២០០ ក្រុមហ៊ុន (តារាងដៃគូសហការប្រតិបត្តិការទូទាត់វិក្កយបត្រមាននៅឧបសម្ព័ន្ធទី២)។

ការទូទាត់វិក្កយបត្រតាមវីងនេះប្រព្រឹត្តទៅបានចំពោះប្រភេទក្រុមហ៊ុនដៃគូសហការរបស់ធនាគារ ដូចជាក្រុមហ៊ុនដែលបម្រើសេវាៈ

- ទឹក ភ្លើង (Utilities)
- កាតធនាគារ (Bank Card)

[25] USSD (Unstructured Supplementary Service Data) គឺជាប្រព័ន្ធបច្ចេកវិទ្យាលក្ខណ:សាកលមួយ (Global System for Mobile GSM) សម្រាប់ទូរស័ព្ទដៃដែលប្រើប្រាស់សម្រាប់ធ្វើការបញ្ជូនព័ត៌មានជាអក្សរទៅកាន់កម្មវិធីស្មាតហ្វូនក្នុងបណ្តាញ។

- ខ្សែកាបទូរទស្សន៍ (Cable TV Company)
- ធានារ៉ាប់រង (Insurance Company)
- អ៊ិនធឺណេត (Internet Company)
- ជួល (Leasing)
- មីក្រូហិរញ្ញវត្ថុ (Micro Finance Institutions)
- អប់រំ (Schools)
- ប្រព័ន្ធទូរគមនាគមន៍ (Telecommunication)

**៣.១.១.១ នីតិវិធីនៃការទូទាត់បង់វិក្កយបត្រ** ( Bill Payment )

អតិថិជន អាចធ្វើការបង់វិក្កយបត្រទៅកាន់អង្គភាពដែលខ្លួនបានប្រើប្រាស់សេវាកម្មតាមរយៈវីង ទោះនៅក្នុងល័ក្ខខ័ណ្ឌដែលខ្លួនមានគណនី ឬគ្មានគណនីតាម ២របៀបដូចខាងក្រោម ៖

**ក. នីតិវិធីនៃការទូទាត់បង់វិក្កយបត្រតាមរយៈ** USSD

អតិថិជនដែលមានគណនីវីងស្រាប់ អាចធ្វើការបង់ទូទាត់វិក្កយបត្រទៅកាន់ក្រុមហ៊ុនយ៉ាងលឿនរហ័ស និងចំណាយថវិកាតិច ត្រឹមមានទូរស័ព្ទដៃមួយដើម្បីដំណើរការតាមជំហានដូចខាងក្រោម៖

ជំហានទី១ ៖ អតិថិជនត្រូវមានគណនីវីង ដែលមានសមតុល្យសាច់ប្រាក់គ្រប់គ្រាន់សម្រាប់ធ្វើការទូទាត់ជាមួយវិក្កយបត្ររបស់ខ្លួន

ជំហានទី២ ៖ អតិថិជនត្រូវប្រើប្រាស់ទូរស័ព្ទដៃ វាយលេខ *989# រួចចុចបញ្ជូន

ជំហានទី៣ ៖ បន្ទាប់ពីប្រតិបត្តិការនៅជំហានមុនទទួលបានជោគជ័យ អតិថិជនត្រូវវាយបញ្ចូលលេខគណនីវីង រួចចុចបញ្ជូន

ជំហានទី៤ ៖ អតិថិជនតម្រូវអោយចុចយកនូវលេខ 5."Bill Payment" ដែលបង្ហាញនៅលើអេក្រង់ទូរស័ព្ទ រួចចុចបញ្ជូន

ជំហានទី៥ ៖ អតិថិជនត្រូវជ្រើសប្រភេទក្រុមហ៊ុន (ឧទាៈ ជ្រើសយក 2. Utilities for EDC Bill or Water Bills ជ្រើសយក 3. Finance for AEON Bill, First Finance ។ល។) ហើយចុចបញ្ជូន

ជំហានទី៦ ៖ ខាងធនាគារតម្រូវអោយអតិថិជន ជ្រើសយកឈ្មោះក្រុមហ៊ុនមួយ សម្រាប់ធ្វើការទូទាត់ទៅកាន់ (ឧទាៈ EDC, AEON, First Finance, Manulife, Digi ។ល។) រួចចុចបញ្ជូន

ជំហានទី៧ ៖ ក្រោយមកអតិថិជនវាយបញ្ចូលលេខសម្គាល់ ID (ឧទាៈ លេខវិក្កយបត្រ លេខសម្គាល់អតិថិជន លេខគណនី ។ល។) នឹងធ្វើការចុចបញ្ជូនបន្ត

ជំហានទី៨ ៖ អតិថិជនត្រូវផ្ទៀងផ្ទាត់នូវវិក្កយបត្រដែលត្រូវបង់អោយបានច្បាស់លាស់ហើយវាយបញ្ចូលចំនួនទឹកប្រាក់ទូទាត់

ជំហានទី៩ ៖ បញ្ចូលលេខសម្ងាត់ PIN ដែលបានបង្កើតរបស់ខ្លួនបន្ត និងចុចបញ្ជូន

ជំហានទី១០ ៖ អតិថិជននឹងទទួលបានសារបង្ហាញថាការធ្វើប្រតិបត្តិការទទួលបានជោគជ័យ។

**ខ. នីតិវិធីនៃការទូទាត់បង់វិក្កយបត្រតាមរយៈកម្មវិធីស្មាតហ្វូនវីង**

កាន់តែមានភាពជឿនលឿនទាន់សម័យ អតិថិជនដែលមានគណនីវីងក្រៅពីវិធីសាស្រ្តនៃការបង់ ដែលបានរៀបរាប់នៅខាងលើ អតិថិជនអាចមានសិទ្ធិជ្រើសរើស នូវការបង់តាមរយៈទូរស័ព្ទដៃរបស់ខ្លួន ដោយគ្រាន់តែអនុវត្តតាមជំហានងាយៗ ដូចខាងក្រោម ៖

ជំហានទី១ ៖ អតិថិជនត្រូវមានគណនីវីង ហើយមានកម្មវិធីស្មាតហ្វូនវីងដែលភ្ជាប់ជាមួយគណនី

ជំហានទី២ ៖ អតិថិជនចូលទៅកាន់កម្មវិធី ហើយជ្រើសរើសពាក្យ "ទូទាត់វិក្កយបត្រ" ព្រមទាំងជ្រើសរើសក្រុមហ៊ុនដែលខ្លួនចង់បង់សេវាកម្ម ឬទូទាត់វិក្កយបត្រទៅកាន់

ជំហានទី៣ ៖ ករណីអតិថិជនមានគណនីវីងច្រើនលើសពីពីរ អតិថិជនត្រូវជ្រើសរើសគណនីមួយណាដែលចង់ធ្វើការទូទាត់ហើយមានសមតុល្យគ្រប់គ្រាន់សម្រាប់កាត់សាច់ប្រាក់ចេញ បន្ទាប់មកត្រូវវាយបញ្ចូលនូវចំនួនទឹកប្រាក់ដែលត្រូវបង់

ជំហានទី៤ ៖ ចុងក្រោយអតិថិជនត្រូវចុចលើពាក្យបង់ប្រាក់ ហើយវាយលេខសំងាត់បួនខ្ទង់ដែលខ្លួនបានបង្កើតសម្រាប់ប្រើកម្មវិធីស្មាតហ្វូនវីង នោះប្រតិបត្តិការទូទាត់ទទួលបានជោគជ័យ។

**គ. នីតិវិធីនៃការទូទាត់បង់វិក្កយបត្រតាមរយៈភ្នាក់ងារវីង**

ដើម្បីសម្របទៅតាមការចង់បានរបស់អតិថិជន ធនាគារឯកទេសវីងមិនត្រឹមតែសម្រួលដល់ការបង់វិក្កយបត្រ តាមរយៈ២ វិធីសាស្រ្តខាងលើប៉ុណ្ណោះទេ ធនាគារក៏បានគិតគូដល់អតិថិជនដែលមិនមានគណនីវីង ហើយចង់ប្រើប្រាស់សេវាវីង ក្នុងការបង់វិក្កយបត្ររបស់ខ្លួនបានផងដែរដោយអតិថិជនអាចធ្វើតាមការណែនាំដែលបានរៀបរាប់ដូចខាងក្រោម៖

ជំហានទី១៖ អតិថិជនត្រូវយកវិក្កយបត្រទៅកាន់ភ្នាក់ងារវីង ដែលនៅជិតបំផុត

ជំហានទី២៖ អតិថិជនតម្រូវអោយប្រាប់ទៅកាន់ ភ្នាក់ងារវីងពីគោលបំណងរបស់ខ្លួន ក្នុងការមកធ្វើប្រតិបត្តិការ គឺការបង់វិក្កយបត្រ

ជំហានទី៣៖ បន្ទាប់មកអតិថិជនត្រូវសរសេរឈ្មោះក្រុមហ៊ុន លេខសម្គាល់វិក្កយបត្រ ចំនួនទឹកប្រាក់ និង លេខទូរស័ព្ទរបស់ខ្លួនអោយទៅកាន់ភ្នាក់ងារវីង

ជំហានទី៤ ៖ បន្តមកទៀតអតិថិជនត្រូវរាប់ និងផ្ទៀងផ្ទាត់ប្រាក់អោយបានគ្រប់ចំនួនមុននឹងផ្តល់ប្រាក់ទៅកាន់ភ្នាក់ងាររីង

ជំហានទី៥ ៖ ក្រោយមក ភ្នាក់ងាររីងនឹងអោយវិក្កយបត្រដែលបង្ហាញពីទឹកប្រាក់ដែលបានបង់ទៅកាន់អតិថិជន

ជំហានទី៦៖ អតិថិជនអាចធ្វើការពិនិត្យសារ ជាអក្សរក្នុងទូរស័ព្ទដៃ ដែលបង្ហាញអំពីការធ្វើប្រតិបត្តិការទូទាត់ទទួលបានជោគជ័យ។

### ៣.១.១.២ តម្លៃសេវានៃការទូទាត់បង់វិក្កយបត្រ

ចំពោះការទូទាត់ថ្លៃសេវាលើការទូទាត់បង់វិក្កយបត្រធនាគារឯកទេសរីង ធ្វើការកំណត់យកទៅតាមប្រភេទខុសៗគ្នានៃក្រុមហ៊ុនទូទាត់ (តារាងថ្លៃសេវាដែលលម្អិតមាននៅឧបសម្ព័ន្ធទី២)។

**ចំពោះការទូទាត់លើប្រភេទកាតធនាគារ**

- ក្នុងករណីដែលអតិថិជនធ្វើការទូទាត់លើប្រភេទកាត FTB Bank អស់ចាប់ពី៖
  - $០-$៥០០.៩៩ ធនាគារគិតថ្លៃសេវាចំនួន $២.២៥
  - $៥០១-$១,០០០.៩៩ ធនាគារគិតថ្លៃសេវាចំនួន $៤.២៥
  - $១,០០១-$១,៥០០.៩៩ ធនាគារគិតថ្លៃសេវាចំនួន $៦.២៥
  - $១,៥០១-$២,០០០ ធនាគារគិតថ្លៃសេវាចំនួន $៨.២៥
- ក្នុងករណីដែលអតិថិជនធ្វើការទូទាត់លើប្រភេទកាត Cathay United Bank មិនគិតពីចំនួនទឹកប្រាក់ នៅក្នុងមួយប្រតិបត្តិការ គឺកំណត់យកត្រឹម$០.៥០។
- ចំពោះប្រភេទកាតរបស់ធនាគារមួយចំនួនទៀត គឺពុំមានការកំណត់យកថ្លៃសេវាតែម្តង គឺប្រភេទកាតរបស់ធនាគារ UCB។

**ចំពោះការទូទាត់លើប្រភេទក្រុមហ៊ុនខ្សែកាប** គឺមិនមានការយកថ្លៃសេវានោះទេ ចំពោះក្រុមហ៊ុនដូចជា ខេមបូឌាឌីជីថលធីវី, ភីភីស៊ីធីវី និងវ៉ែនធីវី។

**ចំពោះការទូទាត់លើប្រភេទធានារ៉ាប់រង** គឺមិនមានគិតថ្លៃសេវាចំពោះ ក្រុមហ៊ុនធានារ៉ាប់រង AIA Life Insurance, Manulife ។ល។

**ចំពោះការទូទាត់លើប្រភេទក្រុមហ៊ុនអ៊ីនធឺណេត**

- ក្នុងករណីដែលអតិថិជនធ្វើការទូទាត់លើ សេវាអ៊ីនធើណេតរបស់ក្រុមហ៊ុន Online និង ក្រុមហ៊ុនអ៊ីនធឺណេតហ្វម ធនាគារឯកទេសធ្វើការយកថ្លៃសេវាទូទាត់ចំនួន $០.៥០។
- ក្នុងករណីដែលអតិថិជនធ្វើការទូទាត់ទៅកាន់ក្រុមហ៊ុន ទូរគមនាគមន៍កម្ពុជាអស់ចាប់ពី

- $០-$២៥ ធនាគារគិតថ្លៃសេវាចំនួន $០.២៥
- $២៥.០១-$៣,០០០ ធនាគារគិតថ្លៃសេវាចំនួន $០.៥០

- ចំពោះការបង់ថ្លៃសេវាអ៊ីនធឺណេតមួយចំនួនទៀត គឺពុំមានការកំណត់យកថ្លៃសេវាតែម្តងរួមមាន ដូចជា ក្រុមហ៊ុនឌីជី វ៉ាយហ្វាយណែត មេគង្គណេត ជាដើម។

**ចំពោះការទូទាត់លើប្រភេទក្រុមហ៊ុនជួល**

- ក្នុងករណីដែលអតិថិជន ធ្វើការទូទាត់ទៅកាន់ក្រុមហ៊ុនដូចជា ឆាយលីសរ៉ូយ៉ាល់លីស៊ីងម.ក មេហ្គាលីស៊ីង អាយហ្វាយនែនភីអិលស៊ី អ៊ីនប៊ីសណោសម.ក គឺតម្រូវអោយយកថ្លៃសេវាចំនួន $០.៥០។
- ដោយឡែកចំពោះការបង់ទៅកាន់ក្រុមហ៊ុន RMA Cambodia គឺយកតម្លៃសេវាចំនួន $១។

**ចំពោះការទូទាត់លើប្រភេទគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនូវការបង់កម្ចី**

- ក្នុងករណីដែលអតិថិជនធ្វើការទូទាត់ទៅកាន់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត ធនាគារឯកទេសវីង គិតតម្លៃសេវាទាបបំផុតនៅត្រឹម $០.២៥ គ្រប់ប្រតិបត្តិការដោយមិនកំណត់ពីចំនួនសាច់ប្រាក់នៃការបង់។
- ចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដទៃទៀត គឺយកតម្លៃសេវា $០.៥០ រួមមាន៖ ព្រីនស៍ហ្វាយនែនភីអិលស៊ី ដេកស៍ហ្វាយនែន ខេមាមីក្រូហិរញ្ញវត្ថុ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុវ៉ាយស៊ីភី ។ល។
- រីឯ គ្រឹះស្ថានមួយចំនួនទៀត គឺមិនមានការយកថ្លៃសេវាពីអតិថិជនដែលមកធ្វើការបង់តែម្តងរួមមាន គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអិលអូអិលស៊ី ជីអិលហ្វាយនែន គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុហ្វឺសហ្វាយនែន ជាដើម។

**ចំពោះការទូទាត់លើសេវាអប់រំទៅកាន់សាលា**

- ក្នុងករណីដែលអតិថិជនធ្វើការទូទាត់ទៅកាន់វិទ្យាស្ថាន CAMED និងសាកលវិទ្យាល័យបញ្ញាសាស្ត្រ ធនាគារយកថ្លៃសេវាកម្ម $១។
- ចំណែកឯ សាលាមួយចំនួនទៀតដូចជា មូលនិធិដុនបូស្កូកម្ពុជា សាលាអន្តរជាតិវេស្ទើន សាលាអង់គ្លេសអ៊ើដនិចជាដើម គឺមិនមានការយកថ្លៃសេវានោះទេ។

**ចំពោះការទូទាត់លើសេវាប្រព័ន្ធទូរគមនាគមន៍**

- អតិថិជនអាចធ្វើការបង់ទៅលើ ថ្លៃសេវាកម្មរបស់ក្រុមហ៊ុនសែលកាត ដោយឥតគិតថ្លៃជាមួយភ្នាក់ងាររីងដោយឥតគិតថ្លៃ។

**ចំពោះការទូទាត់លើសេវា ទឹក-ភ្លើង**

- ក្នុងករណីអតិថិជនធ្វើការបង់លើវិក្កយបត្រថ្លៃទឹក ដែលបានប្រើប្រាស់ទៅកាន់រដ្ឋាករទឹកភ្នំពេញ និងរដ្ឋាករទឹកសៀមរាប តាមរយៈភ្នាក់ងាររឹង ចាប់ពី៖

- 0-១0,000៛ ភ្នាក់រឹងគិតនៅក្នុងមួយវិក្កយបត្រ ១,000៛
- លើសពី ១0,000៛ ភ្នាក់រឹងគិតនៅក្នុងមួយវិក្កយបត្រ ២,000៛

- បើអតិថិជនធ្វើការបង់ទៅកាន់អគ្គិសនី-ទឹក នៅក្នុងមួយវិក្កយបត្រ ដោយមិនកំណត់ពីចំនួនដែលត្រូវបង់នៅក្នុងវិក្កយបត្រ រឹងគិតថ្លៃសេវាចំនួន ៨00៛
- ចំពោះការបង់ទៅលើថ្លៃភ្លើងទូទាំងប្រទេស ជាទូទៅ រឹងកំណត់ថ្លៃសេវាទៅតាមតម្លៃបង់នៅក្នុងមួយវិក្កយបត្រចាប់ពី៖

- 0- ១0,000៛ ភ្នាក់រឹងគិតតម្លៃសេវា ១,000៛
- លើសពី ១0,000៛ ភ្នាក់រឹងគិតតម្លៃសេវា ២,000៛

### ៣.១.២ សេវាទូទាត់តាមអ៊ីនធឺណេត (Online Payment)

សេវាទូទាត់តាមអ៊ីនធឺណេត គឺជាសេវាកម្មទូទាត់មួយដែលត្រូវបានបង្កើតឡើងសម្របទៅនឹងបរិបទទាន់សម័យ សម្រាប់ការទូទាត់ដែលបានធ្វើឡើងតាមរយៈអ៊ីនធឺណេត ឬ អតិថិជនធ្វើការចុះឈ្មោះ នៅក្នុងគេហទំព័រលក់ទាំងនោះតែម្តង ដើម្បីធ្វើការកុម្មង់ទិញសំបុត្រកុន សំបុត្រឡានក្រុង សំលៀកបំពាក់ និងសៀវភៅតាមអនឡាញនានា ដោយមិនចាំបាច់ទៅហាងផ្ទាល់។ រឹងអ្នកលក់ក៏អាចទាក់ទាញភ្ញៀវបានច្រើន ដោយមិនចាំបាច់មានទីតាំង ធំទូលាយសម្រាប់ដាក់តាំងបង្ហាញទំនិញផ្សេងៗ ជាដើម។

សេវាទូទាត់តាមអ៊ីនធឺណេត (Online Payment Partners) នេះអាចធ្វើប្រតិបត្តិការបានជាមួយប្រភេទក្រុមហ៊ុនដែលជាដៃគូសហការមានដូចជា ក្រុមហ៊ុនបច្ចេកវិទ្យា សម្លៀកបំពាក់ អាហារ និងភេសជ្ជៈ ក្រុមហ៊ុនចែកចាយ ក្រុមហ៊ុនទេសចរណ៍ អ៊ីនធឺណេត និងក្រុមហ៊ុនផ្សេងៗដទៃទៀត។

#### ៣.១.២.១ នីតិវិធីនៃការទូទាត់តាមអ៊ីនធឺណេត (Online Payment)

សម្របទៅតាមភាពជឿនលឿននៃបច្ចេកវិទ្យា ដែលធ្វើឲ្យការទិញទំនិញកាន់តែចំណាយពេលតិចទៅៗនោះ សេវាទូទាត់តាមអ៊ីនធឺណេត (Online Payment) របស់ធនាគារឯកទេសរឹងបានបម្លែងការប្រើប្រាស់វិធីសាស្រ្ត ក្នុងការបង់វិក្កយបត្រតាមអ៊ីនធឺណេត យ៉ាងងាយស្រួល ដូចខាងក្រោម ចំពោះអតិថិជនរឹងដែលមានគណនីផ្ទាល់ខ្លួន៖

ជំហានទី១ ៖ អតិថិជនអាចចូលទៅកាន់គេហទំព័រណាមួយក៏បានដែលខ្លួនចង់ទិញ

(ឧទា: www. L192.com, A-Y Collection, i-quick, Legend, Shop 168 …etc.)

ជំហានទី២ ៖ ក្នុងករណីដែលគេហទំព័រនោះតម្រូវអោយអតិថិជនចុះឈ្មោះជាមុនសិន អតិថិជនត្រូវបង្កើតគណនីនៅក្នុងគេហទំព័រនោះ តាមរយៈអ៊ីម៉ែលផ្ទាល់ខ្លួន

ជំហានទី៣ ៖ បន្ទាប់មកអតិថិជនអាចជ្រើសរើសទិញទំនិញ ឬសំបុត្រកុនអ្វីមួយនៅក្នុងគេហទំព័រ

ជំហានទី៤ ៖ ក្រោយមកប្រភេទនៃការទូទាត់នឹងត្រូវបានបង្ហាញនៅលើគេហទំព័រ អតិថិជនត្រូវជ្រើសរើសវីង សម្រាប់ការទូទាត់នូវទំនិញ

ជំហានទី៥ ៖ អតិថិជនចុចលើរូបកាតវីង បន្ទាប់មកត្រូវវាយបញ្ចូលលេខគណនីវីង ព្រមទាំងថ្ងៃខែឆ្នាំកំណើត និងលេខកូដបង់ប្រាក់ដែលជាលេខសម្ងាត់ PIN ៤ខ្ទង់

ជំហានទី៦ ៖ អតិថិជនត្រូវជ្រើសរើសពាក្យ " Confirm " សម្រាប់ទូទាត់

ជំហានទី៧ ៖ ចុងក្រោយការទូទាត់បានជោគជ័យនឹងបង្ហាញនៅលើគេហទំព័រ

ចំណែកឯ នីតិវិធីនៃការផ្ទេរលុយបន្តទៅកាន់ដៃគូពាណិជ្ជកម្មរបស់វីងវិញ គឺមានលក្ខណៈរឹតតែងាយស្រួលដោយភ្លាមៗ បន្ទាប់ពីអតិថិជន ធ្វើការទូទាត់តាមជំហានខាងលើរួចរាល់ ប្រាក់ដែលអតិថិជនបានបង់នឹងលោតចូល ទៅក្នុងគណនីរបស់ពាណិជ្ជករភ្លាម ដោយមិនបាច់មាននីតិវិធីបញ្ជូនបន្តសាច់ប្រាក់ ពីធនាគារឯកទេសវីង ទៅកាន់ពាណិជ្ជករតាមក្រោយ ដែលធ្វើអោយចំណាយពេលយូរ នៅពេលដែលពាណិជ្ជករត្រូវការបង្វិលសាច់ប្រាក់ ក្នុងការស្តុកនូវទំនិញថ្មីៗ។

### ៣.១.២.២ តម្លៃសេវានៃការទូទាត់តាមអ៊ីនធឺណេត

ចំពោះការគិតកម្រៃទៅលើថ្លៃសេវានៃការទូទាត់ពីអតិថិជន ទៅកាន់ពាណិជ្ជករ គឺធនាគារឯកទេសវីងមិនមាននីតិវិធីនៃការយកកម្រៃពីអតិថិជននោះទេ ដោយធនាគារធ្វើការគិតកម្រៃនោះពីពាណិជ្ជករតាមរយៈការចរចារគ្នាដោយបុគ្គល ទៅលើការយកថ្លៃសេវា ហើយការគិតសេវាបែបនេះ គឺដើម្បីទាក់ទាញនូវកំណើនអតិថិជនប្រើប្រាស់ប្រតិបត្តិការទូទាត់តាមអ៊ីនធឺណេតអោយមានទំនុកចិត្ត នៅក្នុងការប្រើប្រាស់សេវាកាន់តែច្រើនឡើងបន្ថែមទៀត។

### ៣.១.៣. សេវាទូទាត់តាមវីងគិតលុយ (WingPay)

សេវាទូទាត់វីងគិតលុយ គឺជាសេវាកម្មមួយដែលត្រូវបានបង្កើតឡើងចំពោះអតិថិជនដែលមានគណនីនៅវីងស្រាប់ និងចំពោះជនបរទេសដែលមិនមានគណនីធនាគារនៅប្រទេសកម្ពុជា។ អតិថិជន អាចប្រើប្រាស់ការទូទាត់ភ្លាមៗយ៉ាងរហ័សបានផងដែរ ជាមួយនឹងទូរស័ព្ទដៃរបស់ពួកគេផ្ទាល់ទៅកាន់ហាងនីមួយៗ ដែលជាដៃគូសហការរបស់ធនាគារឯកទេសវីង។ ការទូទាត់របស់អតិថិជនអាចធ្វើឡើងតាមច្រើនវិធីសាស្រ្តដែលអតិថិជនគិតថាងាយស្រួលសម្រាប់ខ្លួន។

**៣.១.៣.១ នីតិវិធីនៃការទូទាត់តាមវីងគិតលុយ** ( WingPay )

ពេលមានគណនីវីង អតិថិជនអាចធ្វើការចាយ ឬទូទាត់ទំនិញនៅតាមហាង ជាមួយនឹងសុវត្ថិភាពខាងផ្នែកហិរញ្ញវត្ថុ ដោយធនាគារផ្តល់ជម្រើសអោយអតិថិជនទូទាត់តាម ៣ វិធីសាស្ត្រដូចខាងក្រោមៈ

**ក. សេវាទូទាត់** WingPay **តាមរយៈវីងកាត**

ធនាគារឯកទេសវីង បានគិតដល់សុវត្ថិភាពដល់អតិថិជនវីងតាមរយៈការកាន់សាច់ប្រាក់ទៅទូទាត់ទំនិញ តាមហាងនីមួយៗ ដោយជំនួសតាមការប្រើប្រាស់កាតឆូត លើម៉ាស៊ីនដែលងាយស្រួល ទាំងការដាក់តាមខ្លួន និងងាយទូទាត់ ដោយអតិថិជនអនុវត្ត តាមជំហានដែលបានរៀបរាប់ខាងក្រោមៈ

ជំហានទី១ៈ អតិថិជនអាចប្រាប់ទៅកាន់អ្នកគិតលុយ ឬម្ចាស់ហាងថា បង់ប្រាក់តាមរយៈកាតវីង

ជំហានទី២ៈ អតិថិជនត្រូវហុចវីងកាតទៅអោយអ្នកគិតលុយ ឬម្ចាស់ហាង ដើម្បីឆូតលើម៉ាស៊ីនវីង

ជំហានទី៣ៈ ប្រសិនបើ ទឹកប្រាក់ដែលត្រូវបង់តិចជាង ១០ដុល្លារ អតិថិជននឹងមិនតម្រូវឲ្យចុចលេខសម្ងាត់ PIN ៤ខ្ទង់ទេ។

ជំហានទី៤ៈ បន្ទាប់មកម៉ាស៊ីន POS វីងនឹងចេញវិក្កយបត្រ អតិថិជនអាចទទួលយកវិក្កយបត្រពីអ្នកលក់ ឬ ម្ចាស់ហាង

ជំហានទី៥ៈ ក្រោយមកអតិថិជននឹងទទួលបានសារ ពេលប្រតិបត្តិការទទួលបានជោគជ័យ។

**ខ. សេវាទូទាត់** WingPay **តាមរយៈ** USSD

ក្រៅពីការទូទាត់តាមរយៈកាត ធនាគារឯកទេសវីងក៏បានបង្កើតជាជម្រើសមួយផ្សេងទៀតសម្រាប់អតិថិជន ក្នុងករណីដែលអតិថិជនភ្លេចយកកាតមកតាមខ្លួន គឺអាចធ្វើការទូទាត់តាមរយៈ USSD ដែលជាការទូទាត់តាមរយៈប្រព័ន្ធសារនៅក្នុងទូរស័ព្ទដៃ ដើម្បីអោយប្រតិបត្តិការទទួលបានជោគជ័យអតិថិជនត្រូវអនុវត្តតាមនីតិវិធីទាំង ៦រួមមានៈ

ជំហានទី១ៈ អតិថិជនត្រូវប្រើប្រាស់ទូរស័ព្ទ និងវាយលេខ *989# រួចចុចបញ្ជូន

ជំហានទី២ៈ បន្ទាប់ពីមក អតិថិជនត្រូវវាយបញ្ចូលលេខគណនីវីង រួចចុចបញ្ជូន

ជំហានទី៣ៈ បន្តមកទៀត អតិថិជនតម្រូវអោយចុចយកនូវលេខ 7. "WingPay"

ជំហានទី៤ៈ បន្ទាប់មកអតិថិជនតម្រូវអោយបញ្ចូលលេខកូដទូទាត់ (Till Number) របស់ម្ចាស់ហាង

ជំហានទី៥ៈ អតិថិជនត្រូវវាយបញ្ចូលចំនួនទឹកប្រាក់ដែលត្រូវចំណាយទូទាត់

ជំហានទី៦ៈ អតិថិជនវាយបញ្ចូលលេខសម្ងាត់ ៤ខ្ទង់ដើម្បីឲ្យប្រតិបត្តិការទូទាត់ជោគជ័យ។

**គ. សេវាទូទាត់** WingPay **តាមរយៈ** QR Code

QR Code គឺជាប្រព័ន្ធទូទាត់មួយដែលជាទីពេញនិយមនៅប្រទេសចិន ដោយសារតែការទូទាត់មានភាពលឿនរហ័សជាងការទូទាត់នានាដទៃ ព្រមទាំងធានានូវសុវត្ថិភាពខ្ពស់ជូន ទាំងអតិថិជន និងពាណិជ្ជករ។ ដោយឃើញពីសារៈសំខាន់ និងអត្ថប្រយោជន៍របស់ QR Code ធនាគារឯកទេសវីងបានដាក់ QR Code ជាឧបករណ៍ទូទាត់មួយ នៅក្នុងចំណោមឧបករណ៍ទូទាត់ ដទៃទៀតរបស់ វីងគិតលុយ (WingPay)។ ដើម្បីទូទាត់តាម QR Code អតិថិជន អាចអនុវត្តតាមជំហានខាងក្រោមៈ

ជំហានទី១ៈ អតិថិជនត្រូវមានកម្មវិធីស្មាតហ្វូនវីង តម្លើងនៅលើទូរស័ព្ទដៃផ្ទាល់របស់ខ្លួន

ជំហានទី២ៈ អតិថិជនត្រូវចុចចូលទៅក្នុងកម្មវិធី ហើយជ្រើសយកពាក្យថា "WingPay"

ជំហានទី៣ៈ អតិថិជនតម្រូវអោយស្កេន QR Code ឬវាយលេខកូដទូទាត់ ដើម្បីកំណត់ពី Merchant ដែលត្រូវបង់

ជំហានទី៤ៈ បន្ទាប់មកអតិថិជនត្រូវវាយបញ្ចូលចំនួនទឹកប្រាក់ដែលត្រូវបង់

ជំហានទី៥ៈ ចុងក្រោយអតិថិជនត្រូវបញ្ចូលលេខកូដសម្ងាត់ ៤ខ្ទង់ ដែលជាលេខសម្ងាត់ប្រើ ដើម្បីបញ្ចប់ប្រតិបត្តិការទូទាត់បានជោគជ័យ។

**ឃ. សេវាទូទាត់** WingPay **តាមរយៈ** MasterPass QR

សេវាទូទាត់វីងគិតលុយបង្កើតឡើង ដោយមិនត្រឹមតែទាក់ទាញការទូទាត់ពីអតិថិជននៅក្នុងស្រុកដែលជាអតិថិជនមានគណនីវីងប៉ុណ្ណោះទេ លើសពីនេះធនាគារបានសហការជាមួយក្រុមហ៊ុនម៉ាស្ទ័រកាត (Master Card) ដើម្បីបង្កើតជា MasterPass QR ដែលអនុញ្ញាតទាំងអតិថិជនដែលមានគណនីវីង និងជាពិសេស គឺជនបរទេសដែលមិនមានគណនី នៅក្នុងប្រទេសកម្ពុជា ប៉ុន្តែ មានម៉ាស្ទ័រកាត ក៏អាចមានសិទ្ធិធ្វើការទូទាត់ទៅកាន់ ហាងទំនិញផ្សេងៗដែលមាន MasterPass QR របស់វីងផងដែរ។ ចំពោះអតិថិជនដែលមានគណនីវីង ហើយចង់ធ្វើការទូទាត់តាមរយៈ MasterPass QR ដើម្បីទទួលបានការបញ្ចុះតម្លៃអាចអនុវត្តតាមជំហានខាងក្រោមៈ

ជំហានទី១ៈ អតិថិជនត្រូវមានកម្មវិធីស្មាតហ្វូនវីងតម្លើងនៅលើទូរស័ព្ទដៃរបស់ខ្លួន

ជំហានទី២ៈ អតិថិជនត្រូវចុចចូលទៅក្នុងកម្មវិធី ហើយជ្រើសយកពាក្យថា "WingPay"

ជំហានទី៣ៈ ស្កេន QR Code ចំពោះ QR ដែលមានទាំង និមិត្តសញ្ញាម៉ាស្ទ័រកាត និងវីង

ជំហានទី៤ៈ បន្ទាប់មកអតិថិជន ត្រូវវាយបញ្ចូលចំនួនទឹកប្រាក់ដែលត្រូវបង់

ជំហានទី៥៖ ចុងក្រោយ អតិថិជនត្រូវបញ្ចូលលេខកូដសម្ងាត់ ៤ខ្ទង់ ដើម្បីបញ្ចប់ប្រតិបត្តិការទូទាត់បានជោគជ័យ។

រីឯចំពោះអតិថិជន ជាជនបរទេសអ្នកដែលគ្មានគណនីនៅវិញ គឺអាចធ្វើការស្កេនតាមរយៈកម្មវិធីទូរស័ព្ទដៃរបស់គេផ្ទាល់ហើយធ្វើការវាយបញ្ចូលនូវចំនួនទឹកប្រាក់មួយគ្រប់ចំនួនរួចចុចទូទាត់។

ចំពោះនីតិវិធីនៃការបញ្ជូនសាច់ប្រាក់បន្តពីអតិថិជនទៅកាន់ពាណិជ្ជករ ដូចគ្នាជាមួយនឹងការទូទាត់តាមអ៊ីនធឺណេតដែរ រៀងរាល់ពេលដែលអតិថិជនធ្វើការទូទាត់ នោះសាច់ប្រាក់នឹងហូរចូលទៅក្នុងគណនីរបស់ពាណិជ្ជករភ្លាមៗដែលអាចផ្ទៀងផ្ទាត់នូវចំណូលបាន នៅក្នុងពេលតែមួយជាមួយនឹងលំហូរចេញ ជាចំណាយរបស់អតិថិជន។

**៣.១.៣.២ តម្លៃសេវានៃការទូទាត់តាមវីងគិតលុយ**

ការទូទាត់តាមរយៈវីងគិតលុយ ជាជម្រើសដ៏ឆ្លាតវៃមួយ ដែលធនាគារបាននាំមកជូនអតិថិជនដើម្បីបានប្រើប្រាស់ និងបានស្គាល់នូវបច្ចេកវិទ្យាថ្មីៗទាន់សម័យ។ តាមរយៈការទូទាត់តាមវីងគិតលុយនេះ អតិថិជនមិនមានការបង់ថ្លៃសេវាអ្វីនោះទេ តែផ្ទុយទៅវិញ អតិថិជននឹងទទួលបានការបញ្ចុះតម្លៃ ទៅលើការទូទាត់តាមវីងគិតលុយតាមរយៈវិធីសាស្ត្រណាមួយ ដែលរៀបរាប់ខាងលើផងដែរ។ ការគិតថ្លៃសេវា គឺគិតពីពាណិជ្ជករដោយតម្រូវតាមការចរចារពីភាគីទាំងសងខាងរវាងពាណិជ្ជករ និង ធនាគារ ដែលអាចធ្វើការយកកម្រៃសេវា តាមរយៈក្នុងមួយការប្រតិបត្តិការរបស់អតិថិជន នៅក្នុងករណីដែលការទូទាត់ក្នុងមួយវិក្កយបត្រ មានចំនួនទឹកប្រាក់ច្រើន ឬគិតតាមរយៈចំនួនប្រតិបត្តិការដែលបានទូទាត់ទៅកាន់ពាណិជ្ជករ។

**៣.១.៤ អត្ថប្រយោជន៍នៃប្រតិបត្តិការទូទាត់**

ជាមួយនឹងសេវានាំមុខគេរបស់ធនាគារឯកទេសវីង ទៅលើប្រតិបត្តិការលឿនរហ័សប្រកបទៅដោយបច្ចេកវិទ្យាទំនើបបានផ្តល់អត្ថប្រយោជន៍ជាច្រើន ដូចខាងក្រោម៖

- អតិថិជនអាចធ្វើការបង់ទូទាត់ ចំពោះការប្រើប្រាស់របស់ខ្លួនតាមរយៈទូរស័ព្ទរបស់ខ្លួន ឬភ្នាក់ងារវីងបានភ្លាមៗគ្រប់ពេលវេលា។
- អតិថិជនអាចមើលឃើញនូវការបង់វិក្កយបត្រចាស់ៗរបស់ខ្លួន និងមើលតាមដានទៅលើការបង់នៅវិក្កយបត្របានទៀងទាត់ និងត្រូវតាមការកំណត់។
- ជួយកាត់បន្ថយនូវកំហុសដែលកើតឡើងដោយមនុស្សមិនបានផ្ទៀងផ្ទាត់ ហើយងាយស្រួលនៅក្នុងការកែកំហុសនោះភ្លាមៗ តាមរយៈការបង់នៅលើទូរស័ព្ទដៃផ្ទាល់។

- ដៃគូសហការរបស់វីង គឺអាចសន្សំសំចៃថវិកាក្នុងការបើកហាងដោយធ្វើការលក់តាមអនឡាញ ហើយសហការជាមួយវីង នៅក្នុងការទូទាត់តាមអ៊ីនធឺណេតពីអតិថិជនមកកាន់ខ្លួន។
- ដៃគូពាណិជ្ជកម្មរបស់ធនាគារឯកទេសវីង គឺអាចទទួលបានសាច់ប្រាក់ភ្លាមៗនៅរាល់ពេលដែលអតិថិជនធ្វើការទូទាត់សាច់ប្រាក់ទៅកាន់ភ្នាក់ងារវីង ឬតាមគណនីវីងផ្ទាល់នៅលើទូរស័ព្ទដៃ។
- ការលក់របស់ពាណិជ្ជករ អាចនឹងមានការកើនឡើង ជាលំដាប់ជាមួយនឹង ភាពងាយស្រួល តាមការបង់ទូទាត់នៅលើអ៊ីនធឺណេត។
- ធានាសុវត្ថិភាព និងមានហានិភ័យទាបទាំងចំពោះអតិថិជន និងពាណិជ្ជករដោយតាមរយៈការបង់ គឺនឹងមានការទូទាត់លុយចេញពីគណនីអតិថិជន ទៅកាន់គណនីពាណិជ្ជករភ្លាមៗផ្ទាល់តែម្តង។
- ជួយសម្រួលដល់ភាពលំបាក ស្មុគស្មាញ របស់អង្គភាពរដ្ឋ ដូចជា អង្គភាពអគ្គិសនី ក៏ដូចជារដ្ឋាករទឹកស្វយ័ត ក្នុងការប្រមូលនូវថ្លៃប្រើប្រាស់ សេវាកម្មរបស់អតិថិជនខ្លួន ជារៀងរាល់ខែ ដោយក្នុងនោះ គឺអនុញ្ញាតឲ្យអតិថិជនបង់តាមរយៈភ្នាក់ងារវីង និងងាយស្រួលនៅក្នុងការគ្រប់គ្រងសាច់ប្រាក់។
- កាត់បន្ថយការចាយក្រដាសប្រាក់ មិនមានការប៉ះពាល់នៃអត្រាឡើងចុះនៃរូបិយប័ណ្ណបរទេស។
- ទាក់ទាញអតិថិជនបរទេសអោយធ្វើប្រតិបត្តិការចាយទូទាត់ នៅក្នុងស្រុកកាន់តែច្រើន ដូចជាតាមរយៈម៉ាស្ទ័រ Pass QR Code ជាដើម ដែលធ្វើអោយការលក់ និងចំណូលប្រជាជន នៅក្នុងស្រុកមានការកើនឡើង។
- ធនាគារបានរួមចំណែកនៅក្នុងការអភិវឌ្ឍទៅលើវិស័យ FinTech (ហិរញ្ញវត្ថុបច្ចេកវិទ្យា) នៅក្នុងប្រទេសកម្ពុជាឲ្យមានភាពជឿនលឿន ទៅតាមប្រទេសអភិវឌ្ឍ និងមហាសេដ្ឋកិច្ចពិភពលោក ដូចជា ការដាក់ឲ្យប្រើប្រាស់ការទូទាត់តាមរយៈ QR Code ជាដើម។

## ៣.២. សេវាផ្ទេរប្រាក់

បង្កើតឡើងក្នុងឆ្នាំ ២០០៩ ធនាគារឯកទេសវីងបានចាប់ផ្តើមជាមួយនឹងសេវាកម្មផ្ទេរប្រាក់តាមរយៈទូរស័ព្ទដៃមុនគេបង្អស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ដោយសង្កេតឃើញពីសន្ទុះនៃការកើនឡើងនៃការប្រើប្រាស់សេវាកម្មនេះពីសំណាក់ប្រជាជនខ្មែរភាគច្រើន ធនាគារឯកទេសវីងក៏បានពង្រីកសេវាកម្មរបស់ខ្លួនដើម្បីផ្តល់ភាពងាយស្រួលដល់អតិថិជនរបស់ខ្លួន។ បច្ចុប្បន្ន សេវាផ្ទេរប្រាក់របស់ធនាគារឯកទេសវីងរួមមាន ២ប្រភេទធំៗ គឺ សេវាផ្ទេរប្រាក់ក្នុងប្រទេស និងសេវាផ្ទេរប្រាក់ក្រៅប្រទេស។

**៣.២.១. សេវាផ្ទេរប្រាក់ក្នុងប្រទេស**

សេវាផ្ទេរប្រាក់ក្នុងប្រទេស គឺជាដំណើរការនៃការផ្ទេរប្រាក់តាមរយៈគណនី (ករណីមានគណនីវីងប្រើប្រាស់) ឬលេខទូរស័ព្ទដៃ (ករណីគ្មានគណនីវីងប្រើប្រាស់) របស់អតិថិជន ដែលការផ្ទេរនោះសម្រាប់តែការផ្ទេរប្រាក់ទៅវិញទៅមកក្នុងប្រទេសកម្ពុជា។ ចំពោះប្រតិបត្តិការនៃការផ្ទេរប្រាក់ក្នុងប្រទេសរបស់ធនាគារឯកទេសវីង បានកំណត់យករូបិយប័ណ្ណពីរប្រភេទគឺ ប្រាក់រៀលខ្មែរ (KHR) និងប្រាក់ដុល្លារអាមេរិក (USD)។

ធនាគារឯកទេសវីង បានបង្កើតសេវាផ្ទេរប្រាក់ក្នុងប្រទេស ៤ ប្រភេទដូចខាងក្រោម៖

- សេវាផ្ទេរប្រាក់វីងទៅវីង (Wing To Wing)
- សេវាផ្ទេរប្រាក់វីងវេរលុយ (Wing Wei Luy)
- សេវាផ្ទេរប្រាក់វេរលុយអ៊ិចប្រេស (WeiLuy Xpress)
- សេវាផ្ទេរប្រាក់រវាងគណនីវីង និងធនាគារ (Wing to Bank and Bank to Wing)

**៣.២.១.១ សេវាផ្ទេរប្រាក់វីងទៅវីង** ( Wing To Wing )

សេវាផ្ទេរប្រាក់វីងទៅវីង គឺជាសេវាកម្មផ្ទេរប្រាក់តាមរយៈទូរស័ព្ទដៃលើកម្មវិធីស្មាតហ្វូនវីង (Wing Money Application) និង USSD ពីអ្នកដែលមានគណនីវីងទៅកាន់អ្នកដែលមានគណនីវីងមួយទៀត។ ប្រតិបត្តិការផ្ទេរប្រាក់ប្រភេទនេះអាចធ្វើទៅបាន លុះត្រាទាំងអ្នកផ្ញើប្រាក់ និងអ្នកទទួលប្រាក់មានគណនីវីងប្រើប្រាស់ដូចគ្នា។

**ក. នីតិវិធីនៃការប្រើប្រាស់សេវាផ្ទេរប្រាក់វីងទៅវីងតាម** USSD

ធនាគារឯកទេសវីងបានបង្កើតសេវាផ្ទេរប្រាក់វីងទៅវីងតាម USSD នេះឡើងដើម្បីបំពេញតម្រូវការដល់អតិថិជនប្រើប្រាស់ នៅពេលទូរស័ព្ទរបស់ពួកគេ គ្មានតំណភ្ជាប់អ៊ីនធឺណេត ឬនៅតំបន់ដាច់ស្រយាលមិនអាចប្រើអ៊ីនធឺណេតបាន។ អតិថិជនដែលមានគណនីវីងទាំងអស់អាចប្រើប្រាស់សេវាម្មផ្ទេរប្រាក់បែបនេះបាន ដោយគ្រាន់តែអនុវត្តតាមជំហានងាយៗដូចខាងក្រោមនេះ ៖

ជំហានទី ១ ៖ វាយលេខ *989# រួចចុចបញ្ជូន

ជំហានទី ២ ៖ ក្នុងករណីដែលអតិថិជនមានគណនីលើសពីមួយភ្ជាប់ជាមួយលេខទូរស័ព្ទតែមួយត្រូវបញ្ចូលលេខគណនីដែលខ្លួនចង់ផ្ទេរប្រាក់ចេញនោះឲ្យបានត្រឹមត្រូវ

ជំហានទី ៣ ៖ បញ្ចូលលេខ ២ (Wing-2-Wing) ដើម្បីប្រើប្រាស់សេវាផ្ទេរប្រាក់វីងទៅវីង

ជំហានទី ៤ ៖ បញ្ចូលលេខគណនីរបស់អ្នកទទួលឲ្យបានត្រឹមត្រូវ

ជំហានទី ៥ ៖ បញ្ចូលចំនួនទឹកប្រាក់ដែលចង់ផ្ទេរទៅ

ជំហានទី ៦ ៖ បញ្ចូលលេខសម្ងាត់ ៤ ខ្ទង់ (PIN)

**ខ. នីតិវិធីនៃការប្រើប្រាស់សេវាផ្ទេរប្រាក់វីងទៅវីងតាមកម្មវិធីស្មាតហ្វូនវីង**

រាល់អតិថិជនដែលមានគណនីវីងទាំងអស់ អាចប្រើសេវាផ្ទេរប្រាក់វីងទៅវីង បានតាមរយៈកម្មវិធីស្មាតហ្វូនវីង ដោយគ្រាន់តែទាញយកកម្មវិធីនេះ នៅលើកម្មវិធីដោនឡូតរបស់ទូរស័ព្ទ។ ការផ្ទេរប្រាក់ពីគណនីមួយទៅគណនីវីងមួយទៀត តាមកម្មវិធីស្មាតហ្វូនវីង គឺតម្រូវអោយមានអ៊ីនធឺណេតទើបអាចដំណើរការបាន។ នីតិវិធីនៃការប្រើប្រាស់មានដូចខាងក្រោម៖

ជំហានទី ១ ៖ ចូលទៅកាន់កម្មវិធីស្មាតហ្វូនវីង (Wing Money App)

ជំហានទី ២ ៖ ចុចលើប៊ូតុង "ផ្ទេរប្រាក់" ឬ "Transfer"

ជំហានទី ៣ ៖ ជ្រើសរើសលេខគណនី (បើអតិថិជនដែលមានគណនីចាប់ពី ២ ឡើងទៅ)

ជំហានទី ៤ ៖ ជ្រើសរើសប្រភេទនៃការផ្ទេរប្រាក់វីងទៅវីង (Wing to Wing)

ជំហានទី ៥ ៖ វាយលេខគណនីរបស់អ្នកទទួល

ជំហានទី ៥ ៖ បញ្ចូលចំនួនទឹកប្រាក់ ដែលចង់ផ្ទេរចេញ រួចចុចបញ្ជាក់ ហើយវាយលេខសម្ងាត់ PIN ៤ខ្ទង់។

**គ. ការយកថ្លៃសេវាផ្ទេរប្រាក់វីងទៅវីង**

ធនាគារឯកទេសវីងកំណត់យកថ្លៃសេវាកម្មវីងទៅវីងដូចខាងក្រោម៖

- បើសិនជាការផ្ទេរប្រាក់ចន្លោះពី ០ ដល់ ៤០០,០០០រៀល ធនាគារនឹងយកកម្រៃសេវាស្មើនឹង ៤០០រៀល។
- បើសិនជាការផ្ទេរប្រាក់ចន្លោះពី ៤០០,១០០ ដល់ ២,០០០,០០០រៀល ធនាគារនឹងយកកម្រៃ
- សេវាស្មើនឹង ៨០០រៀល។
- បើសិនជាការផ្ទេរប្រាក់ចន្លោះពី ២,០០០,០០០ ដល់ ៤,០០០,០០០រៀល ធនាគារនឹងយកកម្រៃ
- សេវាស្មើនឹង ១,២០០រៀល។

រាល់ថ្លៃសេវាកម្មផ្ទេរប្រាក់ពីគណនីវីងទៅវីង ធនាគារនឹងធ្វើការកាត់យកពីក្នុងគណនីរបស់អតិថិជនដែលជាអ្នកផ្ទេរប្រាក់ដោយស្វ័យប្រវត្តិ។

**៣.២.១.២ សេវាផ្ទេរប្រាក់វីងវេរលុយ** (Wing Wei Luy)

សេវាផ្ទេរប្រាក់វីងវេរលុយ គឺជាសេវាកម្មផ្ទេរប្រាក់តាមទូរស័ព្ទដៃ លើកម្មវិធីស្មាតហ្វូនវីង (Wing Money Application) និង USSD ដែលអនុញ្ញាតឲ្យអតិថិជនដែលមានគណនីវីងធ្វើការផ្ទេរប្រាក់ពីគណនីរបស់ខ្លួនទៅកាន់ អ្នកដែលគ្មានគណនីវីងបាន។ ល័ក្ខខ័ណ្ឌចាំបាច់នោះ គឺអ្នកផ្ញើ

ប្រាក់ត្រូវមានគណនីវីង ហើយអ្នកទទួលប្រាក់ ត្រូវមានលេខទូរស័ព្ទផ្ទាល់ខ្លួន។ នីតិវិធីនៃការប្រើប្រាស់សេវាផ្ទេរប្រាក់វីងវេរលុយអាចប្រព្រឹត្តទៅតាមកម្មវិធីស្មាតហ្វូនវីង (Wing Money) ឬ USSD បានដូចការផ្ទេរប្រាក់វីងទៅវីងដែរ។

**ក. នីតិវិធីនៃការប្រើប្រាស់សេវាផ្ទេរប្រាក់វីងវេរលុយតាម** USSD

សម្រាប់អ្នកមានគណនីវីងដែលចង់ផ្ទេរប្រាក់ឲ្យទៅអ្នកដែលគ្មានគណនីវីងអាចជ្រើសរើសវិធីផ្ទេរប្រាក់វីងវេរលុយតាម USSD បាន ដូចខាងក្រោម៖

ជំហានទី ១ ៖ វាយលេខ *989# រួចចុចបញ្ជូន

ជំហានទី ២ ៖ ក្នុងករណីដែល អតិថិជនមានគណនី លើសពីមួយ ភ្ជាប់ជាមួយលេខទូរស័ព្ទតែមួយ ត្រូវបញ្ចូលលេខគណនីដែលខ្លួនចង់ផ្ទេរប្រាក់ចេញនោះឲ្យបានត្រឹមត្រូវ

ជំហានទី ៣ ៖ ជ្រើសរើសលេខ ៤ (Wing WeiLuy) ដើម្បីប្រើប្រាស់សេវាផ្ទេរប្រាក់វីងវេរលុយ

ជំហានទី ៤ ៖ បញ្ចូលលេខទូរស័ព្ទដៃរបស់អ្នកទទួលប្រាក់

ជំហានទី ៥ ៖ បញ្ចូលចំនួនទឹកប្រាក់ដែលចង់ផ្ទេរចេញ រួចចុចបញ្ជាក់ ហើយវាយលេខសំងាត់ PIN ៤ខ្ទង់។

**ខ. នីតិវិធីនៃការប្រើប្រាស់សេវាផ្ទេរប្រាក់វីងវេរលុយតាមកម្មវិធីស្មាតហ្វូនវីង**

នីតិវិធីនៃការផ្ទេរប្រាក់វីងវេរលុយ តាមកម្មវិធីស្មាតហ្វូនវីងស្រដៀងគ្នា ទៅនឹងការផ្ទេរប្រាក់វីងទៅវីងតាមកម្មវិធីស្មាតហ្វូនវីងដែរ គ្រាន់តែការជ្រើសរើសប្រភេទនៃការផ្ទេរខុសគ្នា។ ខាងក្រោមនេះជាជំហាននៃការប្រើប្រាស់សេវាកម្មនេះ៖

ជំហានទី ១ ៖ ចូលទៅកាន់កម្មវិធីស្មាតហ្វូនវីង (Wing Money App)

ជំហានទី ២ ៖ ចុចលើប៊ូតុង "ផ្ទេរប្រាក់" ឬ "Transfer"

ជំហានទី ៣ ៖ ជ្រើសរើសលេខគណនី (ករណីអតិថិជនមានគណនីចាប់ពី ២ ឡើងទៅ)

ជំហានទី ៤ ៖ ជ្រើសរើសប្រភេទនៃការផ្ទេរប្រាក់វីងវេរលុយ (Wing WeiLuy)

ជំហានទី ៥ ៖ វាយលេខទូរស័ព្ទដៃរបស់អ្នកទទួលប្រាក់

ជំហានទី ៦ ៖ បញ្ចូលចំនួនទឹកប្រាក់ដែលចង់ផ្ទេរចេញ រួចចុចបញ្ជាក់ ហើយវាយលេខសំងាត់ ៤ ខ្ទង់ជាការស្រេច។

**គ. ការយកថ្លៃសេវាផ្ទេរប្រាក់វីងវេរលុយ**

ធនាគារឯកទេសវីងកំណត់យកថ្លៃសេវាកម្មវីងវេរលុយដូចខាងក្រោម៖

- បើសិនជាការផ្ទេរប្រាក់ចន្លោះពី ០ ដល់ ១០០,០០០រៀល ធនាគារនឹងយកកម្រៃសេវាស្មើនឹង ១,៥០០រៀល។
- បើសិនជាការផ្ទេរប្រាក់ចន្លោះពី ១០០,១០០ ដល់ ២០០,០០០រៀល ធនាគារនឹងយកកម្រៃសេវាស្មើនឹង ៣,០០០រៀល។
- បើសិនជាការផ្ទេរប្រាក់ចន្លោះពី ២០០,១០០ ដល់ ៤០០,០០០រៀល ធនាគារនឹងយកកម្រៃសេវាស្មើនឹង ៤,០០០រៀល។
- បើសិនជាការផ្ទេរប្រាក់ចន្លោះពី ៤០០,១០០ ដល់ ២,០០០,០០០រៀល ធនាគារនឹងយកកម្រៃសេវាស្មើនឹង ៦,០០០រៀល។
- បើសិនជាការផ្ទេរប្រាក់ចន្លោះពី ២,០០០,១០០ ដល់ ៤,០០០,០០០រៀល ធនាគារនឹងយកកម្រៃសេវាស្មើនឹង ៨,០០០រៀល។

រាល់ថ្លៃសេវាកម្មផ្ទេរប្រាក់ពីគណនីវីងវេរលុយ ធនាគារនឹងធ្វើការកាត់យកពីក្នុងគណនីរបស់អតិថិជនដែលជាអ្នកផ្ទេរប្រាក់ដោយស្វ័យប្រវត្តិ។

**បញ្ជាក់** ៖ រាល់ប្រតិបត្តិការផ្ទេរវីងទៅវីង ឬវីងវេរលុយនឹងជោគជ័យភ្លាមៗ បន្ទាប់ពីបញ្ចូលលេខសម្ងាត់ ៤ ខ្ទង់រួចដោយអ្នកផ្ញើប្រាក់នឹងទទួលបានសារបញ្ជាក់ ពីប្រតិបត្តិការផ្ទេរប្រាក់ជោគជ័យពីវីង ដោយមានបង្ហាញពីឈ្មោះអ្នកទទួល លេខគណនី ចំនួនទឹកប្រាក់ ថ្លៃប្រតិបត្តិការ និងសមតុល្យទឹកប្រាក់ដែលនៅសល់របស់ខ្លួន។ វីង អ្នកទទួលប្រាក់ក៏ទទួលបានសារទទួលប្រាក់ដូចគ្នា ដែលសារនោះនឹងបង្ហាញពីឈ្មោះអ្នកផ្ញើ ចំនួនទឹកប្រាក់ដែលទទួលបាន និងសមតុល្យទឹកប្រាក់ដែលមានផងដែរ។ ជាទូទៅ ថ្លៃចំណាយប្រតិបត្តិការ គឺតម្រូវឲ្យអ្នកផ្ញើប្រាក់ជាអ្នកទូទាត់រាល់ពេលពួកគេធ្វើប្រតិបត្តិការដោយទូទាត់ពីគណនីនោះផ្ទាល់តែម្តង។

**សម្គាល់** ៖ អតិថិជនវីងអាចមានគណនីច្រើនរហូតដល់ទៅ ៨ គណនី អាស្រ័យតម្រូវការចាំបាច់របស់ខ្លួន។ ជាទូទៅ អតិថិជនម្នាក់មានគណនី ២ គឺគណនីដែលមានរូបិយប័ណ្ណប្រាក់រៀល និងគណនីដែលមាន រូបិយប័ណ្ណប្រាក់ដុល្លារអាមេរិក ដើម្បីងាយស្រួលក្នុងការប្រើប្រាស់។ ចំពោះប្រភេទរូបិយប័ណ្ណដែលផ្ទេរចេញ គឺត្រូវបានផ្លាស់ប្តូរដោយស្វ័យប្រវត្តិតាមរូបិយប័ណ្ណរបស់គណនីវីងរបស់អ្នកទទួល។ ដូចនេះ នៅពេលអតិថិជនផ្ញើទៅគណនីដែលមានប្រភេទរូបិយប័ណ្ណខុសពីប្រភេទរូបិយប័ណ្ណគណនីរបស់ខ្លួន ធនាគារឯកទេសវីងនឹងធ្វើការផ្លាស់ប្តូររូបិយប័ណ្ណទៅតាមអត្រាប្តូរប្រាក់នៅថ្ងៃធ្វើប្រតិបត្តិការដោយស្វ័យប្រវត្តិតែម្តង។

**៣.២.១.៣ សេវាផ្ទេរប្រាក់វេរលុយអ៊ិចប្រេស** (WeiLuy Xpress)

សេវាផ្ទេរប្រាក់វេរលុយអ៊ិចប្រេស គឺជាសេវាកម្មផ្ទេរប្រាក់តាមរយៈភ្នាក់ងាររីង (Wing Cash Xpress) ដែលអនុញ្ញាតឲ្យអ្នកដែលមិនមានគណនីវីងទាំងអ្នកផ្ញើ និងអ្នកទទួល អាចផ្ញើប្រាក់បានយ៉ាងងាយស្រួលជាមួយភ្នាក់ងាររីងដែលមានច្រើនជាង ៦,០០០ កន្លែងនៅទូទាំងប្រទេស។ សេវាកម្មនេះជាសេវាកម្មនាំមុខ និងដំបូងគេបង្អស់ដែលវីងចាប់បើកដំណើរការ។ ចំពោះ ប្រតិបត្តិការផ្ទេរប្រាក់នេះប្រព្រឹត្តទៅតាមរយៈភ្នាក់ងាររីង ហើយអតិថិជនដែលជាអ្នកផ្ញើ និងអ្នកទទួលប្រើប្រាស់លេខទូរស័ព្ទដៃរបស់ខ្លួនដើម្បីធ្វើប្រតិបត្តិការផ្ទេរប្រាក់វេរលុយអ៊ិចប្រេសបាន។

**ក. នីតិវិធីនៃការផ្ទេរប្រាក់តាមភ្នាក់ងាររីង**

អតិថិជនដែលមានតម្រូវការផ្ទេរប្រាក់ក្នុងស្រុកដោយប្រើប្រាស់សេវាផ្ទេរប្រាក់វេរលុយអ៊ិចប្រេស ត្រូវអនុវត្តតាមរបៀបផ្ញើប្រាក់ដូចខាងក្រោមនេះ៖

ជំហានទី ១ ៖ អញ្ជើញទៅកាន់ភ្នាក់ងាររីងណាមួយដែលនៅជិតលោកអ្នកបំផុត

ជំហានទី ២ ៖ បន្ទាប់មកអតិថិជនត្រូវបំពេញនូវទម្រង់បែបបទដើម្បីផ្ទេរប្រាក់ (Send Money Form) ដែលរួមមានព័ត៌មានដូចខាងក្រោម៖

- ចំនួនទឹកប្រាក់ដែលចង់ផ្ទេរ
- លេខទូរស័ព្ទរបស់អ្នកផ្ញើប្រាក់
- លេខទូរស័ព្ទរបស់អ្នកទទួលផល (អ្នកទទួលប្រាក់)

ជំហានទី ៣ ៖ អតិថិជនត្រូវប្រគល់ទឹកប្រាក់ដែលត្រូវផ្ទេរឲ្យទៅភ្នាក់ងាររីងឲ្យបានគ្រប់ចំនួន រួមបញ្ចូលទាំងថ្លៃសេវាកម្មផ្ទេរប្រាក់

ជំហានទី ៤ ៖ ភ្នាក់ងាររីងនឹងចេញក្រដាសបញ្ជាក់ពីការផ្ទេរប្រាក់ឲ្យទៅអតិថិជន

បញ្ជាក់ ៖ នៅលើក្រដាសបញ្ជាក់ពីការផ្ទេរប្រាក់នោះបង្ហាញពី លេខទូរស័ព្ទអ្នកផ្ញើ លេខទូរស័ព្ទអ្នកទទួលលេខកូដសម្ងាត់ ៨ខ្ទង់ ចំនួនទឹកប្រាក់ផ្ទេរ តម្លៃសេវាកម្ម និងទឹកប្រាក់សរុបដែលត្រូវទូទាត់។

ជំហានទី ៥ ៖ អតិថិជនចាំបាច់ផ្តល់លេខកូដសម្ងាត់ ៨ ខ្ទង់ និងលេខទូរស័ព្ទសម្រាប់ទទួលប្រាក់នោះទៅកាន់អ្នកទទួលដើម្បីធ្វើការដកប្រាក់ពីភ្នាក់វីង។

**ខ. នីតិវិធីនៃការទទួលប្រាក់តាមភ្នាក់ងាររីង**

ក្រោយពីទទួលបានលេខកូដសម្ងាត់៨ ខ្ទង់រួច អ្នកទទួលប្រាក់អាចទៅដកប្រាក់នោះបានភ្លាមៗ ដោយគ្រាន់តែអនុវត្តតាមនីតិវិធីនៃការទទួលប្រាក់ដូចខាងក្រោម៖

ជំហានទី ១ ៖ យកលេខកូដសម្ងាត់ ៨ខ្ទង់ និងលេខទូរស័ព្ទសម្រាប់ទទួលទៅកាន់ភ្នាក់ងាររីងដែលនៅជិតបំផុត

ជំហានទី ២ ៖ ប្រាប់ភ្នាក់ងាររីងថាអ្នកត្រូវការដកប្រាក់

ជំហានទី ៣ ៖ អតិថិជនត្រូវបង្ហាញលេខទូរស័ព្ទរបស់ខ្លួនឲ្យទៅភ្នាក់ងាររីងពិនិត្យ និងបញ្ជាក់ដើម្បីប្រាកដថាលេខទូរស័ព្ទរបស់អ្នកជាលេខទូរស័ព្ទអ្នកទទួលពិតប្រាកដ។

ជំហានទី ៤ ៖ ត្រូវបង្ហាញលេខសម្ងាត់ ៨ខ្ទង់នោះឲ្យទៅភ្នាក់ងាររីង

ជំហានទី ៥ ៖ ភ្នាក់ងាររីងនឹងចេញក្រដាសបញ្ជាក់ពីការដកប្រាក់ និងទឹកប្រាក់នោះឲ្យមកអតិថិជន

ជំហានទី ៥ ៖ អតិថិជនទទួលក្រដាសបញ្ជាក់ពីការដកប្រាក់ និងទឹកប្រាក់ទាំងនោះ (អតិថិជនត្រូវពិនិត្យ និងរាប់ប្រាក់នោះឲ្យបានត្រឹមត្រូវ គ្រប់ចំនួនមុននឹងចាកចេញពីកន្លែងភ្នាក់ងារផ្ទេរប្រាក់។

ដើម្បីបញ្ជាក់ពីលេខទូរស័ព្ទ ជាលេខអ្នកទទួលពិតប្រាកដនោះ អតិថិជនចាំបាច់ត្រូវប្រគល់ទូរស័ព្ទរបស់ខ្លួនឲ្យភ្នាក់ងារពិនិត្យមើល។ ករណីលេខទូរស័ព្ទនោះ គឺមិនមែនជាលេខអ្នកទទួលភ្នាក់ងាររីងនឹងមិនធ្វើការដកប្រាក់នោះឲ្យអតិថិជនឡើយ។

**គ. ការយកថ្លៃសេវាផ្ទេរប្រាក់វេរលុយអ៊ិចប្រេស**

ធនាគារឯកទេសរីងកំណត់យកថ្លៃសេវាកម្មវេរលុយអ៊ិចប្រេសដូចខាងក្រោម៖

- បើសិនជាការផ្ទេរប្រាក់ចន្លោះពី ០ ដល់ ១០០,០០០រៀល ធនាគារនឹងយកកម្រៃសេវាស្មើនឹង ១,៥០០រៀល។
- បើសិនជាការផ្ទេរប្រាក់ចន្លោះពី ១០០,១០០ ដល់ ២០០,០០០រៀល ធនាគារនឹងយកកម្រៃសេវាស្មើនឹង ៣,០០០រៀល។
- បើសិនជាការផ្ទេរប្រាក់ចន្លោះពី ២០០,១០០ ដល់ ៤០០,០០០រៀល ធនាគារនឹងយកកម្រៃសេវាស្មើនឹង ៤,០០០រៀល។
- បើសិនជាការផ្ទេរប្រាក់ចន្លោះពី ៤០០,១០០ ដល់ ២,០០០,០០០រៀល ធនាគារនឹងយកកម្រៃសេវាស្មើនឹង ៦,០០០រៀល។
- បើសិនជាការផ្ទេរប្រាក់ចន្លោះពី ២,០០០,១០០ ដល់ ៤,០០០,០០០រៀល ធនាគារនឹងយកកម្រៃសេវាស្មើនឹង ១០,០០០រៀល។

ចំពោះការផ្ទេរប្រាក់តាមភ្នាក់ងាររីង រាល់ថ្លៃសេវាកម្មផ្ទេរប្រាក់ នឹងធ្វើការទូទាត់ជាមួយអតិថិជនដែលជាអ្នកផ្ទេរប្រាក់។

ដ្យាក្រាមទី១ ៖ ដ្យាក្រាមសង្ខេបនៃប្រតិបត្តិការផ្ទេរប្រាក់វេរលុយអ៊ិចប្រេសរបស់ធនាគារឯកទេសវីង




### ៣.២.១.៤ សេវាផ្ទេរប្រាក់រវាងគណនីវីង និងធនាគារ ( Wing to Bank and Bank to Wing )

ក្រៅពីប្រភេទសេវាផ្ទេរប្រាក់ទាំង ៣ ខាងលើ ធនាគារឯកទេសវីងក៏មានប្រភេទសេវាផ្ទេរប្រាក់មួយទៀតដែលអតិថិជនអាចធ្វើការប្រើប្រាស់នៅលើកម្មវិធីស្មាតហ្វូនវីងបាន ដែលមានដូចខាងក្រោម៖

- សេវាផ្ទេរប្រាក់ពីគណនីវីងទៅធនាគារ (Wing to Bank) គឺជាសេវាផ្ទេរប្រាក់ដែលអ្នកមានគណនីវីងអាចផ្ទេរប្រាក់ពីគណនីរបស់ខ្លួនទៅគណនីធនាគារ។ បច្ចុប្បន្ននេះ សេវាមួយនេះអាចផ្ទេរទៅធនាគារដែលជាដៃគូសហការចំនួន ៤ ប៉ុណ្ណោះរួមមាន៖ ធនាគារស្ថាបនា ធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា ធនាគារគ្រូបមីនកម្ពុជា និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត។
- សេវាផ្ទេរប្រាក់ពីគណនីធនាគារទៅគណនីវីង (Bank to Wing) ចំពោះសេវាកម្មផ្ទេរប្រាក់ពីគណនីធនាគារចូលគណនីវីង គឺអាចផ្ទេរបានចំពោះតែគណនី នៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹតតែប៉ុណ្ណោះ។

### ៣.២.១.៥ អត្ថប្រយោជន៍សេវាផ្ទេរប្រាក់ក្នុងស្រុក

ក្រៅពីគោលបំណងស្វែងរកចំណេញឲ្យបានអតិបរមា ធនាគារឯកទេសវីង បានបង្កើត និងអភិវឌ្ឍន៍នូវសេវាកម្មផ្ទេរប្រាក់របស់ខ្លួនឡើង គឺដើម្បីបំពេញតម្រូវការចាំបាច់របស់ប្រជាជនកម្ពុជាឲ្យកាន់តែមានភាពល្អប្រសើរឡើង។ ជាក់ស្តែង សេវាផ្ទេរប្រាក់ក្នុងស្រុកជាច្រើនប្រភេទរបស់

ធនាគារឯកទេសវីង បានផ្តល់នូវអត្ថប្រយោជន៍ជាច្រើនសម្រាប់អតិថិជន ដែលជាអ្នកប្រើប្រាស់ដូចជា ៖

- ផ្តល់ភាពងាយស្រួលដល់អតិថិជនទូទៅក្នុងការប្រើប្រាស់សេវាផ្ទេរប្រាក់ ដោយមិនចាំបាច់មានគណនីវីង ឬពុំមានគណនីនៅធនាគារណាមួយក្នុងប្រទេសកម្ពុជា ព្រោះការផ្ទេរប្រាក់របស់ធនាគារឯកទេសវីងអាចធ្វើឡើងតាមរយៈលេខទូរស័ព្ទដៃផ្ទាល់របស់អតិថិជន។
- អតិថិជន អាចធ្វើការផ្ទេរប្រាក់នៅក្នុងស្រុកតាមរយៈ សេវាផ្ទេរប្រាក់វេរលុយអ៊ិចប្រេសដែលធ្វើឡើងជាមួយនឹងភ្នាក់ងារវីងដែលមានជាង ៦,០០០ ភ្នាក់ងារ គ្របដណ្តប់ទូទាំងប្រទេស ដែលជាហេតុធ្វើឲ្យមានភាពងាយស្រួលក្នុងការផ្ទេរប្រាក់បានគ្រប់ពេលវេលា និងគ្រប់ទីកន្លែង។
- ការផ្ទេរប្រាក់របស់ធនាគារឯកទេសវីងមានភាពលឿនរហ័សទាន់ចិត្ត ដែលអ្នកទទួលប្រាក់អាចទៅបើកប្រាក់បានភ្លាមៗ បន្ទាប់ពីការផ្ទេរប្រាក់ត្រូវបានដំណើរការ និងទទួលបានលេខកូដសម្ងាត់ ៨ខ្ទង់។
- សេវាកម្មផ្ញើប្រាក់របស់ធនាគារឯកទេសវីងមានតម្លៃសមរម្យសម្រាប់ប្រជាជនកម្ពុជា ជាក់ស្តែងដូចជា សេវាផ្ទេរប្រាក់វីងទៅវីងដែលចំណាយត្រឹមតែ ៥០០ រៀល ប៉ុណ្ណោះក្នុងមួយប្រតិបត្តិការ។ រីឯ សេវាផ្ទេរប្រាក់វេរលុយអ៊ិចប្រេស គឺមានតម្លៃចាប់ពី ១,៥០០ រៀលឡើងទៅ។
- ជាមួយនឹងការប្រើប្រាស់កម្មវិធីស្មាតហ្វូនវីង អតិថិជនដែលមានគណនីវីង អាចធ្វើការផ្ទេរប្រាក់ទៅកាន់អ្នកដែលគ្មានគណនីវីង តាមរយៈលេខទូរស័ព្ទដៃជាមួយនឹងតម្លៃសមរម្យ គឺមានតម្លៃចាប់ពី ១,៥០០ រៀល ដូចគ្នាទៅនឹងការផ្ទេរប្រាក់តាមភ្នាក់ងារវីងដែរ។ អត្ថប្រយោជន៍នេះ នឹងអាចឲ្យអតិថិជនសន្សំសំចៃប្រាក់បានច្រើន។
- អតិថិជនអាចធ្វើការផ្ទេរប្រាក់ពីគណនីរបស់ធនាគារមួយផ្សេងទៀត ចូលក្នុងគណនីវីង ឬធ្វើការផ្ទេរប្រាក់ចេញទៅកាន់នរណាម្នាក់ ដែលមានគណនីនៅធនាគារផ្សេងដែលជាដៃគូរបស់វីង ដូចជាធនាគារស្ថាបនាជាដើម តាមរយៈកម្មវិធីស្មាតហ្វូនវីង ដោយមិនចាំបាច់ទៅធនាគារផ្ទាល់។
- ជួយសម្រួលដល់អាជីវកម្មធំៗ ដែលត្រូវការបង្វិលសាច់ប្រាក់ច្រើនៗ ពីអ្នកលក់ទៅអ្នកទិញ តាមរយៈការផ្ទេរប្រាក់ចូលគណនីវីង។
- ចូលរួមកាត់បន្ថយហានិភ័យនៃការលួច ឬបាត់លុយតាមរយៈការផ្ញើរប្រាក់តាមឡាន ឬផ្ញើប្រាក់តាមបុគ្គល មកជាការផ្ញើប្រាក់តាមទូរស័ព្ទដៃដែលអាចរក្សាសាច់ប្រាក់គ្រប់ចំនួនដល់អ្នកទទួល។ វីងមិនត្រឹមតែបានផ្តល់សេវាផ្ទេរប្រាក់លឿន និងងាយស្រួលប៉ុណ្ណោះទេ ថែមទាំងផ្តល់ការផ្ទេរប្រាក់ដែលមានសុវត្ថិភាពអាចទទួលបានការជឿទុកចិត្តពីអតិថិជនរបស់ខ្លួនថែមទៀត។

**៣.២.២. សេវាផ្ទេរប្រាក់ក្រៅប្រទេស** ( Wing to World )

សេវាផ្ទេរប្រាក់ក្រៅប្រទេសរបស់ ធនាគារឯកទេសវីង ត្រូវបានបង្កើតឡើងនៅដើមឆ្នាំ ២០១៨ ដែលអាចផ្ទេរប្រាក់ទៅក្រៅប្រទេស ឬទទួលប្រាក់ពីបរទេសរហូតដល់ទៅជាង ២០០ ប្រទេសនៅលើពិភពលោកបានយ៉ាងរហ័ស និងមានសុវត្ថិភាព។ ដើម្បីផ្តល់ជាជម្រើសនៃការផ្ទេរប្រាក់ក្រៅប្រទេស ធនាគារឯកទេសវីងបានសហការជាមួយដៃគូក្រៅប្រទេស និងបានប្រើប្រាស់នូវប្រព័ន្ធផ្ទេរប្រាក់អន្តរជាតិជាច្រើន។

**៣.២.២.១ នីតិវិធីនៃការផ្ទេរប្រាក់ទៅក្រៅប្រទេស**

តាមរយៈសេវាផ្ទេរប្រាក់អន្តរជាតិរបស់វីង (Wing2World) អតិថិជនអាចធ្វើការផ្ទេរប្រាក់ទៅក្រៅប្រទេសបានយ៉ាងងាយស្រួលតាមរយៈធនាគារឯកទេសវីង ដែលអាចឲ្យអតិថិជនផ្ទេរប្រាក់ទៅជាង ២០០ប្រទេសនៅទូទាំងពិភពលោកជាមួយនឹងដៃគូសហការក្រៅប្រទេសរបស់វីង។ នីតិវិធីនៃការផ្ទេរប្រាក់ទៅក្រៅប្រទេសប្រព្រឹត្តទៅខុសៗគ្នា តាមប្រទេសនីមួយៗ ដូចជាការផ្ទេរតាមប្រព័ន្ធ Western Union ឬតាមប្រព័ន្ធផ្សេងទៀត ដូចជា ការផ្ទេរទៅកាន់ប្រទេសហ្វីលីពីន ប្រទេសវៀតណាម និងប្រទេសថៃជាដើម។

**ក. ការផ្ទេរប្រាក់ចេញតាមប្រព័ន្ធ** Western Union

Western Union គឺជាប្រព័ន្ធផ្ទេរប្រាក់មួយដែលធនាគារឯកទេសវីងបានចាប់ផ្តើមប្រើប្រាស់ដើម្បីធ្វើប្រតិបត្តិការផ្ទេរប្រាក់ទៅក្រៅប្រទេសចាប់តាំងពីឆ្នាំ ២០១៨។ បច្ចុប្បន្ននេះ អតិថិជនអាចផ្ទេរប្រាក់ទៅជាង ២០០ ប្រទេសតាមរយៈវីងដោយផ្ញើប្រាក់ទៅកាន់សាខារបស់ Western Union នៅក្រៅប្រទេស តាមរយៈកម្មវិធីស្មាតហ្វូតវីង។ អតិថិជន អាចធ្វើការផ្ទេរប្រាក់ដោយប្រើប្រាស់លើកម្មវិធី Wing Money App និងត្រូវតែមានគណនីវីងដែលមានសមតុល្យសាច់ប្រាក់គ្រប់គ្រាន់ ដើម្បីធ្វើការផ្ទេរប្រាក់បាន។

**របៀបនៃការផ្ទេរប្រាក់ដោយប្រើកម្មវិធី Wing Money App**

ជំហានទី ១ ៖ ចូលទៅកាន់កម្មវិធីស្មាតហ្វូនវីង (Wing Money App)

ជំហានទី ២ ៖ ចុចលើប៊ូតុង "ផ្ទេរប្រាក់" ឬ "Transfer"

ជំហានទី ៣ ៖ ជ្រើសរើសប្រភេទនៃការផ្ទេរប្រាក់ទៅក្រៅប្រទេស (Wing to World)

ជំហានទី ៤ ៖ ជ្រើសរើសលេខគណនី (បើអតិថិជនដែលមានគណនីចាប់ពី ២ ឡើងទៅ)

ជំហានទី ៥ ៖ ជ្រើសរើសឈ្មោះប្រទេសដែលចង់ផ្ទេរទៅ និងដៃគូផ្ទេរប្រាក់ (Western Union) សម្រាប់ប្រទេសនោះ

ជំហានទី ៥ ៖ បំពេញព័ត៌មានចាំបាច់ដែលមានដូចជា ប្រភេទរូបិយប័ណ្ណ ប្រភេទសេវាកម្ម ចំនួនប្រាក់ដែលផ្ទេរ ព័ត៌មានរបស់អ្នកផ្ញើ (មុខរបរ ប្រទេសដែលចេញអត្តសញ្ញាណប័ណ្ណ អាសយដ្ឋាន លេខកូដប្រៃសណីយ ប្រភពថវិកា) ព័ត៌មានរបស់អ្នកទទួល (ឈ្មោះ ថ្ងៃខែឆ្នាំកំណើត សញ្ជាតិ) និងគោលបំណងនៃការផ្ទេរប្រាក់ រួចចុចបញ្ជូន និងវាយលេខសំងាត់ ៤ខ្ទង់ជាការស្រេច។

**បញ្ជាក់** ៖ កម្រិតចំនួនទឹកប្រាក់ដែលអាចផ្ទេរបានប្រចាំថ្ងៃ គឺ ១,០០០ ដុល្លារក្នុងមួយប្រតិបត្តិការ និងអាចផ្ទេរបានត្រឹម ៥,០០០ ដុល្លារក្នុងមួយថ្ងៃ។

**តម្លៃសេវាកម្មនៃការផ្ទេរចេញតាមប្រព័ន្ធ Western Union**

តម្លៃសេវាធម្មតា ជាតម្លៃសម្រាប់ការផ្ទេរទៅបណ្តាប្រទេសជាង ២០០ ប្រទេស។

តារាងទី២ ៖ តម្លៃសេវាកម្មនៃការផ្ទេរចេញតាមប្រព័ន្ធ Western Union

| **ចំនួនទឹកប្រាក់ផ្ទេរចេញ (USD)** | **ថ្លៃសេវាកម្ម (USD)** |
|---|---|
| ០ ទៅ ១០០ | ១៥ |
| ១០០.០១ ទៅ ២០០ | ២២ |
| ២០០.០១ ទៅ ៣០០ | ២៩ |
| ៣០០.០១ ទៅ ៤០០ | ៣៤ |
| ៤០០.០១ ទៅ ៥០០ | ៤១ |
| ៥០០.០១ ទៅ ៦២៥ | ៤៦ |
| ៦២៥.០១ ទៅ ៧៥០ | ៤៧ |
| ៧៥០.០១ ទៅ ១០០០.០០ | ៥២ |
| ១,០០០.០១ ទៅ ១,៥០០.០០ | ៦៧ |
| ១,៥០០.០១ ទៅ ១,៧៥០.០០ | ៧៨ |
| ១,៧៥០.០១ ទៅ ២,០០០.០០ | ៩១ |
| ២,០០០.០១ ទៅ ២,៥០០.០០ | ១១១ |
| ២,៥០០.០១ ទៅ ៣,០០០.០០ | ១៣១ |
| ៣,០០០.០១ ទៅ ៣,៥០០.០០ | ១៥១ |

ប្រភព៖ https://www.wingmoney.com/en/wing2world/

តម្លៃសេវាពិសេស គឺជាតម្លៃកំណត់ពិសេសសម្រាប់តែការផ្ទេរប្រាក់តាមប្រព័ន្ធ Western Union ទៅកាន់ប្រទេសមួយចំនួនដូចជា ប្រទេសវៀតណាម ប្រទេសហ្វីលីពីន ប្រទេសចិន និង ប្រទេសមីយ៉ាន់ម៉ា តែប៉ុណ្ណោះ។

**ប្រទេសវៀតណាម**

តារាងទី៣ ៖ តម្លៃសេវាកម្មនៃការផ្ទេរចេញទៅប្រទេសវៀតណាម

| ចំនួនទឹកប្រាក់ដែលផ្ទេរចេញ (USD) | ថ្លៃសេវាកម្ម (USD) |
|---|---|
| ០ ទៅ ៣០០ | ៥ |
| ៣០០.០១ ទៅ ៥០០ | ៨ |
| ៥០០.០១ទៅ ១,០០០.០០ | ១០ |
| ១,០០០.០១ ទៅ ២,០០០.០០ | ២១ |
| ២,០០០.០១ ទៅ ៤,០០០.០០ | ២៦ |
| ៤,០០០.០១ ទៅ ៥,០០០.០០ | ៣១ |
| ៥,០០០.០១ ទៅ ៦,០០០.០០ | ៣៦ |
| ៦,០០០.០១ ទៅ ៧,០០០.០០ | ៤១ |
| ៧,០០០.០១ ទៅ ៨,០០០.០០ | ៤៦ |
| ៨,០០០.០១ ទៅ ៩,០០០.០០ | ៥១ |
| ៩,០០០.០១ ទៅ ១០,០០០.០១ | ៥៦ |

ប្រភព៖ https://www.wingmoney.com/en/wing2world/

**ប្រទេសហ្វីលីពីន**

តារាងទី៤ ៖ តម្លៃសេវាកម្មនៃការផ្ទេរចេញទៅប្រទេសហ្វីលីពីន

| ចំនួនទឹកប្រាក់ដែលផ្ទេរចេញ (ដុល្លារអាមេរិច USD) | ថ្លៃសេវាកម្ម (ដុល្លារអាមេរិច USD) |
|---|---|
| ០ ទៅ ៦០០.០០ | ៨ |
| ៦០០.០១ ទៅ ២,០០០.០០ | ២៥ |
| ចាប់ពី ២,០០០.០១ ឡើងទៅ | ៨០ |

ប្រភព៖ https://www.wingmoney.com/en/wing2world/

**ប្រទេសចិន**

តារាងទី៥ ៖ តម្លៃសេវាកម្មនៃការផ្ទេរចេញទៅប្រទេសចិន

| ចំនួនទឹកប្រាក់ដែលផ្ទេរចេញ (ដុល្លារអាមេរិច USD) | ថ្លៃសេវាកម្ម (ដុល្លារអាមេរិច USD) |
|---|---|
| ០ ទៅ ៣,០០០.០០ | ១២.០៨ |
| ចាប់ពី ៣,០០០.០១ ឡើងទៅ | ២២ |

ប្រភព៖ https://www.wingmoney.com/en/wing2world/

**ប្រទេសមីយ៉ាន់ម៉ា**

តារាងទី៦ ៖ តម្លៃសេវាកម្មនៃការផ្ទេរចេញទៅប្រទេសមីយ៉ាន់ម៉ា

| ចំនួនទឹកប្រាក់ដែលផ្ទេរចេញ (ដុល្លារអាមេរិច USD) | ថ្លៃសេវាកម្ម (ដុល្លារអាមេរិច USD) |
|---|---|
| ០ ទៅ ១,០០០.០០ | ១០ |
| ចាប់ពី ១,០០០.០១ ឡើងទៅ | ១% នៃចំនួនទឹកប្រាក់ដែលផ្ទេរចេញ |

ប្រភព៖ https://www.wingmoney.com/en/wing2world/

ដ្យាក្រាមទី២ ៖ ដ្យាក្រាមសង្ខេបនៃប្រតិបត្តិការផ្ទេរប្រាក់ទៅក្រៅប្រទេសតាម Western Union



**ខ. ការផ្ទេរប្រាក់ចេញតាមប្រព័ន្ធផ្សេងៗទៀត**

ចំពោះប្រទេសជិតខាងមួយចំនួន ដូចជាប្រទេសហ្វីលីពីន ប្រទេសវៀតណាម និងប្រទេសថៃជាដើម ធនាគារឯកទេសរីង បានផ្តល់នូវជម្រើសផ្ទេរប្រាក់ផ្សេងៗទៀត ដែលជាដៃគូសហការរបស់រីងដែលមានដំណើរការនៃការផ្ទេរប្រាក់ខុសៗគ្នាតាមប្រទេសនីមួយៗ។

**ខ.១ ការផ្ទេរប្រាក់ទៅប្រទេសហ្វីលីពីន**

ធនាគារឯកទេសរីង បានសហការជាមួយដៃគូ នៅប្រទេសហ្វីលីពីនក្នុងការផ្តល់នូវសេវាផ្ទេរប្រាក់ដែលអាចឲ្យអតិថិជន ជាពិសេសប្រជាជនហ្វីលីពីនដែលរស់នៅ ប្រទេសកម្ពុជាអាចផ្ញើប្រាក់តាមរយៈកម្មវិធីស្មាតហ្វូនរីង។ នីតិវិធីនៃការផ្ទេរប្រាក់ និងកម្រិតសាច់ប្រាក់ដែលអាចផ្ទេរចេញបានគឺត្រូវបានធ្វើឡើង ដូចការផ្ទេរតាមប្រព័ន្ធ Western Union ដែរ គ្រាន់តែអតិថិជនត្រូវជ្រើសរើសប្រភេទនៃការផ្ទេរប្រាក់តាមឈ្មោះធនាគារដែលចង់ផ្ទេរទៅ ។ ម្យ៉ាងទៀត ការផ្ទេរនេះនឹងធ្វើទៅបានសម្រាប់ករណីអ្នកទទួលមានគណនីធនាគារដែលជាដៃគូប៉ុណ្ណោះ។ ចំពោះការផ្ទេររវាងអ្នកមានគណនីទៅអ្នកមានគណនីដូចគ្នានេះ មានធនាគារជាដៃគូចំនួន ៣២ (ឧបសម្ព័ន្ធទី៩) នៅប្រទេសហ្វីលីពីន ។ រីឯការផ្ទេរប្រាក់ពីអ្នកមានគណនីទៅអ្នកគ្មានគណនីវិញ គឺមានធនាគារដៃគូសហការចំនួន ៣ធនាគារ ហើយកម្រិតចំនួនប្រាក់ផ្ទេរចេញមានត្រឹមចន្លោះពី ៣០០ ទៅ ៥០០ ដុល្លារ។

លក្ខណៈពិសេសនៃការផ្ទេរប្រាក់នេះ គឺអ្នកទទួលអាចទទួលប្រាក់បាន ទាំងរូបិយប័ណ្ណដុល្លារអាមេរិច (USD) និងរូបិយប័ណ្ណប៉េសូ (PHP)។ ករណីដែលអាចទទួលបានរូបិយប័ណ្ណដុល្លារលុះត្រាតែគណនីធនាគាររបស់អ្នកទទួល ជាគណនីប្រាក់ដុល្លារ។ បើសិនជាប្រភេទរូបិយប័ណ្ណរបស់អ្នកផ្ញើ និងអ្នកទទួលខុសគ្នានោះ ធនាគារឯកទេសរីងនឹងធ្វើការផ្លាស់ប្តូររូបិយប័ណ្ណដោយផ្ទាល់ពីគណនីរបស់អ្នកផ្ញើតាម អត្រាប្តូរប្រាក់បច្ចុប្បន្នដែលបង្ហាញផ្ទាល់លើកម្មវិធីស្មាតហ្វូនរីង។

**ខ.២ ការផ្ទេរប្រាក់ទៅប្រទេសវៀតណាម**

មធ្យោបាយនៃការផ្ទេរប្រាក់ទៅប្រទេសវៀតណាម ជាការផ្ទេរពីគណនីរីងទៅកាន់ធនាគារដៃគូសហការនៅប្រទេសវៀតណាម គឺធនាគារសាខមប៉ែង (Sacombank SBR) ដែលនីតិវិធីនៃការផ្ទេរត្រូវបានធ្វើឡើងតាមរយៈកម្មវិធីស្មាតហ្វូនរីង។ ការកំណត់កម្រិតប្រាក់ផ្ទេរចេញ គឺ ១០០០ ដុល្លារក្នុងមួយប្រតិបត្តិការ និង ៥,០០០ដុល្លារក្នុងមួយថ្ងៃ។ ម្យ៉ាងទៀត លក្ខណៈពិសេសនៃការផ្ទេរប្រាក់នេះ គឺអ្នកទទួលអាចទទួលបានប្រាក់ទាំងរូបិយប័ណ្ណដុល្លារអាមេរិច (USD) និងរូបិយប័ណ្ណ

ដុង (VDN) ប៉ុន្តែអ្នកទទួលអាចទទួលបានរូបិយប័ណ្ណដុល្លារបានក្នុងករណីគណនីធនាគាររបស់ខ្លួនជាប្រភេទរូបិយប័ណ្ណដុល្លារប៉ុណ្ណោះ។ ជាងនេះទៅទៀត អតិថិជនអាចជ្រើសរើសការផ្ទេរពីគណនីទៅគណនី ពីគណនីទៅអ្នកគ្មានគណនី (តាមលេខទូរស័ព្ទ) ឬការផ្ទេរប្រាក់ដល់ផ្ទះក៏បានដែរ។ ការយកកម្រៃសេវាកម្មនេះមានដូចខាងក្រោម៖

តារាងទី៧ ៖ តម្លៃសេវាកម្មផ្ទេរប្រាក់ទៅប្រទេសវៀតណាមតាមធនាគារសាខមប៊ែង

| ចំនួនទឹកប្រាក់ | ផ្ទេរប្រាក់ទៅគណនី | ផ្ទេរប្រាក់ទៅអ្នកគ្មានគណនី | ផ្ទេរប្រាក់ដល់ផ្ទះ |
|---|---|---|---|
| ០.០១$ - ៥០០$ | $ ៣.០០ | $ ៤.០០ | $ ៥.០០ |
| ៥០០.០១$- ១,០០០$ | $ ៥.០០ | $ ៦.០០ | $ ១០.០០ |

ប្រភព៖ https://www.wingmoney.com/en/wing2world/

### ខ.៣ ការផ្ទេរប្រាក់ទៅប្រទេសថៃ

ការផ្ទេរប្រាក់ទៅប្រទេសថៃ គឺត្រូវបានធ្វើឡើងតាមប្រព័ន្ធផ្ទេរប្រាក់ Deemoney ដែលអតិថិជននៅកម្ពុជាអាចផ្ទេរប្រាក់ទៅកាន់ធនាគារណាមួយនៅប្រទេសថៃ ឬលេខទូរស័ព្ទរបស់អ្នកទទួលតាមរយៈកម្មវិធីស្មាតហ្វូនវីង។ ធនាគារឯកទេសវីង បានសហការជាមួយដៃគូ ជាធនាគារនៅប្រទេសថៃ ចំនួន ៣១ធនាគារ ដែលអតិថិជនអាចផ្ទេរពីគណនីវីង ទៅគណនីធនាគារជាដៃគូបានតាមកម្មវិធីស្មាតហ្វូនវីង។ រីឯការផ្ទេរប្រាក់ទៅអ្នកគ្មានគណនី (តាមលេខទូរស័ព្ទ) វិញ គឺជាការផ្ទេរពីគណនីវីងទៅសាខា Deemoney ផ្ទាល់ដែលមាន ៤ទីតាំងនៅប្រទេសថៃ។ អតិថិជនដែលជាអ្នកទទួលអាចដកប្រាក់បានដោយភ្ជាប់ជាមួយនឹងលិខិតឆ្លងដែន ឬអត្តសញ្ញាណប័ណ្ណ លេខទូរស័ព្ទ និងលេខកូដផ្ញើប្រាក់ និងទៅដកនៅទីតាំងរបស់ភ្នាក់ងារ Deemoney ណាមួយដែលនៅជិតដើម្បីធ្វើការដកប្រាក់ដែលផ្ទេរពីគណនីវីងនោះ។

ចំពោះថ្លៃសេវាកម្មក្នុងមួយប្រតិបត្តិការត្រូវបានកំណត់ដូចខាងក្រោម៖

តារាងទី៨ ៖ តម្លៃសេវាកម្មផ្ទេរប្រាក់ទៅប្រទេសថៃតាមប្រព័ន្ធ Deemoney

| ចំនួនទឹកប្រាក់ | ផ្ទេរប្រាក់ទៅគណនី | ផ្ទេរប្រាក់ទៅអ្នកគ្មានគណនី |
|---|---|---|
| ០.០១$ - ៥០០$ | $ ៣.០០ | $ ៤.០០ |
| ៥០០.០១$- ១,០០០$ | $ ៥.០០ | $ ៦.០០ |

ប្រភព៖ https://www.wingmoney.com/en/wing2world/

### ៣.២.២.២ នីតិវិធីនៃការទទួលប្រាក់ពីក្រៅប្រទេស

តាមរយៈសេវាផ្ទេរប្រាក់អន្តរជាតិរបស់វីង (Wing2World) អតិថិជនអាចទទួលបានប្រាក់ពីក្រៅប្រទេសបានយ៉ាងងាយស្រួល និងមានសុវត្ថិភាព។ ដោយសង្កេតឃើញពីតម្រូវការផ្ទេរប្រាក់ដ៏

ចាំបាច់នៃការផ្ទេរប្រាក់ចូលក្នុងប្រទេសកម្ពុជា ធនាគារបានបង្កើតសេវាកម្មនេះដើម្បីឲ្យអតិថិជនដែលនៅក្រៅប្រទេស ជាពិសេសពលករដែលធ្វើការនៅស្រុកក្រៅអាចផ្ញើប្រាក់ឲ្យក្រុមគ្រួសាររបស់ខ្លួនតាមរយៈដៃគូសហការរបស់វីងណាមួយជាង ២០០ ប្រទេសនៅទូទាំងពិភពលោក ខណៈដែលអ្នកទទួលប្រាក់អាចដកប្រាក់តាមភ្នាក់ងារវីងជាង ៦,០០០កន្លែង ទូទាំងប្រទេស ឬទទួលប្រាក់ដោយផ្ទាល់ពីគណនីវីងរបស់ពួកគេគ្រប់ពេលវេលា។

ការផ្ទេរប្រាក់ពីប្រទេសក្រៅចូលមកប្រទេសកម្ពុជាមានដូចជា ការផ្ទេរប្រាក់ចូលតាមប្រព័ន្ធ Western Union ឬតាមប្រព័ន្ធផ្ទេរប្រាក់ផ្សេងៗទៀតដូចជា ការផ្ទេរពីប្រទេសអូស្ត្រាលី ម៉ាឡេស៊ី សិង្ហបុរី ហុងកុង ជប៉ុន កូរ៉េខាងត្បូង ថៃ និងប្រទេសផ្សេងៗទៀតទូទាំងពិភពលោក ដែលដំណើរការនៃការផ្ទេរប្រាក់ទាំងនោះប្រើប្រាស់ប្រព័ន្ធផ្ទេរប្រាក់ខុសៗគ្នាតាមប្រទេសនីមួយៗ។

**ក. ការផ្ទេរប្រាក់ចូលតាមប្រព័ន្ធ** Western Union

តាមរយៈប្រព័ន្ធផ្ទេរប្រាក់អន្តរជាតិមួយនេះ អតិថិជនអាចធ្វើការផ្ទេរប្រាក់ ពីក្រៅប្រទេស (ជាង ២០០ប្រទេស) នៅលើពិភពលោកបានយ៉ាងងាយស្រួល និងមានសុវត្ថិភាពបំផុត។ ដំណើរការនៃការទទួលប្រាក់ពីបរទេសតាមរយៈវីងអាចធ្វើទៅបាន លុះត្រាអតិថិជនជាអ្នកផ្ញើត្រូវអនុវត្តតាមជំហានងាយៗដូចខាងក្រោម៖

ជំហានទី ១ ៖ អតិថិជនជាអ្នកផ្ញើត្រូវស្វែងរកទៅតាំងភ្នាក់ងារ Western Union ណាមួយដែលនៅជិតបំផុត

ជំហានទី ២ ៖ បំពេញសំណុំបែបបទផ្ទេរប្រាក់

ជំហានទី ៣ ៖ ប្រគល់បែបបទនោះទៅឲ្យទៅភ្នាក់ងារ ជាមួយនឹងចំនួនទឹកប្រាក់ដែលត្រូវផ្ទេរ ដែលរួមបញ្ចូលទាំងថ្លៃសេវាកម្មផងដែរ

ជំហានទី ៤ ៖ អតិថិជននឹងទទួលបានលេខបង្កាន់ដៃ និងលេខតាមដាន (MTCN)

ជំហានទី ៥ ៖ ប្រាប់អ្នកទទួលប្រាក់ពីចំនួនទឹកប្រាក់ដែលបានផ្ទេរ និងលេខតាមដាន (MTCN) ដើម្បីឲ្យអ្នកទទួលអាចធ្វើការដកប្រាក់តាមភ្នាក់ងារវីងដែលបានជ្រើសរើសជាង ១,០០០ទីតាំងនៅកម្ពុជា ជាមួយនឹងការបង្ហាញអត្តសញ្ញាណប័ណ្ណរបស់ពួកគេ។

**បញ្ជាក់** ៖ បើទោះបីជា ភ្នាក់ងារវីងបច្ចុប្បន្នមានរហូតដល់ទៅជាង ៦,០០០ ភ្នាក់ងារក៏ដោយ ការទទួលប្រាក់ពីការផ្ទេរពីបរទេសតាមរយៈ Western Union អាចធ្វើទៅបានជាមួយភ្នាក់ងារវីងចំនួនជាង ១,០០០ទីតាំង ដែលធនាគារបានកំណត់តែប៉ុណ្ណោះ។ ការកំណត់នេះ គឺផ្អែកទៅលើកត្តាមួយចំនួនដូចជា ទីតាំងសក្តានុពលរបស់ភ្នាក់ងារនោះ ដែលទីតាំងស្ថិតនៅទីប្រជុំជន ទីផ្សារ កន្លែង

ដែលមានតម្រូវការផ្ទេរប្រាក់ច្រើនជាដើម។ អតិថិជនដែលត្រូវទៅដកប្រាក់នោះ ត្រូវស្វែងរកទីតាំងភ្នាក់ងារវីងណាមួយដែលមានបិតស្លាកសញ្ញា Western Union នៅលើបញ្ជរផ្ទេរប្រាក់។

ដ្យាក្រាមទី៣ ៖ ដ្យាក្រាមសង្ខេបនៃប្រតិបត្តិការទទួលប្រាក់ពីក្រៅប្រទេសតាម Western Union




**ខ. ការផ្ទេរប្រាក់ចូលតាមប្រព័ន្ធ** MoneyGram

ប្រព័ន្ធផ្ទេរប្រាក់ MoneyGram គឺជាជម្រើសដ៏ងាយស្រួលសម្រាប់ការទទួលប្រាក់ពីក្រៅប្រទេសរហូតដល់ទៅជាង ២០០ប្រទេស។ នីតិវិធីនៃការផ្ទេរប្រាក់ពីក្រៅប្រទេសមកកាន់ប្រទេសកម្ពុជាមានដូចតទៅ៖

ជំហានទី ១ ៖ អតិថិជនដែលចង់ផ្ទេរប្រាក់ត្រូវស្វែងរកទៅតាំងភ្នាក់ងារ MoneyGram ណាមួយដែលនៅជិត

ជំហានទី ២ ៖ អតិថិជនត្រូវបំពេញបែបបទផ្ទេរប្រាក់

ជំហានទី ៣ ៖ ប្រគល់បែបបទដែលបំពេញគ្រប់ព័ត៌មាន ហើយនោះឲ្យទៅភ្នាក់ងារ MoneyGram ជាមួយនឹងប្រាក់ដែលត្រូវផ្ទេរ រួមទាំងថ្លៃសេវាផ្ទេរប្រាក់

ជំហានទី ៤ ៖ ត្រូវរក្សាទុកនូវបង្កាន់ដៃ និងជូនដំណឹងដល់អ្នកទទួលប្រាក់ ដោយផ្តល់លេខកូដសម្ងាត់ ៨ ខ្ទង់ដើម្បីដកប្រាក់បាន។ ចំពោះការដកប្រាក់ អតិថិជនដែលជាអ្នកទទួលត្រូវមកកាន់ទៅស្នាក់ការកណ្តាលរបស់ធនាគារឯកទេសវីង ដោយភ្ជាប់មកជាមួយនូវអត្តសញ្ញាណប័ណ្ណរបស់ខ្លួន ព្រមទាំងលេខសម្ងាត់ ៨ ខ្ទង់ (Reference Number)។

**គ. ការផ្ទេរប្រាក់ចូលតាមប្រព័ន្ធ WorldRemit**

ក្រៅពីប្រព័ន្ធផ្ទេរប្រាក់ទាំង ២ខាងលើ ការផ្ទេរប្រាក់មកប្រទេសកម្ពុជាក៏អាចផ្ទេរបានតាមរយៈកម្មវិធីស្មាតហ្វូន WorldRemit ឬ គេហទំព័រ WorldRemit។ តាមរយៈការប្រើប្រាស់ប្រព័ន្ធផ្ទេរប្រាក់អន្តរជាតិ WorldRemit អតិថិជនអាចផ្ទេរពីប្រទេសជាង ៥០ប្រទេសនៅលើពិភពលោកមកកាន់ប្រទេសកម្ពុជា។

តារាងទី៩ ៖ បញ្ជីឈ្មោះប្រទេសដែលអាចផ្ទេរមកប្រទេសកម្ពុជាបានតាមប្រព័ន្ធ WorldRemit

| ទ្វីប | ប្រទេស |
|---|---|
| អាមេរិច | សហរដ្ឋអាមេរិក និងកាណាដា |
| អឺរ៉ុប | ប្រទេសអូទ្រីស; បែលហ្ស៊ិម; ប៊ុលហ្គារី; ឆែក; ដាណឺម៉ាក; អេស្តូនី; ហ្វាំងឡង់; បារាំង; អាល្លឺម៉ង់; អ៊ីហ្គែរតារ៍; ក្រិក; ហុងគ្រី; អ៊ីស្លង់; អ៊ីតាលី; ឡាតវី; លីទុយអានី; លុចសំបួ; ម៉ាល់តា; ហូល្លង់; ណ័រវេ; ប៉ូឡូញ; ព័រទុយហ្គាល់; រ៉ូម៉ានី; ស្លូវ៉ាគី; ស្លូវេនី អេស្ប៉ាញ; ស៊ុយ; អែតស៊្វីស; និងចក្រភពអង់គ្លេស |
| អាស៊ីបូព៌ា | បារ៉ែន; ស៊ីព្រូស; ហ្សកជានី; គុយវ៉ែត; អូម៉ង់; កាតា; អារ៉ាប៊ីសាអូឌីត; អាហ្វ្រិកខាងត្បូង; និងអារ៉ាប់អេរ៉ត |
| អាស៊ីប៉ាស៊ីហ្វិច | អូស្ត្រាលី; ហ្គាម; ហុងកុង; ជប៉ុន; ម៉ាឡេស៊ី; នូវែលសេឡង់; ហ្វីលីពីន; សឹង្ហបូរី; កូរ៉េខាងត្បូង; និងតៃវ៉ាន់ |

ប្រភព៖ https://www.wingmoney.com/en/wing2world/

**ឃ. ការផ្ទេរប្រាក់ចូលតាមប្រព័ន្ធផ្សេងៗ**

**ឃ.១ ការផ្ទេរប្រាក់ពីប្រទេសអូស្ត្រាលី**

ដើម្បីអាចធ្វើការផ្ទេរប្រាក់អតិថិជនដែលមានបំណងផ្ញើប្រាក់ពីប្រទេសអូស្ត្រាលីមកកម្ពុជាអាចជ្រើសរើសរបៀបផ្ទេរប្រាក់ ២ បែប។ ទីមួយ ការផ្ទេរប្រាក់តាមរយៈ Hai Ha Money Transfer (ជាមួយTranglo) ដែលមានទីស្នាក់ការចំនួន ២៥នៅក្នុងប្រទេសអូស្ត្រាលី។ របៀបផ្ទេរប្រាក់ គឺមានភាពងាយស្រួលដោយអតិថិជន គ្រាន់តែស្វែងរកសាខាណាមួយ ដែលជិតជាងគេ ហើយត្រូវភ្ជាប់មកជាមួយនូវឯកសារសម្រាប់បង្ហាញមានដូចជា អត្តសញ្ញាណ (លិខិតឆ្លងដែន ឬលិខិតអនុញ្ញាតិការងារ) លិខិតឆ្លងដែនដែលបានចុះឈ្មោះមុន និងឯកសារពាក់ព័ន្ធផ្សេងៗ (គណនី ឬអាសយដ្ឋានធនាគារ) រួចធ្វើតាមការណែនាំរបស់ភ្នាក់ងាររបស់ Hai Ha Money Transfer។ រីឯ ទីពីរ គឺការផ្ទេរប្រាក់មកកម្ពុជាតាម DollarSmart Global Australia (AUDSmart) ដែលជាការផ្ទេរតាមអនឡាញ ពុំមានសាខាឡើយ។

ចំពោះល័ក្ខខ័ណ្ឌសម្រាប់ផ្ទេរវិញនោះគឺ អតិថិជនចាំបាច់ចុះឈ្មោះតាមអនឡាញ ដោយភ្ជាប់មកជាមួយនឹង លិខិតឆ្លងដែន ឬប័ណ្ណបើកបរ (ដែលមានសុពលភាព) តាមរយៈគេហទំព័រ https://www.audsmart.com/ បន្ទាប់ពីគណនីត្រូវបានគេដាក់ឲ្យដំណើរការ។ របៀបនៃការផ្ទេរប្រាក់ គឺអតិថិជនអាចធ្វើការផ្ទេរប្រាក់តាមគេហទំព័រ https://www.audsmart.com/ ហើយ ផ្ញើមកកាន់ AUDSmart តាមអនឡាញ ២៤/៧ មិនគិតតម្លៃសេវាកម្ម។

## ឃ.២ ការផ្ទេរប្រាក់ពីប្រទេសម៉ាឡេស៊ី និងសិង្ហបុរី

ចំពោះការផ្ទេរប្រាក់ពីប្រទេសម៉ាឡេស៊ី និងសិង្ហបុរីមកកាន់ប្រទេសកម្ពុជា គឺមាន ៣ បែប ៖

- ការផ្ទេរប្រាក់តាម TIKFX (Tranglo) ៖ អតិថិជនត្រូវទៅកាន់សាខារបស់ TIKFX (Tranglo) ដែលមានទីតាំងនៅម៉ាឡេស៊ី ១សាខា និងនៅសិង្ហបុរី ១សាខា។ ឯកសារចាំបាច់ត្រូវភ្ជាប់មកជាមួយរួមមានអត្តសញ្ញាណប័ណ្ណ លិខិតឆ្លងដែន លិខិតអនុញ្ញាតការងារ និងឯកសារពាក់ព័ន្ធផ្សេងៗ (គណនី ឬអាសយដ្ឋានធនាគារ)។
- ការផ្ទេរប្រាក់តាម Mass Express ៖ អតិថិជនអាចវេរប្រាក់តាមបញ្ជរ (OTC) ដោយគ្រាន់តែទៅកាន់សាខារបស់ Mass Express ដែលមាន ២សាខានៅសិង្ហបុរី ជាមួយនឹងអត្តសញ្ញាណប័ណ្ណ លិខិតឆ្លងដែន លិខិតអនុញ្ញាតការងារ និងលិខិតបញ្ជាក់ទីលំនៅដ្ឋាននៅប្រទេសសិង្ហបុរី។
- ការផ្ទេរប្រាក់តាម VALYOU ៖ អតិថិជនអាចរកសាខា VALYOU ណាមួយក្នុងចំណោម ២៤សាខា និងភ្នាក់ងារផ្ទេរប្រាក់ ១៣ កន្លែងដោយភ្ជាប់ជាមួយនឹង លិខិតឆ្លងដែន ឬ ឯកសារ ដែលនៅមានសុពលភាពផ្សេងៗ។

## ឃ.៣ ការផ្ទេរប្រាក់ពីប្រទេសហុងកុង

ដើម្បីផ្ទេរប្រាក់ពីហុងកុងមកប្រទេសកម្ពុជា អតិថិជនអាចធ្វើការផ្ទេរតាមរយៈ គេហទំព័ររបស់ DollarSmart Global HongKong (HKDSmart)។ ល័ក្ខខ័ណ្ឌចាំបាច់នោះ គឺត្រូវចុះឈ្មោះតាមអនឡាញ ដើម្បីអាចដំណើរការគណនីបាន ហើយអតិថិជនអាចផ្ទេរប្រាក់តាមអនឡាញ ២៤ម៉ោង មិនគិតថ្លៃសេវាកម្ម។

## ឃ.៤ ការផ្ទេរប្រាក់ពីប្រទេសជប៉ុន

ធនាគារឯកទេសរីងបានបង្កើតជម្រើសនៃការផ្ទេរប្រាក់ពីប្រទេសជប៉ុនកមកម្ពុជាតាមរយៈ World Family Remit ដែលប្រើប្រាស់ជាមួយកម្មវិធីស្មាតហ្វូន Tranglo ឬ ការប្រើកម្មវិធីស្មាតហ្វូន World Remit ឬផ្ទេរប្រាក់តាមគេហទំព័រ www.worldfamilyremit.com ។

## ឃ.៥ ការផ្ទេរប្រាក់ពីប្រទេសកូរ៉េខាងត្បូង

ក្រៅពីការផ្ទេរប្រាក់តាមប្រព័ន្ធ Western Union ធនាគារឯកទេសវីង ក្រៅពីការផ្ទេរប្រាក់តាមប្រព័ន្ធ Western Union ធនាគារឯកទេសវីងបានផ្ដល់នូវវិធីផ្ទេរប្រាក់ពីប្រទេសកូរ៉េខាងត្បូងតាមប្រព័ន្ធផ្ទេរប្រាក់ផ្សេងៗទៀតដូចជា៖

**ការផ្ទេរប្រាក់តាមធនាគារ Kookmin**

ការផ្ទេរប្រាក់តាមធនាគារ Kookmin មកកាន់កម្ពុជាត្រូវបានធ្វើឡើងតាមកម្មវិធីស្មាតហ្វូនរបស់ធនាគារ Kookmin (ឈ្មោះកម្មវិធីLiiv) ដែលជាដៃគូសហការរបស់វីង និងអនុញ្ញាតឲ្យអតិថិជនអាចផ្ទេរប្រាក់ពីគណនីនៅធនាគារ Kookmin ចូលក្នុងគណនីវីង ឬផ្ទេរទៅកាន់លេខទូរស័ព្ទដៃបានយ៉ាងងាយស្រួល។ ចំពោះថ្លៃសេវាកម្មត្រូវបានកំណត់ដូចខាងក្រោម៖

តារាងទី១០ ៖ តម្លៃសេវាកម្មនៃការផ្ទេរពីប្រទេសកូរ៉េខាងត្បូងតាមធនាគារ Kookmin

| សេវាកម្ម | ចំនួនទឹកប្រាក់ | ថ្លៃសេវាកម្ម |
|---|---|---|
| គណនីទៅកាន់លេខទូរស័ព្ទដៃ | 0$ - ៥០០.៤៩$ | $ ២.៥០ |
| | ៥០០.៥០$ - ១,០០០$ | $ ៥.០០ |
| គណនីទៅគណនីវីង | 0$ - ៥០០.៤៩$ | $ ២.៥០ |
| | ៥០០.៥០$ - ២,៥០០$ | $ ៣.៥០ |

ប្រភព៖ https://www.wingmoney.com/en/wing2world/

**ការផ្ទេរប្រាក់តាមធនាគារ PPCBank**

ការផ្ទេរប្រាក់តាមធនាគារ PPCBank មកកម្ពុជា គឺអតិថិជនត្រូវអញ្ជើញមកកាន់សាខាធនាគារ Jeonbuk ឬអាចធ្វើការផ្ទេរប្រាក់ ដោយប្រើប្រាស់កម្មវិធីស្មាតហ្វូនរបស់ PPCBank។ សម្រាប់ការយកថ្លៃសេវាត្រូវបានកំណត់ ដូចការផ្ទេរតាមកម្មវិធីស្មាតហ្វូនរបស់ធនាគារ Kookmin ដែរ។

តារាងទី១១ ៖ តម្លៃសេវាកម្មនៃការផ្ទេរពីប្រទេសកូរ៉េខាងត្បូងតាមធនាគារ PPCBank

| ប្រភេទសេវាកម្ម | ចំនួនទឹកប្រាក់ | ថ្លៃសេវាកម្ម |
|---|---|---|
| គណនីទៅកាន់លេខទូរស័ព្ទដៃ | 0$ - ៥០០.៤៩$ | $ ២.៥០ |
| | ៥០០.៥០$ - ១០០០$ | $ ៥.០០ |
| គណនីទៅគណនីវីង | 0$ - ៥០០.៤៩$ | $ ២.៥០ |
| | ៥០០.៥០$ - ២,៥០០$ | $ ៣.៥០ |

ប្រភព៖ https://www.wingmoney.com/en/wing2world/

**ការផ្ទេរប្រាក់តាមធនាគារ Shinhan**

អតិថិជនដែលចង់ផ្ទេរប្រាក់តាមពីធនាគារ Shinhan មកកម្ពុជាត្រូវតែមានគណនីធនាគារស៊ីនហាន បន្ទាប់មកត្រូវចុះឈ្មោះបង្កើតកម្មវិធីស្មាតហ្វូនធនាគារស៊ីនហាន (Shinhan Global Bank) ដើម្បីផ្ទេរប្រាក់ទៅគណនីវីង ឬលេខទូរស័ព្ទដៃរបស់អ្នកទទួលមកកាន់កម្ពុជា។ ប៉ុន្តែ តម្លៃសេវាត្រូវបានកំណត់យក ៥ដុល្លារ ក្នុងមួយប្រតិបត្តិការគ្រប់ចំនួនទឹកប្រាក់។

**ការផ្ទេរប្រាក់តាមកម្មវិធីស្មាតហ្វូន GMoney Trans ឬ HanPass App**

វិធីនៃការផ្ទេរប្រាក់នោះ គឺអតិថិជនគ្រាន់តែធ្វើការផ្ទេរប្រាក់តាមជំហានងាយនៅលើកម្មវិធីស្មាតហ្វូន GMoney Trans ឬ HanPass App ដែលអាចធ្វើការចុះឈ្មោះដោយខ្លួនឯងនៅលើកម្មវិធីនោះ ឬអាចទៅកាន់សាខា GMoney Trans ឬ HanPass ដោយផ្ទាល់ដើម្បីធ្វើការភ្ជាប់ទៅកម្មវិធី។ កម្រិតផ្ទេរប្រាក់គឺ ១,០០០ដុល្លារ ជាមួយនឹងថ្លៃសេវា ៥,០០០ វ៉ុនក្នុងមួយប្រតិបត្តិការ។

**ការផ្ទេរប្រាក់តាមកម្មវិធីស្មាតហ្វូន GME (Global Money Express) Remittance**

ការផ្ទេរអាចធ្វើឡើងតាមកម្មវិធីស្មាតហ្វូនរបស់ GME Remittanceដែលអតិថិជនអាចចុះឈ្មោះដោយខ្លួនឯងលើកម្មវិធីនោះ ឬអាចទៅកាន់សាខាដោយផ្ទាល់ដែលស្ថិតនៅ ៨ទីតាំងក្នុងប្រទេសកូរ៉េខាងត្បូងដើម្បីភ្ជាប់កម្មវិធី។

**ការផ្ទេរប្រាក់តាមរយៈ SBI Cosmoney**

របៀបផ្ទេរប្រាក់តាមកម្មវិធីស្មាតហ្វូន SBI Cosmoney មាន ២របៀបគឺ ការផ្ទេរប្រាក់តាមរយៈគេហទំព័ររបស់ SBI ( sbicosmoney.com) និង ការផ្ទេរប្រាក់តាមកម្មវិធីស្មាតហ្វូនរបស់ SBI ។ កម្រិតផ្ទេរប្រាក់គឺ ១០០០ដុល្លារជាមួយនឹងថ្លៃសេវា ៥,០០០ វ៉ុនក្នុងមួយប្រតិបត្តិការ។

### ឃ.៦ ការផ្ទេរប្រាក់ពីប្រទេសថៃ

ចំពោះការផ្ទេរប្រាក់ពីប្រទេសថៃមកកម្ពុជា គឺអាចប្រើប្រាស់ការផ្ទេរប្រាក់តាមកម្មវិធីស្មាតហ្វូន ឌីម៉ាន់នី (Deemoney) ឬផ្ទេរតាមភ្នាក់ងារឌីម៉ាន់នីណាមួយក្នុងចំណោម ៤ ទីតាំងនៅប្រទេសថៃ។

តារាងទី១២ ៖ តម្លៃសេវាកម្មនៃការផ្ទេរពីប្រទេសថៃតាម Deemoney

| ចំនួនទឹកប្រាក់ | ថ្លៃសេវាកម្ម |
|---|---|
| ១,០០០ - ៤,៩៩៩ បាត | ៧៥ បាត |
| ៥,០០០ បាតឡើងទៅ | ១៥០ បាត |

ប្រភព៖ https://www.wingmoney.com/en/wing2world/

### ៣.២.២.៣ អត្ថប្រយោជន៍នៃសេវាផ្ទេរប្រាក់អន្តរជាតិ

ចំពោះសេវាកម្មផ្ទេរប្រាក់អន្តរជាតិរបស់ធនាគាររីង ដែលទើបតែបានបង្កើតឡើង នាពេលថ្មីៗនេះ បានទទួលការគាំទ្រ និងការប្រើប្រាស់ពីអតិថិជនជាច្រើន ក៏ព្រោះតែអត្ថប្រយោជន៍ដ៏លើសលប់របស់សេវាកម្មនេះដូចខាងក្រោម៖

- អនុញ្ញាតឲ្យពលករខ្មែរដែលធ្វើការនៅស្រុកក្រៅ ដូចជាប្រទេសថៃ ប្រទេសហ្វីលីពីន និងប្រទេសកូរ៉េ អាចផ្ញើប្រាក់មកក្រុមគ្រួសាររបស់ខ្លួនដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសារបានទៀងទាត់ និងទាន់ពេលវេលា នៅគ្រប់ទីកន្លែង តាមរយៈដៃគូសហការរបស់រីងនៅក្រៅប្រទេស។
- មានភាពងាយស្រួល មិនស្មុគស្មាញក្នុងការប្រើប្រាស់ ព្រោះរាល់ការផ្ទេរចេញប្រើប្រាស់កម្មវិធីស្មាតហ្វូនរីង ដែលមានលើទូរស័ព្ទផ្ទាល់ ដោយអតិថិជនមិនចាំបាច់ត្រូវស្វែងរកសាខាណាមួយ និងបំពេញព័ត៌មានលើទំរង់បែបបទផ្ទេរប្រាក់នោះឡើយ។ ចំពោះការដកប្រាក់ ដែលផ្ទេរចូលពីក្រៅប្រទេសវិញ គឺអាចទៅដកប្រាក់បានជាមួយនឹង ភ្នាក់ងាររីងជាង ១០០០ ភ្នាក់ងារនៅទូទាំងប្រទេសកម្ពុជា។
- ប្រតិបត្តិការផ្ទេរប្រាក់ប្រកបដោយសុវត្ថិភាពបំផុត ព្រោះទឹកប្រាក់របស់អតិថិជន នឹងត្រូវបានការពារដោយប្រព័ន្ធបច្ចេកវិទ្យាទំនើបដែលមានហានិភ័យទាបក្នុងការបញ្ជូនសាច់ប្រាក់ទៅកាន់អ្នកទទួលតាមរយៈការប្រើប្រាស់កម្មវិធីស្មាតហ្វូនរីង។
- មានភាពងាយស្រួលក្នុងការផ្ទេរសាច់ប្រាក់ដែលមានរូបិយប័ណ្ណពីរខុសគ្នា ព្រោះរីងបានធ្វើការប្តូរប្រភេទរូបិយប័ណ្ណដោយស្វ័យប្រវត្តិ នៅពេលធ្វើការផ្ទេរប្រាក់ ដោយអត្រាប្តូរប្រាក់យោងតាមអត្រា ប្តូរប្រាក់នាថ្ងៃធ្វើប្រតិបត្តិការផ្ទេរប្រាក់។
- ផ្តល់នូវសេវាកម្មផ្ទេរប្រាក់អន្តរជាតិដល់អតិថិជនជាមួយនឹងតម្លៃសេវាកម្មសមរម្យ និងមានការបត់បែនបានច្រើនជម្រើស ដូចជាការផ្ទេរប្រាក់តាមប្រព័ន្ធ Western Union MoneyGram និង WorldRemit ឬតាមរយៈធនាគារបរទេសដែលជាដៃគូសហការរបស់ធនាគារជាច្រើនថែមទៀត។
- ចូលរួមចំណែកក្នុងការជំរុញប្រជាជនកម្ពុជា ឲ្យប្រើប្រាស់សេវាផ្ទេរប្រាក់ក្រៅប្រទេស តាមរយៈប្រព័ន្ធផ្ទេរប្រាក់ Western Union និងជំរុញឲ្យមានការប្រាស្រ័យទាក់ទង ការផ្ទេរប្រាក់ឆ្លងប្រទេសទៅកាន់ដៃគូអាជីវកម្មនានា។

## ៣.៣ ការសិក្សាពីបម្រែបម្រួលចំណូលនៃប្រតិបត្តិការទូទាត់ និងសេវាផ្ទេរប្រាក់

ការសិក្សាលើ ចំណូលនៃប្រតិបត្តិការទូទាត់ និងសេវាផ្ទេរប្រាក់ របស់ធនាគារឯកទេសរីង យើងនឹងធ្វើការវិភាគទៅលើ បម្រែបម្រួលចំណូលនៅក្នុងកំឡុងពេល ៤ឆ្នាំនៃសន្ទុះរីកចម្រើនរបស់

ធនាគារឯកទេសរីងចាប់ពីឆ្នាំ ២០១៣ ដល់ ២០១៦ និងជាឆ្នាំដែល ធនាគារនេះបានទទួលការធ្វើសវនកម្មដោយសវនករឯករាជ្យតែប៉ុណ្ណោះ។

តារាងទី១៣ ៖ ចំណូលនៃប្រតិបត្តិការទូទាត់ និងសេវាផ្ទេរប្រាក់របស់ធនាគារឯកទេសរីងចន្លោះឆ្នាំ ២០១៣ ដល់ ២០១៦

| ឆ្នាំ | ចំណូលពីកម្រៃសេវា | បម្រែបម្រួល | អត្រា (ភាគរយ) |
|---|---|---|---|
| ២០១៣ | $ ៣,៩៣៧,១៩២ | - | - |
| ២០១៤ | $ ១០,៨៣២,៥៣៥ | $ ៦,៨៩៥,៣៤៣ | ៦៤% |
| ២០១៥ | $ ១៦,៧៩៧,២៩០ | $ ៥,៩៦៤,៧៥៥ | ៣៦% |
| ២០១៦ | $ ១៩,១៩៩,៦០៧ | $ ២,៤០២,៣១៧ | ១៣% |

ប្រភព៖ របាយការណ៍ប្រចាំឆ្នាំពីឆ្នាំ ២០១៣ ដល់ ឆ្នាំ ២០១៦ *ធនាគារជាតិនៃកម្ពុជា*

ខាងក្រោមនេះ ជាក្រាបដែលបង្ហាញពីចំណូលនៃប្រតិបត្តិការទូទាត់ និងសេវាផ្ទេរប្រាក់របស់ធនាគារឯកទេសរីង នៅក្នុងរយៈពេល ៤ឆ្នាំ គិតចាប់ពី ២០១៣ ដល់ ២០១៦៖




តាមការអង្កេតឃើញជាក់ស្តែងទៅលើក្រាបសសរខាងលើ យើងឃើញថាចំណូលដែលបានមកពីប្រតិបត្តិការទូទាត់ និងសេវាផ្ទេរប្រាក់របស់ធនាគារឯកទេសរីង ពិតជាមានការកើនឡើងជាលំដាប់ប្រាកដមែន ក្រោយពីបានបង្កើតឡើងនៅឆ្នាំ២០០៨ និងដាក់ចេញនូវសេវាកម្មរបស់ខ្លួនអោយអតិថិជនប្រើប្រាស់ ព្រមទាំងទទួលបានការទទួលស្គាល់នៅក្នុងស្រុកច្រើនបំផុត គឺចាប់ផ្តើមនៅឆ្នាំ ២០១៣។ ចំណូលនោះ គឺប្រមាណ ៣,៩៣៧,១៩២ ដុល្លារ ហើយកើនដល់ជាង ១០លានដុល្លារនៅក្នុងឆ្នាំ២០១៤ ដែលស្មើនឹងសន្ទុះកំណើនគិតជាអត្រា ៦៤%។ លុះមកដល់ ឆ្នាំ២០១៥ ជាឆ្នាំដែលមានការប្រកួតប្រជែងខ្លាំងពី សំណាក់ក្រុមហ៊ុនហិរញ្ញវត្ថុទូទាត់បរទេសនានាធៀបនឹង ឆ្នាំចាស់ ២០១៤ ធនាគារបានបង្កើនប្រាក់ចំណូលពីតម្លៃសេវាកម្មប្រមាណ ៣៦% ដែលគិតជាទឹក

ប្រាក់ គឺកើនចំនួន ៥,៩៦៤,៧៥៥ ដុល្លារ។ លុះមកដល់ឆ្នាំ ២០១៦ សន្ទុះនៃចំណូលពីកម្រៃសេវារបស់ធនាគារក៏នៅតែមានការកើនឡើងគួរកត់សម្គាល់ គឺកើនដល់ជាង ១៩លានដុល្លារ ដែលស្មើនឹងអត្រាកំណើន ១៣%។ បើទោះបីជា ធនាគារមានកំណើនចំណូលពីកម្រៃសេវារៀងរាល់ឆ្នាំក៏ពិតមែន ប៉ុន្តែយើងអង្កេតឃើញថា អត្រាកំណើននៃចំណូល គឺមានការថយជាលំដាប់ដែលមិនសូវជាមានការកើនឡើង ជាសាច់ប្រាក់ទ្វេរដងនោះទេ។

សរុបសេចក្តីមក តាមរយៈការសិក្សាទៅលើ បម្រែបម្រួលចំណូលពី កម្រៃសេវាកម្មរបស់ធនាគារឯកទេសវីង យើងអង្កេតឃើញថា ចំណូលរបស់ធនាគារឯកទេសវីង នៅក្នុងចន្លោះឆ្នាំ ២០១៣ ដល់ ២០១៦ ពិតជាមានសន្ទុះខ្លាំង។ ដោយឡែក កំណើនស្ទុះខ្លាំងរបស់ធនាគារឯកទេសវីង គឺមានតែនៅកំឡុងឆ្នាំ ២០១៣ ដល់ ២០១៥ តែប៉ុណ្ណោះ លុះមកដល់ឆ្នាំ ២០១៦ កំណើននេះមានការធ្លាក់ចុះជាងមុនពាក់កណ្តាល (ពី ៣៦% មកត្រឹម ១៣%)។ យើងអាចធ្វើការវិភាគបានថា កំណើនចំណូលរបស់ធនាគារគឺបានមក ដោយសារកំណើនការប្រើប្រាស់សេវាកម្មវីងមានការកើនឡើង ស្របពេលជាមួយនឹងការប្រកួតប្រជែងទីផ្សារមានការកើនឡើងដែរនោះ តម្លៃសេវាកម្មក្នុងមួយប្រតិបត្តិការរបស់វីងមានការទម្លាក់ថ្លៃ ជាហេតុធ្វើឲ្យកំណើននៃចំណូលមានការធ្លាក់ចុះធៀបទៅនឹងឆ្នាំមុនៗ។

## ៣.៤ ហានិភ័យ និងវិធីសាស្ត្រគ្រប់គ្រងហានិភ័យនៃប្រតិបត្តិការទូទាត់

### ៣.៤.១ ហានិភ័យនៃប្រតិបត្តិការទូទាត់

ចំពោះការទូទាត់មួយណាក៏មានហានិភ័យដែរតែអាចមានហានិភ័យទាប ឬខ្ពស់គឺអាស្រ័យទៅលើការគ្រប់គ្រង មិនថាទៅលើដំណើរការនៃប្រតិបត្តិការប្រព្រឹត្តទៅ ឬបច្ចេកវិទ្យារបស់ធនាគារ និងចំណេះដឹងរបស់អតិថិជនផ្ទាល់ នៅក្នុងការប្រើប្រាស់សេវានោះ ហានិភ័យដែលអតិថិជន និងពាណិជ្ជករដែលជាដៃគូសហការរបស់ធនាគារឯកទេសវីង ធ្លាប់ជួបប្រទះក្នុងការប្រើប្រាស់សេវាកម្មរបស់ធនាគារឯកទេសវីងលើប្រតិបត្តិការទូទាត់មានដូចជា ៖

- អតិថិជនធ្វើការបង់វិក្កយបត្រ ទៅកាន់អង្គភាពអគ្គិសនីដោយលើសសាច់ប្រាក់៖ ជាទូទៅបញ្ហានេះមិនសូវជាកើតមានឡើងទៅលើការបង់ដោយផ្ទាល់នៅតាមភ្នាក់ងារវីងទេ តែភាគច្រើនគឺអាចកើតមានឡើងតាមរយៈការបង់ នៅលើកម្មវិធីស្មាតហ្វូនវីង ដោយសារតែអតិថិជនមិនបានផ្ទៀងផ្ទាត់សាច់ប្រាក់ច្បាស់លាស់មុននឹងសម្រេចបង់ ហើយនៅពេលខ្លះទៀត អតិថិជនអាចនឹងច្រឡំធ្វើការបង់ពីរដងជាន់គ្នា ដោយមិនបានចំណាំ ឬត្រួតពិនិត្យនូវប្រតិបត្តិការចុងក្រោយរបស់ខ្លួន។

- ដៃគូពាណិជ្ជកម្មទទួលបានការបង់វិក្កយបត្រដោយខ្វះសាច់ប្រាក់៖ ដូចគ្នាទៅនឹងករណីខាងលើ ដៃរភាគច្រើនកំហុសនេះ គឺកើតឡើងតាមរយៈការប្រើប្រាស់ការបង់នៅលើកម្មវិធីស្មាតហ្វូនរឹង ដែលអតិថិជនធ្វើការវាយបញ្ចូលសាច់ប្រាក់ច្រឡំតួលេខណាមួយធ្វើឲ្យខ្វះនូវចំនួនដែលតម្រូវឲ្យបង់នៅក្នុងវិក្កយបត្រ និងក្នុងករណីមួយទៀត គឺអតិថិជនធ្វើការជ្រើសឈ្មោះក្រុមហ៊ុនដែលខ្លួនត្រូវបង់ច្រឡំ ហើយមិនបានធ្វើការផ្ទៀងផ្ទាត់នៅមុនពេលចុចបង់ចុងក្រោយ។
- អតិថិជនធ្វើការទូទាត់ ទៅកាន់គេហទំព័រដែលមិនមែនជាដៃគូសហការរបស់វីង ធ្វើឲ្យមានការកាត់ប្រាក់ ដោយមិនដឹងមូលហេតុ។ ហានិភ័យនេះកើតមានឡើងតិចតួចបំផុត ចំពោះការប្រើប្រាស់ប្រតិបត្តិការទូទាត់ តាមអ៊ីនធឺណេត ដោយសារអតិថិជនមិនបានផ្ទៀងផ្ទាត់ ចូលមើលជាមុនថា តើគេហទំព័រណាខ្លះដែលជាដៃគូសហការរបស់វីង ដែលជាហេតុនៅពេលដែលចូលទៅប្រើប្រាស់ ឬធ្វើការទូទាត់ដោយខ្វះការប្រុងប្រយ័ត្ន បើកឱកាសអោយជនឆបោកដែលគ្រប់គ្រងគេហទំព័រនោះនឹងកាត់លុយពីគណនីអតិថិជនទៅដោយមិនអាចយកមកវិញបាន។

### ៣.៤.២ វិធីសាស្ត្រគ្រប់គ្រងហានិភ័យនៃប្រតិបត្តិការទូទាត់

ហានិភ័យគឺអាចកើតមានឡើងគ្រប់ពេលបើទោះជាការគ្រប់គ្រងនោះល្អយ៉ាងណាក៏ដោយ តែវា អាចស្ថិតនៅក្នុងកម្រិតដែលមិនប៉ះពាល់ដល់ផ្នែកហិរញ្ញវត្ថុរបស់ធនាគារទាំងមូល ឬក៏អត់គឺអាស្រ័យទៅលើនីតិវិធីនៃការគ្រប់គ្រងនិងវិធីសាស្ត្រនៃការកាត់បន្ថយនូវហានិភ័យទាំងនោះអោយនៅកម្រិតទាបដែលមិនអាចប៉ះពាល់ដល់ប្រយោជន៍ភាគីណាមួយទាំងធនាគារ អតិថិជន ឬជាដៃគូសហការរបស់ធនាគារផ្ទាល់។ ខាងក្រោមនេះ គឺជាវិធីសាស្ត្រកាត់បន្ថយហានិភ័យ ចំពោះអតិថិជនក្នុងនាមជាអ្នកប្រើប្រាស់ផ្ទាល់ រួមទាំងនីតិវិធីនៃការគ្រប់គ្រងហានិភ័យ លើប្រតិបត្តិការទូទាត់ដែលធនាគារបានដាក់អនុវត្តចេញទៅ៖

- ដើម្បីកាត់បន្ថយការបង់វិក្កយបត្រនូវសាច់ប្រាក់លើសឬខ្វះ អតិថិជនត្រូវមានការប្រុងប្រយ័ត្ននៅពេលធ្វើប្រតិបត្តិការ ដោយផ្ទៀងផ្ទាត់នូវឈ្មោះក្រុមហ៊ុនដែលខ្លួនបង់ លេខកូដរបស់ក្រុមហ៊ុនព្រមទាំងបញ្ចូលចំនួនទឹកប្រាក់ឲ្យសមាមាត្រទៅនឹងទឹកប្រាក់ដែលកំណត់នៅលើវិក្កយបត្រ។ នៅក្នុងនោះដែរ ករណីដែលអតិថិជនធ្វើប្រតិបត្តិការខុសនោះបាត់ទៅហើយ ហើយធនាគារបានអង្កេតឃើញភាពមិនប្រក្រតីនោះ ធនាគារក៏មានជាល័ក្ខខ័ណ្ឌបង្ការជាមុនផងដែរ។ ប្រសិនបើការបង់នោះគឺលើសសាច់ប្រាក់ អតិថិជនអាចជ្រើសរើសពីរល័ក្ខខ័ណ្ឌ គឺទីមួយ ធ្វើការបន្តសាច់ប្រាក់ដែលបង់នោះទៅកាន់ការបង់នៅខែបន្ទាប់ ដោយស្វ័យប្រវត្តិ និងទីពីរគឺអតិថិជន អាចមកកាន់ធនាគារដើម្បីបំពេញបែបបទយកសាច់ប្រាក់ដែលបង់លើសបង្វិលចូលគណនីវិញ។ បើសិនជា

ការបង់នោះខ្វះវិញ អតិថិជន គឺតម្រូវអោយទៅកាន់ ក្រុមហ៊ុនដែលខ្លួនត្រូវបង់វិក្កយបត្រនោះ ហើយធ្វើការបង់នូវសាច់ប្រាក់បន្ថែមក្នុងល័ក្ខខ័ណ្ឌដែលហួសថ្ងៃកំណត់ តែបើមិនទាន់ដល់ថ្ងៃកំណត់នោះទេអតិថិជន នៅតែអាចធ្វើការបង់បង្គ្រប់សាច់ប្រាក់តាមរយៈកម្មវិធីស្មាតហ្វូនរឹង ឬតាមភ្នាក់ងាររឹងបាន។

- ចូលរួមនៅក្នុងការការពារនូវហានិភ័យនៃការឆបោកតាមរយៈប្រតិបត្តិការទូទាត់តាមអ៊ីនធឺណេត ធនាគារឯកទេសរឹងតម្រូវអោយអតិថិជន ប្រើប្រាស់គណនីជំនួសអោយកាតដោយធ្វើការផ្ទៀងផ្ទាត់ជាមួយនឹងគេហទំព័រដែលត្រូវបង់ជាមួយនឹងឆ្នាំកំណើត ហើយលេខសំងាត់របស់អតិថិជននៅក្នុងការប្រើប្រាស់កម្មវិធីស្មាតហ្វូនរឹង ដោយកម្មវិធីនេះ គឺអាចតម្លើងនៅលើទូរស័ព្ទតែមួយដែលបានមកភ្ជាប់ផ្ទាល់នៅធនាគារតែប៉ុណ្ណោះ ដូចនេះហើយជនឆបោក គឺមិនអាចធ្វើការលួចយកលុយអតិថិជនបាននោះទេតាមរយៈលេខគណនីដែលខ្លួនយកបាន លុះត្រាតែអតិថិជនធ្វើការទូទាត់ច្រឡំទៅលើគេហទំព័រឆបោកនោះតែប៉ុណ្ណោះ។ បន្ថែមពីនេះ ធនាគារឯកទេសរឹងបានដាក់ផ្សព្វផ្សាយនូវដៃគូពាណិជ្ជកម្មរបស់ខ្លួននៅលើគេហទំព័ររឹងផ្ទាល់ ក៏ដូចជាប្រព័ន្ធផ្សព្វផ្សាយសង្គមនានា ពិសេសផ្តល់ដំណឹងអំពីដៃគូសហការថ្មីរបស់ខ្លួននៅតាមកម្មវិធីស្មាតហ្វូនរឹងភ្លាមៗតែម្តង។
- ដើម្បីធានានូវសុវត្ថិភាព ចំពោះប្រតិបត្តិការបង់ផ្ទាល់ធនាគារក៏បាននាំប្រព័ន្ធបច្ចេកវិទ្យាថ្មីនៃការទូទាត់គឺ QR Code ដែលធានាសុវត្ថិភាពបានខ្ពស់ នៅពេលអតិថិជនស្កេនទូទាត់ គឺអតិថិជនជាអ្នកស្កេន QR Code ក្រុមហ៊ុនដោយផ្ទាល់ ព្រមទាំងចុចតម្លៃទូទាត់ ដោយខ្លួនឯងទៀតផង។ ចំណែកឯក្រុមហ៊ុន ឬដៃគូពាណិជ្ជកម្មរបស់រឹង នឹងទទួលបាននូវទឹកប្រាក់ ចូលគណនីរបស់ខ្លួនភ្លាមៗតាមរយៈការលោតសារបង្ហាញ ធ្វើអោយកំហុសមិនងាយនឹងកើតឡើង បើទោះជាកើតមានឡើងក៏ភាគីទាំងពីររវាងអ្នកលក់ និងអ្នកទិញអាចដឹងបានភ្លាមៗដែរ។

## ៣.៥ ហានិភ័យ និងវិធីសាស្ត្រគ្រប់គ្រងហានិភ័យនៃសេវាកម្មផ្ទេរប្រាក់

### ៣.៥.១ ហានិភ័យនៃសេវាកម្មផ្ទេរប្រាក់

ចំពោះហានិភ័យនៃការផ្ទេរប្រាក់ក្នុងប្រទេសតាមរយៈរឹង អាចកើតឡើងដោយសារកត្តាមួយចំនួនដូចខាងក្រោម៖

- ហានិភ័យដែលកើតឡើងដោយសារអតិថិជន៖ ភាគច្រើននៃករណីនៃការផ្ទេរប្រាក់ខុសទិសដៅបណ្តាលមកពីអតិថិជនបំពេញព័ត៌មានផ្ទេរប្រាក់មិនបានត្រឹមត្រូវ។ ចំពោះការផ្ទេរប្រាក់វេរលុយខាសអ៊ិចប្រេស ដែលធ្វើឡើងតាមរយៈភ្នាក់ងាររឹង អាចនឹងមានបញ្ហាផ្ទេរប្រាក់ខុស នៅពេល

អតិថិជនដែលជាអ្នកផ្ញើបំពេញទម្រង់ផ្ញើប្រាក់ព័ត៌មា នដូចជា លេខទូរស័ព្ទអ្នកទទួលជាដើម ដែលជាហេតុធ្វើឲ្យការផ្ទេរប្រាក់ត្រូវបានផ្ទេរ ទៅលេខទូរស័ព្ទរបស់បុគ្គលផ្សេងទៀត ដែលមិនមែនជាអ្នកទទួលពិតប្រាកដ។ ដូចគ្នានេះដែរ ហានិភ័យនេះ ក៏អាចកើតឡើងចំពោះការផ្ទេរប្រាក់វីងទៅវីង ឬការផ្ទេរប្រាក់វីងវេលុយ គឺកើតឡើងនៅពេលអតិថិជនដែលជាអ្នកផ្ញើបញ្ចូលលេខគណនី ឬលេខទូរស័ព្ទអ្នកទទួលមិនបានត្រឹមត្រូវ។ ក្នុងករណីខាងលើនេះ គឺអតិថិជនមិនមានការខាតបង់ប្រាក់ដែលផ្ទេរនោះទេដោយសារតែលេខកូដសម្ងាត់ ៨ខ្ទង់មិនបានផ្ញើផ្ទាល់ចូលលេខទូរស័ព្ទដែលខុសនោះទេ។ វីង ការផ្ទេរប្រាក់វីងទៅវីងខុសទិសដៅ ជាធម្មតាអតិថិជនអាចផ្ទៀងផ្ទាត់ឈ្មោះរបស់ម្ចាស់គណនីបាន គឺនៅមុនពេលបញ្ចូល PIN សម្ងាត់ ៥ខ្ទង់ដើម្បីបញ្ជាក់ប្រតិបត្តិការនោះ។ ប៉ុន្តែប្រសិនបើ អតិថិជនមិនបានចាប់អារម្មណ៍ពិនិត្យឈ្មោះអ្នកទទួលទៀតនោះ ការផ្ទេរប្រាក់ នឹងត្រូវផ្ទេរចូលក្នុងគណនីរបស់ម្ចាស់គណនីដែលមិនមែនជាអ្នកទទួលពិតប្រាកដ។

- ហានិភ័យដែលកើតឡើងដោយសារបុគ្គលិកធនាគារ ឬភ្នាក់ងារវីង៖ ហានិភ័យនេះកើតមានឡើងនៅពេលបុគ្គលិក ឬភ្នាក់ងារវីងខ្វះការប្រុងប្រយ័ត្នក្នុងការបំពេញទិន្នន័យ ឬព័ត៌មានអតិថិជនខុសដោយអចេតនានៅលើម៉ាស៊ីន POS វីង។ ឧទាហរណ៍៖ ការបំពេញលេខទូរស័ព្ទអ្នកទទួលខុសដោយសារការភ័ន្តច្រឡំ ដោយបានបំពេញលេខខុស ឬបញ្ច្រាសលេខជាដើម។ ទោះជាយ៉ាងណាក៏ដោយ ហានិភ័យនេះកម្រនឹងកើតមានឡើងណាស់ ព្រោះបុគ្គលិក ឬភ្នាក់ងារវីងតែងតែធ្វើការផ្ទៀងផ្ទាត់លេខទូរស័ព្ទជាមួយអ្នកផ្ញើប្រាក់ម្តងទៀតមុនធ្វើប្រតិបត្តិការផ្ទេរប្រាក់នោះ។
- ហានិភ័យដែលកើតឡើង ដោយសារជនក្លែងបន្លំ៖ ករណីនេះ អាចកើតមានឡើងដោយសារជនខិលខូចដែលឆ្លៀតឱកាសមួយចំនួនតូច ធ្វើការបន្លំខ្លួនជាអតិថិជនអ្នកទទួលប្រាក់ ហើយទៅដកប្រាក់ដែលផ្ញើនោះ។ ហានិភ័យនេះកើតមាន នៅពេលដែលជននោះបានដឹងពីព័ត៌មានសំខាន់ ២ របស់អតិថិជន គឺលេខទូរស័ព្ទរបស់អ្នកទទួល និងលេខកូដសម្ងាត់ ៨ខ្ទង់។ ក្រោយពីបានព័ត៌មាន ២ប្រភេទនេះ ជនក្លែងបន្លំ នឹងអាចដកប្រាក់ នៅតាមភ្នាក់ងារវីងណាមួយ ដោយបង្ហាញនូវកូដសម្ងាត់ ៨ខ្ទង់នោះ ហើយនៅពេលដែលភ្នាក់ងារមិនបានត្រួតពិនិត្យលេខទូរស័ព្ទអ្នកទទួលដោយផ្ទាល់ទៀតនោះ ភ្នាក់ងារនឹងធ្វើការដកប្រាក់ឲ្យជនក្លែងក្លាយ។ វីង អ្នកទទួលពិតប្រាកដនឹងមិនអាចទៅដកប្រាក់នោះបានទៀតឡើយ។ ហានិភ័យមួយទៀត គឺជាការឆបោកពីសំណាក់ក្រុមហ៊ុនមិនស្គាល់ឈ្មោះ។ ជារឿយៗ តែងលេចឮព័ត៌មាននៃការឆបោកនេះដែលវាកើតឡើងដោយសារអតិថិជនដែលជាអ្នកផ្ញើប្រាក់ទទួលបានព័ត៌មានថា ខ្លួនឈ្នះរង្វាន់ហើយក្រុមហ៊ុន

តម្រូវឲ្យផ្ទេរប្រាក់មួយចំនួនទៅឲ្យគេជាមុនសិនសម្រាប់ថ្លៃសេវា ឬថ្លៃប្រតិបត្តិការផ្សេងៗ។ ជាក់ស្តែង អតិថិជនពុំបានឈ្នះរង្វាន់អ្វីទេ ហើយការផ្ទេរប្រាក់នោះនឹងត្រូវខាតបង់ដោយអសារបង់។

- ចំពោះហានិភ័យនៃការផ្ទេរប្រាក់អន្តរជាតិរបស់ធនាគារឯកទេសវីង មានលក្ខណៈស្រដៀងគ្នានឹងការផ្ទេរប្រាក់ក្នុងស្រុកដែរ គឺការផ្ទេរប្រាក់ខុសទិសដៅ ដោយសារកំហុសបំពេញព័ត៌មានខុស។ ដោយសារសេវាកម្មផ្ទេរប្រាក់អន្តរជាតិរបស់វីងតម្រូវឲ្យប្រើប្រាស់នៅលើកម្មវិធីស្មាតហ្វូនរបស់វីង ហើយប្រតិបត្តិការនៃការផ្ទេរប្រាក់មិនត្រូវបានត្រួតពិនិត្យដោយបុគ្គលិក ឬភ្នាក់ងារទៀតនោះ ការផ្ទេរប្រាក់អាចនឹងខុសទិសដៅ នៅពេលអតិថិជនមានការភ័ន្តច្រឡំ។ ជាធម្មតា នៅពេលប្រើប្រាស់សេវាផ្ទេរប្រាក់អន្តរជាតិ អតិថិជនតម្រូវឲ្យបំពេញព័ត៌មានច្រើនដែលជាហេតុធ្វើឲ្យមានការភ័ន្តច្រឡំខុសលេខគណនីអ្នកទទួល ឬលេខទូរស័ព្ទអ្នកទទួល ឬខុសលេខកូដប្រៃសណីយ៍ ឬឈ្មោះធនាគារទទួលផល (Beneficiary Bank) ជាដើម។

### ៣.៥.២ វិធីសាស្ត្រគ្រប់គ្រងហានិភ័យនៃសេវាកម្មផ្ទេរប្រាក់

ធនាគារឯកទេសវីងបានដាក់ចេញនូវវិធីសាស្ត្រដែលអាចគ្រប់គ្រងហានិភ័យរបស់សេវាផ្ទេរប្រាក់ទាំងក្នុង និងក្រៅប្រទេសមានដូចតទៅៈ

**វេរលុយខាសអ៊ិចប្រេសខុសទិសដៅ**

- អតិថិជនត្រូវបង្កើនការប្រុងប្រយ័ត្នលើព័ត៌មានដែលបានបំពេញក្នុងទំរង់ផ្ទេរប្រាក់ និងត្រូវផ្ទៀងផ្ទាត់ឲ្យបានច្បាស់លាស់ មុននឹងប្រគល់ឲ្យភ្នាក់ងារវីង។
- នៅពេលមានការផ្ទេរប្រាក់ខុសលេខទូរស័ព្ទកើតឡើង អតិថិជនត្រូវផ្តល់ដំណឹងទៅភ្នាក់ងារវីងដើម្បីដកប្រាក់ដែលផ្ទេរខុសនោះមកវិញ ដោយភ្ជាប់ទៅជាមួយនឹងប័ណ្ណផ្ទេរប្រាក់របស់ខ្លួន ដែលមានបង្ហាញលេខទូរស័ព្ទអ្នកទទួល និងលេខកូដសម្ងាត់ ៨ ខ្ទង់។ បន្ទាប់មកអតិថិជនស្នើសុំធ្វើការផ្ទេរប្រាក់នោះម្តងជាថ្មីម្តងទៀតជាមួយនឹងលេខទូរស័ព្ទដែលត្រឹមត្រូវ ករណីនេះអតិថិជនដែលជាអ្នកស្នើសុំ ត្រូវទទួលខុសត្រូវលើការចំណាយថ្លៃប្រតិបត្តិការផ្ទេរប្រាក់ទាំងពីរដងនេះ ដោយខ្លួនឯង។

**វីងទៅវីង និងវីងវេរលុយខុសទិសដៅ**

វិធីសាស្ត្រដើម្បីដោះស្រាយហានិភ័យនេះគឺ អតិថិជនត្រូវទំនាក់ទំនងទៅកាន់ ផ្នែកបម្រើសេវាកម្មអតិថិជន ដើម្បីស្នើសុំដាក់ព័ត៌មានលុបការផ្ទេរប្រាក់នោះ នៅពេលដែលអតិថិជនបំពេញគ្រប់ព័ត៌មានលុបប្រតិបត្តិការផ្ទេរប្រាក់នោះរួចរាល់ហើយ ខាងក្រុមការងារបច្ចេកទេសនឹងធ្វើការវេរទឹកប្រាក់ដែលខុសនោះចេញ រួចធ្វើការ Freeze Amount ដែលផ្ទេរចូលក្នុងគណនីដែលខុស

នោះ។ បន្ទាប់មក ទឹកប្រាក់នឹងត្រូវផ្ទេរចូលគណនីម្ចាស់ដើមវិញ។ អតិថិជន អាចធ្វើការផ្ទេរជាថ្មី តាមដំណើរការធម្មតា ប៉ុន្តែប្រសិនបើ ក្នុងករណីម្ចាស់គណនីដែលបានទទួលការផ្ទេរខុសនោះបានទៅដកប្រាក់ចេញពីគណនីអស់ នោះអតិថិជនដែលជាអ្នកផ្ញើនឹងត្រូវទទួលរងការខាតបង់ដោយខ្លួនឯង។

**ការក្លែងបន្លំ និងឆបោក**

- អតិថិជនចាំបាច់រក្សាព័ត៌មានសម្ងាត់ដែលមានដូចជាលេខទូរស័ព្ទអ្នកទទួល និងលេខសំងាត់ ៨ ខ្ទង់នោះ ជាសម្ងាត់ ហើយអ្នកទទួលត្រូវប្រញាប់ទៅដកប្រាក់កាន់តែឆាប់កាន់តែល្អ ជៀសវាងជនទីបីណាម្នាក់បន្លំយកព័ត៌មាននោះហើយទៅដកប្រាក់បានមុន។
- ធនាគារឯកទេសវីង បានដាក់ចេញនូវគោលការណ៍ សម្រាប់ភ្នាក់ងារក្នុងការអនុវត្តលើប្រតិបត្តិការ វេរលុយអ៊ិចប្រេស ដើម្បីជៀសវាងការឆបោកទាំងនោះ គឺភ្នាក់ងារតម្រូវឲ្យមានការត្រួតពិនិត្យលេខទូរស័ព្ទ មុនពេលបើកប្រាក់ឲ្យអតិថិជន។ ដូចនេះនៅពេលភ្នាក់ងារវីងធ្វេសប្រហែសមិនបានត្រួតពិនិត្យលេខទូរស័ព្ទដោយផ្ទាល់ និងបានបើកប្រាក់ឲ្យទៅជនក្លែងបន្លំនោះភ្នាក់ងារនឹងត្រូវទទួលខុសត្រូវលើសំណងទឹកប្រាក់ ដែលបាត់បង់នោះដល់អតិថិជន។
- ដើម្បីជៀសវាងការឆបោក អតិថិជនត្រូវមានការយកចិត្តទុកដាក់ខ្ពស់ និងមិនត្រូវផ្ញើប្រាក់ដល់នរណាម្នាក់ដែលខ្លួនមិនស្គាល់ឡើយ។ ក្នុងករណីនេះ បើអតិថិជនបានផ្ទេរប្រាក់នោះ អតិថិជននឹងត្រូវប្រឈមមុខនឹងការខាតបង់របស់ខ្លួន ដោយសារធនាគារឯកទេសវីងនឹងមិនអាចមិនទទួលខុសត្រូវ ចំពោះករណីបែបនេះឡើយ។

**ផ្ទេរប្រាក់ក្រៅប្រទេសខុសទិសដៅ**

ធនាគារឯកទេសវីង បានផ្តល់ដំណោះស្រាយដល់អតិថិជនដែលជួបបញ្ហា ដោយកំហុសឆ្គងព័ត៌មានដែលបានបំពេញតាមរយៈការធ្វើសំណើរសុំប្តូរព័ត៌មាន ដូចជា ឈ្មោះអ្នកទទួល ឈ្មោះប្រទេស លេខគណនីអ្នកទទួលជាដើម។ នៅពេលមានហានិភ័យនេះកើតឡើងអតិថិជនចាំបាច់ត្រូវទំនាក់ទំនងមកកាន់ ផ្នែកបម្រើសេវាកម្មអតិថិជនរបស់ធនាគារឯកទេសវីង ក្នុងកំឡុងរយៈពេល ២៤ ម៉ោងបន្ទាប់ពីការផ្ទេរខុសនោះ។ បន្ទាប់ពីការកែប្រែព័ត៌មានរួចរាល់ វីងនឹងផ្តល់ដំណឹងទៅកាន់ដៃគូក្រៅប្រទេសរបស់ខ្លួនដើម្បីផ្លាស់ប្តូរទិន្នន័យផ្ទេរប្រាក់នោះជូនដល់អតិថិជន។ ដំណើរការនេះនឹងប្រព្រឹត្តទៅក្នុងថ្ងៃតែមួយ ប្រសិនបើធ្វើឡើងក្នុងកំឡុងម៉ោង និងថ្ងៃធ្វើការរបស់ដៃគូក្រៅប្រទេស ប៉ុន្តែ ករណីជាថ្ងៃឈប់សម្រាក ប្រតិបត្តិការផ្ទេរប្រាក់នឹងត្រូវលើកទៅថ្ងៃបន្ទាប់ទៀត។

## ៣.៦ ការវិភាគ SWOT

### ៣.៦.១ ភាពខ្លាំង

ជាការពិតណាស់ ភាពរីកចម្រើនឥតឈប់ឈររបស់ ធនាគារឯកទេសវីង គឺបានមកពីចំណុចខ្លាំងរបស់ខ្លួននៅក្នុងទីផ្សារកម្ពុជាក៏ដូចជាទីផ្សារអន្តរជាតិ ដែលភាពខ្លាំងទាំងនោះរួមមានដូចជា៖

- ធនាគារឯកទេសវីង គឺជាធនាគារឯកទេសតែមួយគត់ ដែលជ្រើសយកការផ្តល់ជូននូវសេវាទូទាត់និងផ្ទេរប្រាក់លក្ខណៈ Mobile Banking ដំបូងគេបង្អស់នៅប្រទេសកម្ពុជា ខណៈពេលដែលធនាគារឯកទេសដទៃជ្រើសរើសយកការផ្តល់នូវសេវាកម្មី។ នេះជាហេតុធ្វើឲ្យធនាគារនេះមានកេរ្តិ៍ឈ្មោះ មានការទទួលស្គាល់ច្រើន ព្រមទាំងទទួលបានការជឿទុកចិត្តខ្ពស់ពីអតិថិជនរបស់ខ្លួនយ៉ាងពេញទំហឹង។ សក្តានុពលនៃការចាប់យកចំណែកទីផ្សារនៃសេវាទូទាត់ និងផ្ទេរប្រាក់តាមទូរស័ព្ទដៃនេះហើយបានជំរុញឲ្យធនាគារឯកទេសវីង មានការរីកចម្រើនឥតឈប់ឈរនៅកម្ពុជាអស់រយៈពេល ១០ឆ្នាំកន្លងមកនេះ។
- ធនាគារឯកទេសវីង គឺជាធនាគារឯកទេសដែលមានភ្នាក់ងារដែលដើរតួនាទីជាអ្នកផ្តល់សេវាកម្មទាំងឡាយរបស់វីងដល់អតិថិជនដោយផ្ទាល់ ខុសប្លែកពីធនាគារដទៃដែលមានជាសាខាធនាគារតាមតំបន់នីមួយៗ និងមានការគ្រប់គ្រងដាច់ដោយឡែកពីគ្នា។ ភ្នាក់ងារវីងមានចំនួនច្រើនរហូតដល់ទៅជាង ៦,០០០ ភ្នាក់ងារគ្របដណ្តប់ពាសពេញប្រទេសកម្ពុជា ដែលជំនួសអោយម៉ាស៊ីន ATMអនុញ្ញាតអោយអតិថិជនដកលុយបានគ្រប់ទីកន្លែង លើសពីនោះក៏ជំរុញឲ្យប្រតិបត្តិការទូទាត់ និងសេវាផ្ទេរប្រាក់របស់វីងកាន់តែមានភាពងាយស្រួលថែមទៀត។
- ធនាគារឯកទេសវីង មានដៃគូសហការច្រើនទាំងក្នុង និងក្រៅប្រទេសដែលជួយគាំទ្រដល់សេវាកម្មរបស់ខ្លួន។ ចំពោះដៃគូសហការក្នុងប្រទេស ធនាគារបានសហការជាមួយនឹងធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ ក្រុមហ៊ុនបម្រើសេវាកម្មនានា រដ្ឋាករទឹកស្វយ័ត អគ្គិសនីកម្ពុជា ជាដើម ដើម្បីធ្វើឲ្យសេវាទូទាត់របស់ខ្លួនកាន់តែរីកដុះដាលឡើង។ រីឯ ដៃគូសហការនៅក្រៅប្រទេសក៏មានច្រើនក្រុមហ៊ុនធំៗ ព្រមទាំងធនាគារក្រៅប្រទេសមួយចំនួន ដែលជួយជំរុញឲ្យសេវាផ្ទេរប្រាក់អន្តរជាតិប្រព្រឹត្តទៅបានកាន់តែរលូន។
- ធនាគារឯកទេសវីង បានដាក់ចេញនូវការទូទាត់ប្រភេទ QR Code ដែលមានទាំងការស្កេន និងការវាយលេខដាក់បញ្ចូលដែលមានទម្រង់ដូចប្រព័ន្ធ Alipay ដែលកំពុងតែពេញនិយមប្រើនៅ

ប្រទេសចិន ធ្វើអោយប្រព័ន្ធទូទាត់របស់ខ្លួនទទួលបានការចាប់អារម្មណ៍យ៉ាងច្រើន ពីសំណាក់ពាណិជ្ជករ និងអតិថិជនប្រើប្រាស់។

- ធនាគារឯកទេសវីង មានបទពិសោធន៍ច្រើនលើប្រតិបត្តិការ E-Banking ដែលធ្វើឲ្យការបំរើសេវាកម្មធនាគារបែប FinTech របស់ខ្លួនឲ្យមានភាពប្រសើរឡើង។ រាល់សេវាកម្មទាំងឡាយរបស់ធនាគារសុទ្ធតែបានប្រព្រឹត្តទៅតាមប្រព័ន្ធបច្ចេកវិទ្យាដែលវីងព្យាយាមអភិវឌ្ឍ ប្រព័ន្ធអេឡិចត្រូនិចរបស់ខ្លួន ដើម្បីឲ្យប្រតិបត្តិការសេវាកម្មកាន់តែមានលក្ខណៈទំនើបថែមទៀត។ ជាក់ស្តែង ការផ្ទេរប្រាក់ក្នុងស្រុករបស់វីងដែលបានធ្វើឡើងតាមភ្នាក់ងារវីង គឺរាល់ដំណើរការនៃការផ្ទេរទាំងនោះ ត្រូវបានធ្វើឡើងតាមរយៈម៉ាស៊ីន POS វីងដែលអាចធ្វើប្រតិបត្តិការផ្ទេរប្រាក់ ទូទាត់ប្រាក់ ដាក់ប្រាក់និងដកប្រាក់បានយ៉ាងងាយស្រួល និងរហ័ស។
- រាល់សេវាកម្មរបស់វីង គឺមានលក្ខណៈងាយស្រួលក្នុងការប្រើប្រាស់ និងជាប្រភេទសេវាកម្មដែលអាចប្រើប្រាស់បានសម្រាប់ជនទូទៅ ព្រោះសេវាកម្មទាំងនោះមានល័ក្ខខ័ណ្ឌនៃការប្រើប្រាស់សាមញ្ញ និងងាយស្រួលស្វែងយល់។ វីង ដំណើរការនៃការប្រើប្រាស់សេវាកម្ម គឺមានភាពរហ័សទាន់ចិត្ត មិនមានភាពរអាក់រអួលនៅពេលអតិថិជនប្រើប្រាស់ ព្រោះតែធនាគារបានជ្រើសរើសការបម្រើសេវាបែប FinTech ។

### ៣.៦.២ ភាពខ្សោយ

ទន្ទឹមនឹងភាពខ្លាំងរបស់ខ្លួនធនាគារឯកទេសវីងក៏មានភាពលំបាក ក៏ដូចជាចំណុចខ្សោយមួយចំនួនដែលនឹងត្រូវអភិវឌ្ឍបន្ថែមផងដែរ ដើម្បីអោយការបម្រើសេវាកម្មរបស់ខ្លួនមានភាពលេចធ្លោ និងដណ្តើមយកទីផ្សារពីធនាគារដទៃមកពង្រីកនូវទីផ្សាររបស់ខ្លួន ដែលចំណុចខ្សោយទាំងនោះរួមមាន៖

- ធនាគារមានទីតាំងតែមួយ៖ បច្ចុប្បន្នធនាគារឯកទេសវីង មានសាខាកណ្តាលតែមួយដែលស្ថិតនៅទីតាំងរាជធានីភ្នំពេញ តែបើក្រឡេកទៅមើលទីផ្សារគោលដៅរបស់ធនាគារវិញ គឺសំដៅទៅកាន់ប្រជាជនកម្ពុជាគ្រប់តំបន់ ជាពិសេសគឺសេវាផ្ទេរប្រាក់ពីក្រុងទៅខេត្ត នៅក្នុងករណី ដែលអតិថិជន មានបញ្ហានឹងសេវាផ្ទេរប្រាក់ឡើងអតិថិជនមិនអាចទទួលបានការដោះស្រាយដោយផ្ទាល់ពីបុគ្គលិកវីងនោះទេ តែគេនឹងទទួលបានការប្រឹក្សាតាមរយៈទូរស័ព្ទដែលធ្វើអោយបញ្ហាត្រូវបានដោះស្រាយយឺតយ៉ាវមិនរហ័សទាន់ចិត្ត។
- ដៃគូសហការរបស់ធនាគារនៅមានលក្ខណៈតូចចង្អៀត៖ ចំពោះដៃគូសហការលើប្រតិបត្តិការទូទាត់ធនាគារមានត្រឹម ២០០ជាង និងការទូទាត់ដែលមានការបញ្ចុះតម្លៃក៏នៅមានតិច។

ចំពោះកិច្ចសហការលើ សេវាផ្ទេរប្រាក់ក្នុងប្រទេសទៅកាន់ធនាគារ ឬគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដទៃ ធនាគារឯកទេសវីង អាចផ្ទេរចេញទៅបាន ចំពោះតែធនាគារមួយចំនួនតែប៉ុណ្ណោះ រួមមានធនាគារFTB ធនាគារគុកមីន ធនាគារប្រៃសណីយ៍ និង គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត រីឯការផ្ទេរចូលគណនីវីងវិញគឺបានតែគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹតតែមួយគត់។

- ទីផ្សារគោលដៅរបស់ធនាគារនៅមានកម្រិត៖ ការវាយលុកទីផ្សាររបស់ធនាគារឯកទេសវីង គឺចាប់យកត្រឹមបុគ្គលដែលមានចំណេះដឹងមធ្យម ដូចជា សំដៅលើការផ្ញើប្រាក់របស់ពលករកម្មករនិយោជិកជាដើម ដែលមិនអាចទាញនឹងក្តោបក្តាប់នូវអ្នកវិនិយោគិនធំៗ ឬអតិថិជនសក្តានុពលដែលមានកម្រិតប្រាក់ចំណូលខ្ពស់ ជាអតិថិជនប្រចាំរបស់ខ្លួននៅឡើយ។
- ធនាគារតាមទូរស័ព្ទនៅខ្វះមុខងារសំខាន់ៗ និងមិនទាន់ដំណើរការរលូនល្អ ៖ ក្រៅពីប្រតិបត្តិការផ្ទេរ ឬទូទាត់វិក្កយបត្រនានា តាមទូរស័ព្ទដៃ អតិថិជនប្រើប្រាស់ធនាគារតាមទូរស័ព្ទដៃជាចម្បងជំនួសអោយសៀវភៅធនាគារ ដើម្បីមើលពីប្រតិបត្តិការចេញ និងចូលនៃគណនីរបស់ខ្លួន។ ដោយឡែក ចំពោះធនាគារតាមទូរស័ព្ទដៃរបស់វីង គឺបង្ហាញតែសមតុល្យសាច់ប្រាក់ និងប្រតិបត្តិការ ៣ខែចុងក្រោយតែប៉ុណ្ណោះទៅកាន់អតិថិជន ដែលជាចំណុចខ្វះខាត ក្នុងការផ្តល់ព័ត៌មានគ្រប់ជ្រុងជ្រោយទៅកាន់អតិថិជន។ ចំពោះវិធីសាស្ត្រ នៅក្នុងការប្រើមុខងារនីមួយៗក្នុងកម្មវិធីស្មាតហ្វូនវីងក៏នៅមានភាពរអាក់រអួល ក្នុងការប្រើប្រាស់នៅពេលខ្លះដែរ។

**៣.៦.៣ ឱកាស**

ធនាគារឯកទេសវីង ក៏អាចនឹងមានឱកាសបន្ថែមលើប្រតិបត្តិការសេវាកម្មរបស់ខ្លួន ដើម្បីពង្រីកខ្លួនក៏ដូចជាអាចទាក់ទាញអតិថិជន និងបង្កើនការប្រើប្រាស់សេវាកម្មរបស់ខ្លួនដូចជា ៖

- ប្រព័ន្ធបច្ចេកវិទ្យាមានការរីកចម្រើនលូតលាស់ ធ្វើឲ្យប្រជាជនកម្ពុជាកាន់តែមានទំនោរលើការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗទាំងនោះ ដើម្បីសម្រួលដល់ការរស់នៅរបស់ពួកគេ ដែលជាហេតុបើកឱកាសឲ្យធនាគារឯកទេសវីងកាន់តែមានភាពងាយស្រួល ក្នុងការជម្រុញសេវាកម្ម E-Banking និង Mobile Banking របស់ខ្លួន។
- កត្តាអប់រំនៅកម្ពុជាមានការកើនឡើង ធ្វើឲ្យប្រជាជនមានចំណេះដឹងខ្ពស់ជាងមុន ដែលនាំឲ្យមានការយល់ដឹងពីប្រព័ន្ធអ៊ីនធឺណេត ឬបច្ចេកវិទ្យាទំនើបផ្សេងៗទៀតប្រសើរជាងមុន។ ហេតុដូច្នេះហើយ ធនាគារឯកទេសវីងអាចដាក់បម្រើសេវាកម្មដែលប្រកបទៅដោយបច្ចេកវិទ្យាខ្ពស់របស់ខ្លួនជូនអតិថិជន នាំអោយទទួលបានការគាំទ្រខ្លាំងពីអតិថិជន និងទំនុកចិត្តខ្ពស់លើការប្រើ

ប្រាស់សេវាកម្មរបស់ធនាគារដែរ ព្រោះពួកគេបានយល់ដឹង ព្រមទាំងចង់ស្វែងយល់ពីមុខងារនៃប្រព័ន្ធបច្ចេកវិទ្យាទាំងនោះបន្ថែម។

- កំណើននៃចំណាកស្រុកទៅធ្វើការនៅក្រៅប្រទេស បានផ្តល់ឱកាសដល់ធនាគារ ក្នុងការដាក់ចេញនូវសេវាកម្មផ្ទេរប្រាក់អន្តរជាតិកាន់តែប្រសើរឡើង ព្រោះពលករស់នៅក្រៅប្រទេសមានតម្រូវការក្នុងការផ្ទេរប្រាក់ទៅក្រុមគ្រួសាររបស់ពួកគេ។ កត្តានេះ បានធ្វើឲ្យធនាគារចាប់យកចំណែកទីផ្សារ និងប្រឹងប្រែងអភិវឌ្ឍសេវាកម្មរបស់ខ្លួនឲ្យមានភាពល្អប្រសើរ និងបំពេញតម្រូវការរបស់អតិថិជនបានល្អជាងមុន។
- កេរ្តិ៍ឈ្មោះល្អរបស់ធនាគារឯកទេសរឹង បានធ្វើឲ្យអតិថិជនមានការទទួលស្គាល់ និងជឿទុកចិត្តយ៉ាងខ្លាំងក្នុងការប្រើប្រាស់សេវាកម្ម។ កត្តានេះ បានក្លាយជាសក្តានុពលមួយដ៏ធំសម្រាប់រឹងក្នុងការអភិវឌ្ឍផលិតផល និងសេវាកម្មរបស់ខ្លួនបានយ៉ាងងាយ ដោយសារមានអតិថិជនច្រើនរួចជាស្រេច។ ផលិតផល និងសេវាកម្មថ្មីៗបានទាក់ទាញចំណាប់អារម្មណ៍ប្រើប្រាស់ពីសំណាក់ជនទូទៅ ព្រោះសេវាកម្មទាំងនោះ ជាសេវាកម្មចាំបាច់ដែលគាំទ្រដល់ការរស់នៅប្រចាំថ្ងៃ។ ឱកាសនេះបានធ្វើឲ្យរឹងកាន់តែអាចបង្កើនប្រាក់ចំណូលរបស់ខ្លួន ព្រមទាំងអាចពង្រីកខ្លួនក្នុងវិស័យទីផ្សារហិរញ្ញវត្ថុបានយ៉ាងមានប្រសិទ្ធភាព។

### ៣.៦.៤ ការគំរាមគំហែង

ដោយវិស័យធនាគារ និងហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជាបានឈានជើងចូលទៅកាន់បែបផែនទីផ្សារថ្មីដែលជាលក្ខណៈបច្ចេកវិទ្យាហិរញ្ញវត្ថុ មានន័យថាការប្រើប្រាស់កម្មវិធីកុំព្យូទ័រ និងឧបករណ៍បច្ចេកវិទ្យាផ្សេងៗ ក្នុងការគ្រប់គ្រងផ្នែកហិរញ្ញវត្ថុ ការសម្រួលដល់ការផ្តល់ និងទទួលសេវាកម្មហិរញ្ញវត្ថុ ការទូទាត់ប្រាក់ និងសេវាកម្មផ្សេងៗក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុ ដូចនេះការប្រកួតប្រជែង គឺតែងតែមានច្រើន។ នេះ គឺជាការគំរាមគំហែងដល់ស្ថិរភាពមួយរបស់ធនាគារនៅក្នុងការរក្សានូវអតិថិជនរបស់ខ្លួន ដែលការគំរាមគំហែងទាំងនោះមានដូចខាងក្រោម៖

- សេវា E-Banking ត្រូវបានប្រើប្រាស់ដោយធនាគារពាណិជ្ជ ធនាគារឯកទេស រួមទាំង គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមួយចំនួនទៀត ដែលជាការប្រកួតប្រជែង ទៅលើផ្នែកបច្ចេកវិទ្យាខ្លាំង ក្នុងការអភិវឌ្ឍខ្លួនអោយនាំមុខគេបាន។
- ការពង្រីកម៉ោងការងារ ដោយការបម្រើសេវាអតិថិជន ១សប្តាហ៍ ៧ថ្ងៃ និង មួយថ្ងៃ ១២ម៉ោង៖ ការពង្រីកម៉ោងការងាររបស់ធនាគារដទៃទៀត នាពេលបច្ចុប្បន្នជានិន្នាការថ្មីមួយ ដែលធ្វើឲ្យអតិថិជនមានទំនោរទៅកាន់ការប្រើពេលវេលាបន្ថែមទៀតដើម្បីប្រើប្រាស់សេវាធនាគារ ដូចនេះ

ដើម្បីរក្សាអតិថិជន ក៏ដូចជាទាក់ទាញអតិថិជនមកប្រើប្រាស់សេវាកម្មរបស់ខ្លួនបន្ថែមធនាគារឯកទេសរឹងត្រូវតែសម្របខ្លួននឹងនិន្នាការមួយនេះ ដែលអាចជាការគំរាមគំហែងដល់ចំណូល និងចំណាយបន្ថែមទៅលើកម្លាំងពលកម្មបន្ថែម។

- ការប្រើប្រាស់បច្ចេកវិទ្យានៃការដាក់ប្រាក់ទៅក្នុងគណនីតាមរយៈម៉ាស៊ីនដាក់ប្រាក់ ដោយកាត់បន្ថយលើការកកស្ទះនៃការមកប្រើសេវាផ្ទាល់នៅធនាគារ ភ្នាក់ងារ និងសម្រួលដល់ពេលវេលារបស់អតិថិជនអាចដាក់លុយបាន២៤ម៉ោង ចូលគណនីផ្ទាល់ខ្លួន ឬគណនីភាគីទីពីរ ដោយមិនចាំបាច់ធ្វើការផ្ទេរ បន្ទាប់ពីដាក់ប្រាក់ហើយ។
- ការយកធនាគារចល័ត (Mobile Banking) តាមខ្លួនគឺមានដែនកំណត់៖ អតិថិជនអាចប្រើប្រាស់ធនាគារចល័ត ឬធនាគារតាមទូរស័ព្ទដៃរបស់ខ្លួនបានតែនៅក្នុងស្រុកប៉ុណ្ណោះ ខណៈធនាគារដទៃអនុញ្ញាតអោយអតិថិជនយកធនាគារចល័តតាមខ្លួនទៅគ្រប់ទីកន្លែងជុំវិញពិភពលោកបាន ដោយប្រើប្រាស់នៅ Internet Banking ជំនួសអោយ Mobile Banking អតិថិជនអាចធ្វើការមើលប្រតិបត្តិការរបស់ខ្លួននៅគ្រប់ទីកន្លែងនិងពេលវេលា។
- ការតភ្ជាប់ទំនាក់ទំនងដ៏ជិតស្និទ្ធរបស់ធនាគារ ជាមួយគ្រឹះស្ថានមីក្រូដទៃ៖ ធនាគារពាណិជ្ជគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមួយចំនួន គឺបានក្លាយជាសមាជិករបស់សេវាទូទាត់រហ័សរបស់ធនាគារជាតិ ដែលជាសេវាផ្ទេរប្រាក់ និងទូទាត់សងប្រាក់ជាប្រាក់រៀលឆ្លងគ្រឹះស្ថានដែលអាច អោយអតិថិជនទទួលបានមូលនិធិភ្លាមៗ ដោយឡែកនៅក្នុងចំណោមឈ្មោះសមាជិកទាំងនោះ គឺនៅមិនទាន់មានវត្តមានរឹងនៅឡើយ ដែលជាចំណុចខ្វះខាតក្នុងការចាប់យក និងផ្សារភ្ជាប់ទំនាក់ទំនងជាមួយធនាគារដទៃដើម្បីពង្រីកភាពខ្លាំងរបស់ខ្លួននៅក្នុងចំណោមធនាគារទាំងនោះ។

# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ១. សេចក្តីសន្និដ្ឋាន

ក្រោយពីបានសិក្សាស្រាវជ្រាវទៅលើប្រធានបទនេះរួចមក យើងខ្ញុំបានទទួលការយល់ដឹងជាច្រើនអំពី ប្រតិបត្តិការទូទាត់ និងសេវាផ្ទេរប្រាក់របស់ធនាគារឯកទេសវីង។ ការសិក្សាបានបង្ហាញឲ្យឃើញថា ធនាគារឯកទេសវីង គឺជាគ្រឹះស្ថានហិរញ្ញវត្ថុមួយដែលបានផ្តល់ជូននូវសេវាកម្មជាច្រើនប្រភេទរួមមានដូចជា សេវាផ្ទេរប្រាក់ក្នុង និងក្រៅប្រទេស ប្រតិបត្តិការទូទាត់វិក្កយបត្រទូទាត់តាមអ៊ីនធឺណេត វីងគិតលុយ និងសេវាផ្សេងៗទៀត។

លើសពីនេះទៅទៀត យើងអាចកត់សម្គាល់ឃើញថា ក្នុងចំណោមសេវាកម្មទាំងឡាយរបស់ធនាគារឯកទេសវីង សេវាផ្ទេរប្រាក់ គឺជាសេវាមួយដែលទទួលបានការប្រើប្រាស់ពីសំណាក់អតិថិជនជាច្រើន នៅទូទាំងប្រទេសកម្ពុជា ក៏ដូចជានៅក្រៅប្រទេសផងដែរតាមរយៈសេវាផ្ទេរប្រាក់អន្តរជាតិ។ ម្យ៉ាងទៀត សេវាផ្ទេរប្រាក់នេះផងដែរ មិនត្រឹមតែ ជួយសម្រួលការលំបាកក្នុងការផ្ទេរប្រាក់របស់អតិថិជន ដែលពុំមានគណនីធនាគារប្រើប្រាស់ប៉ុណ្ណោះទេ ថែមទាំងបានចូលរួមចំណែកជម្រុញអោយសេដ្ឋកិច្ចជាតិមានការរីកចម្រើន និងបានធ្វើឲ្យទំនាក់ទំនងជាមួយធនាគារអន្តរជាតិកាន់តែមានភាពជិតស្និទ្ធឡើង។ ទន្ទឹមនឹងនេះដែរការដាក់ចេញនូវប្រតិបត្តិការទូទាត់តាមមធ្យោបាយច្រើនជម្រើសរបស់ធនាគារឯកទេសវីង បាននឹងកំពុងរីកដុះដាលទៅមុខឥតឈប់ឈរដោយធនាគារនេះ បានខិតខំពង្រឹងលើសេវាកម្មទូទាត់របស់ខ្លួនឲ្យកាន់តែទូលំទូលាយជាងនេះ។ ជាក់ស្តែងនាពេលបច្ចុប្បន្ននេះ ប្រតិបត្តិការទូទាត់ បានចូលរួមចំណែកដោះស្រាយបញ្ហាមួយចំនួនរបស់ប្រជាជនកម្ពុជា ដូចជាការទូទាត់វិក្កយបត្រទឹកភ្លើង ការទូទាត់ថ្លៃសាលារៀន ការទូទាត់សំណងកម្ចីនានា ឬថ្លៃទំនិញជាដើម ដែលវីងបានផ្តល់នូវមធ្យោបាយថ្មីៗ និងងាយស្រួលដើម្បីឲ្យប្រជាជនកម្ពុជាអាចប្រើប្រាស់បាន។ កត្តាដែលជាសក្តានុពលរបស់ធនាគារឯកទេសវីងនោះ គឺធនាគារឯកទេសមួយនេះតែងផ្តល់នូវសេវាកម្មថ្មីៗ ខុសប្លែក ពីសេវាកម្មរបស់ធនាគារឯកទេសដទៃ ឬធនាគារពាណិជ្ជជាដើម។

យោងទៅតាមហេតុផលបង្ហាញខាងលើ យើងអាចសន្និដ្ឋានបានថា ការផ្តល់នូវប្រតិបត្តិការទូទាត់ និងសេវាផ្ទេរប្រាក់របស់ធនាគារឯកទេសវីង គឺពិតជាមានភាពល្អប្រសើរ ដល់អតិថិជនដែលជាអ្នកប្រើប្រាស់ សម្រាប់ធនាគារផ្ទាល់ដែលជាធនាគារឯកទេសនាំមុខ ព្រមទាំងសេដ្ឋកិច្ចជាតិទាំងមូលផងដែរ។ សេវាកម្មទាំងពីរនេះ បានធ្វើឲ្យសន្ទុះនៃការវិនិយោគកាន់តែមានការកើនឡើងយ៉ាងល្អប្រសើរ តាមរយៈការជួយសម្រួលដល់ការវិនិយោគទាំងក្នុង និងក្រៅប្រទេស ហើយ

វាក៏ជាកាតាលីករក្នុងការជម្រុញឲ្យប្រព័ន្ធសេដ្ឋកិច្ច និងប្រព័ន្ធហិរញ្ញវត្ថុ នៅកម្ពុជាមានការរីកចម្រើន និងមានដំណើរការល្អប្រសើរ។

## ២. ការផ្តល់អនុសាសន៍

យោងតាមការសិក្សា យើងអង្កេតឃើញថា បើទោះបី ធនាគារឯកទេសវីង គឺជាធនាគារឯកទេសក៏ពិតមែន ក៏ធនាគារបានចូលរួមឈរនៅលំដាប់មុខ ក្នុងចំណោមធនាគារដែលកំពុងតែរីកចម្រើនលើផ្នែក FinTech ដែរ។ ប៉ុន្តែ នៅក្នុងភាពខ្លាំងទាំងនោះ ធនាគារក៏នៅតែមានភាពខ្វះខាតមួយចំនួន ដែលត្រូវអភិវឌ្ឍទៅលើប្រតិបត្តិការទូទាត់ និងសេវាផ្ទេរប្រាក់ដែលជាស្នូលចម្បងនៃចំណូលរបស់ខ្លួនឲ្យកាន់តែមានភាពប្រសើរឡើង។ យើងខ្ញុំ សូមធ្វើការផ្តល់យោបល់ខ្លះៗ ដែលអាចទុកជាការពិចារណា ក្នុងគោលបំណងជួយកែលម្អ និងជាប្រយោជន៍ នៅក្នុងការជំរុញប្រតិបត្តិការទូទាត់ និងសេវាផ្ទេរប្រាក់របស់ធនាគារឯកទេសវីង ដើម្បីទាក់ទាញអតិថិជនអោយកាន់តែច្រើន ព្រមទាំងឈានជើងទៅកាន់ធនាគារលំដាប់ជួរមុខរបស់ប្រទេសកម្ពុជា ៖

- ធនាគារគួរតែមានសាខាបន្ថែម ដែលអាចចាប់ផ្តើម នៅក្នុងរាជធានីភ្នំពេញ ឬតាមបណ្តាខេត្តដែលជាសក្តានុពល នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីអនុញ្ញាតឲ្យអតិថិជនមានភាពងាយស្រួល ក្នុងការទៅប្រើប្រាស់សេវារបស់ធនាគារផ្ទាល់ជាមួយនឹងជំនឿទុកចិត្តខ្ពស់។ ជាមួយគ្នានោះ ធនាគារក៏អាចពង្រីកសក្តានុពលរបស់ខ្លួននៅទូទាំងប្រទេស និងអាចធ្វើការគ្រប់គ្រងយ៉ាងជិតស្និទ្ធ ទៅកាន់ភ្នាក់ងារវីងរបស់ខ្លួន។
- ធនាគារគួរពិចារណា ទៅលើការបង្កើនទំនាក់ទំនង ជាការសហការជាមួយក្រុមហ៊ុនធំៗ ឬភោជនីយដ្ឋានល្បីៗ ដែលជាទីពេញនិយមរបស់អតិថិជន នាពេលបច្ចុប្បន្ន តាមរយៈការសហការជាមួយប្រតិបត្តិការវីងគិតលុយ (WingPay) ជាមួយនឹងក្រុមហ៊ុនទាំងនោះ ដើម្បីបង្កើនទីផ្សារឲ្យមានអតិថិជនស្គាល់ និងការប្រើប្រាស់កាន់តែច្រើនឡើង។
- ក្រៅពីទំនាក់ទំនងរវាងពាណិជ្ជករ ធនាគារក៏គួរផ្តោតទៅលើទំនាក់ទំនងសហការនៃប្រតិបត្តិការផ្ទេររវាងធនាគារ និងធនាគារ ឬធនាគារទៅកាន់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអោយបានកាន់តែទូលាយជាងមុន។ ជាពិសេស គឺការរឹតបណ្តឹងចំណង ទាក់ទិនទៅនឹងការផ្ទេរប្រាក់ក្នុងស្រុកជាមួយធនាគារលំដាប់មុខ ដើម្បីសម្របទៅនឹងបរិបទរបស់ធនាគារជាតិ ដែលបង្កើតឲ្យមានការផ្ទេរប្រាក់ក្នុងស្រុក នៅក្រោមប្រព័ន្ធគ្រប់គ្រងផ្ទេរប្រាក់រហ័ស (Fast Payment)។ ទន្ទឹមនឹងនោះ ធនាគារក៏មានឱកាសសិក្សារវាងគ្នានឹងគ្នា ដើម្បីអភិវឌ្ឍន៍មុខជំនួញរៀងៗខ្លួនផងដែរ។

- ធនាគារគួរអភិវឌ្ឍន៍ទៅលើកម្មវិធីស្មាតហ្វូន (Wing Money Application) របស់ខ្លួន ឲ្យកាន់តែល្អបន្ថែមទៀត ទាំងដំណើរការនៅក្នុងការធ្វើប្រតិបត្តិការនីមួយៗ និងការបន្ថែមនូវភាពទាក់ទាញនៅលើកម្មវិធីឲ្យកាន់តែមានភាពងាយស្រួល ក្នុងការប្រើប្រាស់ឡើង។ លើសពីនោះ ធនាគារក៏គួរពិចារណា ទៅលើការដាក់ឲ្យប្រើប្រាស់នូវ Internet Banking ដែលអនុញ្ញាតឲ្យអតិថិជននៅតែអាចប្រើប្រាស់នូវសេវាធនាគាររបស់វីង តាមរយៈគេហទំព័រអ៊ីនធឺណេត នៅពេលអតិថិជនចេញទៅក្រៅប្រទេសផងដែរ។

# ឯកសារយោង


- ច្បាប់អនុវត្តចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ, លេខ នស/រកម/១១៩៩/១៣, ០៣ វិច្ឆិកា ១៩៩៩, មាត្រា២។
- ធនាគារឯកទេសរីង. ២០១៤. *របាយការណ៍លទ្ធផលសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែធ្នូឆ្នាំ២០១៤*, ២២។
- ធនាគារឯកទេសរីង. ២០១៥. *របាយការណ៍លទ្ធផលសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែធ្នូឆ្នាំ២០១៥*, ២៦។
- ធនាគារឯកទេសរីង. ២០១៦. *របាយការណ៍លទ្ធផលសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែធ្នូឆ្នាំ២០១៦*, ៤២។
- ហ៊ី សុខនី. ២០១៣. នីតិធនាគារ. សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច។
- ហ៊ីង ថូរ៉ាក់ស៊ី និងហ៊ាន សាហ៊ីប. ១៩៩៨. *វចនានុក្រមសេដ្ឋកិច្ច* . ភ្នំពេញ៖ អគ្គលេខាធិការដ្ឋាន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
- Dr.Hem, D. (2015, November). *Licensing of Banking and Financial Institutions in Cambodia*, p.02
- Rose, P.s., & Hudgins, S.C., 2008, "Bank management & Financial Service", p.08
- https://www.bankingcircle.com/payments-terminology-acronyms-glossary
- https://www.business.gov.au/finance/payments-and-invoicing/choosing-payment-methods
- https://pocketsense.com/advantages-money-transfers-6627547.html
- https://www.bis.org/publ/bcbsc215.pdf
- https://embily.com/the-history-of-western-union/
- https://khemsarith.wordpress.com/2016/10/12/ការសុំអាជ្ញាប័ណ្ណធនាគា-2
- http://moneygram.com.ng/how-to-send-money
- http://moneygram.com.ng/how-to-receive-
- http://www.keralabanking.com/advantages-of-payments-bank/
- https://www.wikihow.com/Transfer-Money-with-Western-Union
- http://corporate.moneygram.com/about-moneygram/history
- https://www.my-learningz.biz/2017/04/various-types-of-banks.html?m=1
- https://www.euromoney.com/article/b12kjgf8txkb94/cash-management-payment-risk
- https://en.wikipedia.org/Society_for_Worldwide_Interbank_Financial_Telecommunication

- http://tfig.unece.org/contents/payments-types.htm
- http://cststudy.blogspot.com/2018/05/specialized-banks.html
- https://business-finance.blurtit.com/107203/what-is-the-importance-of-the-banks

# របាយការណ៍ប្រតិបត្តិការអ្នកដំណើរការតតិយភាគី

## កាលបរិច្ឆេទ ៣១ ធ្នូ ២០១៨

**ឈ្មោះធនាគារ** : Wing (Cambodia) Ltd Specialised Bank

| ល.រ<br>N | សាខា<br>Branches | ចំនួនម៉ោងក្នុង១ថ្ងៃ<br>Hours per Day | ចំនួនភ្នាក់ងារ<br>Agents |
|---|---|---|---|
| ១ | កណ្តាល | ៨ ម៉ោង | ៩៩០ |
| ២ | កែប | ៨ ម៉ោង | ១៧ |
| ៣ | កោះកុង | ៨ ម៉ោង | ៦០ |
| ៤ | ក្រចេះ | ៨ ម៉ោង | ១២២ |
| ៥ | កំពង់ចាម | ៨ ម៉ោង | ៣៩១ |
| ៦ | កំពង់ឆ្នាំង | ៨ ម៉ោង | ១៥៣ |
| ៧ | កំពង់ធំ | ៨ ម៉ោង | ២២៣ |
| ៨ | កំពង់ស្ពឺ | ៨ ម៉ោង | ២៤៣ |
| ៩ | កំពត | ៨ ម៉ោង | ១៨៧ |
| ១០ | តាកែវ | ៨ ម៉ោង | ២៨៧ |
| ១១ | ត្បូងឃ្មុំ | ៨ ម៉ោង | ២៥២ |
| ១២ | បន្ទាយមានជ័យ | ៨ ម៉ោង | ២៥៨ |
| ១៣ | ប៉ៃលិន | ៨ ម៉ោង | ២៩ |
| ១៤ | បាត់ដំបង | ៨ ម៉ោង | ៣៦៩ |
| ១៥ | ពោធិ៍សាត់ | ៨ ម៉ោង | ១៤៣ |
| ១៦ | ព្រៃវែង | ៨ ម៉ោង | ២៥៤ |
| ១៧ | ព្រះវិហារ | ៨ ម៉ោង | ៨៤ |
| ១៨ | ព្រះសីហនុ | ៨ ម៉ោង | ១២៨ |
| ១៩ | ភ្នំពេញ | ៨ ម៉ោង | ១៦០៩ |
| ២០ | មណ្ឌលគិរី | ៨ ម៉ោង | ៥០ |
| ២១ | រតនគិរី | ៨ ម៉ោង | ៨៥ |
| ២២ | សៀមរាប | ៨ ម៉ោង | ៣៥៩ |
| ២៣ | ស្ទឹងត្រែង | ៨ ម៉ោង | ៥៥ |
| ២៤ | ស្វាយរៀង | ៨ ម៉ោង | ១៧៤ |
| ២៥ | ឧត្តរមានជ័យ | ៨ ម៉ោង | ៨០ |
| សរុប Total | | | ៦០០២ |

ថ្ងៃពុធ ១១រោច ខែមិគសិរ ឆ្នាំច សំរិទ្ធស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី០២ ខែមករា គ.ស.២០១៩

# Bill Payment Partner

Wing

| COMPANY | ប្រភេទ | COMPANY CODE | REFERENCE NUMBER | CUSTOMER SERVICE FEE |
|---|---|---|---|---|
| FTB Visa Cashcard | Bank Card | 7777 ($) | Card Number 16 digit | 0$-500.99$ = 2.25$<br>501$-1,000.99$ = 4.25$<br>1,001$-1,500.99$ = 6.25$<br>1,501$-2,000$ = 8.25$ |
| UCB | Bank Card | 7033 ($) | Card Number 16 digit or national ID card number 10 digit | Free |
| ធនាគារ FTB ( FTB Visa Cashcard ) | Bank Card | 7777 ($) | លេខកាត ១៦ខ្ទង់ | 0$-500.99$ = 2.25$<br>501$-1,000.99$ = 4.25$<br>1,001$-1,500.99$ = 6.25$<br>1,501$-2,000$ = 8.25$ |
| ធនាគារ កាថេ យូណៃធីត ( Cathay United Bank ) | Bank Card | 8000 ($) | លេខសម្គាល់អតិថិជន ៦ ខ្ទង់ | 0.50$ |
| ធនាគារ សហពាណិជ្ជ ក.អ ( UCB ) | Bank Card | 7033 ($) | លេខកាត ១៦ខ្ទង់ ឬ លេខអត្តសញ្ញាណប័ណ្ណ១០ខ្ទង់ | ឥតគិតថ្លៃ |
| ខេមបូឌា ឌីជីថល ធីវី ( Cambodia Digital TV ) | Cable TV Company | 7058 ($) | លេខសម្គាល់អតិថិជន ៦-១៦ខ្ទង់ | ឥតគិតថ្លៃ |
| ខេមបូឌា ឌីជីថល ធីវី ( CDTV Battambang ) | Cable TV Company | 9112 ($) | លេខសម្គាល់អតិថិជន ៦-១៦ខ្ទង់ | ឥតគិតថ្លៃ |
| ភីភីស៊ីធីវី ( PPCTV ) | Cable TV Company | 6768 ($) | លេខវិក្កយបត្រ ១៤-១៦ខ្ទង់ | ឥតគិតថ្លៃ |
| វ៉ាន់ធីវី | Cable TV Company | 6363 ($) | លេខកិច្ចសន្យា ១០ខ្ទង់ | ឥតគិតថ្លៃ |
| ក្រុមហ៊ុន សុវណ្ណភូមិ ឡាយហ្វ៍ អឹស្យូរ៉ែនស៍ ភីអិលស៊ី ( Sovannaphum Life Assurance Plc ) | Insurance Company | 9009 ($) | លេខបណ្ណសន្យា ៦-១០ខ្ទង់ | ឥតគិតថ្លៃ |
| ក្រុមហ៊ុនធានារ៉ាប់រង BIMA ( BIMA Insurance ) | Insurance Company | 7272 ($) | លេខទូរស័ព្ទ ៩-១០ខ្ទង់ | ឥតគិតថ្លៃ |
| ក្រុមហ៊ុនធានារ៉ាប់រង អេអាយអេ ឡាយហ្វ៍អិនស្វ៊ិន ( AIA Life Insurance ) | Insurance Company | 1168($) | លេខបណ្ណសន្យា ១០ខ្ទង់ | ឥតគិតថ្លៃ |
| ក្រុមហ៊ុនធានារ៉ាប់រង អ៊ិនហ្វីនីធី អិនស្វ៊ិន | Insurance Company | 7019 ($) | លេខយោងវិក្កយបត្រ ៨ខ្ទង់ | ឥតគិតថ្លៃ |
| ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត កម្ពុជាឡាយហ្វ៍ ( Camlife ) | Insurance Company | 5678 ($) | លេខបណ្ណសន្យា ៨ខ្ទង់ ឬលេខកូដវិក្កយបត្រ ១២ខ្ទង់ | ឥតគិតថ្លៃ |
| ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត ព្រូដិនសល ( Prudential ) | Insurance Company | 6666 ($) | លេខពាក្យស្នើសុំ ៨-៩ខ្ទង់ | ឥតគិតថ្លៃ |
| ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត មេនូឡាយហ្វ៍ ( Manulife ) | Insurance Company | 8989 ($) | លេខបណ្ណសន្យា ១០ខ្ទង់ ឬលេខកូដ ១២ខ្ទង់ | ឥតគិតថ្លៃ |

| COMPANY | ប្រភេទ | COMPANY CODE | REFERENCE NUMBER | CUSTOMER SERVICE FEE |
|---|---|---|---|---|
| EZECOM | Internet Company | 5151 ($) | លេខសម្គាល់អតិថិជន ២-៦ខ្ទង់ | ឥតគិតថ្លៃ |
| KINGTEL | Internet Company | 7017 ($) | លេខសម្គាល់អតិថិជន ៤-៨ខ្ទង់ | ឥតគិតថ្លៃ |
| Online | Internet Company | 7077 ($) | លេខសម្គាល់អតិថិជន ២-៧ខ្ទង់ | 0.50$ |
| S.I Group | Internet Company | 7999 ($) | លេខសម្គាល់អតិថិជន ១០ខ្ទង់ | ឥតគិតថ្លៃ |
| SingMeng | Internet Company | 1166 ($) | លេខសម្គាល់អតិថិជន ៨ខ្ទង់ | ឥតគិតថ្លៃ |
| ក្រុមហ៊ុន ធូដេ ( Today Communication ) | Internet Company | 9084 ($) | Customer's ID 6 digit | Free |
| ក្រុមហ៊ុន មេគង្គណេត ( MekongNet ) | Internet Company | 9106 ($) | លេខសម្គាល់អតិថិជន ៦ខ្ទង់ | ឥតគិតថ្លៃ |
| ក្រុមហ៊ុន អ៊ិនធឺណេត ហូម ( Internet Home ) | Internet Company | 9111 ($) | លេខសម្គាល់អតិថិជន ២-៧ខ្ទង់ | 0.50$ |
| ឌីជី Digi ( Digi Internet ) | Internet Company | 3444 ($) | លេខសម្គាល់អតិថិជន ៦ខ្ទង់ | ឥតគិតថ្លៃ |
| ទូរគមនាគមន៍កម្ពុជា ( Telecom Cambodia ) | Internet Company | 7074 ($) | លេខយោង ១២ខ្ទង់ | 0-25$ = 0.25$<br>25.10$-3,000$ = 0.50$ |
| វ៉ាយហ្វាយណែត ( WiFi Net ) | Internet Company | 6655 ($) | លេខវិក្កយបត្រ ៦ខ្ទង់ | ឥតគិតថ្លៃ |
| ឆាយលីស រ៉ូយ៉ាល់ លីស៊ីង ម.ក ( Chailease Royal Leasing Plc ) | Leasing | 8083 ($) | លេខសម្គាល់អតិថិជន ៧ខ្ទង់ | 0.50$ |
| ជី អិល គូបូតា ( GLF Kubota ) | Leasing | 6778 ($) | លេខកិច្ចសន្យា ៨ខ្ទង់ | ឥតគិតថ្លៃ |
| ជី អិល ហ្វាយណាន់ ( Collection ) | Leasing | 6779 ($) | លេខសម្គាល់បុគ្គលិក ៨ខ្ទង់ | ឥតគិតថ្លៃ |
| ជី អិល ហ្វាយណាន់ ( GL Finance ) | Leasing | 6777 ($) | លេខកិច្ចសន្យា ៨ខ្ទង់ | ឥតគិតថ្លៃ |

| | | | | | |
|---|---|---|---|---|---|
| | ជី អិល ហ្វាយណាន់ (Solar) | Leasing | 6780 ($) | លេខកម្ចី ៨ខ្ទង់ | ឥតគិតថ្លៃ |
| | តូយ៉ូតា ស៊ូយស៊ូ ហ្វាយនែន (Toyota Tsusho Finance) | Leasing | 5599 ($) | លេខកិច្ចសន្យា ១១ខ្ទង់ | ឥតគិតថ្លៃ |
| | មេហ្គា លីស៊ីង (Mega Leasing Plc) | Leasing | 8181 ($) | លេខសម្គាល់អតិថិជន ១០ ឬ១៥ខ្ទង់ | 0.50$ |
| | អ អិម អេ ខេមបូឌា RMA Financial Service | Leasing | 7068 ($) | លេខសម្គាល់អតិថិជន ១០ខ្ទង់ | 1.00$ |
| | អាយ ហ្វាយនែន ភីអិលស៊ី (I-Finance Leasing Plc) | Leasing | 7063 ($) | លេខសម្គាល់អតិថិជន ១២ខ្ទង់ | 0.50$ |
| | អ៊ីន ប៊ីសណេស ម.ក (InBizNest Plc) | Leasing | 1112 ($) | លេខសម្គាល់អតិថិជន ១០-១៥ខ្ទង់ | 0.50$ |
| | ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត (Camma MFI) | Microfinance Institutions | 7061 (៛) \| 7060 ($) | លេខកម្ចី ១៥ខ្ទង់ | 2,000៛ ឬ 0.50$ |
| | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ចំរើន (Chamroeun Microfinance) | Microfinance Institutions | 7756 (៛) \| 7755 ($) | លេខគណនី ១៥ខ្ទង់ (លេខសាខា ៣ខ្ទង់ + លេខគណនី ១២ ខ្ទង់) | 2,000៛ ឬ 0.50$ |
| | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឆាយលីស រ៉ូយ៉ាល់ លីស៊ីង (Chailease Royal Leasing Plc.) | Microfinance Institutions | 8085 ($) | លេខកិច្ចសន្យា ៧ ខ្ទង់ | 2,000៛ ឬ 0.50$ |
| | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដាប់ប៊ែលយូប៊ី ហ្វាយនែន (WB Finance) | Microfinance Institutions | 7026 (៛) \| 7025 ($) | លេខគណនី ៧-៨ខ្ទង់ | ឥតគិតថ្លៃ |
| | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ណុងហ៊ីប ហ្វាយនែន (ខេមបូឌា) ម.ក (NongHyup Finance) | Microfinance Institutions | 9099 (៛) \| 9098 ($) | លេខសម្គាល់អតិថិជន ១០ខ្ទង់ | ឥតគិតថ្លៃ |
| | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ បរិបូរណ៍ (Borribo) | Microfinance Institutions | 8222 ($) | លេខសម្គាល់អតិថិជន ៦ខ្ទង់ | 2,000៛ ឬ 0.50$ |
| | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ពិភពថ្មី (Piphup Thmey MFI) | Microfinance Institutions | 1688 ($) | លេខគណនី ១២ខ្ទង់ | 2,000៛ ឬ 0.50$ |
| | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ រ៉ូយ៉ាល់ ម៉ាយក្រូហ្វាយនែន ភីអិលស៊ី (Royal Finance Plc) | Microfinance Institutions | 7023 ($) \| 7024 (៛) | លេខកម្ចី ១២ខ្ទង់ | ឥតគិតថ្លៃ |
| | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ វែលខម ហ្វាយនែន (ខេម្ជា) ម.ក(Welcome Finance Cambodia Plc.) | Microfinance Institutions | 9103 ($) \| 9105 (៛) | លេខសម្គាល់អតិថិជន ១២ខ្ទង់ | 2,000៛ ឬ 0.50$ |
| | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ វ៉ាយ ស៊ីភី (YCP MFI) | Microfinance Institutions | 8899 ($) \| 8799 (៛) | លេខគណនី ១១-១២ខ្ទង់ | 2,000៛ ឬ 0.50$ |

| | | | | |
|---|---|---|---|---|
| គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ សហការ ភីអិលស៊ី (Sahaka Microfinance Institute PLC.) | Microfinance Institutions | 9114 ($) \| 9115 (៛) | លេខគណនី ១៤ ខ្ទង់ | 2,000៛ ឬ 0.50$ |
| គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ សំរិទ្ធិស័ក (Samrithisak) | Microfinance Institutions | 8888 ($) \| 8887 (៛) | លេខកម្ចី ១២-១៥ខ្ទង់ | 2,000៛ ឬ 0.50$ |
| គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ស៊ីធី ភីអិលស៊ី (City MFI) | Microfinance Institutions | 7083 ($) | លេខសម្គាល់អតិថិជន ១២ខ្ទង់ | 2,000៛ ឬ 0.50$ |
| គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វឹសហ្វាយនែន (First Finance MFI) | Microfinance Institutions | 1120 ($) | Leasing Number 6-14 digit | Free |
| គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វឹសហ្វាយនែន (First Finance) | Microfinance Institutions | 1120 ($) | លេខកម្ចី ៦-១៤ខ្ទង់ | ឥតគិតថ្លៃ |
| គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អនាគត ភីអិលស៊ី (Anakut MFI) | Microfinance Institutions | 8005 ($) \| 8007 (៛) | លេខគណនី ១៧ខ្ទង់ | 2,000៛ ឬ 0.50$ |
| គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អមតៈ (Amatak MFI) | Microfinance Institutions | 3233 ($) \| 4233 (៛) | លេខកិច្ចសន្យា ១២-១៥ខ្ទង់ | 2,000៛ ឬ 0.50$ |
| គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រ៉ែត (Amret MFI) | Microfinance Institutions | 9094 ($) \| 9095 (៛) | លេខគណនី ៦-១២ខ្ទង់ | 0.25$ |
| គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាក់ទីវភីភល (Active People's MFI) | Microfinance Institutions | 7575 (៛) \| 7676 ($) | លេខគណនី ៨ខ្ទង់ | 2,000៛ ឬ 0.50$ |
| គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិលអូអិលស៊ី | Microfinance Institutions | 9987 (៛) \| 9988 ($) | លេខកម្ចី ១៤ - ១៥ខ្ទង់ | ឥតគិតថ្លៃ |
| គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឥណទានពលរដ្ឋរុងរឿង អិលធីឌី (Intean Poalroath Rongroeurng Ltd.,) | Microfinance Institutions | 7789 ($) \| 7790 (៛) | លេខគណនី ១៤ ខ្ទង់ | 2,000៛ ឬ 0.50$ |
| គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ សូណាត្រា ភីអិលស៊ី (Sonatra Microfinance Plc) | Microfinance Institutions | 9126 ($) \| 9127 (៛) | លេខឥណទានអតិថិជន ១-៥ ខ្ទង់ | 2,000៛ ឬ 0.50$ |
| ជី អិល ហ្វាយនែន (GL Finance) | Microfinance Institutions | 6777 ($) | លេខកិច្ចសន្យា ៨ ខ្ទង់ | ឥតគិតថ្លៃ |
| ជី អិល ហ្វាយនែន គូបូតា (GLF Kubota) | Microfinance Institutions | 6778 ($) | លេខអតិថិជន ៨ ខ្ទង់ | ឥតគិតថ្លៃ |
| ជី អិល ហ្វាយនែន សូឡា (GL Finance Solar) | Microfinance Institutions | 6780 ($) | លេខអតិថិជន ៨ ខ្ទង់ | ឥតគិតថ្លៃ |

| | | | | |
|---|---|---|---|---|
| ជេកស៍ ហ្វាយនែន (JACCS Finance) | Microfinance Institutions | 9121 ($) | លេខសម្គាល់អតិថិជន ៨ ខ្ទង់ | 2,000៛ ឬ 0.50$ |
| តូយ៉ូតា ស៊ុយស៊ូ ហ្វាយនែន (ខេមបូឌា) ភីអិលស៊ី ( TOYOTA TSUSHO Finance) | Microfinance Institutions | 5599 ($) | លេខកិច្ចសន្យា ១១ ខ្ទង់ | ឥតគិតថ្លៃ |
| ធនាគារ ស្ថាបនា ភីអិលស៊ី (Sathapana Bank Plc) | Microfinance Institutions | 9107 ($) \| 9108 (៛) | លេខគណនី ១៧ខ្ទង់ | 0.25$ |
| ធនាគារឯកទេស អ៊ីអន (AEON) | Microfinance Institutions | 1366 ($) | លេខកិច្ចសន្យា ១២-១៨ខ្ទង់ | 2,000៛ ឬ 0.50$ |
| ធនាគារ ប្រៃសណីយ៍ កម្ពុជា ក.អ (Cambodia Post Bank Plc) | Microfinance Institutions | 7087 (៛) \| 7079 ($) | លេខគណនី ១២ខ្ទង់ | 2,000៛ ឬ 0.50$ |
| និរន្តរ មីក្រូហិរញ្ញវត្ថុ (NIRON MFI) | Microfinance Institutions | 8868 (៛) 8869 ($) | Customer's ID 9 digit | Free |
| ព្រីនស៍ ហ្វាយនែនភីអិលស៊ី (Prince Finance) | Microfinance Institutions | 7031 (៛) \| 7030 ($) | លេខគណនី ៩-១៧ខ្ទង់ | 2,000៛ ឬ 0.50$ |
| មេហ្គា លីស៊ីង ភីអិលស៊ី (Mega Leasing Plc.) | Microfinance Institutions | 8181 ($) | លេខសម្គាល់អតិថិជន ១-១៥ ខ្ទង់ | 2,000៛ ឬ 0.50$ |
| ម៉ាក់ស៊ីម៉ា ភីអិលស៊ី (Maxima MFI) | Microfinance Institutions | 8086 ($) | លេខសម្គាល់អតិថិជន ៨ខ្ទង់ | 2,000៛ ឬ 0.50$ |
| លែនថេក (ខេមបូឌា) ឯ.ក (Lendtech Cambodia Co., Ltd) | Microfinance Institutions | 5562 ($) | លេខកម្ចី ៨ ខ្ទង់ | 2,000៛ ឬ 0.50$ |
| វីស៊ិនហ្វាន់ (Vision Fund) | Microfinance Institutions | 7026 (៛) 7025 ($) | Account Number 7 digit | 1,600៛ or 0.40$ |
| សម្បត្តិ ហ្វាយនែន ភីអិលស៊ី (Sambat Finance) | Microfinance Institutions | 7027 ($) \| 8027 (៛) | លេខគណនីសន្សំ ១៣ខ្ទង់ | 2,000៛ ឬ 0.50$ |
| សាមិក មីក្រូហិរញ្ញវត្ថុ (Samic Plc) | Microfinance Institutions | 9099 (៛) 9098 ($) | Customer's ID 11 digit | Free |
| សួស្តី ហ្វាយនែន (Suosdey Finance) | Microfinance Institutions | 5522 ($) | លេខកម្ចី ១៨ខ្ទង់ | 2,000៛ ឬ 0.50$ |
| សេអឹមកា (CMK) | Microfinance Institutions | 7005 (៛) \| 7004 ($) | លេខសម្គាល់អតិថិជន ៨ខ្ទង់ (លេខសាខា ៣ខ្ទង់ + លេខគណនី ៥ខ្ទង់) | 2,000៛ ឬ 0.50$ |
| សែលកាតហ្វាយនែន (Cellcard Finance) | Microfinance Institutions | 7003 ($) | លេខកម្ចី ១០ខ្ទង់ | ឥតគិតថ្លៃ |

| | | | | |
|---|---|---|---|---|
| ហ្វូណន មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី (Funan MFI) | Microfinance Institutions | 8004 (៛) \| 8003 ($) | លេខគណនី ១៧ខ្ទង់ | 2,000៛ ឬ 0.50$ |
| ហ្វូតាបា មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី (Futaba MFI) | Microfinance Institutions | 9086 ($) \| 9131 (៛) | លេខគណនី ១០ខ្ទង់ | 2,000៛ ឬ 0.50$ |
| អង្គការឥណទាន បៃតង (Baytang Credit Organization) | Microfinance Institutions | 8081 (៛) \| 8082 ($) | លេខសម្គាល់អតិថិជន ១៥ខ្ទង់ | ឥតគិតថ្លៃ |
| អង្គការឥនទាន បៃតង (Baytang Credit Organization) | Microfinance Institutions | 8081 (៛) 8082 ($) | Leasing Number 15 digit | Free |
| អរអិមអេ ហ្វាយនែនសល សឺវីស (ខេមបូឌា) ភីអិលស៊ី(RMA Financial Service) | Microfinance Institutions | 7068 ($) | លេខកូតអតិថិជន ១០ ខ្ទង់ | 1$ |
| អាយហ្វាយនែន លីស៊ីង ភីអិលស៊ី (I-Finance leasing Plc.) | Microfinance Institutions | 7063 ($) | លេខគណនី ៨-១៨ ខ្ទង់ | 2,000៛ ឬ 0.50$ |
| អិល ប៊ី ភី មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី (L B P MFI) | Microfinance Institutions | 7172 ($) \| 7174 (៛) | លេខគណនី ៦ខ្ទង់ | 2,000៛ ឬ 0.50$ |
| អូរ៉ូហ្វាយនែន (ORO Finance) | Microfinance Institutions | 7020 ($) | លេខគណនី ១២ខ្ទង់ | 1.50$ |
| អេលីន លីស៊ីង ភីអិលស៊ី (Elin Leasing) | Microfinance Institutions | 3610 ($) | លេខកិច្ចសន្យា ១០ ខ្ទង់ | ឥតគិតថ្លៃ |
| អ៊ីដេមីតស៊ូ សេហ្សុង ម៉ាយក្រូហ្វាយនែន (IDEMITSU SAISON MICROFINANCE) | Microfinance Institutions | 7038 (៛) \| 7037 ($) | លេខកម្ចី ១២ខ្ទង់ | 2,000៛ ឬ 0.50$ |
| អ៊ីនប៊ីសណេស ភីអិលស៊ី (InBizNest Plc.) | Microfinance Institutions | 1112 ($) | លេខកម្ចី ១០ ខ្ទង់ | 2,000៛ ឬ 0.50$ |
| E – School Cambodia | School | 9144 ($) | លេខសម្គាល់សិស្ស ៧ខ្ទង់ | ឥតគិតថ្លៃ |
| ក្រុមសាលារៀនរបស់ NTC Group* | School | 9333 ($) | លេខសម្គាល់សិស្ស ៧ខ្ទង់ | ឥតគិតថ្លៃ |
| មូលនិធិ ដុនបូស្កូកម្ពុជា (Don Bosco Foundation of Cambodia) | School | 9142 ($) | លេខសម្គាល់សិស្ស ១៣ ខ្ទង់ | ឥតគិតថ្លៃ |
| វិទ្យាស្ថាន CamEd | School | 7050 ($) | លេខសម្គាល់សិស្ស ៩ខ្ទង់ | 1.00$ |

| | | | | | |
|---|---|---|---|---|---|
| | សកលវិទ្យាល័យ បញ្ញាសាស្ត្រកម្ពុជា | School | 9116 ($) | លេខសម្គាល់សិស្ស ៥-៦ខ្ទង់ | 1.00$ |
| | សាលាអន្តរជាតិវេស្ទើន (ថ្លៃផ្សេងៗ) | School | 7080 ($) | លេខសម្គាល់សិស្ស ៦-១០ខ្ទង់ | ឥតគិតថ្លៃ |
| | សាលាអន្តរជាតិវេស្ទើន (ថ្លៃសាលា) | School | 7078 ($) | លេខសម្គាល់សិស្ស ៦-១០ខ្ទង់ | ឥតគិតថ្លៃ |
| | សាលាភាសាអង់គ្លេស អ៊ែតនិច (Ednich English School) | School | 9128 ($) | លេខសម្គាល់សិស្ស ៦ខ្ទង់ | ឥតគិតថ្លៃ |
| | សែលកាត (Post Paid) | Telecommunication | 6969 ($) | លេខទូរស័ព្ទ ៨-១០ខ្ទង់ | ឥតគិតថ្លៃ |
| | រដ្ឋាករទឹកភ្នំពេញ (PPWSA) | Utilities | 7240 (៛) | លេខវិក្កយបត្រ ១- ១៥ ខ្ទង់ | 0-100,000៛ = 1,000៛<br>> 100,000៛ = 2,000៛ |
| | រដ្ឋាករទឹកសៀមរាប (SRWSA) | Utilities | 7700 (៛) | លេខសម្គាល់អតិថិជន ១០ខ្ទង់ | 0-100,000៛ = 1,000៛<br>> 100,000៛ = 2,000៛ |
| | សេវាករ អគ្គិសនី-ទឹក (Electricity Licensee and Water Supply) | Utilities | 6065 (៛) | លេខសម្គាល់អតិថិជន ៩ខ្ទង់ | 800៛ |
| | អគ្គិសនីកែវសីមា (EDC Keo Seyma) | Utilities | 7092 (៛) | លេខទីតាំងប្រើប្រាស់ចរន្ត ៧-៨ខ្ទង់ Consumer Number (7 - 8 ខ្ទង់) | 0-100,000៛ = 1,000៛<br>> 100,000៛ = 2,000៛ |
| | អគ្គិសនីកោះញែក (EDC Koh Nhek) | Utilities | 9118 (៛) | លេខទីតាំងប្រើប្រាស់ចរន្ត ៧-៨ខ្ទង់ Consumer Number (7 - 8 ខ្ទង់) | 0-100,000៛ = 1,000៛<br>> 100,000៛ = 2,000៛ |
| | អគ្គិសនីកំពង់ចាម (EDC Kampong Cham) | Utilities | 7045 (៛) | លេខទីតាំងប្រើប្រាស់ចរន្ត ៧-៨ខ្ទង់ Consumer Number (7 - 8 ខ្ទង់) | 0-100,000៛ = 1,000៛<br>> 100,000៛ = 2,000៛ |
| | អគ្គិសនីកំពង់ត្រាច (EDC Kampong Trach) | Utilities | 7069 (៛) | លេខទីតាំងប្រើប្រាស់ចរន្ត ៧-៨ខ្ទង់ Consumer Number (7 - 8 ខ្ទង់) | 0-100,000៛ = 1,000៛<br>> 100,000៛ = 2,000៛ |
| | អគ្គិសនីកំពង់រោទិ៍ (EDC Kampong Rou) | Utilities | 7065 (៛) | លេខទីតាំងប្រើប្រាស់ចរន្ត ៧-៨ខ្ទង់ Consumer Number (7 - 8 ខ្ទង់) | 0-100,000៛ = 1,000៛<br>> 100,000៛ = 2,000៛ |
| | អគ្គិសនីកំពង់ស្ពឺ (EDC Kampong Speu) | Utilities | 7046 (៛) | លេខទីតាំងប្រើប្រាស់ចរន្ត ៧-៨ខ្ទង់ Consumer Number (7 - 8 ខ្ទង់) | 0-100,000៛ = 1,000៛<br>> 100,000៛ = 2,000៛ |
| | អគ្គិសនីកំពង់ស្រឡៅ (EDC Kampong Sralao) | Utilities | 7085 (៛) | លេខទីតាំងប្រើប្រាស់ចរន្ត ៧-៨ខ្ទង់ Consumer Number (7 - 8 ខ្ទង់) | 0-100,000៛ = 1,000៛<br>> 100,000៛ = 2,000៛ |

| | | | | |
|---|---|---|---|---|
| អគ្គិសនីកំពត (EDC Kompot) | Utilities | 7072 (៛) | លេខទីតាំងប្រើប្រាស់ចរន្ត ៧-៨ខ្ទង់ Consumer Number (7 - 8 ខ្ទង់) | 0-100,000៛ = 1,000៛<br>> 100,000៛ = 2,000៛ |
| អគ្គិសនីក្រចេះ (EDC Kratie) | Utilities | 7096 (៛) | លេខទីតាំងប្រើប្រាស់ចរន្ត ៧-៨ខ្ទង់ Consumer Number (7 - 8 ខ្ទង់) | 0-100,000៛ = 1,000៛<br>> 100,000៛ = 2,000៛ |
| អគ្គិសនីជាំក្រវៀន (EDC Choam Krovien) | Utilities | 9147(៛) | លេខទីតាំងប្រើប្រាស់ចរន្ត ៧-៨ខ្ទង់ Consumer Number (7 - 8 ខ្ទង់) | 0-100,000៛ = 1,000៛<br>> 100,000៛ = 2,000៛ |
| អគ្គិសនីជីភូ (EDC Chipou) | Utilities | 7056 (៛) | លេខទីតាំងប្រើប្រាស់ចរន្ត ៧-៨ខ្ទង់ Consumer Number (7 - 8 ខ្ទង់) | 0-100,000៛ = 1,000៛<br>> 100,000៛ = 2,000៛ |
| អគ្គិសនីតាកែវ (EDC Takeo) | Utilities | 7051 (៛) | លេខទីតាំងប្រើប្រាស់ចរន្ត ៧-៨ខ្ទង់ Consumer Number (7 - 8 ខ្ទង់) | 0-100,000៛ = 1,000៛<br>> 100,000៛ = 2,000៛ |
| អគ្គិសនីត្បូងឃ្មុំ (EDC Tbong Khmum) | Utilities | 9146 (៛) | លេខទីតាំងប្រើប្រាស់ចរន្ត ៧-៨ខ្ទង់ Consumer Number (7 - 8 ខ្ទង់) | 0-100,000៛ = 1,000៛<br>> 100,000៛ = 2,000៛ |
| អគ្គិសនីបន្ទាយមានជ័យ (EDC Banteay Meanchey) | Utilities | 7064 (៛) | លេខទីតាំងប្រើប្រាស់ចរន្ត ៧-៨ខ្ទង់ Consumer Number (7 - 8 ខ្ទង់) | 0-100,000៛ = 1,000៛<br>> 100,000៛ = 2,000៛ |
| អគ្គិសនីបាត់ដំបង (EDC Battambang) | Utilities | 1515 (៛) | លេខទីតាំងប្រើប្រាស់ចរន្ត ៧-៨ខ្ទង់ Consumer Number (7 - 8 ខ្ទង់) | 0-100,000៛ = 1,000៛<br>> 100,000៛ = 2,000៛ |
| អគ្គិសនីបាវិត (EDC Bavet) | Utilities | 7059 (៛) | លេខទីតាំងប្រើប្រាស់ចរន្ត ៧-៨ខ្ទង់ Consumer Number (7 - 8 ខ្ទង់) | 0-100,000៛ = 1,000៛<br>> 100,000៛ = 2,000៛ |
| អគ្គិសនីពញាក្រែក (EDC Ponhea Krek) | Utilities | 7047 (៛) | លេខទីតាំងប្រើប្រាស់ចរន្ត ៧-៨ខ្ទង់ Consumer Number (7 - 8 ខ្ទង់) | 0-100,000៛ = 1,000៛<br>> 100,000៛ = 2,000៛ |
| អគ្គិសនីពេជ្រាដា (EDC Pichitda) | Utilities | 9120 (៛) | លេខទីតាំងប្រើប្រាស់ចរន្ត ៧-៨ខ្ទង់ Consumer Number (7 - 8 ខ្ទង់) | 0-100,000៛ = 1,000៛<br>> 100,000៛ = 2,000៛ |
| អគ្គិសនីព្រៃវែង (EDC Prey Veng) | Utilities | 7088 (៛) | លេខទីតាំងប្រើប្រាស់ចរន្ត ៧-៨ខ្ទង់ Consumer Number (7 - 8 ខ្ទង់) | 0-100,000៛ = 1,000៛<br>> 100,000៛ = 2,000៛ |
| អគ្គិសនីព្រះសីហនុ (EDC Sihanouk) | Utilities | 9797 (៛) | លេខទីតាំងប្រើប្រាស់ចរន្ត ៧-៨ខ្ទង់ Consumer Number (7 - 8 ខ្ទង់) | 0-100,000៛ = 1,000៛<br>> 100,000៛ = 2,000៛ |
| អគ្គិសនីភ្នំពេញ (EDC Phnom Penh) | Utilities | 7500 (៛) | លេខទីតាំងប្រើប្រាស់ចរន្ត ៧-៨ខ្ទង់ Consumer Number (7 - 8 ខ្ទង់) | 0-100,000៛ = 1,000៛<br>> 100,000៛ = 2,000៛ |

| | | | | | |
|---|---|---|---|---|---|
| | អគ្គិសនីមង្គលបុរី (EDC Mongkol Borey) | Utilities | 7053 (៛) | លេខទីតាំងប្រើប្រាស់ចរន្ត ៧-៨ខ្ទង់ Consumer Number (7 - 8 ខ្ទង់) | 0-100,000៛ = 1,000៛<br>> 100,000៛ = 2,000៛ |
| | អគ្គិសនីមេមត់ (EDC Memot) | Utilities | 7048 (៛) | លេខទីតាំងប្រើប្រាស់ចរន្ត ៧-៨ខ្ទង់ Consumer Number (7 - 8 ខ្ទង់) | 0-100,000៛ = 1,000៛<br>> 100,000៛ = 2,000៛ |
| | អគ្គិសនីរតនគិរី (EDC Rattanakiri) | Utilities | 7086 (៛) | លេខទីតាំងប្រើប្រាស់ចរន្ត ៧-៨ខ្ទង់ Consumer Number (7 - 8 ខ្ទង់) | 0-100,000៛ = 1,000៛<br>> 100,000៛ = 2,000៛ |
| | អគ្គិសនីសៀមរាប (EDC Siem Reap) | Utilities | 6600 (៛) | លេខទីតាំងប្រើប្រាស់ចរន្ត ៧-៨ខ្ទង់ Consumer Number (7 - 8 ខ្ទង់) | 0-100,000៛ = 1,000៛<br>> 100,000៛ = 2,000៛ |
| | អគ្គិសនីសែនមនោរម្យ (EDC Senmonorom) | Utilities | 7090 (៛) | លេខទីតាំងប្រើប្រាស់ចរន្ត ៧-៨ខ្ទង់ Consumer Number (7 - 8 ខ្ទង់) | 0-100,000៛ = 1,000៛<br>> 100,000៛ = 2,000៛ |
| | អគ្គិសនីស្ទឹងត្រែង (EDC Steung Treng) | Utilities | 7084 (៛) | លេខទីតាំងប្រើប្រាស់ចរន្ត ៧-៨ខ្ទង់ Consumer Number (7 - 8 ខ្ទង់) | 0-100,000៛ = 1,000៛<br>> 100,000៛ = 2,000៛ |
| | អគ្គិសនីស្នួល (EDC Snoul) | Utilities | 7094 (៛) | លេខទីតាំងប្រើប្រាស់ចរន្ត ៧-៨ខ្ទង់ Consumer Number (7 - 8 ខ្ទង់) | 0-100,000៛ = 1,000៛<br>> 100,000៛ = 2,000៛ |
| | អគ្គិសនីស្វាយរៀង (EDC Svay Rieng) | Utilities | 7067 (៛) | លេខទីតាំងប្រើប្រាស់ចរន្ត ៧-៨ខ្ទង់ Consumer Number (7 - 8 ខ្ទង់) | 0-100,000៛ = 1,000៛<br>> 100,000៛ = 2,000៛ |
| | អគ្គិសនីអង្គតាសោម (EDC Ang Tasom) | Utilities | 7062 (៛) | លេខទីតាំងប្រើប្រាស់ចរន្ត ៧-៨ខ្ទង់ Consumer Number (7 - 8 ខ្ទង់) | 0-100,000៛ = 1,000៛<br>> 100,000៛ = 2,000៛ |
| ANGKOR DAVANN | ANGKOR DAVANN | Other Companies | 7780 (៛) \| 7779 ($) | លេខសម្គាល់អតិថិជន ៦ខ្ទង់ | ឥតគិតថ្លៃ |
| | Betagro (Cambodia) | Other Companies | 7049 ($) | លេខសម្គាល់អតិថិជន ១០ខ្ទង់ | ឥតគិតថ្លៃ |
| CAMHR.com | CamHR | Other Companies | 6688 ($) | លេខសម្គាល់និយោជក ១-១០ខ្ទង់ | ឥតគិតថ្លៃ |
| gear | G Gear (LG) | Other Companies | 5567 ($) | លេខសម្គាល់អតិថិជន ៩-១០ខ្ទង់ | ឥតគិតថ្លៃ |
| | Kenda Shop | Other Companies | 1566 ($) | លេខវិក្កយបត្រ ៤-១២ខ្ទង់ | 1.50$ |
| | Khmer Mondial Dealer | Other Companies | 9898 ($) | លេខវិក្កយបត្រ ៦-១២ខ្ទង់ | ឥតគិតថ្លៃ |

| | | | | |
|---|---|---|---|---|
| Kosign (Cambodia) | Other Companies | 3333 ($) | គណនីនិម្មិត (Virtual Account) ១២ខ្ទង់ | ឥតគិតថ្លៃ |
| MWDIS International Co., Ltd | Other Companies | 9117($) | លេខសម្គាល់អតិថិជន ៤-១២ខ្ទង់ | ឥតគិតថ្លៃ |
| Nitrogen Chemicals & Fertilizer | Other Companies | 7076 ($) | លេខទូរស័ព្ទ ៥-១០ខ្ទង់ | ឥតគិតថ្លៃ |
| NKR Trading Co., Ltd | Other Companies | 9109 ($) | លេខវិក្កយបត្រ ៤-១២ខ្ទង់ | 1.50$ |
| Ovtras GPS Company | Other Companies | 7002 ($) | លេខសម្គាល់ពាក្យស្នើសុំ (Application) ៦ខ្ទង់ | 0.50$ |
| Piseth Shop | Other Companies | 7028 ($) | លេខកិច្ចសន្យា ៦-១២ខ្ទង់ | ឥតគិតថ្លៃ |
| TECHXPERT Limited | Other Companies | 6789 ($) | លេខសម្គាល់អតិថិជន ៧-១២ខ្ទង់ | 1.50$ |
| THY MEAN HENG | Other Companies | 7044 (៛) \| 7043 ($) | លេខសម្គាល់អតិថិជន ៥-១០ខ្ទង់ | ឥតគិតថ្លៃ |
| VT Grow | Other Companies | 7035 (៛) \| 7034 ($) | លេខសម្គាល់អតិថិជន ៥ខ្ទង់ | ឥតគិតថ្លៃ |
| Yong Sheng Global Trading | Other Companies | 7057 ($) | លេខសម្គាល់អតិថិជន ៥-១០ខ្ទង់ | ឥតគិតថ្លៃ |
| កាហុក (KaHok) | Other Companies | 7006 ($) | លេខសម្គាល់ហាង/ លេខសម្គាល់អតិថិជន ៤ខ្ទង់ | ឥតគិតថ្លៃ |
| កាំវើក (KAMWORKS) | Other Companies | 8585 ($) | លេខសម្គាល់អតិថិជន ៥ខ្ទង់ | ឥតគិតថ្លៃ |
| ក្រសួងសាធារណការ និងដឹកជញ្ជូន (MPWT) | Other Companies | 7066 (៛) | លេខវិក្កយបត្រ ១៣ខ្ទង់ | 0 - 100,000 ៛ = 1,000៛<br>លើសពី 100,000 ៛ - 2,600,000 ៛ = 2,000៛<br>លើសពី 2,600,000 ៛ - 100,000,000 ៛ = 0.10% |
| ក្រុមហ៊ុន (KTH) | Other Companies | 6669 ($) | លេខសម្គាល់ហាង ៣-៦ខ្ទង់ | ឥតគិតថ្លៃ |
| ក្រុមហ៊ុន ខ្មែរ មហា សំណាង ឯ.ក (Khmer Moha Samnang) | Other Companies | 8006 (៛) | លេខគណនីអតិថិជន ៥-១០ខ្ទង់ | ឥតគិតថ្លៃ |

| | | | | | |
|---|---|---|---|---|---|
| | ក្រុមហ៊ុន ឆ្នោតកីឡាជាតិ | Other Companies | 9129($) | លេខសម្គាល់អតិថិជន ៨-១០ខ្ទង់ | ឥតគិតថ្លៃ |
| | ក្រុមហ៊ុន ភីអេសអិលឌី ឌីស្ទ្រីប៊្យូធ័រ ឯ.ក (PSLD Distributor Co., Ltd) | Other Companies | 9102($) | លេខសម្គាល់អតិថិជន ៦ខ្ទង់ | ឥតគិតថ្លៃ |
| | ក្រុមហ៊ុន ម៉ាលី សាន គ្រុប | Other Companies | 9140(៛) \| 9141 ($) | លេខសម្គាល់អតិថិជន ៥ ខ្ទង់ | ឥតគិតថ្លៃ |
| | ក្រុមហ៊ុន លីនីង អូហ្វ ប៊ីហ្សិណេស សាយអិនស៍ | Other Companies | 9138(៛) \| 9137 ($) | លេខសម្គាល់អតិថិជន ៦ ខ្ទង់ | ឥតគិតថ្លៃ |
| | ក្រុមហ៊ុន វី ធី ជេ (ខេមបូឌា) លីមីតធីត (VTJ Cambodia Co., Ltd.) | Other Companies | 8777 ($) | លេខវិក្កយបត្រ ៨ ខ្ទង់ | ឥតគិតថ្លៃ |
| | ក្រុមហ៊ុន វី អេច ភី ត្រេឌីង (VHP Trading Co., Ltd.) | Other Companies | 8788 ($) | លេខយោង ៤ - ៦ ខ្ទង់ | ឥតគិតថ្លៃ |
| | ក្រុមហ៊ុន វើធស៍ ខេមបូឌា លីមីតធីត Wuerth (Cambodia) Limited | Other Companies | 8666 ($) | លេខកូដអតិថិជន ៩ ខ្ទង់ | ឥតគិតថ្លៃ |
| | ក្រុមហ៊ុន សុវណ្ណនីតា គ្រុប | Other Companies | 9133($) | លេខសម្គាល់អតិថិជន ៤ ខ្ទង់ | ឥតគិតថ្លៃ |
| | ក្រុមហ៊ុន ស៊ី អេ ធី ខេមបូឌា អេស៊ា ត្រាវែល ខូអិលធីឌី (មេគង្គ អិចប្រេស) | Other Companies | 7071($) | លេខសម្គាល់អតិថិជន ៩-១០ខ្ទង់ (ជាលេខទូរស័ព្ទអតិថិជន) | ឥតគិតថ្លៃ |
| | ក្រុមហ៊ុន ហ្វលខន ថេក ឯ.ក (Falcon Tech Co. Ltd) | Other Companies | 1368 ($) | លេខសម្គាល់អតិថិជន ៦-១២ខ្ទង់ | ឥតគិតថ្លៃ |
| | ក្រុមហ៊ុន ហ្វា ភើហ្វមីង សូសល អេនធើប្រាយ (PPSE) | Other Companies | 9143($) | លេខកូដកក់សំបុត្រ ៩ ខ្ទង់ | ឥតគិតថ្លៃ |
| | ក្រុមហ៊ុន អរុណាកូ ខូ អិលធីឌី (Arunaco Co.,Ltd) | Other Companies | 8084 ($) | លេខសម្គាល់អតិថិជន ៧ខ្ទង់ | ឥតគិតថ្លៃ |
| | ក្រុមហ៊ុន អេសអេស ប្រែនសប ឯ.ក (SS Brandshop Co.,Ltd) | Other Companies | 8998 ($) | លេខសម្គាល់អតិថិជន ៦-១២ខ្ទង់ | ឥតគិតថ្លៃ |
| | ក្រុមហ៊ុន អ៊ី ឆៃ គ្រុប (Y-CHHE Group) | Other Companies | 8168 ($) | លេខ សម្គាល់លក់ ៣-៤ខ្ទង់ | ឥតគិតថ្លៃ |

| | | | | | |
|---|---|---|---|---|---|
| | ក្រុមហ៊ុនទឹកបរិសុទ្ធ វីតាល់ (NVC Corporation) | Other Companies | 8686 ($) | លេខសម្គាល់ ១៤ខ្ទង់ | ឥតគិតថ្លៃ |
| | ក្រុមហ៊ុនភេសជ្ជៈកម្ពុជា (Coca Cola) | Other Companies | 66666 ($) | លេខកូដដឹកជញ្ជូន (៦-១៥ ខ្ទង់) | ឥតគិតថ្លៃ |
| | គៀងហួត អិលធីឌី (Keang Huot Co., Ltd) | Other Companies | 7075 ($) | គៀងហួត អិលធីឌី (Keang Huot Co., Ltd) | ឥតគិតថ្លៃ |
| | ជីប ម៉ុង (Chip Mong) | Other Companies | 1982 ($) | លេខសម្គាល់អតិថិជន ៦ខ្ទង់ + លេខវិក្កយបត្រ ៥ខ្ទង់ | ឥតគិតថ្លៃ |
| | បងធំ ដតខម (BongThom Dot Com) | Other Companies | 7013 ($) | លេខវិក្កយបត្រ ៤-៦ខ្ទង់ | ឥតគិតថ្លៃ |
| | បុរី ប៉េង ហួត (Borey Peng Huoth) | Other Companies | 77888 ($) | លេខសម្គាល់អតិថិជន ៨ខ្ទង់ | ឥតគិតថ្លៃ |
| | បុរី ប៉េង ហួត (Management) | Other Companies | 77788 ($) | លេខសម្គាល់អតិថិជន ៨ខ្ទង់ | 0.25$ |
| | បេឡាជាតិរបបសន្តិសុខសង្គម (NSSF) | Other Companies | 9119 (៛) | លេខសម្គាល់សហគ្រាស ៧ខ្ទង់ | 2000 ៛ |
| | ពិភពថ្មី គ្រុប (Piphup Thmey Group) | Other Companies | 7799 ($) | លេខសម្គាល់អតិថិជន ៧ខ្ទង់ | 0.50$ |
| | មូលនិធិគន្ធបុប្ផាកម្ពុជា | Other Companies | 5559 (៛) \| 5558 ($) | យោងតាមលេខទូរស័ព្ទអតិថិជន | ឥតគិតថ្លៃ |
| | ម៉ាស្ទ័រ ហ្វាម៉ាគ្រុប (Master Pharma Group) | Other Companies | 7073 ($) | លេខសម្គាល់អតិថិជន ៦ខ្ទង់ | ឥតគិតថ្លៃ |
| | យក្សខ្មែរ (Yak Khmer App) | Other Companies | 9135 (៛) | លេខសម្គាល់អតិថិជន ៥ - ១០ខ្ទង់ | ឥតគិតថ្លៃ |
| | សហគ្រាស ហ្គូដហៀល កម្ពុជា (Goodhill) | Other Companies | 1111 ($) | លេខសម្គាល់អតិថិជន ១០ខ្ទង់ | 0.50$ |
| | សាយ៉ាម អ៊ីនធើណេស៊ិនណាល (Sayam) | Other Companies | 7788 ($) | លេខវិក្កយបត្រ ៦-៧ខ្ទង់ | 1.50$ |
| | ស៊ី ភី ខេមបូឌា (CP Cambodia) | Other Companies | 7010 ($) | ស៊ី ភី ខេមបូឌា | ឥតគិតថ្លៃ |

| | | | | | |
|---|---|---|---|---|---|
| | ហាងលក់ទំនិញអនឡាញ ឡារ៉ូ (La Rue) | Other Companies | 0222 ($) | លេខសម្គាល់អតិថិជន (យោងតាមលេខបញ្ជាទិញ - Order Number) | 0.50$ |
| | ហុង ហួត (Hong Huot) | Other Companies | 7007 ($) | លេខសម្គាល់អតិថិជន ៤-៨ខ្ទង់ | ឥតគិតថ្លៃ |
| | អ៊ី ផៅវើរ ស៊ីស៊ីអិល (E-Power CCL) | Other Companies | 7011 ($) | លេខសម្គាល់អតិថិជន ៣ខ្ទង់ | 1.50$ |
| | អ៊ីស៊ីអាយ ឌីស្ទ្រីប្យូសិន (ECI Distribution) | Other Companies | 7021 ($) | លេខវិក្កយបត្រ ៧-១០ខ្ទង់ | ឥតគិតថ្លៃ |

# Online Payment Partner

Wing

## Technology

| | |
|---|---|
| CINet Technologies Co., Ltd | ចុចទៅកាន់ គេហទំព័រ |
| ICE Technology | ចុចទៅកាន់ គេហទំព័រ |
| Netbase | ចុចទៅកាន់ គេហទំព័រ |
| South East Asia Telecom (Cambodia) Co., Ltd | ចុចទៅកាន់ គេហទំព័រ |
| Yak Khmer | ចុចទៅកាន់ គេហទំព័រ |
| i-Qlick Marketing Co., Ltd | ចុចទៅកាន់ គេហទំព័រ |
| iPay88 | ចុចទៅកាន់ គេហទំព័រ |

## Entertainment

| | |
|---|---|
| Fannow | ចុចទៅកាន់ គេហទំព័រ |
| Legend Cinema | ចុចទៅកាន់ គេហទំព័រ |
| Major Platinum Cineplex (Cambodia) Co., Ltd | ចុចទៅកាន់ គេហទំព័រ |
| Obsok Republic | ចុចទៅកាន់ គេហទំព័រ |
| Sabay Digital Ltd | ចុចទៅកាន់ គេហទំព័រ |

## Fashion

| | |
|---|---|
| AY Collection | ចុចទៅកាន់ គេហទំព័រ |
| Atomy (Cambodia) | ចុចទៅកាន់ គេហទំព័រ |
| Guitar Fashion Shop | ចុចទៅកាន់ គេហទំព័រ |
| Little Fashion | ចុចទៅកាន់ គេហទំព័រ |
| Sovereign Retail Group Co., Ltd | ចុចទៅកាន់ គេហទំព័រ |
| World Bridge E-Commerce | ចុចទៅកាន់ គេហទំព័រ |

## Food and Beverage

| | |
|---|---|
| Nham24 | ចុចទៅកាន់ គេហទំព័រ |
| Pathmazing | ចុចទៅកាន់ គេហទំព័រ |

## Others

| | |
|---|---|
| Floral Express | ចុចទៅកាន់ គេហទំព័រ |
| Map One Investment | ចុចទៅកាន់ គេហទំព័រ |

## Retails

- Cambo Market
- Fortune Wave Investment
- Hong Kong Souvenir
- Mode Store
- Mom Varin Investment
- Rue International
- TenCent Technology

## Licences

- Ministry Of Commerce
- Ministry of Publice Work and Transportation
- Ministry of Tourism

## Travel

- Bayon Booking
- Bookmebus
- Buvasea
- Camboticket
- Crystal Express
- Larryta Trading
- Mekong Express
- PSD Express
- Phnom Penh Sorya Dekchunchoun Nakdamnoeur Co., Ltd
- Plus Enterprise Co., Ltd
- Royal Cambodian Limousine Service Co., Ltd ( Giant Ibist )
- The Moon Light Kiss Hostel
- Vreak Buntham

## Internet

- Today Communication Co., Ltd

# ឈ្មោះធនាគារដៃគូសហការរបស់វីង

| ប្រទេស | ឈ្មោះ |
|---|---|
| Philippine | Asia United Bank ; Bank of Commerce ; BDO (Banco De Oro) ; BPI ; BPI Family Savings ; Chinabank Saving ; Chinabank Savings ; Citibank ; DBP ; EastWest Bank ; Equicom Savings Bank ; HSBC ; HSBC Savings ; Landbank ; Malayan Bank ; Metrobank ; Philippine Savings Bank ; Philippine Veterans Bank ; PNB-Allied Bank ; PNB-Allied Savings Bank ; RCBC ; RCBC Savings ; Security Bank ; Security Savings Bank ; Standard Chartered Bank ; Sterling Bank ; Tong Yang Bank ; UCPB ; UCPB Savings Unionbank ; |
| Thailand | Bangkok Bank Public Company Limited ; Bank of Ayudhya Public Company Limited ; Krung Thai Bank Public Company Limited ; Kasikornbank Public Company Limited ; Siam Commercial Bank Public Company Limited ; TMB Bank Public Company Limited ; CIMB Thai Bank Public Company Limited ; Citibank, N.A., Bangkok Branch ; Government Housing Bank ; Kiatnakin Bank Public Company Limited ; Land And House Bank Public Company Limited ; Mizuho Corporate Bank ; Siam City Bank Public Company Limited ; The Bank for Agriculture and Agricultural CooperativesSumitomo Mitsui Banking Corporation (Thailand)Standard Chartered Bank (Thai) Public Company Limited ; Thanachart Bank Public Company Limited ; The Government Savings Bank ; The Hongkong and Shanghai Banking (Thailand) Corporation Limited ; The Islamic Bank of Thailand ; TISCO BANK ; United Overseas Bank (Thai) Public Company Limited ; Abn-Amro Bank N.V. (Thailand) ; Abn-Amro Bank N.V. (Thailand) ; Bank Of America, National Association ; Calyon Bank Thailand - Crédit Agricole Corporate and Investment Bank S.A. ; Deutsche Bank Aktiengesellschaft ; GE Money (Thailand) Limited ; J.P. Morgan Chase & Company Limited ; Mega International Commercial Bank Public Company Limited ; The Bank of Tokyo-Mitsubishi UFJ, Limited ; Mega International Commercial Bank Public Company Limited |
| South Korean | Kookmin Bank ; PPCBank ; Shinhan Bank |

## ដៃគូសហការដទៃ មិនមែនជាធនាគារ

| ប្រទេស | ឈ្មោះ |
|---|---|
| **Philippine** | Cebuana Lhuillier ; M. Lhuillier Padala ; Palawan Pawnshop |
| **Thailand** | Deemoney<br>*សាខា ៖ :Imperial World Samrong Branch*<br>*សាខា ៖ :Asoke Branch*<br>*សាខា ៖ :Tesco Lotus Mahachai Branch*<br>*សាខា ៖ :Sukhumvit Soi 8 Branch* |
| **Australia** | HAI HA Money Transfer ; DollarSmart Global (AUDSmart) |
| **Malaysia and Singapore** | TIKFX (Tranglo)<br>*ប្រទេសម៉ាឡេស៊ី :អាសយដ្ឋាន៖ :TIKFX (Tranglo): G27B, S'Mart Building, PTD 68948, Batu 7 1/2Jalan Kota Tinggi, Johor*<br>*ប្រទេសសិង្ហបុរី:អាសយដ្ឋាន៖ : Tranglo/TIKFX Branch Address: 505 Tampines Central 1, Singapore លេខទូរស័ព្ទ៖ +6569201938*<br>VALYOU<br>Merchantrade Asia |
| **Hong Kong** | DollarSmart Global HongKong (HKDSmart)<br>*គេហទំព័រ៖ :https://www.hkdsmart.com/* |
| **Japan** | World Family Remit (With Tranglo)<br>*សាខា Shinjuku-ku ទីក្រុងតូក្យូប្រទេសជប៉ុន 2-4-6 Mate Shinjuku អាគារជាន់ទី 3(ជាន់ទី អាគារ 3Meito, Hyakunin-cho) ។ វាចំណាយពេលត្រឹមតែពីរនាទីប៉ុណ្ណោះពីផ្លូវ JR Yamanote, ស្ថានីយ Shin-okubu ។ គេហទំព័រ ::www.worldfamilyremit.com* |
| **South Korean** | Gmoney Trans ; GME (Global Money Express) Remittance ; HANPASS ; SBI Cosmoney |

តម្លៃសេវាផ្ទេរប្រាក់ក្នុងស្រុករបស់ធនាគារឯកទេសវីង

# តារាងតម្លៃសេវាកម្ម

| ចំនួនទឹកប្រាក់រៀល (៛) | | តម្លៃសេវាកម្មជាទឹកប្រាក់រៀល (៛) | | | | |
|---|---|---|---|---|---|---|
| ចាប់ពី | ដល់ | ដាក់ប្រាក់ចូលគណនី Cash In (Max 24លាន/ប្រតិបត្តិការ) | ដកប្រាក់ពីគណនី Cash Out (Max 4លាន/ប្រតិបត្តិការ) | ផ្ញើលុយពីគណនីទៅគណនី WING-2-WING | ផ្ញើលុយពីគណនីទៅអ្នកគ្មានគណនី WING Wei Luy | ផ្ញើលុយតាមភ្នាក់ងារវីង Wei Luy Xpress |
| 0 | 100,000 | ឥតគិតថ្លៃ | 1,100 | 400 | 1,500 | 1,500 |
| 100,100 | 200,000 | | 2,600 | | 3,000 | 3,000 |
| 200,100 | 400,000 | | 3,600 | | 4,000 | 4,000 |
| 400,100 | 2,000,000 | | 5,200 | 800 | 6,000 | 6,000 |
| 2,000,100 | 4,000,000 | | 6,000 | 1,200 | 8,000 | 10,000 |

| ចំនួនទឹកប្រាក់ដុល្លារ ($) | | តម្លៃសេវាកម្មជាទឹកប្រាក់ដុល្លារ ($) | | | | |
|---|---|---|---|---|---|---|
| ចាប់ពី | ដល់ | ដាក់ប្រាក់ចូលគណនី Cash In (Max 6,000$/ប្រតិបត្តិការ) | ដកប្រាក់ពីគណនី Cash Out (Max 1,000$/ប្រតិបត្តិការ) | ផ្ញើលុយពីគណនីទៅគណនី WING-2-WING | ផ្ញើលុយពីគណនីទៅអ្នកគ្មានគណនី WING Wei Luy | ផ្ញើលុយតាមភ្នាក់ងារវីង Wei Luy Xpress |
| 0 | 25 | ឥតគិតថ្លៃ | 0.28 | 0.10 | 0.38 | 0.38 |
| 25.01 | 50 | | 0.65 | | 0.75 | 0.75 |
| 50.01 | 100 | | 0.90 | | 1.00 | 1.00 |
| 100.01 | 500 | | 1.30 | 0.20 | 1.50 | 1.50 |
| 500.01 | 1,000 | | 1.50 | 0.30 | 2.00 | 2.50 |

# តម្លៃសេវាផ្ទេរប្រាក់ទៅក្រៅប្រទេសតាមរយៈវីង

## ១. ប្រទេសហ្វីលីពីន

**ដៃគូសហការ (សេវាផ្ទេរប្រាក់ទៅអ្នកគ្មានគណនី)**

| ដៃគូសហការ | ចំនួនទឹកប្រាក់ក្នុងមួយប្រតិបត្តិការ(ដុល្លារ) | ចំនួនទឹកប្រាក់ក្នុងមួយប្រតិបត្តិការ(ប៉េសូ) | ពេលកំណត់ ទទួលប្រាក់ |
|---|---|---|---|
| Cebuana Lhuillier | ~500 ដុល្លារ | 30,000 ប៉េសូ | រង់ចាំ ១០ នាទី |
| M. Lhuillier Padala | ~500 ដុល្លារ | 30,000 ប៉េសូ | |
| Palawan Pawnshop | ~300 ដុល្លារ | 20,000 ប៉េសូ | 1, រយៈពេលទទួលប្រាក់ពី ៤ ទៅ៨ម៉ោង ពេលកំណត់ ម៉ោង ៩ ព្រឹក ១ ល្ងាច និងម៉ោង៤ល្ងាច។ |
| | | | 2, ថ្ងៃឈប់សម្រាកនិងចុងសប្តាហ៍: ប្រាក់នឹងត្រូវបានគេផ្ញើនៅថ្ងៃធ្វើការបន្ទាប់។ |

**តម្លៃសេវាកម្ម**

| ចំនួនទឹកប្រាក់ | ផ្ទេរប្រាក់ទៅគណនី | ផ្ទេរប្រាក់ទៅអ្នកគ្មានគណនី |
|---|---|---|
| | តម្លៃ | តម្លៃ |
| $ 0.01-$ 500.00 | TBD | TBD |
| $ 500.01-$1,000.00 | TBD | TBD |

**កម្រិតចំនួនទឹកប្រាក់ ដែលអាចផ្ទេរបានប្រចាំថ្ងៃ**

- ១,០០០ ដុល្លារក្នុងមួយប្រតិបត្តិការ
- រហូតដល់ ៥០០០ ដុល្លារក្នុងមួយថ្ងៃ

## ២. ប្រទេសវៀតណាម

| ចំនួនប្រាក់ | ផ្ទេរប្រាក់ទៅគណនី | ផ្ទេរប្រាក់ទៅអ្នកគ្មានគណនី | ផ្ទេរប្រាក់ដល់ផ្ទះ |
|---|---|---|---|
| $ 0.01-$ 500.00 | $3.00 | $4.00 | $5.00 |
| $ 500.01-$ 1,000.00 | $5.00 | $6.00 | $10.00 |

២. ប្រទេសថៃ តាម)DeeMoney)

## តម្លៃសេវាកម្ម

| ចំនួនទឹកប្រាក់ | ផ្ទេរប្រាក់ទៅគណនី | ផ្ទេរប្រាក់ទៅអ្នកគ្មានគណនី |
|---|---|---|
| | Fee | Fee |
| $0.01-$ 500.00 | $3 | $4 |
| $500.01-$1,000.00 | $4 | $5 |

## កម្រិតចំនួនទឹកប្រាក់ ដែលអាចផ្ទេរបានប្រចាំថ្ងៃ

- ១០០០ ដុល្លារក្នុងមួយប្រតិបត្តិការ
- រហូតដល់ ៥០០០ ដុល្លារក្នុងមួយថ្ងៃ

# តម្លៃសេវាផ្ទេរប្រាក់ពីក្រៅប្រទេសមកធនាគារឯកទេសរីង

១. ប្រទេសកូរ៉េខាងត្បូង

ធនាគារ Kookmin

តម្លៃ

| សេវាកម្ម | ចំនួនទឹកប្រាក់ | ថ្លៃសេវា |
|---|---|---|
| *គណនីទៅកាន់ទូរស័ព្ទដៃ | ចាប់ពី 0 ដល់ USD500.49 | USD2.5 |
| | ចាប់ពី USD500.50 ដល់ USD1,000 | USD5 |
| *គណនីទៅគណនីរីង | ចាប់ពី 0 ដល់ USD500.49 | USD2.5 |
| | ចាប់ពី USD500.50 ដល់ USD2,500 | USD3.5 |

ធនាគារ PPCBank

តម្លៃសេវា

| សេវាកម្ម | ចំនួនទឹកប្រាក់ | ថ្លៃសេវា |
|---|---|---|
| *គណនីទៅកាន់ទូរស័ព្ទដៃ | ចាប់ពី 0 ដល់ USD500.49/td> | USD2.5 |
| | ចាប់ពី USD500.50 ដល់ USD1,000 | USD5 |
| *គណនីទៅគណនីរីង | ចាប់ពី 0 ដល់ USD500.49 | USD2.5 |
| | ចាប់ពី USD500.50 ដល់ USD2,500 | USD3.5 |

## ២. ប្រទេសថៃ  តាម)DeeMoney(

### តម្លៃសេវា

#### ទទួលប្រាក់ជារៀល

| ចំនួនទឹកប្រាក់ | ថ្លៃសេវា |
|---|---|
| 1,000 – 4,999 បាត | 75 បាត |
| 5,000 បាតឡើង | 150 បាត |

#### ទទួលប្រាក់ជាដុល្លារ

| ចំនួនទឹកប្រាក់ | ថ្លៃសេវា |
|---|---|
| 1,000 – 4,999 បាត | 150 បាត |
| 5,000 បាតឡើងទៅ | ឥតគិតថ្លៃ |

# តារាងថ្លៃសេវាផ្ទេរប្រាក់តាម Western Union

## Western Union Pricing

### Cambodia ( Domestic )

| Amount to send (USD) | Transfer fee* (USD) |
|---|---|
| 0 – 100 | 15 |
| 100.01 – 200 | 22 |
| 200.01 – 300 | 28 |
| 300.01 – 400 | 34 |
| 400.01 – 500 | 41 |
| 500.01 – 625 | 46 |
| 625.01 – 750 | 47 |
| 750.01 – 1,000.00 | 52 |
| 1,000.01 – 1,500.00 | 66 |
| 1,500.01 – 1,750.00 | 77 |
| 1,750.01 – 2,000.00 | 90 |
| 2,000.01 – 2,500.00 | 110 |
| 2,500.01 – 3,000.00 | 130 |
| 3,000.01 – 3,500.00 | 150 |

### Brazil, Egypt, Mexico, South Africa, USA, other countries

| Amount to send (USD) | Transfer fee* (USD) |
|---|---|
| 0 – 100 | 15 |
| 100.01 – 200 | 22 |
| 200.01 – 300 | 29 |
| 300.01 – 400 | 34 |
| 400.01 – 500 | 41 |
| 500.01 – 625 | 46 |
| 625.01 – 750 | 47 |
| 750.01 – 1,000.00 | 52 |
| 1,000.01 – 1,500.00 | 67 |
| 1,500.01 – 1,750.00 | 78 |
| 1,750.01 – 2,000.00 | 91 |
| 2,000.01 – 2,500.00 | 111 |
| 2,500.01 – 3,000.00 | 131 |
| 3,000.01 – 3,500.00 | 151 |

## Vietnam

| Amount to send (USD) | Transfer fee* (USD) |
|---|---|
| 0 – 300 | 5 |
| 300.01 – 500 | 8 |
| 500.01 – 1,000.00 | 10 |
| 1,000.01 – 2,000.00 | 21 |
| 2,000.01 – 4,000.00 | 26 |
| 4,000.01 – 5,000.00 | 31 |
| 5,000.01 – 6,000.00 | 36 |
| 6,000.01 – 7,000.00 | 41 |
| 7,000.01 – 8,000.00 | 46 |
| 8,000.01 – 9,000.00 | 51 |
| 9,000.01 – 10,000.01 | 56 |

## Philippines

| Amount to send (USD) | Transfer fee* (USD) |
|---|---|
| 0.01 – 600 | 8 |
| 600.01 – 2,000.00 | 25 |
| 2,000.01 – above | 80 |

## China

| Amount to send (USD) | Transfer fee* (USD) |
|---|---|
| 0 – 3,000.00 | 12.08 |
| 3,000.01 – above | 22 |

## Myanmar

| Amount to send (USD) | Transfer fee* (USD) |
|---|---|
| 0 – 1,000.00 | 10 |
| 1,000.01 – above | 1% of sending amount |

*Western Union also makes money from currency exchange. When choosing a money transmier, carefully compare both transfer fees and exchange rates. Fees and foreign exchange rates may vary by brand, channel, and location based on a number of factors. Fees and rates subject to change without notice.

© 2018 Western Union Holdings, Inc. All rights reserved.

**សេវាផ្ទេរប្រាក់WESTERNUNION (WESTERN UNION MONEY TRANSFERSM) ត្រូវបានផ្តល់ជូនស្របតាមលក្ខខណ្ឌដូចបានកំណត់ខាងក្រោមនេះ៖**

ប្រតិបត្តិការផ្ទេរប្រាក់ WESTERNUNION អនុញ្ញាតឲ្យអតិថិជនអាចធ្វើការផ្ញើ និងទទួលប្រាក់បាននៅភ្នាក់ងារ WESTERN UNION ជុំវិញពិភពលោក។ អតិថិជនអាចទូរស័ព្ទមកលេខដូចបានផ្តល់ជូនក្នុងតារាងខាងក្រោមនេះ ដើម្បីទទួលបានព័ត៌មានអំពីអាសយដ្ឋាន និងម៉ោងធ្វើការរបស់ទីតាំងដែលនៅជិតលោកអ្នកបំផុត។ ទីតាំងមួយចំនួនបើកបម្រើសេវាជូន 24 ម៉ោង។ ជាទូទៅ ក្នុងរយៈពេលពីរបីនាទីប៉ុណ្ណោះអ្នកទទួលប្រាក់អាចមកបើកប្រាក់ដែលបានផ្ទេរតាមរយៈប្រតិបត្តិការផ្ទេរប្រាក់ជាប្រក្រតីបានអាស្រ័យលើ ម៉ោងធ្វើការរបស់ភ្នាក់ងារWESTERN UNION (?ភ្នាក់ងារ") ដែលត្រូវបើកប្រាក់ជូន។ សេវាផ្ទេរប្រាក់ថ្ងៃបន្ទាប់/ពីរថ្ងៃ និងសេវាផ្ទេរប្រាក់តាមរយៈគណនីត្រូវបានផ្តល់ជូនតាមការស្នើសុំក្នុងប្រទេសមួយចំនួនប៉ុណ្ណោះ។ ប្រាក់ដែលបានផ្ញើដោយប្រើសេវាផ្ទេរប្រាក់ថ្ងៃបន្ទាប់ នឹងអាចបើកយកបានក្នុងរយៈពេល 24 ម៉ោង ចំណែកឯប្រាក់ដែលបានផ្ញើដោយប្រើសេវាផ្ទេរប្រាក់ពីរថ្ងៃនឹងអាចបើកយកបានក្នុងរយៈពេល 48 ម៉ោង។ សេវាផ្ទេរប្រាក់តាមរយៈគណនី ជាទូទៅត្រូវចំណាយពេលរហូតដល់ទៅ 5 ថ្ងៃធ្វើការ ក៏ប៉ុន្តែការផ្ទេរទៅកាន់កាបូបចល័ត (mobile wallets) ជាទូទៅចំណាយពេលតែពីរបីនាទីប៉ុណ្ណោះ។ការផ្ទេរប្រាក់លើសចំនួនកំណត់ ការដាក់កម្រិតរបស់និយ័តករ ឬការដាក់កម្រិតផ្សេងៗទៀតនៅក្នុងប្រទេសមួយចំនួនអាចនឹងពន្យារពេលប្រតិបត្តិការផ្ទេរ។ WESTERNUNION មិនមែនជាភ្នាក់ងារ ឬអ្នកតំណាងរបស់ធនាគារសម្រាប់គោលបំណងណាមួយឡើយនិងមិនទទួលយកប្រាក់បញ្ញើក្នុងនាមធនាគារណាមួយឡើយ។សូមទូរស័ព្ទទៅកាន់លេខខាងក្រោមដើម្បីទទួលបានព័ត៌មានលម្អិត។ ជាធម្មតា ការផ្ទរប្រាក់នឹងត្រូវបានទូទាត់ជូនជាសាច់ប្រាក់សុទ្ធ ក៏ប៉ុន្តែភ្នាក់ងារមួយចំនួនអាចទូទាត់ជូនតាមរយៈមូលប្បទានប័ត្រ ឬតាមរយៈសាច់ប្រាក់សុទ្ធលាយជាមួយមូលប្បទានប័ត្រ ឬអាចទូទាត់តាមមធ្យោបាយផ្សេងទៀតឬអ្នកទទួលអាចជ្រើសរើសមធ្យោបាយផ្សេងទៀតដើម្បីទទួលបានប្រាក់ ហើយការផ្ទេរប្រាក់មួយចំនួនអាចនឹងត្រូវបានទូទាត់ចូលទៅក្នុងគណនីផ្ទាល់។ការទូទាត់សាច់ប្រាក់ទាំងអស់ត្រូវយោងលើសាច់ប្រាក់ដែលមានស្រាប់ និងការបង្ហាញភស្តុតាងជាឯកសារបញ្ជាក់អត្តសញ្ញាណរបស់អ្នកទទួល និងការផ្តល់ព័ត៌មានលម្អិត អំពីការផ្ទេរប្រាក់ដែលតម្រូវដោយ WESTERNUNIONមានជាអាទិ៍ ឈ្មោះរបស់អ្នកផ្ញើ និងអ្នកទទួល ប្រទេសនៃប្រភពដើម ចំនួនប្រាក់ប្រហាក់ប្រហែល MTCN និងលក្ខខណ្ឌផ្សេងទៀតដែលតម្រូវឲ្យអនុវត្តនៅទីតាំងភ្នាក់ងារ។ អ្នកផ្ញើយល់ព្រម និងអនុញ្ញាតឲ្យWESTERN UNION គោរពតាមជម្រើសរបស់អ្នកទទួលអំពីមធ្យោបាយទទួលប្រាក់ ទោះបីជាវាខុសពីជម្រើសរបស់អ្នកផ្ញើក៏ដោយ។ ការផ្ទេរប្រាក់ជាសាច់ប្រាក់សុទ្ធនឹងត្រូវបានទូទាត់ទៅឲ្យបុគ្គលដែលភ្នាក់ងារយល់ឃើញថាគាត់មានសិទ្ធិទទួលបានប្រាក់នេះ ក្រោយពេលផ្ទៀងផ្ទាត់អត្តសញ្ញាណ ដែលជាញឹកញាប់ត្រូវធ្វើឡើងតាមរយៈការពិនិត្យឯកសារបញ្ជាក់អត្តសញ្ញាណ។ ការទូទាត់ប្រាក់បែបនេះអាចត្រូវបានធ្វើឡើង ទោះបីជាសំណុំបែបបទដែលបានបំពេញដោយអ្នកទទួលមានកំហុសបន្តិចបន្តួចក៏ដោយ។ WESTERN UNION និងភ្នាក់ងាររបស់ខ្លួននឹងមិនធ្វើការប្រៀបធៀបទម្រង់ផ្ញើប្រាក់ ជាមួយនឹងទម្រង់"ទទួលប្រាក់" ដើម្បីផ្ទៀងផ្ទាត់អាសយដ្ឋានរបស់អ្នកទទួលដែលបានផ្តល់ឲ្យឡើយ។ ក្នុងតំបន់មួយចំនួន អ្នកទទួលប្រាក់នឹងអាចត្រូវបានតម្រូវឲ្យផ្តល់នូវ លិខិតសម្គាល់អត្តសញ្ញាណនិង/ឬ ឆ្លើយសំណួរដើម្បីទទួលបានប្រាក់ជាសាច់ប្រាក់សុទ្ធ។សំណួរមិនមែនជាលក្ខខណ្ឌសុវត្ថិភាពបន្ថែមឡើយ និងមិនអាចត្រូវបានប្រើប្រាស់ដើម្បីកំណត់ពេល ឬពន្យារពេលក្នុងការទូទាត់ប្រាក់ ហើយក៏ត្រូវបានហាមឃាត់នៅក្នុងប្រទេសមួយចំនួន។ច្បាប់ជាធរមានហាមឃាត់ប្រតិបត្តិការផ្ទេរប្រាក់ មិនឲ្យធ្វើប្រតិបត្តិការអាជីវកម្មជាមួយបុគ្គល និងប្រទេសមួយចំនួន។ WESTERNUNION ត្រូវបានតម្រូវឲ្យផ្ទៀងផ្ទាត់ប្រតិបត្តិការទាំងអស់ជាមួយនឹងបញ្ជីឈ្មោះដែលបានផ្តល់ឲ្យដោយរដ្ឋាភិបាលនៃបណ្តាប្រទេស ដែលពួកយើងធ្វើអាជីវកម្ម រួមទាំងការិយាល័យត្រួតពិនិត្យទ្រព្យសម្បត្តិបរទេស (OFAC)របស់ក្រសួងរតនាគារអាមេរិក(US Treasure Department) និងសហភាពអឺរ៉ុបផងដែរ។ ប្រសិនបើមានចំណុចសក្តានុពលណាមួយត្រូវបានរកឃើញ WESTERNUNION ត្រូវធ្វើការស្រាវជ្រាវដើម្បីកំណត់ថា តើបុគ្គលនោះដូចគ្នានឹងបុគ្គលដែលមានកំណត់នៅក្នុងបញ្ជីឈ្មោះដែរឬទេ។ ក្នុងកាលៈទេសៈខ្លះ អតិថិជនត្រូវបានតម្រូវឲ្យផ្តល់នូវលិខិតសម្គាល់អត្តសញ្ញាណ ឬព័ត៌មានបន្ថែម ដែលអាចធ្វើឲ្យប្រតិបត្តិការផ្ទេរមានការយឺតយ៉ាវ។ នេះគឺជាលក្ខខណ្ឌតម្រូវរបស់ច្បាប់ សម្រាប់រាល់ប្រតិបត្តិការទាំងអស់ដែលអនុវត្តដោយWESTERN UNION(រួមទាំងការផ្ទេរប្រាក់ដែលមានប្រភពចាប់ផ្តើម និងបញ្ចប់នៅខាងក្រៅសហរដ្ឋអាមេរិកផងដែរ)។

**ថ្លៃសេវាផ្ទេរ** -ព័ត៌មាន ជាលាយលក្ខណ៍អក្សរដែលពន្យល់ពីរបៀបដែល WESTERNUNIONយកកម្រៃពីអ្នកផ្ញើសម្រាប់ធ្វើការផ្ទេរប្រាក់នឹងត្រូវបានដាក់បង្ហាញឲ្យឃើញច្បាស់នៅទីតាំងរបស់ភ្នាក់ងារ ឬបង្ហាញដល់អ្នកផ្ញើ មុនពេលបំពេញបែបបទបញ្ជាផ្ទេរប្រាក់។ លើកលែងតែច្បាប់នៅក្នុងប្រទេសនៃទីតាំងនោះមានកំណត់ផ្សេងពីនេះ អ្នកផ្ញើនឹងទទួលបន្ទុកបង់ថ្លៃសេវាទាំងអស់សម្រាប់ការផ្ទេរប្រាក់។ នៅក្នុងករណីមួយចំនួន ការទូទាត់ការផ្ទេរប្រាក់អាចជាប់ពន្ធក្នុងស្រុក និងថ្លៃសេវាផ្សេងៗទៀត។

**ការប្តូរប្រាក់បរទេស** - ការទូទាត់ប្រាក់ដែលបានផ្ញើជាធម្មតាត្រូវបានធ្វើឡើងទៅតាមរូបិយប័ណ្ណរបស់ប្រទេសដែលជាគោលដៅផ្ញើប្រាក់ (នៅក្នុងប្រទេសមួយចំនួនការទូទាត់ប្រាក់អាចធ្វើបានតែជាប្រាក់ដុល្លារអាមេរិក ឬជារូបិយប័ណ្ណមួយចំនួនតែប៉ុណ្ណោះ )។ បន្ថែមលើថ្លៃសេវាសម្រាប់រាល់ការផ្ទេរប្រាក់នីមួយៗ ហើយប្រសិនបើរូបិយប័ណ្ណដែលអ្នកផ្ញើបានបង្ហាញជូនភ្នាក់ងារ មិនមែនជារូបិយប័ណ្ណដែលត្រូវទទួលបានដោយអ្នកទទួល នោះរាល់រូបិយប័ណ្ណទាំងអស់នឹងត្រូវប្តូរទៅតាមអត្រាប្តូរប្រាក់បច្ចុប្បន្ននៅតាមទីតាំង WESTERN UNION នោះ។ រូបិយប័ណ្ណនឹងត្រូវបានប្តូរនៅពេលផ្ទេរប្រាក់ ហើយអ្នកទទួលនឹងទទួលបានទឹកប្រាក់ ជារូបិយប័ណ្ណបរទេសទៅតាមចំនួន ដូចមានបង្ហាញនៅលើ សំណុំបែបបទប្រតិបត្តិការផ្ទេរប្រាក់។ នៅក្នុងប្រទេសមួយចំនួន បទប្បញ្ញត្តិក្នុងស្រុកតម្រូវឲ្យធ្វើការប្តូររូបិយប័ណ្ណនៅពេលទូទាត់ប្រាក់ជូនអ្នកទទួល ដែលក្នុងករណីនេះអត្រាប្តូរប្រាក់ និងចំនួនដែលបានបង្ហាញនៅលើទម្រង់ប្រតិបត្តិការផ្ទេរប្រាក់ អាចប្រែប្រួលទៅតាមអត្រាប្តូរប្រាក់រវាងពេលដែលការផ្ទេរត្រូវបានធ្វើឡើង និងពេលដែលអ្នកទទួលមកទទួលប្រាក់។ WESTERN UNION គណនាអត្រាប្តូរប្រាក់របស់ខ្លួនដោយផ្អែកលើអត្រាប្តូរប្រាក់អន្តរធនាគារដែលមាននាពេលនោះរួមទាំងចន្លោះប្រែប្រួល។ អត្រាប្តូរប្រាក់ភាគច្រើន ប្រែប្រួលជាច្រើនដង ជារៀងរាល់ថ្ងៃអនុលោមតាមអត្រានៅពេលបិទប្រតិបត្តិការរបស់ទីផ្សារហិរញ្ញវត្ថុសកល។ អត្រាប្តូរប្រាក់ដែលយកមកអនុវត្តអាចទាបជាងអត្រាប្តូរប្រាក់ពាណិជ្ជកម្មដែលបានប្រកាសជាសាធារណៈសម្រាប់ប្រើប្រាស់ក្នុងប្រតិបត្តិការរវាងធនាគារ និង ស្ថាប័នហិរញ្ញវត្ថុផ្សេងទៀត។ភាគដែលខុសគ្នា រវាងអត្រាប្តូរប្រាក់ផ្តល់ជូនអតិថិជន និងអត្រាប្តូរប្រាក់ទទួលដោយWESTERNUNIONនិងត្រូវបានរក្សាទុកដោយ WESTERN UNION (និងនៅក្នុងករណីមួយចំនួន ត្រូវបានរក្សាទុកដោយភ្នាក់ងាររបស់ខ្លួន) បន្ថែមទៅលើថ្លៃសេវាផ្ទេរប្រាក់។លោកអ្នកអាចទទួលបានព័ត៌មានបន្ថែមអំពីអត្រាប្តូរប្រាក់សម្រាប់ប្រទេសដែលជាគោលដៅ ដោយទូរស័ព្ទទៅកាន់លេខខាងក្រោម ឬនៅលើគេហទំព័ររបស់យើwww.westernunion.com។ការផ្ញើ និងការទទួលប្រាក់នៅក្នុងប្រទេសដែលផ្តល់ការទូទាត់ជារូបិយប័ណ្ណច្រើនប្រភេទ៖ អ្នកផ្ញើត្រូវជ្រើសរើសរូបិយប័ណ្ណនៃការទូទាត់ប្រាក់នៅពេលធ្វើប្រតិបត្តិការផ្ញើប្រាក់។ ថ្លៃសេវាផ្ទេរ និងប្រាក់ដែល WESTERN UNION(ឬភ្នាក់ងាររបស់ខ្លួន ឬតាមរយៈទូរស័ព្ទដៃ ឬអ្នកផ្តល់សេវាគណនី) ទទួលបាននៅពេលប្តូរប្រាក់ទៅរូបិយប័ណ្ណបរទេសអាចនឹងប្រែប្រួលទៅតាមរូបិយប័ណ្ណទូទាត់ប្រាក់ដែលបានជ្រើសរើស។ នៅក្នុងប្រទេសមួយចំនួន អ្នកទទួលប្រាក់អាចសម្រេចជ្រើសរើសទទួលយកប្រាក់ក្នុងរូបិយប័ណ្ណខុសពីរូបិយប័ណ្ណដែលអ្នកផ្ញើបានជ្រើសរើស។ WESTERNUNION (ឬភ្នាក់ងាររបស់ខ្លួន ឬតាមរយៈទូរស័ព្ទដៃ ឬអ្នកផ្តល់សេវាគណនី) អាចទទួលបានកម្រៃបន្ថែមទៀតនៅពេលដែលប្រាក់របស់លោកអ្នកត្រូវបានប្តូរទៅជារូបិយប័ណ្ណដែលបានជ្រើសរើសដោយអ្នកទទួល។

**សេវាកម្មពិសេសៗ**

**សេវាជូនដំណឹងតាមទូរស័ព្ទ** ទៅអ្នកទទួលថាគាត់ អាចមកបើកប្រាក់ផ្ទេរបាន ត្រូវផ្តល់ជូនក្នុង ប្រទេសភាគច្រើនដោយមានគិតថ្លៃសេវាបន្ថែម។ សេវាប្រគល់មូលប្បទានប័ត្រឬប័ណ្ណធនាគារ (bank draft) តាមរយៈអ្នកនាំសារ អាចផ្តល់ជូននៅក្នុងប្រទេសមួយចំនួន សម្រាប់ផ្ញើទៅកាន់គោលដៅមួយចំនួនដោយមានគិតថ្លៃសេវាបន្ថែមទៀត។ សេវាផ្ញើសារបញ្ជាក់អាចត្រូវបានផ្តល់ដោយគិតថ្លៃសេវាបន្ថែមសម្រាប់ការផ្ទេរប្រាក់ទៅកាន់បណ្តាប្រទេសភាគច្រើន។

**ការផ្ញើសារតាមទូរស័ព្ទSMS** - នៅក្នុងប្រទេសមួយចំនួន WESTERN UNION ធ្វើការជូនដំណឹងតាមរយៈសារទូរស័ព្ទដោយឥតគិតថ្លៃ ដើម្បីបញ្ជាក់ថា ប្រតិបត្តិការត្រូវបានមកទទួលដោយអ្នកទទួលប្រាក់ (សម្រាប់អ្នកផ្ញើប្រាក់) ឬថាអ្នកទទួល អាចអញ្ជើញមកបើកប្រាក់បាន (សម្រាប់អ្នកទទួលប្រាក់)។ ថ្លៃសេវាដែលកាត់យកដោយក្រុមហ៊ុនផ្តល់សេវាទូរស័ព្ទ គឺជាទំនួលខុសត្រូវផ្តាច់មុខរបស់អ្នកផ្ទេរ ឬអ្នកទទួល។ប្រសិនច្បាប់អនុញ្ញាត នោះសារទូរស័ព្ទនឹងត្រូវបានផ្ញើទៅ លេខទូរស័ព្ទរបស់អ្នកផ្ញើ និង/ឬរបស់អ្នកទទួល ដែលពួកគេបានផ្តល់ឲ្យ។ WESTERNUNIONនឹងផ្ញើសារទូរស័ព្ទទៅកាន់ភាគីទីបីសម្រាប់ធ្វើការផ្ញើបន្ត។ WESTERN UNION នឹងមិនទទួលខុសត្រូវចំពោះសារទូរស័ព្ទ ដែលមិនអាចផ្ញើចេញបាន ឬបញ្ហាផ្នែកបច្ចេកទេសណាមួយដែលកើតមានឡើងក្រៅប្រព័ន្ធដែលជាកម្មសិទ្ធិរបស់ខ្លួនឡើយ។

**សេវាផ្ទេរតាមរយៈគណនី** - ក្នុងប្រទេសមួយចំនួនអ្នកទទួលអាចត្រូវបង់ថ្លៃសេវាបន្ថែមដើម្បីទទួលប្រាក់ពីអ្នកផ្ញើតាមរយៈទូរស័ព្ទដៃ ឬផ្ទេរទៅកាន់ធនាគារ ឬគណនីផ្សេងទៀត។ ការផ្ទេរប្រាក់គួរតែត្រូវបានផ្ញើទៅកាន់គណនី (អ្នកទទួល) ជារូបិយប័ណ្ណក្នុងស្រុក បើមិនដូច្នេះទេ ស្ថាប័នដែលបានទទួលការផ្ទេរអាចប្តូរប្រាក់តាមអត្រាប្តូរប្រាក់របស់ខ្លួនឬអាចបដិសេធប្រតិបត្តិការនេះបាន។ កិច្ចព្រមព្រៀងរបស់អ្នកទទួលជាមួយនឹងសេវាទូរស័ព្ទចល័ត mWallet ធនាគារឬអ្នកផ្តល់សេវាគណនីផ្សេងទៀតនឹងត្រូវគ្រប់គ្រងគណនី និងកំណត់អំពីសិទ្ធិ ការទទួលខុសត្រូវ ថ្លៃសេវា សាច់ប្រាក់ដែលអាចដកបាន និងលក្ខខណ្ឌកំណត់នៃគណនីនោះ។ នៅក្នុងករណីដែលលេខគណនីដែលបានផ្តល់ឲ្យ (រួមទាំងលេខទូរស័ព្ទដៃសម្រាប់គណនីទូរស័ព្ទ) មិនមែនជាកម្មសិទ្ធិរបស់ឈ្មោះអ្នកទទួលប្រាក់ នោះប្រាក់ផ្ទេរនឹងត្រូវបញ្ចូលទៅក្នុង លេខគណនីដែលផ្តល់ដោយអ្នកផ្ញើ។ WESTERN UNION អាចទទួលបានកម្រៃបន្ថែមពីថ្លៃសេវាទាក់ទងនឹងការប្រើ

ប្រាស់គណនី។ WESTERN UNION នឹងមិនទទួលខុសត្រូវចំពោះអ្នកផ្ញើ ឬម្ចាស់គណនីណាមួយឡើយ ចំពោះថ្លៃសេវាអត្រាប្តូរប្រាក់ ដែលត្រូវបានប្រើសម្រាប់ការប្តូរប្រាក់ទៅជារូបិយប័ណ្ណផ្សេង ពីរូបិយប័ណ្ណក្នុងស្រុក សកម្មភាពណាមួយ ឬការខកខានមិនបានអនុវត្តកិច្ចណាមួយរបស់ភ្នាក់ងារផ្តល់សេវាតាមគោលដៅនានា ឬអន្តរការផ្តល់សេវាហិរញ្ញវត្ថុ។

**ការបង្វិលសងប្រាក់វិញ** - WESTERN UNION នឹងបង្វិលសងវិញនូវចំនួនប្រាក់ដើមនៃការផ្ទេរប្រាក់ណាមួយ (ដោយយោងលើអត្រាប្តូរប្រាក់ដូចបានរៀបរាប់នៅក្នុងឯកសារនេះនិងដែលមានអានុភាពអនុវត្តនៅពេលមានការបង្វិលសងប្រាក់វិញនេះ) ដោយយោងតាមការស្នើសុំជាលាយលក្ខណ៍អក្សររបស់អ្នកផ្ញើប្រសិនបើការទូទាត់ប្រាក់ទៅឲ្យអ្នកទទួលមិនទាន់បានធ្វើឡើង ឬអ្នកទទួលមិនបានមកបើកប្រាក់ក្នុងរយៈពេល 45 ថ្ងៃ។ ការបង្វិលសងថ្លៃសេវាសម្រាប់ការផ្ទេរប្រាក់ត្រូវបានធ្វើឡើងតាមការស្នើសុំ ជាលាយលក្ខណ៍អក្សររបស់អ្នកផ្ញើ ប្រសិនបើការផ្ទេរប្រាក់មិនអាចផ្ញើទៅដល់អ្នកទទួលប្រាក់ ក្នុងរយៈពេលដែលបានកំណត់ទៅតាមប្រភេទសេវាកម្មដែលបានជ្រើសរើសប៉ុន្តែអាស្រ័យលើសាច់ប្រាក់ដែលអាចមានជាក់ស្តែងនិងម៉ោងធ្វើការនៃទីតាំងដែលបានជ្រើសរើសសម្រាប់ទូទាត់ប្រាក់ និងផ្អែកលើលក្ខខណ្ឌផ្សេងទៀត រួមទាំងស្ថានភាពដែល WESTERN UNION ឬភ្នាក់ងាររបស់ខ្លួនមិនអាចគ្រប់គ្រងបានមានជាអាទិ៍ដូចជាអាកាសធាតុមិនអំណោយផល ឬបញ្ហាប្រព័ន្ធទូរគមនាគមន៍។ ថ្លៃសេវាសម្រាប់ការផ្ទេរប្រាក់មិនត្រូវបានបង្វិលសងវិញឡើយ ប្រសិនបើការផ្ទេរប្រាក់ ត្រូវបានបញ្ឈប់តាមសំណើរបស់អ្នកផ្ញើ។ ការទូទាត់ការផ្ទេរប្រាក់មួយចំនួនអាចត្រូវបានពន្យារពេលដោយសារការអនុវត្តច្បាប់របស់សហរដ្ឋអាមេរិក ឬច្បាប់ពាក់ព័ន្ធដទៃទៀត។ អាស្រ័យទៅតាមការអនុញ្ញាត ដោយច្បាប់WESTERN UNIONអាចកាត់ថ្លៃសេវារដ្ឋបាលពីការផ្ទេរប្រាក់ដែលមិនត្រូវបានទូទាត់ក្នុងរយៈពេលមួយឆ្នាំដោយគិតពីថ្ងៃផ្ទេរ។

**ការទទួលខុសត្រូវ** - WESTERN UNION មិនធានាលើការប្រគល់ ឬភាពសមស្របនៃទំនិញ ឬសេវាកម្មដែលបានទូទាត់តាមរយៈសេវាផ្ទេរប្រាក់ WESTERNUNION ទេ។ ទិន្នន័យប្រតិបត្តិការរបស់អ្នកផ្ញើជាទិន្នន័យសម្ងាត់របស់អ្នកផ្ញើនិងមិនត្រូវបានចែករំលែកជាមួយបុគ្គលផ្សេងក្រៅពីអ្នកទទួលប្រាក់ឡើយ។ អ្នកផ្ញើត្រូវប្រុងប្រយ័ត្ននៅក្នុងការផ្ញើប្រាក់ទៅបុគ្គលដែលខ្លួនមិនស្គាល់។ ទោះក្នុងករណីណាក៏ដោយ WESTERN UNION ឬភ្នាក់ងាររបស់ខ្លួននឹងមិនទទួលខុសត្រូវឡើយ ប្រសិនបើអ្នកផ្ញើផ្តល់ទិន្នន័យប្រតិបត្តិការទៅបុគ្គលណាម្នាក់ផ្សេងទៀតក្រៅពីអ្នកទទួលប្រាក់។ទោះក្នុងករណីណាក៏ដោយWESTERN UNION ឬភ្នាក់ងាររបស់ខ្លួននឹងមិនទទួលខុសត្រូវចំពោះព្យសនកម្មដែលកើតឡើងដោយសារការយឺតយ៉ាវ ការមិនបានទូទាត់ប្រាក់ឬការទូទាត់ប្រាក់មិនគ្រប់ចំនួនក្នុងប្រតិបត្តិការផ្ទេរប្រាក់នេះ ឬមិនផ្ញើសារបញ្ជាក់ណាមួយទោះបីកើតឡើងដោយសារការធ្វេសប្រហែសរបស់បុគ្គលិក ឬភ្នាក់ងាររបស់ខ្លួន ឬតាមរបៀបផ្សេងទៀតក៏ដោយ លើសពីចំនួនទឹកប្រាក់ស្មើនឹង 500 ដុល្លារអាមេរិកឡើយ (បន្ថែមលើការបង្វិលសងប្រាក់ដើមដែលត្រូវផ្ទេរ និងថ្លៃសេវាផ្ទេរ)។ ទោះក្នុងករណីណាក៏ដោយ WESTERN UNION ឬភ្នាក់ងាររបស់ខ្លួននឹងមិនទទួលខុសត្រូវចំពោះព្យសនកម្មទោះដោយប្រយោលដែលមានលក្ខណៈពិសេសណាមួយដោយយថាហេតុ ឬដែលមានលក្ខណៈសំខាន់ណាមួយ។ ការកម្រិតការទទួលខុសត្រូវដូចបានរៀបរាប់ពីខាងដើមនេះ នឹងមិនកម្រិតការទទួលខុសត្រូវរបស់ WESTERN UNION ឬភ្នាក់ងាររបស់ខ្លួនចំពោះព្យសនកម្មដែលកើតមានឡើងដោយសារការធ្វេសប្រហែសដ៏ធ្ងន់ធ្ងរឬកំហុសដោយចេតនា របស់ WESTERN UNION ឬភ្នាក់ងាររបស់ខ្លួននៅក្នុងយុត្តាធិការដែលចាត់ទុកការកម្រិតការទទួលខុសត្រូវដូចបានរៀបរាប់ខាងលើនេះជាមោឃៈ។នៅពេលដែលភ្នាក់ងារយល់ព្រមទទួលយកមូលប្បទានប័ត្រធនាគារ(cheque draft)កាតឥណទាន (creditcard) ឬកាតឥណពន្ធ (debit card) ឬរបៀបទូទាត់ប្រាក់ក្រៅពីសាច់ប្រាក់សុទ្ធផ្សេងទៀត WESTERN UNION ឬភ្នាក់ងាររបស់ខ្លួននឹងមិនមានកាតព្វកិច្ចក្នុងការដំណើរការ ឬការទូទាត់ការផ្ទេរប្រាក់ប្រសិនបើរបៀបនៃការទូទាត់ប្រាក់មិនអាចអនុញ្ញាតឲ្យបើកប្រាក់បាន ហើយយើងខ្ញុំក៏មិនទទួលខុសត្រូវចំពោះការខូចខាតដែលបណ្តាលមកពីការមិនទូទាត់ការផ្ទេរប្រាក់ ដោយមូលហេតុមិនអាចបើកប្រាក់បានខាងលើនេះ។ WESTERN UNION សូមរក្សាសិទ្ធិក្នុងការផ្លាស់ប្តូរខចែង និងលក្ខខណ្ឌទាំងនេះ ឬសេវាដែលបានផ្តល់ជូនដោយពុំចាំបាច់ជូនដំណឹងជាមុន។ WESTERN UNION ឬភ្នាក់ងាររបស់ខ្លួនអាចបដិសេធក្នុងការផ្តល់សេវាទៅឲ្យបុគ្គលណាមួយ។

**ការការពារទិន្នន័យ** - ព័ត៌មានផ្ទាល់ខ្លួនរបស់លោកអ្នកត្រូវបានយកទៅប្រើប្រាស់ស្របតាមច្បាប់ជាធរមាននិងត្រូវបានគ្រប់គ្រងដោយ WESTERNUNION ។ យើងខ្ញុំប្រើប្រាស់ព័ត៌មានផ្ទាល់ខ្លួនរបស់លោកអ្នកដែលបានផ្តល់ឲ្យយើងខ្ញុំនៅពេលដែលប្រើផលិតផលនិងសេវាកម្មរបស់យើងខ្ញុំក៏ដូចជាព័ត៌មានផ្សេងទៀតដែលត្រូវបានប្រមូលឬដែលត្រូវបានបង្កើតឡើងក្នុងអំឡុងពេលដែលយើងខ្ញុំមានទំនាក់ទំនងជាមួយលោកអ្នក។ នេះរួមបញ្ចូលទាំងព័ត៌មានដែលបានមកពីសេវាផ្សេងទៀតដូចជា ការផ្ទេរប្រាក់ការទូទាត់វិក្កយបត្របង់ប្រាក់ ព័ត៌មានដែលបានមកពីកម្មវិធីអតិថិជនស្មោះត្រង់ ឬកម្មវិធីសមាជិក ប្រវត្តិនៃការប្រើប្រាស់សេវាកម្មរបស់យើងខ្ញុំពេលកន្លងមក និងជម្រើសទីផ្សារនានា។ព័ត៌មានទាំងនេះ ត្រូវបានប្រើប្រាស់ដើម្បីផ្តល់ជូនលោកអ្នកនូវសេវាកម្មដែលលោកអ្នកបានស្នើសុំ និងសម្រាប់សកម្មភាពផ្សេងៗដូចជា ផ្នែករដ្ឋបាលសេវាអតិថិជន ការប្រឆាំងការសម្អាតប្រាក់ ការអនុលោមតាមច្បាប់ និងកាតព្វកិច្ចផ្លូវច្បាប់នានា ការផ្ទៀងផ្ទាត់ព័ត៌មានរបស់លោកអ្នក ដើម្បីជួយឲ្យយើងខ្ញុំយល់ពីអតិថិជនតាមរយៈការវិភាគ និងការស្រាវជ្រាវព័ត៌មានទាំងឡាយដែលយើងខ្ញុំមាន ដើម្បីជួយបង្ការ និងកំណត់ការក្លែងបន្លំ បំណុល និងការលួចណាមួយដើម្បីជួយយើងខ្ញុំធ្វើការកែលម្អផលិតផល សេវាកម្ម និងប្រតិបត្តិការរបស់យើងខ្ញុំហើយយើងខ្ញុំនឹងផ្ញើជូនលោកអ្នកនូវសារផ្សាយពាណិជ្ជកម្មនានាតាមរយៈអ៊ីមែល ទូរស័ព្ទប្រៃសណីយ៍ ផ្ញើសារជាអក្សរ និងដោយវិធីផ្សេងទៀតណាមួយ ដោយគោរពទៅតាមជម្រើសរបស់លោកអ្នក។ WESTERN UNION អាចប្រើប្រាស់ ប្រមូលនិងចែករំលែកជាមួយនឹងអាជីវកម្មផ្សេងៗទៀតដែលធ្វើការជាមួយយើងខ្ញុំ នូវព័ត៌មានទទួលបានតាមរយៈផលិតផល និងសេវាកម្មផ្សេងទៀត និងកម្មវិធីអំពីភាពងាយស្រួល និង/ឬកម្មវិធីផ្តល់រង្វាន់ដែលលោកអ្នកបានចុះឈ្មោះជាមួយយើងខ្ញុំ។ ព័ត៌មានទាំងនេះអាចត្រូវបានប្រើប្រាស់ សម្រាប់គោលបំណងណាមួយដែលមានចែងក្នុងផ្នែកនេះ។ យើងខ្ញុំនឹងគ្រប់គ្រង និងរក្សាទុកនូវព័ត៌មានដែលលោកអ្នកផ្តល់ឲ្យយើងអំពីបុគ្គលផ្សេងទៀត រួមទាំងព័ត៌មានលម្អិតនៃអ្នកទទួលសេវាកម្មរបស់យើងខ្ញុំ ដើម្បីឲ្យយើងខ្ញុំអាចបំពេញប្រតិបត្តិការនេះ។ មុនពេលផ្តល់ព័ត៌មាននេះ លោកអ្នកមានកាតព្វកិច្ចជូនដំណឹង និងទទួលបានការអនុញ្ញាតពីបុគ្គលម្ខាងទៀតអំពីការប្រើប្រាស់ ព័ត៌មានទាំងនេះដូចមានចែងក្នុងផ្នែកនេះ។ ការផ្តល់ព័ត៌មាននេះមិនមានលក្ខណៈចាប់បង្ខំឡើយ ក៏ប៉ុន្តែវាចាំបាច់សម្រាប់បំពេញប្រតិបត្តិការនិងផ្តល់សេវាកម្មទាំងនេះដល់លោកអ្នក។ បើគ្មានព័ត៌មានទាំងនេះទេ WESTERN UNION មិនអាចបំពេញប្រតិបត្តិការផ្ទេរប្រាក់ ឬសេវាទូទាត់ប្រាក់ជួយសម្រួលសកម្មភាពនានា ឬសេវាផ្សេងទៀតដែលលោកបានស្នើសុំ។ពួកយើងអាចផ្តល់ព័ត៌មានដែលពួកយើងគ្រប់គ្រង ទៅភាគីនានា ដែលមានទីតាំងស្ថិតនៅក្នុង បណ្តាប្រទេសផ្សេងទៀត ក្រៅពីប្រទេសដែលព័ត៌មានទាំងនេះត្រូវបានប្រមូលយក ឬបង្កើតឡើងពីខាងដើម រួមទាំងសាខាស្ថិតនៅក្នុងសហរដ្ឋអាមេរិក សម្រាប់គោលបំណងដូចបានចែងនៅក្នុងផ្នែកនេះ។ ប្រភេទនៃទិន្នន័យដែលបានផ្ទេររួមមានព័ត៌មានផ្ទាល់ខ្លួន ព័ត៌មានសម្រាប់ទំនាក់ទំនង និងព័ត៌មានដែលទាក់ទងទៅនឹងការផ្ទេរប្រាក់ ប្រវត្តិប្រតិបត្តិការ និងព័ត៌មានណាមួយផ្សេងទៀតដែលបានផ្តល់ដោយលោកអ្នក។ ប្រសិនជាមានភាពចាំបាច់សមស្របក្នុងការធ្វើដូច្នេះ យើងខ្ញុំក៏អាចផ្តល់ព័ត៌មានដល់ស្ថាប័ន និងអ្នកផ្តល់សេវាស្របច្បាប់ដទៃទៀត រួមទាំងបុគ្គលទាំងឡាយដែលជួយធ្វើឲ្យអាជីវកម្មរបស់យើងខ្ញុំដំណើរការទៅមុខ ដើម្បីបំពេញឬជួយសម្រួលប្រតិបត្តិការផ្ទេរប្រាក់និងសេវាកម្មនាពេលអនាគត សម្រាប់ហេតុផលឬការប្រើប្រាស់ណាមួយដូចមានចែងក្នុងផ្នែកនេះ។ យើងខ្ញុំអាចបន្ថែមទៅលើព័ត៌មានដែលលោកអ្នកផ្តល់ឲ្យនូវព័ត៌មានទទួលបានពីក្រុមហ៊ុនអាជីវកម្ម ឬបុគ្គលផ្សេងទៀតរួមទាំងព័ត៌មានដើម្បីផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃព័ត៌មានដែលផ្តល់ឲ្យដោយអ្នកលោក។ WESTERNUNION និងសាខារបស់ពួកយើងនៅទូទាំងពិភពលោកអាចបង្ហាញព័ត៌មានផ្ទាល់ខ្លួនរបស់លោកអ្នកមាន ជាអាទិ៍ ឈ្មោះលេខសម្គាល់អតិថិជន អាសយដ្ឋាននិងព័ត៌មានគណនីធនាគាររបស់លោកអ្នក ក្នុងករណី៖ (i) ប្រសិនបើពួកយើងត្រូវបានតម្រូវឲ្យធ្វើដូច្នេះ ដោយច្បាប់ក្នុងស្រុក ឬបរទេស នីតិវិធីច្បាប់ឬ (ii) ធ្វើការបង្ហាញព័ត៌មានដល់អាជ្ញាធរអនុវត្តច្បាប់ ឬមន្ត្រីរដ្ឋាភិបាលដទៃទៀត (រួមទាំងអ្នកដែល នៅក្នុងប្រទេសនេះ - សហរដ្ឋអាមេរិក - ឬនៅកន្លែងផ្សេង) ក្នុងគោលបំណងផ្សេងៗដូចជា ការស្វែងរកការស៊ើបអង្កេត ការចោទប្រកាន់ និងការបង្ការបទល្មើសរួមមានការសម្អាតប្រាក់ និងសកម្មភាពពាក់ព័ន្ធបទល្មើសព្រហ្មទណ្ឌ ហើយអ្នកទទួលក៏អាចនឹងបង្ហាញព័ត៌មានក្នុងគោលបំណងដូចគ្នានេះដែរឬក្នុងគោលបំណងប្រហាក់ប្រហែលគ្នានេះ។លោកអ្នកមានសិទ្ធិស្នើសុំមើល និងទទួលបានច្បាប់ចម្លងនៃព័ត៌មានរបស់អ្នក ហើយយើងខ្ញុំ អាចគិតថ្លៃសេវាបន្តិចបន្តួចសម្រាប់ការស្នើសុំនេះ។លោកអ្នកក៏អាចកែលុប ឬដាក់កម្រិតលើការប្រើប្រាស់របស់យើងខ្ញុំ ចំពោះព័ត៌មានដែលមិនពេញលេញ មិនត្រឹមត្រូវ ឬហួសកាលបរិច្ឆេទ។ ដោយយោងលើហេតុផលស្របច្បាប់ណាមួយលោកអ្នកក៏អាចជំទាស់បានគ្រប់ពេលវេលាទៅនឹងការប្រើប្រាស់ព័ត៌មានរបស់លោកអ្នក ក្នុងករណីការប្រើប្រាស់នេះមិនត្រូវបានទាមទារដើម្បីបំពេញសេវាកម្ម ឬមិនតម្រូវដោយច្បាប់ ឬបទប្បញ្ញត្តិណាមួយ។ ប្រសិនបើលោកអ្នកមានបំណងអនុវត្តសិទ្ធិទាំងនេះឬលែងមានបំណងទទួលបានសារផ្សព្វផ្សាយពាណិជ្ជកម្មនានាពី WESTERNUNION សូមទូរស័ព្ទទៅ WESTERN UNION តាមរយៈលេខដូចខាងក្រោម ក្នុងអំឡុងពេលម៉ោងធ្វើការធម្មតា។

**កិច្ចសន្យា និងទំនាក់ទំនងអតិថិជន** - កិច្ចសន្យារបស់ពួកយើងគឺធ្វើឡើងជាមួយអ្នកផ្ញើ។ ពួកយើងគ្មានកាតព្វកិច្ចណាមួយជាមួយភាគីផ្សេងទៀតឡើយ។ ឧទា. ភាគីដែលអ្នកផ្ញើប្រាក់បានផ្ញើប្រាក់ជំនួសជាដើម។ ប្រសិនបើលោកអ្នកមិនពេញចិត្តនឹងសេវាកម្មរបស់យើងខ្ញុំ លោកអ្នកគួរតែទូរស័ព្ទទៅកាន់លេខដូចខាងក្រោម។ អ្នកតំណាងម្នាក់នឹងស៊ើបអង្កេតអំពីកង្វល់របស់លោកអ្នកដោយយកចិត្តទុកដាក់ និង ក្នុងរយៈពេលដ៏ខ្លី។ សេវាផ្ទេរប្រាក់ WesternUnionត្រូវបានផ្តល់ជូនដោយក្រុមហ៊ុន WesternUnionInternational Limited ដែលជាក្រុមហ៊ុនអៀរឡង់តាមរយៈបណ្តាញភ្នាក់ងារនិងអ្នកតំណាងដែលទទួលបានការអនុញ្ញាត។

**រក្សាសិទ្ធិ2019 WESTERN UNION HOLDINGS, INC.**